ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយជំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៣៧ លេខ ១ ខែ មករា

ព. ស. ២៥០៧ គ. ស. ១៩៦៥

- ភ្នំពេញ -

បណ្ណាល័យ
LIBRARY
INSTITUTE
២៥

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ
បេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

### ផ្នែកសាសនា

ទំព័រ

១ – ភិក្ខុអបរិហានិយធម៌ សម្ដេចព្រះពោធិវ័ង្ស រៀបរៀង . . . . . . ១
២ – ជីវិតមានប្រយោជន៍ឬទេ ! ព្រះសាសនមុនី កិម–តូរ រៀបរៀង . . . . ១៣
៣ – ការត្រាស់ដឹងនៃព្រះសម្ពុទ្ធ ព្រះមហា ប៉ាង–ខាត់ រៀបរៀង . . . . . ១៩
៤ – វិធុរជាតក (ត) . . . . . . . . . . . ២៩

### ផ្នែកអក្សរសាស្ត្រ

៥ – វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង – ខាត់ រៀបរៀង (ត) . . . ៣៩
៦ – រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ–កន ប្រែរៀបរៀង(ត) . . . ៤១
៧ - ព្រះរាជនិពន្ធរាមកេរ្តិ៍ លោក ឧ. គាម ស្រាវជ្រាវ . . . . . . ៤៨
៨ – រឿងចោរលាក្លង លោក ឧ. គាម ស្រាវជ្រាវនិងរៀបរៀង . . . . . ៥៦
៩ – ទឹកត្រជាក់ត្រីកុំ អធិប្បាយភាសិតរបស់សាស្ត្រាចារ្យ ឈឹម–ស៊ុម . . . ៦៣
១០ – សាវិតាវវត្តរកាកណ្ដាល . . . . . . . . . ៧៥

### ផ្នែកកំណត់ទិនប្រវត្តការណ៍

១១ – អនុសំវច្ឆរមហាសន្និបាតលើកទី ២១ នៃមន្ត្រីសង្ឃ . . . . . . ៧៨
១២ – ការតាំងចៅអធិការ និង គ្រូសូត្រ . . . . . . . ៨៨
១៣ – លទ្ធផលប្រឡងប្រជែងទំនៀមទម្លាប់ . . . . . . . ១០៦

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជាវ ២៣០រ០០ ។

# ផ្នែកសាសនា

> ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
> ជាការលាមក, ឲ្យធ្វើល្អទៅ,
> ឲ្យជុំសពាត់ចិត្ត កុំឲ្យហ្មងសៅ,
> បីនេះលោកហៅ ពុទ្ធសាសនា ។
>
> ប.ព.

## ភិក្ខុអបរិហានិយធម្មសូត្រ[១]

### បាលី - សេចក្តីប្រែ

(សំរាប់សូត្រ)

*សម្តេចព្រះពោធិវង្ស រៀបរៀង*

ឯវំ មេ សុតំ *ខ្ញុំបានស្តាប់មកយ៉ាងនេះថា :*

ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ *សម័យមួយព្រះមានព្រះភាគ ទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ*

តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ *ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ លើបពិតនោះ (ឲ្យនាំគ្នាតាំងចិត្តស្តាប់នូវភាសិត) ដូច្នេះថា :*[២]

---

១– ក្នុងសុត្តន្តបិដក អង្គុត្តរនិកាយ សត្តកនិបាត ។ ២– ជាពាក្យព្រះអានន្ទត្ថេរ ជាពុទ្ធុបដ្ឋាក ។

សត្ត វោ ភិក្ខវេ អបរិហានិយេ ធម្មេ ទេសិស្សាមិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ

ម្នាលភិក្ខុទាំងឡាយ, តថាគតនឹងសំដែងនូវអបរិហានិយធម៌ទាំងឡាយ ៧ យ៉ាង គឺធម៌ដែលនាំមិនឲ្យមានសេចក្ដីវិនាស មានតែសេចក្ដីចំរើន ដល់អ្នកពល់គ្នា, អ្នកទាំងឡាយ ចូរប្រុងស្ដាប់នូវអបរិហានិយធម៌នោះ, ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសំដែង (ក្នុងកាលឥឡូវនេះ) ។

ឯវម្ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ភិក្ខុទាំងឡាយនោះក៏ទទួលស្ដាប់ ( នូវភាសិត ) របស់ព្រះមានព្រះភាគ ដោយពាក្យថា ឯវម្ភន្តេ «ព្រះករុណាព្រះអង្គ» ដូច្នេះ ( ព្រមគ្នា ) ។

ភគវា ឯតទវោច ទើបព្រះមានព្រះភាគទ្រង់ត្រាស់សំដែងនូវអបរិហានិយធម្មសូត្រនេះថា :

កតមេ ច ភិក្ខវេ សត្ត អបរិហានិយា ធម្មា ម្នាលភិក្ខុទាំងឡាយ, អបរិហានិយធម៌ ៧ យ៉ាង (នោះ) ដូចម្ដេចខ្លះ ?

១– យាវកីវញ្ច ភិក្ខវេ ភិក្ខូ អភិណ្ហាសន្និបាតា ភវិស្សន្តិ សន្និបាតពហុលា; វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ម្នាលភិក្ខុទាំងឡាយ, បើពួកភិក្ខុទាំងមានការប្រជុំគ្នារឿយ ៗ ព្រមទាំងសម្បូរដោយការប្រជុំគ្នា អស់កាល

ត្រឹមណា, ម្នាលភិក្ខុទាំងឡាយ, សេចក្តីចំរើនមែនពិត នឹងកើតប្រាកដដល់ពួកភិក្ខុ, ឥតមានសេចក្តីវិនាសឡើយ ( អស់កាលត្រឹមនោះ ) ។

២– យាវកីវញ្ច ភិក្ខវេ ភិក្ខូ សមគ្គា សន្និបតិស្សន្តិ សមគ្គា វុដ្ឋហិស្សន្តិ សមគ្គា សង្ឃករណីយានិ ករិស្សន្តិ; វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ម្នាលភិក្ខុទាំងឡាយ, បើពួកភិក្ខុនឹងព្រមព្រៀងគ្នាធ្វើសន្និបាត, ព្រមព្រៀងគ្នាក្រោកចាកទីសន្និបាត, ព្រមព្រៀងគ្នាធ្វើកិច្ចដែលសង្ឃត្រូវធ្វើ អស់កាលត្រឹមណា, ម្នាលភិក្ខុទាំងឡាយ, សេចក្តីចំរើនមែនពិតនឹងកើតប្រាកដដល់ពួកភិក្ខុ, ឥតមានសេចក្តីវិនាសឡើយ ( អស់កាលត្រឹមនោះ ) ។

៣– យាវកីវញ្ច ភិក្ខវេ ភិក្ខូ អប្បញ្ញត្តំ ន បញ្ញបេស្សន្តិ បញ្ញត្តំ ន សមុច្ឆិន្ទិស្សន្តិ យថាបញ្ញត្តេសុ សិក្ខាបទេសុ សមាទាយ វត្តិស្សន្តិ; វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ម្នាលភិក្ខុទាំងឡាយ, បើពួកភិក្ខុនឹងមិនបញ្ញត្តនូវសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្តទេ មិនដកនូវសិក្ខាបទ ដែលតថាគតបានបញ្ញត្តហើយ ប្រព្រឹត្តកាន់តាមតែសិក្ខាបទទាំងឡាយ ដែលតថាគតបានបញ្ញត្តហើយ អស់កាលត្រឹមណា,

ម្នាលភិក្ខុទាំងឡាយ, សេចក្ដីចំរើនមែនពិត នឹងកើតប្រាកដដល់ពួកភិក្ខុ, ឥតមានសេចក្ដីវិនាសឡើយ (អស់កាលត្រឹមនោះ) ។

៤– យាវកីវញ្ច ភិក្ខវេ ភិក្ខូ យេ តេ ភិក្ខូ ថេរា រត្តញ្ញូ ចិរបព្វជិតា សង្ឃបិតរោ សង្ឃបរិណាយកា តេ សក្ការិស្សន្តិ គរុករិស្សន្តិ មានេស្សន្តិ បូជេស្សន្តិ តេ-សញ្ច សោតព្វំ មញ្ញិស្សន្តិ, វុឌ្ឍិ យេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ម្នាលភិក្ខុទាំងឡាយ, ភិក្ខុទាំងឡាយណា ជាថេរៈ ជាអ្នកដឹងនូវរាត្រីកាល បួសអស់កាលយូរហើយ ជាបិតារបស់សង្ឃ ជាបរិនាយករបស់សង្ឃ បើពួកភិក្ខុនឹងធ្វើសក្ការៈ គោរព រាប់អានបូជា ចំពោះភិក្ខុជាថេរៈទាំងនោះ ព្រមទាំងសំគាល់នូវភាសិតនៃភិក្ខុជាថេរៈទាំងនោះ ថាជាភាសិតគួរទទួលស្ដាប់ អស់កាលត្រឹមណា, ម្នាលភិក្ខុទាំងឡាយ, សេចក្ដីចំរើនមែនពិត នឹងកើតប្រាកដដល់ពួកភិក្ខុ, ឥតមានសេចក្ដីវិនាសឡើយ (អស់កាលត្រឹមនោះ) ។

៥– យាវកីវញ្ច ភិក្ខវេ ភិក្ខូ ឧប្បន្នាយ តណ្ហាយ បោនោព្ភវិកាយ ន វសំ គច្ឆិស្សន្តិ; វុឌ្ឍិ យេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងមិនលុះក្នុងអំណាចនៃតណ្ហា ដែលជាធម្មជាតិនាំសត្វឲ្យកើត

ក្នុងកពប្ចុះទៀត ដែលកើតឡើងហើយ អស់កាលត្រឹមណា, ម្នាលភិក្ខុទាំងឡាយ, សេចក្តីចំរើនមែនពិត នឹងកើតប្រាកដដល់ពួកភិក្ខុ, ឥតមានសេចក្តីវិនាសឡើយ (អស់កាលត្រឹមនោះ) ។

៦– យាវកីវញ្ច ភិក្ខវេ ភិក្ខូ អារញ្ញកេសុ សេ-នាសនេសុ សាបេក្ខា ភវិស្សន្តិ; វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានិ ម្នាលភិក្ខុទាំងឡាយ, បើពួកភិក្ខុ នឹងមានសេចក្តីប្រាថ្នា (ដើម្បីអាស្រ័យនៅ) ក្នុងទីសេនាសនៈទាំងឡាយ ដែលមាននៅក្នុងព្រៃ អស់កាលត្រឹមណា; ម្នាលភិក្ខុទាំងឡាយ, សេចក្តីចំរើនមែនពិត នឹងកើតប្រាកដដល់ពួកភិក្ខុ ឥតមានសេចក្តីវិនាសឡើយ (អស់កាលត្រឹមនោះ) ។

៧– យាវកីវញ្ច ភិក្ខវេ ភិក្ខូ បច្ចត្តញ្ញេវ សតឹ ឧបដ្ឋបេស្សន្តិ កិន្តិ អនាគតា ច បេសលា សព្រហ្មចារី អាគច្ឆេយ្យុំ អាគតា ច បេសលា សព្រហ្មចារី ផាសុំ វិហរេយ្យុន្តិ; វុឌ្ឍិយេវ ភិក្ខវេ ភិក្ខូនំ បាដិកង្ខា នោ បរិហានីតិ ម្នាលភិក្ខុទាំងឡាយ, បើពួកភិក្ខុ នឹងប្រុងស្មារតីរៀងខ្លួនថា "ធ្វើម្តេចហ្ន៎ អស់លោកជាសព្រហ្មចារីទាំងឡាយ មានសីលជាទីស្រឡាញ់ ដែលមិនទាន់បាននិមន្តមក សូមឲ្យបាននិមន្តមក, លោកជាស-

ព្រហ្មចារីទាំងឡាយ មានសីលជាទីស្រឡាញ់ ដែលបាននិមន្តមកដល់ហើយ សូមឲ្យលោកគង់នៅដោយសេចក្ដីសប្បាយ ,, (យ៉ាងនេះ) អស់កាលត្រឹមណា , ម្នាលភិក្ខុទាំងឡាយ, សេចក្ដីចំរើនមែនពិត នឹងកើតប្រាកដដល់ពួកភិក្ខុ, ឥតមានសេចក្ដីវិនាសឡើយ (អស់កាលត្រឹមនោះ) ។

ឥទមវោច ភគវា ព្រះមានព្រះភាគទ្រង់ត្រាស់សំដែងនូវអបរិហានិយធម្មសូត្រនេះ (ចប់ស្រេចហើយ)

អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុំ ឯភិក្ខុទាំងឡាយនោះ ក៏មានសេចក្ដីពេញចិត្តត្រេកអរក្រៃពេក ចំពោះភាសិតរបស់ព្រះមានព្រះភាគ ដោយប្រការដូច្នេះឯង ។

## សេចក្ដីស្រង់អំពីអបរិហានិយធម្មសូត្រខាងលើនេះ យកមករួបរួមដោយសង្ខេប ដូចខាងក្រោមនេះ :

### អបរិហានិយធម៌ ៧ យ៉ាង

១– ការប្រជុំគ្នារឿយ ៗ ព្រមទាំងសម្បូរដោយការប្រជុំគ្នា ;

២– កាលប្រជុំគ្នា ក៏ព្រមព្រៀងគ្នាប្រជុំ, កាលក្រោកចាកទីប្រជុំ ក៏ព្រមព្រៀងគ្នាក្រោក, កាលធ្វើកិច្ចដែលសង្ឃត្រូវធ្វើ ក៏ព្រមព្រៀងគ្នាធ្វើ ;

៣– មិនបញ្ញត្តសិក្ខាបទ ដែលព្រះសម្មាសម្ពុទ្ធមិនបានបញ្ញត្តទេ, មិនដកសិក្ខាបទដែលព្រះអង្គបញ្ញត្តរួចហើយ, ប្រព្រឹត្តកាន់តាមសិក្ខាបទដែលព្រះអង្គទ្រង់បញ្ញត្តហើយ ;

៤– ធ្វើសក្ការៈគោរពរាប់អានចំពោះភិក្ខុជាថេរៈ, ជាសង្ឃបិតា ជានាយកលើសង្ឃ ព្រមទាំងជឿស្តាប់ឱវាទរបស់លោក;

៥– មិនលុះក្នុងអំណាចនៃតណ្ហាដែលកើតឡើង ;

៦– ចូលចិត្តអាស្រ័យនៅក្នុងទីសេនាសនៈដែលមាននៅក្នុងព្រៃ;

៧– តាំងចិត្តថា សព្រហ្មចារីភិក្ខុទាំងឡាយ លោកអ្នកមានសីលជាទីស្រឡាញ់ ដែលមិនទាន់បាននិមន្តមកកាន់អាវាសនេះ ក៏សូមឲ្យលោកនិមន្តមកចុះ, ដែលនិមន្តមកដល់ហើយ ក៏សូមឲ្យគង់នៅជាសុខសប្បាយ ។

អធិប្បាយ

ពាក្យថា អបរិហានិយធម៌ ប្រែថា ធម៌សម្រាប់ធ្វើមិនឲ្យមានសេចក្តីវិនាស គឺធម៌ជាហេតុនៃសេចក្តីចម្រើន ។ បានសេចក្តីថា បុគ្គលណាបានប្រតិបត្តិធម៌ទាំង ៧ ប្រការនេះ បុគ្គលនោះតែងបានទទួលនូវសេចក្តីចម្រើនដោយពិត ។ បណ្តាធម៌ទាំង ៧ ខាងលើនេះ ក្នុងធម៌នីមួយ ៗ សុទ្ធតែជាធម៌នាំឲ្យកើតសាមគ្គីស្មោះស្ម័គ្រដល់គ្នានិងគ្នា, ឯសាមគ្គីនេះ

កាលបើកើតឡើងក្នុងពួកក្រុមណា អាចញ៉ាំងសេចក្ដីចំរើនឲ្យកើតក្នុងពួកក្រុមនោះ ។

ម្យ៉ាងទៀត អបរិហានិយធម៌នេះ ជាធម៌ដែលព្រះសម្ពុទ្ធបរមគ្រូទ្រង់ត្រាស់ទេសនាចំពោះពួកភិក្ខុ ជាធម៌សម្រាប់ពួកបព្វជិត មិនមែនសម្រាប់គ្រហស្ថទេ ប៉ុន្តែទុកជាដូច្នោះក៏ដោយ បើពួកគ្រហស្ថចង់ចៀសវាងសេចក្ដីវិនាស ចង់ឲ្យកើតមានសេចក្ដីចំរើន ក៏អាចនឹងប្រតិបត្តិបានដូចគ្នា ។ សូមជ្រាបសេចក្ដីអធិប្បាយដូចតទៅនេះ :

ត្រង់ធម៌ទី១– អដ្ឋកថា ពន្យល់ថា ដែលហៅថា ប្រជុំគ្នារឿយ ៗ គឺប្រជុំគ្នាក្នុង ១ ថ្ងៃ ៣ ដង ឬ ក៏ប្រជុំគ្នាក្នុងកាលជាចន្លោះ ៗ, បានសេចក្ដីថា ក្នុងថ្ងៃមួយ ៗ ពេលណាមានឱកាសល្មមប្រជុំបាន ក៏ប្រជុំក្នុងពេលនោះ ៗ ដែលហៅថា សម្បូរដោយការប្រជុំ គឺប្រជុំមិនរសាយព្យាយាម មិនធុញទ្រាន់ថា "ពីថ្ងៃមុនក៏ប្រជុំ ពីម្សិលមិញ ក៏ប្រជុំដែរ, ចុះក្នុងថ្ងៃនេះ យើងប្រជុំធ្វើអ្វីទៀត ? . ដូច្នេះឡើយ ៗ បានសេចក្ដីថា ឥតធុញទ្រាន់ក្នុងការប្រជុំគ្នា, តាមតែប្រជុំរឿយ ៗ ប៉ុន្មានដងក៏ដោយ ៗ

ការប្រជុំញឹកញយនេះ នាំឲ្យកើតមានសេចក្ដីចំរើន នាំឲ្យរួចផុតពីសេចក្ដីវិនាស ទាំងក្នុងផ្លូវលោក និងទាំងក្នុងផ្លូវព្រះពុទ្ធសាសនា ។

## អំពីផ្លូវលោក

តាមអដ្ឋកថា លិច្ឆវិអបរិហានិយធម្មសូត្រថា ក្នុងប្រទេសនីមួយ ៗ បើពួកមន្ត្រីអ្នកកាន់កាប់ការផែនដី មិនបានប្រជុំគ្នារឿយ ៗ ក៏មិនសូវបានដំណឹងពីទិសានុទិសក្នុងប្រទេស ឬក៏មិនបានដឹងថា ឃុំ-ស្រុក-ខេត្តឯណា ៗ មានស្ថានការណ៍យ៉ាងនោះ ៗ ឡើយ, ព្រមទាំងមិនដឹងថា មានពួកចោរនៅក្នុងដំបន់នោះ ៗ ផង ៗ ចំណែកខាងពួកចោរកាលបើដឹងថា ក្សត្រមន្ត្រីមានការធ្វេសប្រហែស ក៏នាំគ្នាចូលទៅកេតត្បាតរុករានបំផ្លាញប្រជារាស្ត្រ ដែលនៅក្នុងឃុំ-ស្រុក-ខេត្ត ពុំបាន ៗ អាស្រ័យហេតុដែលមិនបានប្រជុំគ្នារឿយ ៗ នេះ នាំឲ្យកើតសេចក្តីវិនាស ឥតមានសេចក្តីចំរើនឡើយ ៗ បើបានប្រជុំគ្នារឿយ ៗ ក៏បានឮបានដឹងប្រព្រឹត្តហេតុនោះ ៗ ក្នុងព្រះរាជាណាចក្រ ហើយបញ្ជូនកងពលទៅបង្ក្រាបពួកសត្រូវបាន ៗ ចំណែកខាងពួកចោរកាលបើបានដឹងថា ក្សត្រមន្ត្រីឥតមានធ្វេសប្រហែស គឺប្រុងប្រយ័ត្នជានិច្ច ក៏មិនអាចនឹងផ្តុំគ្នាជាពួកជាកង ហើយបែកគ្នាខ្ចាត់ខ្ចាយអស់ទៅ ៗ អាស្រ័យហេតុយ៉ាងនេះ នាំឲ្យកើតសេចក្តីចំរើនដល់ពលរដ្ឋក្នុងប្រទេស ៗ

## បំណែកខាងព្រះពុទ្ធសាសនា

តាមអដ្ឋកថា ភិក្ខុអបរិហានិយធម្មសូត្រថា ក្នុងព្រះពុទ្ធសាសនា

បើភិក្ខុសង្ឃមិនបានប្រជុំគ្នារឿយ ៗ ទេ ក៏មិនបានឮដំណឹងដែលមានក្នុងទិសានុទិស ឥតបានដឹងថា វិហារសីមាឯណោះខានការប្រចូកប្រចល់, ឧបោសថកម្ម និងបវារណាកម្ម ក៏ឈប់អស់ គឺឥតមានភិក្ខុសង្ឃធ្វើឡើយ ពួកភិក្ខុក្នុងទីឯណោះ ៗ ប្រព្រឹត្តធ្វើអំពើអាក្រក់មានវេជ្ជកម្ម និងទូតកម្មជាដើម, សម្បុរដោយវិញ្ញត្តិ គឺការដើរសុំគេ ប្រព្រឹត្តចិញ្ចឹមជីវិតដោយអនេសនៈ មានការផ្គាប់ផ្គុនគ្រហស្ថដោយការឲ្យផ្លែឈើ និងផ្កាឈើជាដើម ៗ ចំណែកខាងភិក្ខុបាបទាំងឡាយ កាលបើដឹងថាគណៈសង្ឃធ្វេសប្រហែសមិនសូវរវល់នឹងការប្រជុំគ្នាពីរឿងព្រះពុទ្ធសាសនា ក៏នាំគ្នាធ្វើអំពើអាក្រក់ផ្សេង ៗ ដែលជាហេតុនាំឲ្យព្រះពុទ្ធសាសនាអន់ថយចុះដោយលំដាប់ ៗ បើគណៈសង្ឃបានប្រជុំគ្នារឿយ ៗ ក៏បានដឹងបានឮប្រព្រឹត្តហេតុទាំងនោះសព្វទិសទី ហើយបញ្ជូនគណៈសង្ឃឲ្យទៅរៀបចំ កន្លែងណាមិនស្រួលធ្វើឲ្យស្រួលឡើង, ឧបោសថ និងបវារណាជាដើម ដែលសង្ឃឈប់ខានធ្វើ ក៏រៀបចំឲ្យបានធ្វើឡើងវិញ ៗ ចំណែកខាងភិក្ខុបាបទាំងឡាយ កាលបើបានដឹងថា គណៈសង្ឃមិនធ្វេសប្រហែសទេ គឺប្រជុំគ្នាចាត់ការខាងព្រះពុទ្ធសាសនាយ៉ាងម៉ឺងម៉ាត់ ក៏មិនអាចនឹងរួបរួមគ្នាជាបក្ខជាពួកបានឡើយ នឹងបែកគ្នាខ្ចាត់ខ្ចាយអស់ទៅ ៗ ការមិនប្រជុំគ្នារឿយ ៗ ជាហេតុនាំឲ្យវិនាស, ការប្រជុំគ្នារឿយ ៗ ជាហេតុនាំឲ្យមានសេចក្តីចំរើនដូចខាងលើនេះ ៗ

(សេចក្ដីខាងលើនេះ ចង្អុលបង្ហាញឲ្យឃើញថា កិច្ចការខាងព្រះពុទ្ធសាសនាក្នុងសម័យបុរាណ តាំងពីក្នុងពុទ្ធកាលរហូតដល់សម័យខាងក្រោយតាមលំដាប់គ ។ មក ជាការលើគណៈសង្ឃ គណៈសង្ឃមានសិទ្ធិតាក់ការបង្ក្រាបអលជ្ជីភិក្ខុ មានសិទ្ធិរម្ងាប់វិត្តកម្ម.ពាស មិនបើកឱកាសឲ្យបព្វជិតណាមួយមានអំណាចឡើងចិត្តឡើងថាងបាន, គណៈសង្ឃមានអានុភាពអាចគ្រប់គ្រងរក្សាគ្នាដោយពេញមុខ តាមលំអានធម្មវិន័យ មិនមានការពាក់ព័ន្ធសេមសោមដោយគ្រហស្ថផងទេ ពោះរដ្ឋាភិបាលក្ដីប្រជាជនពលរដ្ឋក្ដី; ព្រះមហាក្សត្រ និងរដ្ឋាភិបាលព្រមទាំងប្រជាជនគ្រាន់តែជួយឧបត្ថម្ភ ដោយកិច្ចការណាដែលគួរជួយទំនុកបំរុងប៉ុណ្ណោះ; បព្វជិតក្នុងសាសនមណ្ឌលទាំងមូល ក៏មានសេចក្ដីគោរពកោតក្រែងគណៈសង្ឃពុំហ៊ានល្មើស ព្រោះយល់ថាព្រះសម្មាសម្ពុទ្ធជាបរមគ្រូទ្រង់លើកការគ្រប់គ្រងសង្ឃមណ្ឌលទាំងមូលប្រគល់ឲ្យជុំនុំសង្ឃ គឺឲ្យជុំនុំសង្ឃមានសិទ្ធិគ្រប់គ្រងរក្សាគ្នាតាមលំអានព្រះធម៌វិន័យរបស់ព្រះអង្គ ។ ដោយហេតុនេះ កាលបើពុទ្ធសាសនិកជនក្នុងប្រទេសណា ប្រព្រឹត្ត ឬ ប្រតិបត្តិការផ្ទុយពីរបៀបនោះទៅវិញ ព្រះពុទ្ធសាសនាក្នុងប្រទេសនោះមិនរុងរឿងទេ ក្លាយទៅជាអាប់ឱនទៅវិញ មកពីវាត់ការគ្រប់គ្រងប្របូកប្របល់ មិនត្រូវតាមរបៀបក្នុងព្រះវិន័យ (១) ) ។

---

១ សេចក្ដីក្នុងវង់ក្រចកនេះ ជាយោបល់របស់ខ្ញុំដែលជាអ្នករៀបរៀងអត្ថបទនេះ ។

ម្យ៉ាងទៀត, ការប្រជុំគ្នារឿយ ៗ ដែលនាំឲ្យមានសេចក្ដីចំរើននោះ មិនមែនប្រជុំនិយាយលេងសើចលេងឲ្យគ្រាន់តែបានសប្បាយ រវាងគ្នានឹងគ្នាប៉ុណ្ណោះទេ គឺប្រជុំគ្នាពិគ្រោះសាកសួរចំពោះកិច្ចការណាមួយដែលជាផ្លូវលោកឬជាផ្លូវធម៌ ឬក៏ប្រជុំគ្នាដើម្បីដោះស្រាយបញ្ហាជ្រាលជ្រៅ ជជែកដេញដោលគ្នាដើម្បីឲ្យឃើញផ្លូវដែលត្រូវអនុវត្តតាម ឬពុំនោះ ប្រជុំគ្នាដោយមានលោកជាមហាថេរត្រូវការពន្យល់អំពីច្បាប់ព្រះពុទ្ធសាសនា ឬក៏អំពីច្បាប់សម្រាប់លោក ៗ កាលបើមានការប្រជុំគ្នារឿយ ៗ ហើយ សេចក្ដីចំរើនក៏កើតមានឡើងដល់អ្នកដែលបានចូលមកប្រជុំនោះ ៗ គឺអ្នកដែលចេះដឹងតិច បានសាកសួរទៅអ្នកចេះដឹងច្រើន ចំណែកខាងអ្នកចេះដឹងច្រើន ក៏នឹងបានអធិប្បាយពន្យល់ចង្អុលណែនាំឲ្យយល់ច្បាស់នូវផ្លូវលោកនិងផ្លូវធម៌ ៗ មិនតែប៉ុណ្ណោះទេ, ការប្រជុំគ្នារឿយ ៗ នេះ ជាគ្រឿងប្រមូលមេត្រីភាពយកមកប្រគល់ឲ្យដល់អ្នកដែលប្រជុំគ្នានោះផងទៀត ។ ការប្រជុំគ្នារឿយ ៗ នេះ មាននៅត្រឹមណា, សាមគ្គីធម៌ក៏ឈ្មោះថា មានជីវិតរស់នៅត្រឹមណោះ, សាមគ្គីធម៌មានជីវិតរស់នៅត្រឹមណា សេចក្ដីសុខ ចំរើន ក៏មានត្រឹមណោះដែរ ។

# ជីវិតមានប្រយោជន៍ឬទេ ?

ព្រះសាសនមុនី គឹម គួរ រៀបរៀង

## ជីវិតមានប្រយោជន៍ក៏មាន, ឥតប្រយោជន៍ក៏មាន ៗ

ជីវិតដែលមានប្រយោជន៍នោះ គឺមនុស្សណាមួយដែលកំពុងរស់នៅក្នុងលោក, បើជាគ្រហស្ថ (អ្នកនៅគ្រប់គ្រងផ្ទះ) គ្រហស្ថនោះជាអ្នកមានសទ្ធា មានការសិក្សា មានសប្បុរសធម៌ មានប្រាជ្ញាស្គាល់ការខុសត្រូវ ប្រព្រឹត្តប្រតិបត្តិមិនឲ្យខុសគន្លងបំពានបំពារទៅលើបញ្ញត្តិ ទាំងខាងផ្លូវលោកនិងខាងផ្លូវធម៌ ព្រមទាំងបានធ្វើប្រយោជន៍ឲ្យកើតឡើងដល់ប្រទេសជាតិ ដល់សាសនា ដល់ខ្លួន ដល់ជនទូទៅដោយយកម្លាំងទ្រព្យ និងកម្លាំងកាយ វាចា ចិត្ត ដែលអាចធ្វើទៅបាន ៗ បើជាបព្វជិត (អ្នកបួសក្នុងព្រះពុទ្ធសាសនា )វិញ បព្វជិតនោះ ជាអ្នកមានសទ្ធា មានការសិក្សាធម៌វិន័យ តក្បួនច្បាប់ព្រះពុទ្ធសាសនាចេះដឹងហើយ បានប្រព្រឹត្តប្រតិបត្តិតាមការចេះដឹងនោះ ព្រមទាំងបានបំពេញមុខការតាមឋានៈរបស់ខ្លួនជាបព្វជិត, ទាំងកិច្ចការណាដែលទាក់ទងដល់ផ្លូវលោក ប៉ុន្តែឥតទាស់ខុសនឹងច្បាប់ព្រះពុទ្ធសាសនាទេ ក៏បានបំពេញកិច្ចការនោះឲ្យសមតាមសមត្ថភាពរបស់ខ្លួន ដើម្បីឲ្យកើតផលប្រយោជន៍ដល់ព្រះពុទ្ធសា-សនាផង ដល់ប្រទេសជាតិមាតុភូមិផង ដល់ខ្លួននិងសាធារណជនផង

ដោយឥតមានសេចក្ដីខ្ជិលច្រអូស, ធ្វើខ្លួនឲ្យជាបព្វជិតល្មមទីពឹងខ្លួនឯង
បាន ទាំងជនដទៃក៏អាចចូលមកប្រាស្រ័យទីពឹងពំនាក់បានផង ។ ជីវិត
នៃមនុស្សទាំងនោះ ទោះជាបព្វជិតក្ដី ជាគ្រហស្ថក្ដី ឈ្មោះថាជាជីវិត
មានប្រយោជន៍ដោយពិត ព្រោះជីវិតនៃមនុស្សទាំងនោះ បានបំពេញ
ករណីយកិច្ចក្នុងពេលដែលខ្លួនរស់នៅ លុះអស់ជីវិតទៅ កិច្ចការដែលធ្វើ
នោះក៏អាចផ្ដល់ផលឲ្យដល់ខ្លួនវិញនូវកេរ្ដិ៍ឈ្មោះ និងសេចក្ដីសុខក្នុងលោក
នេះ និងបរលោក ឯកិច្ចការជាស្នាដៃទាំងនោះដែលសល់នៅ ទុកជា
ទិដ្ឋានុគតិសម្រាប់បច្ឆាជនខាងក្រោយទៀតផង ការដែលបានធ្វើអំពើល្អ
ក្នុងពេលមានជីវិតរស់នៅយ៉ាងនេះ ឈ្មោះថាជីវិត មានប្រយោជន៍មិន
សាបសូន្យទេ សមនឹងពុទ្ធភាសិតថា រូបំ ជីរតិ មច្ចានំ នាម-
គោត្តំ ន ជីរតិ "រូបនេះនៃសព្វសត្វ តែងវិបត្តិចាស់ជរា ឯនាមនិង
គោត្តា ពុំជរាដូចរូបឡើយ" ។

ជីវិតដែលឥតប្រយោជន៍នោះ គឺមនុស្សណាមួយដែលកំពុងរស់នៅ
ក្នុងលោក, បើជាគ្រហស្ថ គ្រហស្ថនោះប្រាសចាកសទ្ធានិងប្រាជ្ញា គ្មាន
ការសិក្សា មានតែបមាទធម៌គឺការធ្វេសប្រហែសជានិច្ច ប្រព្រឹត្តធ្វើតែអំពើ
លាមកអាក្រក់ មានអបាយមុខនិងបញ្ចវេរជាដើម ជាអំពើនាំខ្លួនឲ្យ
វិនាសក្នុងលោកទាំងពីរ ឥតបានបំពេញករណីយកិច្ចណាមួយ ដែលនាំ

ឲ្យមានប្រយោជន៍ដល់ប្រទេសជាតិ ដល់ព្រះពុទ្ធសាសនា ដល់ខ្លួន ដល់សាធារណជនសោះឡើយ ។ មនុស្សនោះ ទោះបីកម្លាំងមាន, ទ្រព្យធនមាន ក៏មិនយកកម្លាំងនិងទ្រព្យធននោះធ្វើឲ្យកើតជាប្រយោជន៍សម្រាប់ខ្លួន សម្រាប់ប្រទេសជាតិ ឬ សម្រាប់សាធារណជនទេ លុះអស់ជីវិតទៅ, របស់អ្វីដែលមានក្នុងកាលដែលខ្លួនរស់នៅ ក៏ត្រូវស្លាប់រលាយទៅជាមួយទាំងអស់ គ្មានបានបញ្ចេញផលអ្វីទុកជាកេរ្តិ៍ដំណែលឲ្យសល់នៅជាប្រយោជន៍វែងឆ្ងាយតទៅមុខសោះឡើយ ។ បើជាបណ្ឌិតវិញ បណ្ឌិតនោះ មិនមានសទ្ធា មិនយកចិត្តទុកដាក់ក្នុងការប្រព្រឹត្តិប្រតិបត្តិកាន់តាមច្បាប់ដែលបណ្ឌិតត្រូវកាន់តាមទេ បែរជាយកចិត្តទុកដាក់ក្នុងកិច្ចការដែលទាស់ខុសផ្ទុយនឹងច្បាប់ព្រះពុទ្ធសាសនាទៅវិញ, ឥតបានបំពេញមុខការណាមួយដែលនាំឲ្យមានប្រយោជន៍ដល់ព្រះពុទ្ធសាសនា ដល់ខ្លួន ដល់ជនដទៃ ឬដល់ប្រទេសជាតិ តាមទំនងដែលបណ្ឌិតគួរធ្វើបាននោះសោះឡើយ ។ ជីវិតនៃមនុស្សទាំងនោះ ទោះជាគ្រហស្ថក្តី ជាបណ្ឌិតក្តី ឈ្មោះថាជីវិតធ្លាក់ចុះក្នុងបមាទធម៌សាបសូន្យទៅទទេ ព្រោះថាកាលរស់នៅអស់រយៈកាលខ្លីក្តី វែងក្តី គ្មានបានធ្វើអ្វីដែលមានប្រយោជន៍ យ៉ាងនេះហៅថា ជីវិតឥតប្រយោជន៍ សមនឹងពុទ្ធភាសិតថា យេ បមត្តា យថា មតា "អ្នកណាប្រមាទ អ្នកនោះទុកដូចជាស្លាប់ហើយ" ។ បាន

សេចក្ដីថា អ្នកណាមួយ ដែលខ្វះប្រហែសបណ្ដែតបណ្ដោយគំនិតស្មារតី ឲ្យវង្វេងលង់ទៅក្នុងកាមគុណ ឬ ក្នុងអំពើឥតប្រយោជន៍ ឬក៏ក្នុងអំពើអាក្រក់ណាមួយដោយកាយ វាចា ចិត្ត អ្នកនោះឯងហៅថាជាមនុស្សប្រមាទ; សូម្បីមានជីវិតរស់នៅ ក៏ទុកដូចជាស្លាប់ទៅហើយដែរ ព្រោះសេចក្ដីស្លាប់របស់មនុស្សមានពីរយ៉ាងគឺ ស្លាប់ជីវិតមួយយ៉ាង ស្លាប់គំនិតមួយយ៉ាង ។ បណ្ដាសេចក្ដីស្លាប់ទាំងពីរយ៉ាងនោះ ត្រង់សេចក្ដីស្លាប់គឺអស់ខ្យល់ចេញនិងខ្យល់ចូល ទាំងវិញ្ញាណក៏ប្រាសចេញផុតចាកកាយទៅហើយ ហៅថាស្លាប់ជីវិត, ស្លាប់បែបនេះជាការប្រសើរល្អជាងស្លាប់គំនិត ។ ធម្មតាមនុស្សដែលស្លាប់មែន ៗ គឺមនុស្សដែលមានវិញ្ញាណនិងអស្សាសប្បស្សាស. ប្រាសចេញឃ្លាតផុតចាកកាយទៅហើយ ពុំដែលមានគំនិតគិតថា អាត្មាអញនឹងឲ្យទាន នឹងរក្សាសីល ឬ នឹងធ្វើកិច្ចការណាមួយទុកជាប្រយោជន៍ខ្លួន ឬជាប្រយោជន៍សាធារណៈ សម្រាប់ប្រទេសជាតិសោះឡើយយ៉ាងណាមិញ, ឯមនុស្សប្រមាទគឺមនុស្សស្លាប់គំនិតក៏ដូច្នោះដែរ ។

មួយយ៉ាងទៀត ធម្មតាមនុស្សទាំងឡាយ តែងស្រឡាញ់ខ្លួនឯងជាងអ្នកដទៃ ឬជាងវត្ថុ ៗ ទាំងអស់ នឹងបាច់និយាយទៅអ្វីចំពោះមនុស្សដែលមានរាងកាយល្អមាំមួននោះ ដោយហោចទៅសូម្បីមនុស្សដែលមានរាងកាយពិកលពិការយ៉ាងណាក៏ដោយ គង់តែស្រឡាញ់ខ្លួនឯងជាងអ្នក

ដទៃដែរ ព្រោះហេតុនោះ មនុស្សម្នាក់ ៗ បើស្រឡាញ់ខ្លួនពិតមែន គួរប្រព្រឹត្តខ្លួនឲ្យតាំងនៅក្នុងសុចរិតធម៌ ហើយអនុវត្តទៅតាមច្បាប់លោកនិងច្បាប់ធម៌ផង ទើបឈ្មោះថាជាអ្នកស្រឡាញ់ខ្លួន ព្រោះអត្តភាពគឺខ្លួនយើងនីមួយ ៗ ប្រៀបដូចជាភាជន៍ សម្រាប់ទទួលនូវទង្វើអំពើល្អនិងអាក្រក់ ឬថាជាទីប្រជុំនៃសេចក្ដីល្អនិងសេចក្ដីអាក្រក់គ្រប់យ៉ាងក៏បាន សមនឹងពុទ្ធភាសិតថា អត្រជំ អត្តសម្ភវំ "សេចក្ដីល្អ និងសេចក្ដីអាក្រក់ ឬសុខនិងទុក្ខ រមែងកើតអំពីខ្លួន មានខ្លួនជាដែនកើត" ពាក្យថាខ្លួនក្នុងទីនេះ សំដៅយកអត្តភាពគឺកាយ ទាំងមូលរួមទាំងចិត្តចូលផង ទើបហៅថាខ្លួន ព្រោះហេតុនោះ បុគ្គលគប្បីសម្លឹងពិនិត្យមើលដំណើរការណ៍ប្រព្រឹត្តទៅនៃខ្លួន ទាំងចំណែកខាងល្អ ទាំងចំណែកខាងអាក្រក់ បើដឹងថាខ្លួនប្រព្រឹត្តអាក្រក់ហើយ គួរលះបង់ចោលចេញហើយប្រព្រឹត្តល្អទៅ បើខ្លួនបានប្រព្រឹត្តល្អស្រាប់ហើយ ក៏គួរតែប្រព្រឹត្តសេចក្ដីល្អនោះឲ្យរឹងរឹតតែខ្ជាប់ខ្ជួនក្រៃលែងតទៅទៀត ។

មួយយ៉ាងទៀត ធម្មតាធ្វើជាមនុស្សនីមួយៗ មិនត្រូវប្រគល់ខ្លួនទាំងស្រុងដល់អ្នកដទៃ ហើយដេកចាំយកសេចក្ដីសុខអំពីគេដោយងាយៗនោះឡើយ, មិនត្រូវបណ្ដោយខ្លួនឲ្យធ្លាក់ចុះក្នុងឋានៈដ៏ថោកទាបទៅជាអាយ៉ង ឬជាទាសភាពនៃជនដទៃឡើយ មិនត្រូវបណ្ដោយខ្លួនឲ្យលង់ធ្លាក់ចុះក្នុងបាបធម៌ គឺសេចក្ដីប្រមាទ ឬ សេចក្ដីធ្វេសប្រហែសក្នុងគតិលោក

ឬក្នុងគតិធម៌ណាមួយឡើយ ព្រោះសេចក្តីប្រមាទនេះ ជាមូលហេតុនៃសេចក្តីវិនាសហិនហោចគ្រប់យ៉ាង ។ មនុស្សណាមួយមានសេចក្តីប្រមាទ ឬធ្វើខ្លួនឲ្យលុះក្នុងអំណាចនៃសេចក្តីប្រមាទជានិច្ចហើយ មនុស្សនោះទុកដូចជាបើកទ្វារចំហឲ្យឱកាសដល់សត្រូវ ពោលគឺសេចក្តីអន្តរាយគ្រប់យ៉ាងហូរហូលមកជានិច្ចផង ទុកដូចជាស្លាប់បាត់ទៅហើយផង សូម្បីមានជីវិតកំពុងរស់នៅ ក៏ទុកដូចជាស្លាប់បាត់ទៅហើយដែរ, អ្នកណាមិនប្រមាទ អ្នកនោះទុកដូចជារស់នៅ សូម្បីស្លាប់បាត់ទៅហើយ ក៏ទុកដូចជារស់នៅដែរ ។

ទុកជាគិតឃើញវាសនាស្មោះ មិនត្រូវបង់បោះសេចក្តីប្រឹង
ត្រូវតែព្យាយាមពេញទំហឹង ព្រោះប្រឹងនិងព្រេងជាគូគ្នា ។
គ្រាប់ល្ងបើគេមិនគិតកាញ់ យកទៅបម្រាញ់ឬស្ងោរវា
ទុកជាគ្រាប់សុទ្ធតាមធម្មតា ធ្វើដូចម្តេចណានឹងបានប្រេង ។
ការងារសម្រេចដោយព្យាយាម ពុំមែនបានភ្លាមតាមចិត្តគិត
បើដេកព្រងើយផ្សងបុណ្យពិត ដល់ក្ស័យជីវិតក៏ឥតសុខ ។
សត្វម្រឹគមានមែនពាសពេញព្រៃ តែសត្វរាជសីហ៍ដេកស្រមុក
សត្វម្រឹគណានឹងបោលសម្រុក បញ្ចូលក្នុងមាត់ខ្លួនស៊ី ? ។

# ការត្រាស់ដឹងនៃព្រះសម្ពុទ្ធ

ព្រះ មហា ប៉ាង.ខាត់ រៀបរៀង

ពាក្យថា «ត្រាស់ដឹង» សព្វថ្ងៃនេះ គេឮហើយ គេឆ្លើយភ្លាមថា «មិនយល់ទេ» គេតែងតែឆ្ងល់ ហើយគេផ្តើមសួរថា ដូចម្តេចហៅ "ត្រាស់ដឹង"? សម្រាប់អ្នកមិនមានការសិក្សា ពាក្យថា «ត្រាស់ដឹង» ពិបាកស្តាប់មែនហើយ ព្រោះជាពាក្យបច្ចេកទេសដែលសម្រាប់ប្រើតែក្នុងសាសនា ប៉ុន្តែបើបានទទួលពាក្យពន្យល់ហើយ មិនជាការពិបាកយល់ប៉ុន្មានទេ ហើយក្នុងការសិក្សាពុទ្ធប្រវត្តិនេះ «កណ្ឌត្រាស់ដឹង» ជាចំណុចមួយដ៏សំខាន់ក្រៃលែង ។

គេតែងតែកើតសង្ស័យហើយគេសួរថា «ត្រាស់ដឹង» នោះដូចម្តេច? ដែលនិយាយថាព្រះសម្ពុទ្ធបានត្រាស់ដឹង តើព្រះអង្គបានឃើញធម៌អ្វី ទើបបានជាទ្រង់យល់ថា ព្រះអង្គត្រាស់ដឹង ព្រះអង្គឈប់លែងស្វះស្វែងរកទៅទៀត ហើយចាប់ផ្តើមប្រកាសធម៌ដែលទ្រង់ត្រាស់ដឹងនោះដល់សត្វលោក ។ ប្រស្នាដែលថា «ព្រះអង្គបានឃើញធម៌អ្វី ហើយទើបបានជាព្រះអង្គយល់ថា ព្រះអង្គត្រាស់ដឹង» នោះជាប្រស្នាធំណាស់ ។

ដើម្បីដោះស្រាយប្រស្នានេះ គួរយើងយល់ពាក្យថា «ត្រាស់ដឹង» ទុកមុនសិន ថាពាក្យនេះតើមានន័យដូចម្តេច ។ ព្រះពុទ្ធប្រវត្តិបានបង្ហាញ

ឲ្យយើងឃើញថា ព្រះពោធិសត្វស្តេចចេញសាងអភិនេស្រ្កមណ៍ ចេញសាងរកអ្វី? ថារកសេចក្តីសុខពិត កាលទ្រង់កំពុងស្វែងរក ទ្រង់បានរកឃើញអ្វីមួយនៅក្រោមដើមពោធិព្រឹក្ស ដែលទ្រង់មិនដែលបានឃើញសោះក្នុងអតីតកាល ការរកឃើញអ្វីមួយនោះបានធ្វើឲ្យព្រះអង្គមានព្រះទ័យភ្ញាក់ស្មារតីមើលលោកទាំងបីឃើញពិតទៅតាមពិតដូចជាគេទៅបើកគំរបដែលគេបិទឲ្យរបើកឡើងហើយមើលឃើញអ្វីមួយនៅក្នុងនោះយ៉ាងច្បាស់ឥតកន្ត្រប់ ដោយបញ្ញាព្រះអង្គដែលមិនមានទីបំផុតឥតសល់ចន្លោះត្រង់ណាសោះ មិនតែប៉ុណ្ណោះទេ ការរកឃើញនេះ បានធ្វើឲ្យព្រះអង្គដឹងថាមានសេចក្តីសុខ ជាសេចក្តីសុខដែលទ្រង់មិនដែលបានដឹងមកពីកាលមុន ព្រោះក្រោយដែលទ្រង់បានរកឃើញហើយ គឺក្រោយដែលថាទ្រង់បានត្រាស់ដឹងហើយ ទ្រង់សម្រាកព្រះកាយ ទ្រង់សម្រាក «សោយវិមុត្តិសុខ» សុខដែលកើតឡើងដោយដឹងព្រះអង្គថា បានដោះប្រស្នាទុក្ខដែលអ្នកមុនព្រះអង្គដោះមិនបាន ហើយព្រះអង្គបានដោះស្រាយសម្រេចបរិបូណ៌ ហើយឥតមានសល់ទៀតទេ ប្រថាប់នៅទីណា ជិតពោធិមណ្ឌលដូចជានៅក្រោមអជបាលនិគ្រោធក្តី នៅឋានមុចលិន្ទស្រះក្តី ដើមរាជាយតនក្តី ទ្រង់តែងតែពេញព្រះទ័យបញ្ចេញឧទានថា «ទ្រង់បានសម្រេចហើយៗ» ការរកឃើញអ្វីមួយដែលទ្រង់ចង់បាន ហើយបានសម្រេច គឺការបានរកឃើញអ្វីនោះ ហៅថា «ការត្រាស់ដឹង» ។

ពាក្យថារកឃើញនេះ អាចនឹងប្រែថា «ការត្រាស់ដឹង» បានដែរ ដូចពាក្យថា «ពុទ្ធ» ដែលយើងប្រែថា «អ្នកត្រាស់ដឹង» ក៏គួរប្រែថា «អ្នករកឃើញ» បានដែរ ដូចអ្នករកឃើញវិជ្ជាអ្វីមួយក្នុងលោកនេះ ក៏គួរនឹងហៅថា «ពុទ្ធ» បាន ។

លោក នូតុន (Newton) អ្នកគណិតសាស្ត្រអង់គ្លេស លោកជាអ្នកសិក្សាទ្រឹស្តីនៃលោក កេប្ល័រ (Kepler) គន់គិតរកច្បាប់ការចលនាស្រូបទាញពិភពលោក ថ្ងៃមួយ លោកទៅដេកក្រោមដើមប៉ោមមួយដើម កាលនោះមានផ្លែប៉ោមមួយធ្លាក់ចុះមកក្បែរលោក ស្រាប់តែលោករកឃើញច្បាប់ការចលនាស្រូបទាញនៃពិភពលោក ហើយដោះប្រស្នាផ្សេង ៗ ទៀតបានច្រើនប្រការ លោករត់វិលទៅផ្ទះវិញបណ្ដើរស្រែកបណ្ដើរថា «ខ្ញុំរកឃើញហើយ ៗ» ។ ផ្លែឈើដែលធ្លាក់ពីដើមឈើតែងមានជាធម្មតា អ្នកណាមិនដឹង ? មិនជាការប្លែកទេ អ្នកណាក៏ធ្លាប់ឃើញដែរ តែគេមិនបានឃើញដូចលោកនូតុន ដែលឃើញធ្លុះរហូតទៅតាមពិត ហើយចងក្រងជាទ្រឹស្តីមួយទុកបានដល់មកសព្វថ្ងៃនេះ ។ ការរកឃើញដែលបារាំងហៅថា «Découverte» នេះជាការត្រាស់ដឹងមួយដ៏តូចនៃលោក នូតុន ។

លោក ប៉ាស្ទ័រ (L. Pasteur) ជាអ្នកប្រាជ្ញគីមីបារាំងសេសម្នាក់ លោកបានរកឃើញវិធីការពាររោគ ព្រោះរាងកាយមនុស្សក្ដី សត្វក្ដី ដើមឈើ

ក៏ ជារបស់បរិសុទ្ធ បើការពារកុំឲ្យមានមេរោគមកបៀតបៀន មេរោគមិនអាចកើតឡើងបានទេ ការដែលរាងកាយមានរោគ មានការឈឺចាប់ ព្រោះរាងកាយកើតមានមេរោគ វិធីការពាររោគមិនមានអ្វីដទៃក្រៅទេ គឺការបំបាត់មេរោគនេះឯង ក៏ទុកជាបានការស្រេចទៅហើយ ។ លោកប៉ាស្ទ័រ លោករកវិជ្ជានេះឃើញ ហើយចងក្រងជាទ្រឹស្តីទុកមក ហៅថា រោគនិវារណសាស្ត្រ (Prophylaxie) ជាវិជ្ជាដែលមានគុណប្រយោជន៍ក្នុងការរក្សាមនុស្ស រក្សាសត្វ រក្សាដើមឈើដែលមានផ្លែមិនឲ្យមានរោគៗ ដូច្នេះ លោក ប៉ាស្ទ័រ ជាអ្នកនិរកម្មាក់ដ៏ប្រសើរក្នុងលោក ការរកឃើញរបស់លោកថា «រោគមានមេរោគ» នោះជាការត្រាស់ដឹងយ៉ាងតូចមួយនៃលោកប៉ាស្ទ័រ ។

លោក គុយរី (P. Curie) ជាអ្នកប្រាជ្ញបារាំងសេសខាងរូបវិទ្យានិង គីមី ព្រមទាំងភរិយាលោក នាងម៉ារី ក្លូដូស្កា (Marie Sklodowsksa) ជាតិប៉ូឡូញ បានរកឃើញធាតុរ៉ាដ្យូម (Radium) រកឃើញថា ធាតុរ៉ាដ្យូមនេះមាននៅក្នុងប៉ិចប្លង់ដ៍ ( Pech blende: Pech noix, blend ébloui [oxyde naturel d'uranium] )ធាតុនោះមានប្រយោជន៍ខាងពេទ្យសាស្ត្រ ។ ប៉ិចប្លង់ដ៍មួយតោនមានធាតុរ៉ាដ្យូមតែមួយក្រាមទេ ប្រែបាំ ១ក្នុង១លាន ។ ធាតុប៉ិចប្លង់ដ៍នេះ គេជីករកឃើញច្រើននៅខេត្ត

ប៊ូហែម (Bohem ប្រទេសឆេកូស្លូវ៉ាគី) និងទ្វីបអាហ្វ្រិក គេយកមកដុំធ្វើជាកែវ ៗ ធាតុប៉ិចប៉ាំងដ៏ថ្លៃណាស់គ្រាន់តែមួយក្រាម គេរកលុយទិញស្ទើរមិនបាន ។ ស្វាមីភរិយារិះរកធាតុរ៉ាឌីយ៉ូមនេះយូរឆ្នាំណាស់ រកទៅឃើញថា នៅក្នុងប៉ិចប៉ាំងដ៏មានធាតុរ៉ាឌីយ៉ូម តែរកលុយទិញប៉ិចប៉ាំងដ៏ឲ្យបានគ្រប់ចំនួន ដើម្បីយកធាតុរ៉ាឌីយ៉ូមឲ្យល្មមប្រើជាប្រយោជន៍បានតទៅ ស្វាមីភរិយាគេឃើញទៀតថា ធាតុរ៉ាឌីយ៉ូមនិងអ៊ុយរ៉ានីយ៉ូមនេះដោយឡែកពីគ្នាមិនមែនជាមួយគ្នាទេ បើយកធាតុអ៊ុយរ៉ានីយ៉ូមចេញពីប៉ិចប៉ាំងដ៏ហើយ ក៏នៅមានធាតុរ៉ាឌីយ៉ូមដោយឡែកទៀត ៗ រោងចក្រធ្វើកែវតែងតែយកប៉ិចប៉ាំងដ៏ទៅញែកយកធាតុអ៊ុយរ៉ានីយ៉ូម ដើម្បីទៅប្រើផ្សំធ្វើជាកែវ ហើយបោះកាកប៉ិចប៉ាំងចោលទាំងអស់ ដោយឃើញថាមិនដឹងជានឹងយកប្រើជាប្រយោជន៍អ្វី ៗ កាលស្វាមីភរិយាគេឃើញយ៉ាងនេះហើយក៏ទៅសុំទិញកាកប៉ិចប៉ាំងដ៏ដែល រោងចក្រធ្វើកែវគេចោលនោះមក តែតាមពិតមិនបាច់ទាំទិញក៏បានដែរ ព្រោះគេចោលគរគោក គេចង់តែឲ្យអ្នកណាទៅកកាយយកឲ្យស្រឡះទៅ ព្រោះវានាំឲ្យចង្អៀតគេ ស្វាមីភរិយាបបួលគ្នាកើបយកមកផ្ទះបានចំនួនច្រើន ហើយធ្វើការញែកធាតុក្នុងផ្ទះខ្លួន ព្យាយាមមិនឈប់ឈរ តមក ទីបំផុត ក៏សទ្យបានធាតុរ៉ាឌីយ៉ូម លក់ទៅបានតម្លៃ ១ សែន ៥ ម៉ឺនដុល្លារអាមេរិកាំងបានទ្រព្យសម្បត្តិច្រើន មាន

គេទៅនិយាយប្រាប់ស្វាមីភរិយានេះថា សុំឲ្យគាត់រកស៊ីទៅ តែលោកមិនព្រម ហើយតែងជាក្បួនប្រាប់វិធីរករ៉ាឌីយ៉ូមនេះ ទុកតមកទៀតឲ្យមនុស្សលោកចេះដឹង ។ ធាតុរ៉ាឌីយ៉ូមនេះមានគុណប្រយោជន៍ជួយរក្សារោគសត្វកាចនិងគុណប្រយោជន៍ដទៃទៀតច្រើនប្រការ ។ ដើម្បីជួយជីវិតមនុស្ស ការរកឃើញធាតុរ៉ាឌីយ៉ូម ជាការលឿនយ៉ាងក្រៃលែងនៃពេទ្យសាស្ត្រ លោកទាំងមូលបានឲ្យកិត្តិយសដល់លោក គុយរី និងភរិយាថា លោកជាអ្នករកឃើញដ៏ប្រសើរ ឡើងដល់ឋានៈជាឯកក្នុងលោក ។ ការរកឃើញនេះ ក៏ជាការត្រាស់ដឹងយ៉ាងតូចមួយដែរ ។

រួមទៅបានសេចក្តីថា ការរកឃើញនៃអ្នកគន់គិតដ៏ប្រសើរដូចបានពោលមកហើយនេះ ជាការ «បានរកឃើញអ្វីមួយ» ដែលទុកជាកូនសោចាក់បើកទ្វារចូលទៅធ្វើអ្វីដទៃទៀត ដែលមានប្រយោជន៍បាន ។ ឯការត្រាស់ដឹងនៃព្រះសម្ពុទ្ធក៏នៅក្នុងលក្ខណៈដូចអ្នកដែលរិះគិតដូចបានពណ៌នាមកហើយខាងដើមនេះដែរ តែជាការរកឃើញដ៏ក្រៃលែង ឥតមានអ្នកណាជាគម្រប់ពីរទេ ព្រោះជាការរកប្រស្នាធំបំផុតដែលនិយាយពីចិត្ត ។ មនុស្សគិតគូរដោះស្រាយប្រស្នានេះរាប់ម៉ឺនឆ្នាំមកហើយ តែមិនបានសម្រេចសោះ រីឯអ្នករិះគិតដោះស្រាយប្រស្នាដូចយើងបានពោលមកខាងលើហើយនេះ គន់គិតដោះស្រាយត្រឹមតែប្រស្នាតូចៗ ត្រឹមតែមួយផ្លូវ

ដរឹតក៏បានដូចចិត្តទៅហើយ ដូច្នេះរឿងត្រាស់ដឹងរបស់ព្រះសម្ពុទ្ធប្រសើរវិសេសដូច ម្ដេចទៅទៀត ? តើព្រះអង្គរក ឃើញអ្វី ឬថាទ្រង់ត្រាស់ដឹងអ្វីទើបពេញព្រះទ័យសោយវិមុត្តិសុខ លែងរកតទៅទៀតហើយ ប្រកាសសាសនាព្រះអង្គ ?

បើឆ្លើយថា ព្រះសម្ពុទ្ធ ទ្រង់រកឃើញអរិយសច្ច ឬត្រាស់ដឹងអរិយសច្ចគឺអ្វី ? ឆ្លើយថា ទ្រង់ជ្រាប ថាការប្រព្រឹត្តទៅនៃមនុស្សសត្វទាំងឡាយជាទុក្ខ ឯទុក្ខនេះមិនមែនកើតឯកឯងទេ ទុក្ខតែងកើតមកពីហេតុ (សមុទយសច្ច) បើរលត់ទុក្ខ ក៏ត្រូវរលត់ហេតុនៃទុក្ខ (និរោធសច្ច) មុនសិន ហើយផ្លូវដែលជាទីរលត់ហេតុនៃទុក្ខនោះ គឺផ្លូវ ៨ ប្រការដែលហៅថា អដ្ឋង្គិកមគ្គៈ សម្មាសង្កប្ប សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ។

ព្រះសម្ពុទ្ធទ្រង់ត្រាស់ដឹងត្រឹមតែអរិយសច្ចៈនេះទេឬអ្វី; មុនពីកាលត្រាស់ដឹង ព្រះសម្ពុទ្ធមិនទ្រង់ជ្រាបថា ការប្រព្រឹត្តទៅនៃមនុស្សសត្វនោះជាទុក្ខទេឬអ្វី; ឯទុក្ខនោះមកពីហេតុទេឬអ្វី; កាលពីមុន ព្រះសម្ពុទ្ធទ្រង់មិនទាន់ជ្រាបហេតុទាំងផលនេះទេឬអ្វី; ទើបតែបានជ្រាបក្នុងកាលដែលបានត្រាស់ដឹងនោះឬអ្វី; ដូចម្ដេចក៏បានជាព្រះអង្គបណ្ដោយទុករហូតមកដល់ថ្ងៃធំគឺថ្ងៃបានត្រាស់ដឹងតែម្ដងទើបទ្រង់ប្រកាសថា បើមិនឲ្យមានផល

ត្រូវតែរំលត់ហេតុសិនឬអ្វី; ឯអដ្ឋង្គិកមគ្គក៏ដូចគ្នាដែរ គឺព្រះសម្ពុទ្ធទ្រង់មិនដែលបានរិះគិតមុន ពុំនោះ ធម្មចរិយា ដែលគេប្រដៅឬការប្រតិបត្តិមកមុនពីកាលត្រាស់ដឹងនោះ មិនមានអ្នកណាបានចេះដឹងថា សម្មាទិដ្ឋិៗលៗ សម្មាសមាធិនេះសោះទេឬអ្វី អ្នកដែលឆ្លៀវឆ្លាសប្រាជ្ញកដូចអង្គព្រះសម្ពុទ្ធនេះ ត្រូវប្រើវេលាគន់គិតរិះរកដល់ទៅ ៦ ឆ្នាំ ទើបទ្រង់ត្រាស់ដឹងថា លោកនេះជាទុក្ខ ថាផលមកពីហេតុ ថាប្រតិបត្តិល្អត្រឹមត្រូវ ថាចេះគន់គិតរកផ្លូវប្រសើរ ៗលៗ ទៅឬអ្វី ៗ

សេចក្ដីពិតផ្ទុយស្រឡះពីនោះទៅវិញទេ ពាក្យដែលគេនិយាយថាជីវិតជាទុក្ខនោះ គេបានដឹងមកយូរយារហើយ មិនមែនតែព្រះសម្ពុទ្ធទេដែលចេះដឹងថា "ជីវិតនេះជាទុក្ខ" គេដឹងមកយូរអង្វែងណាស់ហើយដោយហេតុតែដឹងយ៉ាងនេះហើយ ទើបបានជាមានមនុស្សព្យាយាមរកផ្លូវដោះស្រាយទាល់តែកើតមានអ្នកបួស គ្រូបាអាចារ្យធំ ៗ មេលទ្ធិច្រើនអនេក ព្រះសម្ពុទ្ធដែលទ្រង់លះរាជ្យ លះសេចក្ដីសុខមនុស្សចេញទៅសាងបព្វជ្ជានេះ ក៏ព្រោះតែទ្រង់បានជ្រាបច្បាស់ហើយថា "លោកនេះជាទុក្ខ" ហើយបានជាទ្រង់ព្យាយាមរកផ្លូវដោះប្រស្នាទុក្ខនៃលោក ៗ ទ្រឹស្ដីថា "កម្ម គឺអំពើល្អ អាក្រក់ សុខទុក្ខ" ដែលជាផលនៃកម្មនេះ ក៏គេបាន ចេះដឹងមកយូរហើយដែរ តាំងពីមុនពុទ្ធកាលទៅទៀត ៗ រីឯរឿង

ដែលគេប្រកាន់ជឿពីបុរាណកាលមកថាសក្ដិសិទ្ធិ ព្រះអាទិទេព ការបណ្ដាលឱ្យសុខទុក្ខក្ដីពីអាទិទេពនេះ ក្នុងពុទ្ធកាលនោះស្ទើរតែសាបរលាបបាត់បង់ទៅអស់ហើយ ហើយមនុស្សនោះ កំពុងតែគិតរកផ្លូវដោះស្រាយ "កម្ម" រកផ្លូវដោះខ្លួនឱ្យរួចពីទុក្ខគឺការវិលវល់ស្លាប់កើត បានជាមានទ្រឹស្ដីថា "សំសារ"; ថា "មោក្ស" ជមិទាំងនេះបានកើតមានមក ហើយមុនពុទ្ធកាល មានមនុស្សចេញទៅស្វែងរកទាំងស្ដេចទាំងពស្រ្ដ ទៅរកឱ្យឃើញថា "ការដោះខ្លួនឱ្យរួច "មោក្ស" នេះ តើដូចម្ដេច ? តែអ្នកមុនព្រះសម្ពុទ្ធគេរកមិនទាន់ឃើញ គ្រាន់តែដឹង គេដឹងហើយ ៗ

ដូច្នេះយើងឆ្លើយត្រឹមតែថា "ទ្រង់រកឃើញអរិយសច្ចត្រាស់ដឹងអរិយ-សច្ច" ប៉ុណ្ណោះនេះដូចជារកឃើញតិចតួចណាស់ មើលទៅមិនគួរនឹងប្លែកអស្ចារ្យអ្វីប៉ុន្មានទេ ទុកដូចជាបើកប្រកឱ្យអ្នកនិពន្ធ អ្នកផ្សាយសាសនាដទៃ ៗ ដែលគេចង់លុបគុណឬចង់បន្ថយការសំខាន់វិសេសវិសាលនៃព្រះពុទ្ធសាសនា ឬអង្គព្រះសម្ពុទ្ធបានដៃយកទៅពោលក្លែងបន្ថោកបន្ទាបបានជា ការត្រាស់ដឹងនៃព្រះសម្ពុទ្ធនោះ មិនជាការវិសេសវិសាលអ្វីទេ គ្រាន់តែជាការឃើញឬដឹងអ្វី ៗ ដែលគេបានចេះបានដឹងមកហើយ ព្រោះជាការរកឃើញធម្មតា បើគ្រាន់បើណាស់រកឃើញដូចលោកខូតុន លោក

ប៉ាស្ទ័រ ឬលោកគុយរី ស្វាមីភរិយាតែប៉ុណ្ណោះឯង ។

កាលបើដូច្នេះ យើងត្រូវតែទទួលដឹងថា “ការត្រាស់ដឹង„ នៃអង្គព្រះសម្មាសម្ពុទ្ធនោះ មានការវិសេសវិសាលអស្ចារ្យណាស់ ការដែលឆ្លើយថា ព្រះសម្ពុទ្ធត្រាស់ដឹងអរិយសច្ច នោះមិនមែនជាចម្លើយខុសទេ តែបើមានគេសួរថា “ព្រះសម្ពុទ្ធត្រាស់ដឹងអ្វី„ ហើយយើងតបត្រឹមតែថា “ត្រាស់ដឹងអរិយសច្ច„ ដូច្នេះហើយក៏មិនខុសអ្វីនឹងពាក្យដែលគេសួរថា “ផ្លែស្វាយគឺអ្វី„ អ្នកតបលើកផ្លែស្វាយមួយបង្ហាញហើយថា “នេះគឺផ្លែស្វាយ„ ក៏ត្រូវបានដែរ តែចម្លើយត្រឹមតែដល់ទីបំផុត សេចក្ដីពិត “ផ្លែស្វាយ„ នៅមាន អ្វីតទៅទៀតក្រៅពីផលដែលមនុស្សបរិភោគ នៅមានដើម មានឫសគល់ មានសាខាស្លឹកដែលជាការសំខាន់តទៅទៀត ព្រោះថាបើមិនមានការអស់ទាំងនេះទេ ផ្លែស្វាយក៏កើតពុំបានដែរ ។

( នៅមានត )

# វិធុរជាតក

(តពីលេខ ៩២ ឆ្នាំ ១៩៦៤)

មួយសោតទៅកុំលុះនូវអំណាចស្រីឡើយ ។ បុណ្ណកយក្ខ ស្ដាប់ហើយក៏មិនអាច ដើម្បីនឹងទប់ទល់ ដំកល់អាត្មាភាព ដោយនូវសាធុនរធម៌ប្រស្នាទាំង ៤ បទនោះបានឡើយ ។

វរពោធិសត្វព្រះអង្គទេសនា ដោយនូវសង្ខេបនោះបន្តិច ។ អណ្ដាប់នោះ បុណ្ណកយក្ខ ចង់ឲ្យពោធិសត្វ សំដែងថ្លែងឲ្យទូលាយឆ្ងាយជជាយនឹងបានដឹង ទើបដណ្ដឹងទៅស្មូត្រជាបទគាថាថា: កថំ នុ យាតំ អនុយាយី ហោតិ អល្លញ្ច បាណឹ ទហតេ កថំ សោ អសតី ច កា កោ បន មិត្តទុព្ភោ អក្ខាហិ មេ បុច្ឆិ-តោ ឯតមត្ថំ ។ ហៃចៅអ្នកប្រាជ្ញអើយ នាទៅថាដូចអ្នកដើរក្រោយហើយប្រើអ្នកដើរតាមគន្លងនៃអ្នកដើរមុននោះ មួយសោតទៅថា ម្ដេចកុំឲ្យដុតដៃនៃអ្នកដ៏មានដៃទទឹកនោះ មួយសោតទៅថាមិនឲ្យមិត្តទ្រុស្ត លុះនូវអំណាចស្រីនោះតើដូចម្ដេច ចូរទៅសំដែង ថ្លែងស្រាយនូវអាថ៌ប្រស្នាទាំងបួនបទនោះមកហោង ។ ទើបពោធិសត្វ សំដែងថ្លែងសាធុនរធម៌ឲ្យឆ្ងាយទូលាយទៅនោះ មកស្មូត្រជាបទព្រះគាថាថា : អសន្ថុតំ នោបិច ទិដ្ឋបុព្វំ យោ អាសនេនាបិ និមន្តយេយ្យ តស្សេវ អត្ថំ បុរិសោ ករេយ្យ ។ ថាហៃចៅបុណ្ណក-យក្ខអើយ នរអ្នកឯណាមួយ មិនដែលបានឃើញបានស្គាល់គ្នាដល់មុន

ឡើយ អ្នកនោះអញ្ជើញ ឲ្យទៅគាប់គល់ រីអ្នកដែលគេអញ្ជើញឲ្យទៅគាប់គល់នោះ លុះដល់គេទៅ កាន់ស្ថានលំនៅឯងវិញហើយ ក៏គួរទទួលឲ្យគេនៅស្ថានលំនៅនោះគាប់គល់ ដូចគេអញ្ជើញអាត្មានោះវិញហោង អ្នកប្រាជ្ញលោកពោលថា រីអ្នកដំណើរក្រោយប្រើឲ្យដើរតាមអ្នកដើរមុនៗ មួយសោតអ្នកឯណាមួយ ទៅនៅលើផ្ទះគេតែថ្ងៃ ១ ក្តី គេឲ្យបំណើអាហារបាយទឹកបរិភោគ បំពែតស្កប់ស្កល់ហើយ អ្នកនោះ មិនគួរនឹងធ្វើទុកទោសនៃអ្នកម្ចាស់ផ្ទះនោះឡើយ រីអ្នកនោះ ហៅដុតដៃទទឹក ខូចគុណគេនៅថ្មីៗនៅឡើយ ទបមាដូចដៃនៅទទឹកនៅឡើយៗ មួយសោតនរអ្នកឯណាមួយ ចូលទៅឈប់ក្រោមម្លប់ឈើឯណាមួយហើយ ពោះអន្ទ័យក្តី ដេកក្តី កាលបើអ្នកនោះ ក៏នឹងដើរអំពីនោះទៅហើយ មិនគួរគប្បីនឹងកាប់មែកហែកសន្លឹកស្លោះសំបកធ្លុកបណ្តូលឈើនោះឡើយ ថាបើអ្នកនោះធ្វើនូវអំពើដូច្នោះហើយ រីអ្នកនោះឯងលោកហៅទ្រុស្តមិត្តហោងៗ មួយសោតនរអ្នកឯណាមួយ មានចិត្តស្រឡាញ់ស្រី ក៏ឲ្យទ្រព្យអម្រស់ពេញទាំងក្រឡាមហាប្រថពីនោះឲ្យទៅស្រី កាលបើអ្នកនោះ បានទ្រព្យរបស់ច្រើនម៉្លោះហើយ ស្រីនោះខឹងមើលងាយនៃអ្នកនោះហោង នេះហៅព្រះស្តែងលុះទូវឹងអំណាចស្រីនោះហោងៗ បុណ្ណកយក្សស្តាប់ពាក្យពាធិសត្វសំដែងនូវសាធុធម៌ទាំង ៤ បទនោះហើយ បុណ្ណកយក្សទ្រិតឯងថា

នាំទៅពិជ្ជូអ្នកប្រាជ្ញនេះ គាត់សូមអាយុគាត់ឯង នាកាលអញទៅកាន់
គាត់នោះ ក៏គាត់ឲ្យស្លាខលាំនៅ អញនៅជាសុខសប្បាយ ឥឡូវនេះ
អញធ្វើទោសគាត់ដូច្នោះ ដ្បិតតែអញប្រាថ្នាស្រីនោះ ឯង រឺ ពីព័ន ៤
បំពួកនោះ សឹងតែមានខ្ញុំនាខ្លួនអញគ្រប់អស់តាំងនោះឯង ថាបើអញ
សម្លាប់ ទៅពិជ្ជូអ្នកប្រាជ្ញនេះហើយ សមអញមិនបានស្តាប់ធម៌នេះ
ទៀយ ទឹងប្រយោជន៍អ្វី នាងឥឡូវ កូនស្ដេចនាននោះ អញទឹង
នាំទៅពិជ្ជូអ្នកប្រាជ្ញ ទៅដាក់នៅធម្មសភាសាលាវិញ ហោង ៗទៅ
ពិជ្ជូអ្នកប្រាជ្ញអើយ ខំបមាដូចកន្ទេនទៅដូតទឹកកែក អស់អ្នកផ្ទួបថប្បី
ស្រីមហានគរ ឲ្យគេមានចិត្តត្រេកអរ សោះគេជាទុក្ខសោកតែងទឹងគិត
មកសព្វថ្ងៃ អាល័យមកទៅពិជ្ជូអ្នកប្រាជ្ញនេះហោង ៗ បុណ្ណកយក្សគិត
អម្បាលនោះហើយ ស្រដីទៅទឹងពោធិសត្វ សូត្រជាបទព្រះគាថា ថា :
អវសី អហំ តុយ្ហំ តីហំ អគារេ អច្ឆេឆ ធាឆេឆ
ឧបដ្ឋិតោ ស្មិ មុត្តោ មមាសិ វិសជ្ជាមហំ តំ កាមំ
ឃរំ ឧត្តម បញ្ញ គច្ឆ ៗ ថាតែហទៅពិជ្ជូអ្នកប្រាជ្ញអើយ នាអញ
ទៅនៅផ្ទះទៅដាក់របស់ថ្ងៃហើយ ទៅបានឲ្យបាយទឹកហូបចំតែតស្កប់
ស្កល់ហើយ ឥឡូវនេះអញទឹងជូនទៅកាន់ស្រុកទៅវិញហោង ដ្បិត
តែទៅមានគុណទឹងអញ ប្រយោជន៍អ្វី អញទឹងទៅកាន់នាងឥឡូវជា

ប្រពន្ធអញនោះឡើយ ហៃចៅពិធូរអ្នកប្រាជ្ញអើយ នាចៅសម្ដែងថ្លែងព្រះធម៌វិសេសទេស្នាឲ្យអញស្ដាប់ពីរោះហើយ ក៏ចៅរួចអំពីអញសម្លាប់ចៅហោង ៗ អណ្ដាប់នោះ ពោធិសត្វស្ដាប់ហើយឆ្លើយថា ហៃចៅបុណ្ណយក្ខអើយ ចៅកុំអាលនាំអញទៅកាន់ស្ថានលំនៅអញឡើយ ចូរចៅនាំអញទៅកាន់ស្ថានលំនៅបាក្រុក មេក្រុកចៅនោះសិន ត្បិតអញចង់យល់ស្ថានវិមានស្ដេចនាគនោះ អំពីដើមរៀងមកអញពុំដែលឃើញនៃពិភពនាគនោះឡើយ បុណ្ណកយក្ខស្ដាប់ហើយឆ្លើយថា ហៃចៅពិធូរអ្នកប្រាជ្ញអើយ នាព្រះបាទវរុណនាគរាជនោះ ប្រាថ្នាចង់សម្លាប់ចៅ មិនគួរចៅ ក៏នឹងចង់ទៅយល់នៃអ្នកជាសត្រូវនោះឡើយ ៗ ពោធិសត្វស្ដាប់ហើយឆ្លើយថា ហៃចៅមាណពអើយ អញដឹងហើយមិនគួរនឹងចង់យល់ស្ដេចនោះឡើយ តែអញនឹងទៅជាអ្វី នឹងស្ដេចនាគនោះហ៎ះ ហេតុនោះហោងអញមិនខ្លាចស្ដេចនោះឡើយ ដូចអាលចៅឯងមានចិត្តនោះរឹងត្អឹងមហិមា ក៏អញទំងប្រលោមលួងនឹងធម៌ទេសនា ក៏ចៅមានចិត្តនោះទន់លំពោនហើយ ចៅស្រដីនឹងអញថា ឥឡូវនេះ អញមិនគួរនឹងយកនាងឥរន្ទតីឡើយ អញនឹងនាំចៅទៅកាន់ស្ថានលំនៅវិញហោង ហេតុនោះហោងចៅនាំអញឲ្យបានដល់ពិភពនាគនាយ អញនឹងធ្វើឲ្យស្ដេចនោះទន់លំពោនទន់ដូចចៅនោះហោង ៗ បុណ្ណកយក្ខស្ដាប់ហើយ

ឆ្លើយថា ហៃចៅពិធូរអ្នកប្រាជ្ញអើយ ថាះបើដូច្នោះ អញនឹងនាំចៅទៅកាន់ពិភពនាគនាយ ស្រណុកសប្បាយដូចកលនគរ ព្រះបាទវេស្សវណកុវេរមហារាជ បុណ្ណកយក្ខ សរសើរពិភពនាគនោះម្ល៉ោះហើយ បុណ្ណក-យក្ខជិះសេះមនោមយឲ្យពោធិសត្វជិះជាក្រោយ បរបំផាយ ទំលាយទឹកនពមហាសមុទ្រ ប្រាកដនាំពោធិសត្វចុះទៅកាន់ពិភពនាគនាយ បុណ្ណកយក្ខគិតថា បើព្រះបាទពិរុណនាគរាជយល់ចៅពិធូរអ្នកប្រាជ្ញនេះហើយ នឹងមានព្រះហឫទ័យនោះត្រេកអរ នោះអញឥតទោសឡើយ ថាបើព្រះបាទពិរុណនាគរាជ ក៏មិនត្រេកអរឡើយ អញនឹងនាំចៅពិធូរអ្នកប្រាជ្ញនេះត្រឡប់វិញហោង ។ បុណ្ណកយក្ខគិតម្ល៉ោះហើយ ទៅដល់ពិភពនាគនាយនាំពោធិសត្វទៅលើព្រះរាជមណ្ឌលព្រះបាទពិរុណនាគរាជ ឲ្យពោធិសត្វគង់ជាក្រោយ បុណ្ណកយក្ខអង្គុយជាមុខ ទើបព្រះបាទពិរុណនាគរាជទតទៅយល់បុណ្ណយក្ខនោះហើយ មានព្រះតម្រាស់ត្រាស់ដណ្ដឹងទៅថា ហៃចៅមាណពអើយ នាចៅស្វែងរកថ្លើមចៅពិធូរអ្នកប្រាជ្ញនោះ តើបានឬទេ បុណ្ណកយក្ខស្ដាប់ហើយឆ្លើយថា បពិត្រក្សត្រថ្លៃប្រសើរអើយ នាព្រះរាជ-ហឫទ័យ មានព្រះបំណងនឹងចង់បានចៅពិធូរអ្នកប្រាជ្ញនោះមិញ ឥឡូវនេះខ្ញុំបានចៅពិធូរអ្នកប្រាជ្ញនោះ នាំមកដោយនូវធម៌ហោង អញ្ជើញព្រះអង្គទតមើលទៅចៅពិធូរអ្នកប្រាជ្ញនេះ ព្រះអង្គអើយដ៏មានសំដីគាត់នោះពីរោះបពិត្រក្សត្រថ្លៃប្រសើរអើយ ថាបើអ្នកណាមួយ បើបានសុពកតប្រសព្វ

នឹងអ្នកដ៏មានធម៌សប្បុរសប្រសើរនោះ ក៏នឹងជាសុខសប្បាយប្រសើរ ហោង ។ គាថាឡាតិរិកណ្ណំ និដ្ឋិតំ នេះនឹងស្រដីកណ្ឌបុណ្ណយក្ខ ហោលពោធិសត្វក្នុងកាឡាគិរីវិញ ស្រេចនូវប្រការអម្បាលនេះហោង ។

ជាតកជា មហាសត្តំ និស្សា គាថមាហា ។ ព្រះបាទពិរុណនាគរាជយល់ពោធិសត្វហើយសូត្រជាបទព្រះគាថាជណ្ដើងថា: អនិដ្ឋបុព្វំ និស្សាន មច្ចា មច្ចុកយន្តិតោ ព្យម្ហិតោ ជាភិភាទេសិ ន ឥធំ បញ្ញាវតមិភាតិ ។ ជាហៃហាចៅពិធូរអ្នកប្រាជ្ញអើយ ចៅឯមនុស្សលោកនេះ ចៅបានមកយល់ពិភពនាគនេះ ដែលចៅមិនធ្លាប់ឃើញមកអំពីមុន ចៅក៏យខ្លាចស្លាប់ក្តី ក៏ចៅមិនសំពះអញហ្ន៎ះ ចៅអើយ រីអំពើហេតុនេះមិនដែលមានដល់អ្នកប្រាជ្ញតាំងឡាយឡើយ ។ រីព្រះបាទពិរុណនាគរាជប្រាជ្ញាចង់ឲ្យពោធិសត្វសំពះនូវប្រការអម្បាលនោះហើយ ពោធិសត្វឆ្លើយវិញថា បពិត្រមហារាជអើយ រីអញនឹងខ្លាចស្លាប់ក៏មិនសំពះមហារាជនោះឥតអង្គមានឡើយ រីអញដ៏មានទោសដល់ស្លាប់ មិនគួរគេប្រើនឹងសំពះនៃអ្នកដ៏គេសម្លាប់ខ្លួននោះ រីអ្នកដ៏សម្លាប់នោះនោះសោត ហេតុដូចតេម្ដេចក៏ចង់ឲ្យគេសំពះអាត្មានោះ ។ តំ សុត្វា ជាតកជា មហា-សត្តស្ស ជុតិ គារោត្ថា ទេ្វ គាថា អភាសិ ។ ព្រះបាទពិរុណនាគរាជ ស្ដាប់ពាក្យពោធិសត្វហើយ សរសើរពោធិសត្វជាហៃហាចៅពិធូរអ្នកប្រាជ្ញអើយ នាពាក្យចៅស្រដីនោះមែនទៀងក្រៃពេក

អ្នកដ៏មានទោស ទើបនឹងត្រូវសំពះគេសំឡាប់ខ្លួននោះ ឯអ្នកសម្លាប់ខ្លួន នេះសោត ហេតុម្តេចបានឲ្យគេសំពះអាត្មានោះ ។ ព្រះបាទពិរុណ នាគរាជមានព្រះបន្ទូលម៉្លោះហើយ ទើបពោធិសត្វព្រះអង្គធ្វើជាប្រស្រ័យ សួរទូលទៅកាន់ព្រះបាទពិរុណនាគរាជថា: បពិត្រព្រះមហារាជអើយ នាស្ថានវិមានមហារាជ តើយល់ជាគុំទៀនបិតបេរនៅ យល់ម្តងហាក់ ដូចបិតបេរនៅ នាឋានវិមាននោះ អ្នកបង្កើតដោយទូរពិព្យាយាម កម្លាំងឫទ្ធិអានុភាពឬម្តេច ឬមហារាជសម្តែងថ្លែងប្រាប់អាថ៌នោះ ឬមួយ អ្នកបានស្ថានវិមាននឹងអាត្មាដោយទូរហេតុអ្វីមួយ ឬអ្នកបានស្ថានវិមាន នេះដឹកជាស្តេចធំខ្ពស់ក្រៃលែងអ្នកផងទាំងឡាយនេះ ឬមួយអ្នកណាប់ ស្ថានវិមាននេះទីនឹងអាត្មាម្នាក់ឯង ឬមួយទេព្តាឲ្យអ្នក ឬអ្នកសំដែងថ្លែង ប្រាប់មកៈហាង ។ ព្រះបាទពិរុណនាគរាជស្តាប់ហើយ ឆ្លើយថាបៅ ពិត្អូរអ្នកប្រាជ្ញអើយ នាស្ថានវិមាននេះ អញនឹងបានដឹកអញជាធំ ហើយ បង្កើតទូរដូរប្រែប្រួលនោះគ្មានឡើយ មួយសោតអញមិនរណ្តាប់ទីនឹងអាត្មា ឯង មួយសោតឥតទេវតាឯណាក៏ទីនឹងឲ្យអញឡើយ នាអញបានអស់ ស្ថានវិមាននេះដោយទូរអំពីកុសលផលបុណ្យនោះឯង អញបានសាង អំពីមុននោះហាង ។ ពោធិសត្វស្តាប់ហើយឆ្លើយថា បពិត្រមហារាជ នាកាលមុនឡើយ មហារាជបានធ្វើវត្តប្រតិបត្តិម្តេច ឬមួយមហា រាជបានសាងផ្លូវ មួយសោតមហារាជបានសន្សំបុណ្យម្តេច ទើបបានអស់

អានិសង្សនេះឬ មួយមហារាជបានបង្កើតព្យាយាម តាមកម្លាំងបុទ្ធីអានុ-
ភាព ទើបមហារាជបានអស់ស្ថានវិមាននេះ ៗ ព្រះបាទពិរុណនាគរាជ
ស្ដាប់ហើយឆ្លើយថា ហៃទៅពិធូរអ្នកប្រាជ្ញអើយ នាអញនិងប្រពន្ធអញនេះ
យើងទាំងពីរ កាលកើតនៅនាមនុស្សលោកនាយឡើយ នៅស្រុក
បម្បាកនគរ យើងទាំងពីរ មានចិត្តថ្លាសទ្ធាជាពាយកបានឲ្យទានបាយទឹក
សំពត់ ឲ្យគ្រឿងកំរងផ្កាក្ដី នូវកំពលដំណេកផង បានចំអែកស្រមណ៍
ព្រាហ្មណ៍ព្រឹទ្ធាចារ្យផងទាំងឡាយ ហើយយើងបានគោរពប្រណិបតន៍
អ្នកដ៏មានសីលប្រសើរ ហេតុនោះហោង ទើបយើងបានស្ថានវិមាននេះ ៗ
មហាសត្តា អាហា ៗ ពោធិសត្វស្ដាប់ហើយ ឆ្លើយថាហៃ
មហារាជអើយ នាអស់ស្ថានវិមាននេះ មហារាជដឹងថាជាបានដោយនូវ
កុសលផលបុណ្យ បានសាងអំពីមុនហើយ រីដំណតពីនេះទៅ មហារាជ
សង្វាតធ្វើបុណ្យឲ្យទាន កុំបីមហារាជប្រហែសធ្វេសឡើយ ហើយចំណេរ
ទៅឯមុខមហារាជនឹងបានស្ថានវិមានដូច្នេះវិញហោង ៗ ព្រះបាទពិរុណ
នាគរាជស្ដាប់ហើយឆ្លើយថា ហៃទៅពិធូរអ្នកប្រាជ្ញអើយ នាយើង
នឹងឲ្យទានបាយទឹកនោះ គ្មានស្រមណ៍ព្រាហ្មណ៍ព្រឹទ្ធាចារ្យឯណាមួយ
នៅនាពិភពនាគនេះឡើយ បើដូច្នោះហើយតើយើងនឹងឲ្យទានដល់អ្នក
ឯណា ក៏យើងនឹងបានស្ថានវិមាននេះវិញ ចូរចៅសំដែងថ្លែងឲ្យអស់

អាថ៌នោះហោង ។ ពោធិសត្វស្តាប់ហើយឆ្លើយថាបពិត្រមហារាជអើយ នាអស់នាងនាគផងទាំងឡាយ អម្បាលកើតក្នុងព្រះរាជធានីនេះក្តី អស់កូនប្រពន្ធអំបាលមាននាអាស្រ័យចិញ្ចឹមជីវិតនឹងផងមហារាជក្តី ក៏មហារាជមានព្រះបន្ទូលឲ្យពិរោះស្មោះទៅនឹងអ្នកទាំងអម្បាលនោះកុំមហារាជមានបន្ទូលប្រទុស្តឈ្លោះបោះពាក្យអសុរោះ បោះពាក្យអាក្រក់ខ្ញាល់សំបាទៅនឹងអស់អ្នកទាំងអម្បាលនោះឡើយ ហើយឲ្យព្រះគន្ធពិតក្តីក្សា អស់អ្នកទាំងនោះ ដរាបលុះអស់អាយុនៅនាក្នុងស្ថានវិមាននេះ ចំណោរអំពីស្ថាននេះទៅឯក្នុង មហារាជក៏នឹងបានទៅកើតនាសួគ៌ទិព្វលោកនាយនោះប្រាកដហោង ។ ឃរំ ជាតកជា មហាសត្តស្ស ធម្ម-កថំ សុត្វា ។ រីឯព្រះបាទពិរុណនាគរាជ បានស្តាប់ធម៌ទេសនាពោធិសត្វខ្លួនប្រការអម្បាលនោះហើយ មានព្រះហឫទ័យនោះ ត្រេកអរក្រៃពេកហោង ហើយគិតថានាចៅពិធូរអ្នកប្រាជ្ញនេះ អញមិនអាចដើម្បីនឹងទុកទល់នៅស្ថាននេះឲ្យជាយូរបានឡើយ ដូច្នេះហើយអញនឹងនាំទៅបង្ហាញនាងវិមលាទេវី ឲ្យនាងបានស្តាប់ធម៌ចៅពិធូរអ្នកប្រាជ្ញហើយនឹងរំងាប់ក្តីចំណង់នាងនោះ ហើយទើបអញនឹងឲ្យជូនចៅពិធូរអ្នកប្រាជ្ញនេះទៅកាន់ព្រះបាទធនញ្ជយកោរព្យរាជវិញហោង ។ ព្រះបាទពិរុណនាគរាជគិតអំបាលនោះហើយមានព្រះបន្ទូលទៅនឹងពោធិសត្វថា ហៃចៅពិធូរអ្នកប្រាជ្ញអើយ រីឯព្រះបាទធនញ្ជយកោរព្យរាជ អ្នកតែងនឹក

តិតរឭកញឹកៗ មកទៅ កាលនោះឯងហោង ទៅប្រាសាទវិញហើយ ម្ល៉ោះហើយតែននឹងនឹងទុក្ខក្តៅចិត្តទៀតប្រាកដឯង រីចៅនេះជាអាមាត្យប្រសើរ វិសេសមហាជនផងទាំងឡាយ សូម្បីនឹងមានទុក្ខសោកអម្បាលម៉ានក្តី ជាបើបានប្រសព្វនឹងចៅហើយ ក៏សឹងតែបានជាសុខប្រសើរហោង ពោធិសត្វស្តាប់ហើយសរសើរទៅកាន់ព្រះបាទពារុណនាគរាជថា បពិត្រព្រះប្រសើរអើយ នាព្រះអង្គមានព្រះបន្ទូលដោយនូវធម៌ប្រសើរ ក្រៃពេកនោះជាប្រយោជន៍នៃអ្នកដ៏ជាសប្បុរសផងទាំងឡាយ នាកាលកើតសេចក្តីទុក្ខព្រួយផងទាំងឡាយ រីសេចក្តីប្រសើរនោះឃើញប្រាកដមកដូចអញនេះ ក៏នឹងកើតមានប្រាកដហោង រីឯព្រះបាទពារុណនាគរាជ ស្តាប់ហើយក៏មានព្រះហឫទ័យនោះត្រេកអរក្រៃពេក ហើយមានព្រះបន្ទូលថា ហៃចៅពិធូរអ្នកប្រាជ្ញអើយ រីចៅមាណពនេះ ស្រដីថាចៅនេះបានដោយនូវធម៌ ឬមួយបានដោយនូវល្បែងស្កា ទើបចៅនេះមកលុះទៅកណ្តាប់ដៃនៃចៅមាណពនេះ ។

(នៅមានត)

# ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែខ្លួន
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគង់មត់
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សរលត់ ជាតិក៏រលាយ

ប ៣.

## វចនានុក្រមសំស្ក្រឹត ខ្មែរ

(ត)

*ព្រះមហា ចាន់ ទាត់ រៀបរៀង*

អនវេក្ខា ស្ត្រី. កិរិយាមិនមើល, កិរិយាមិនរវល់ ។

អនឝន នបុំ. កិរិយាមិនបរិភោគ; ការអត់បាយ ។

អនឝ្នាន គុ. ដែលមិនស៊ី ។

អនឝ្វាន គុ ដែលមិនផឹស ។

អនឝ្វរ គុ. ដែលមិនអស់ទៅ ។

អនស៑ នបុំ. រទេះបន្ទុក, រថ ។

អនសូយ, អនសូយិត្ប គុ. ដែលមិនមានបំណង ។ អនសូយា ស្ត្រី. ធីតានៃព្រះបាទទក្ស, ម្រក់នៃនាងសកុន្តលា, ស្ត្រី. កិរិយាមិនមានបំណង ។

អនស្សវិ គុ. ដែលមានគតិបណ្ឌិត, បណ្ឌិត ។ បុ. កិរិយាមិនមានគតិបណ្ឌិត, បណ្ឌិត ។

អនស្តង្គត គុ. ដែលមិនទាន់អស្តង្គត ដែលមិនទាន់លិច ។ អនស្តមិត គុ ដែលមិនអស់ទៅ ។

អនស្តិ គុ ដែលមិនមានឆ្អឹង ។

អនហំការ ប៉ុ កិរិយាមិនមានអហំការ, សុភាព ។

អនហំកូត គុ ដែលមិនមានអហំការ, ដែលមិនគិតតែខ្លួន ។

អនហំកូតិ គុ. ដែលមិនជឿថាមានបុគ្គលិកលក្ខណ ។

អនហំពុទ្ធិ គុ ដែលមិនមានគំនិតថាខ្លួន, ដែលមិនប្រកាន់ខ្លួន ។

អនហំវាទិន គុ. ដែលមិនពោលថាមានខ្លួន, ដែលមិនប្រកាន់ខ្លួន ។

អនាកស្មិក គុ ដែលមិនដឹងថាអ្វី ! ។

អនាកាឝ គុ. ដែលមិនមានអាកាស; ដែលមិនមានពន្លឺ, ងងឹត; នប៉ុ. អនាកាស ។

អនាកុល គុ. ដែលមិនច្របូកច្របល់, ដែលរៀបរយ ។

អនាកូប្ត ត. ដែលមិនដឹក, ដែលមិនហ្វូត ( ដាវ ) ដែលមិនដោះ (អាវ) ។

(នៅមានត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា ញ៉ុក ថែម ប្រែរៀបរៀង

(តអក)

---

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ<br>អ្នកវាងវៃឆ្លាស់បើបានអាន<br>នឹងចេះឧបាយកលបំណាន<br>ទាំងមានសន្តានស្នេហាជាតិ<br>យូរ អ៊ុន |

ខណៈនោះ ព្រះចៅហៀនតេទៅគង់នៅក្រុងហ៊ូតោបាន ២៣ ឆ្នាំ ព.ស. ៧៦១ លុះដល់ខែមាឃចូលឆ្នាំថ្មី ឈ្មោះកេងជីពីដើមជានាម៉ឺននៅក្រោមបង្គាប់ចូចូ បានលើនទីជាមន្ត្រីក្នុងព្រះបរមរាជវាំង មានចិត្តស្វាមីភក្តិនឹងព្រះចៅហៀនតេណាស់ កេងជីនោះមានសំឡាញ់ម្នាក់ជានាម៉ឺនឈ្មោះអ៊ុយ-ឡុង កេងជីក៏អញ្ជើញអ៊ុយឡុងទៅប្រឹក្សាក្នុងទីស្ងាត់ថា ចូចូវាធ្វើការជាមិត្រទ្រុស្តនឹងម្ចាស់ផែនដី ដោយអំណាចខ្លាំងណាស់ ឥឡូវវាតាំងខ្លួនជាម្ចាស់វ៉ុយអ៊ង បំណងនឹងដណ្តើមយករាជសម្បត្តិព្រះចៅហៀនតេជាប្រាកដ យើងគិតនឹងឲ្យផែនដីនៅជាសុខក្សេមក្សាន្ត បានជាទីតបស្នងគុណព្រះតេជព្រះគុណព្រះមហាក្សត្រ អ្នកត្រូវជួយគិតដូចម្តេច ដើម្បីនឹងកំចាត់ចូចូចេញបាន ។

អ៊ុយឡុងឆ្លើយថា ខ្ញុំមានសំឡាញ់ស្និទ្ធម្នាក់ឈ្មោះគិមហាន់ ជាតួឧបរាជមកពីដើម, ឯគិមហាន់នេះក៏បានចេញវាចាថានឹងខ្ញុំមកពីយូរមក ហើយថា ចូចូនោះជាមិត្រទ្រុស្តផែនដី គប្បីតែនឹងគិតកំចាត់វាចេញ

ឲ្យស្រឡះទៅ តែនឹងរកប្រកដូវនៅពុំទាន់មានឱកាសនោះ ឯគិមហាន នោះគេជាកៀនសំឡាញ់នឹងអនិប៊ិត ដែលបួចូតាត់មកឲ្យឈរត្រួតត្រាក្សា ស្រុកហ៊្វូគោនេះ បើដូច្នេះយើងនឹងទៅញុះញង់គិមហានឲ្យទៅបញ្ចុះ បញ្ចូលបបួលអនិប៊ិតឲ្យចូលគំនិតនឹងយើង បើប្រសិនជាអនិប៊ុត ចូលគំនិតផងវេលាណា ការដែលគិតក៏នឹងសម្រេចបានដោយងាយ ៗ

កេងជងថា គិមហាននោះជាកៀនសំឡាញ់នឹងអនិប៊ិតពិតមែនណាស់ តែការនេះ ក្រែងគិមហានមិនទៅនិយាយ ព្រោះអនិប៊ុតជាមនុស្សដំនិតរបស់ចូច ៗ អ៊ុយឡុងថា យើងនឹងនាំគ្នាទៅនិយាយមើលកលការគិមហានសិន ថាហើយក៏នាំគ្នាទៅឯផ្ទះគិមហាន។ឃើញក៏ចេញមកទទួលកេងជងនិងអ៊ុយឡុង ឡើងទៅគង្គយខាងលើក្នុងទីស្នាក់ គំនាប់គ្នាតាមសមគួរ អ៊ុយឡុងតាំងនិយាយជាឧបាយថា យើងមករកអ្នកវេលានេះ ព្រោះប្រាថ្នានឹងចងជងស្នេហ៍មួយ ១ តែក្រែងចិត្តអ្នកមិនស្មោះសរគោណភិត ។ គិមហានឆ្លើយថា ការអ្វីឲ្យអ្នកស្រដីទៅចុះ ។

អ៊ុយឡុងថា ខ្ញុំហើយនឹងអ្នកធ្លាប់ស្គាប់គ្នាជាកៀនសំឡាញ់មកយូរហើយ ឯខ្លួនអ្នកក៏ជាមិត្រសំឡាញ់នឹងអនិប៊ុត ឥឡូវខ្ញុំគិតឃើញថា ព្រះចៅវុយអងនឹងបានគ្រងរាជសម្បត្តិជំនួស ព្រះចៅហៀនតេពិតប្រាកដហើយ ឯអនិប៊ុតសោតក៏ជាខ្ញុំរាជការចាស់ គងនឹងស្មើរសេចក្ដីគាប់

ប្រសើរ តាំងឲ្យអ្នកបានជាអាម៉ឺនធំ ដែលខ្លួនខ្ញុំមករកអ្នកនេះប្រាថ្នានឹងឲ្យអ្នកជួយទំនុកបំរុងផង ។

គិមហាន់បានស្តាប់ក៏ខឹងណាស់ ស្ទុះក្រោក ឡើងស្រែកគំហកឲ្យអ៊ុយឡុង ទទួលមនុស្សបំរើចុះតែលើកមកជូន គិមហាន់ក៏ចាប់យកប៉ាន់តែបោះចោលទៅហើយថា ទឹងយកតែមកឲ្យផឹកយកប្រយោជន៍អ្វី អ៊ុយឡុងឃើញដូច្នោះក៏ធ្វើជាខឹងស្រដីថែមថា ខ្លួនខ្ញុំគិតថា អ្នកបានខ្ពង់ខ្ពស់ឡើង ទើបខំសួរហៃទៅមុខមករកអ្នកប្រាថ្នានឹងធ្វើខ្លួនតទៅ នៅមិនទាន់បានដឹងការអ្វី ស្រាប់តែមាក់ងាយប្រមាថធ្វើឲងាប់មុខកណ្តាលជំនុំ ឲ្យអាប់យសដល់មនុស្សបាវព្រាវរបស់អ្នកដូច្នេះ គួរឲ្យឈឺចិត្តណាស់ ។

គិមហាន់ថា មិនមែនខ្ញុំទឹងមិនគិតដល់អ្នកនោះក៏ទេ តែខ្ញុំតូចចិត្តព្រោះអ្នកពីងថា បួច្ចជាសត្រូវពជសម្បត្តិប្រាកដ ហើយមកលើកសរសើរជាជាល្អប្រពៃវិញ មួយទៀតខ្លួនអ្នកក៏ជាខ្ញុំព្រះចៅហៀនតេដូចគ្នា ហេតុម្តេចអ្នកមិនគិតតបស្នងសងគុណព្រះមហាក្សត្រឲ្យប្រាកដ កេរ្តិ៍ឈ្មោះទុក ដែលមិនមកតាំងចិត្តគិតចាំពឹងបុណ្យបួច្ចនោះ ខ្ញុំមិនគួរនឹងរាប់មុខទុកអ្នកជាមិត្រសំឡាញ់តទៅទៀតសោះ ។

អ៊ុយឡុងទឹងកេងដីឃើញដូច្នោះក៏គិតថា គិមហាន់នោះមានចិត្តកតញ្ញូនឹងព្រះចៅហៀនគេពិតប្រាកដណាស់ ។ អ៊ុយឡុងថា ខ្លួនខ្ញុំ

បាននាំគេដើរមកនេះ ប្រាថ្នានឹងជួយទំនុកបំរុង អ្នកគិតកំចាត់ប្ដូរចេញ ដើម្បីនឹងជួបគ្នាការពារផែនដីថ្វាយព្រះមហាក្សត្រតទៅ លុះនិយាយប្រាប់អ្នកដោយការពិតក៏តក់ខ្លាច បានជាក្មួងៗបាយនិយាយលបចិត្តមើលសិន វេលានេះក៏ឃើញចិត្តអ្នកសុចរិតពិតត្រង់ហើយ អ្នកប្ដូរម្ចាស់កំហឹងទៅចុះ ។

គិមហាន់ថា ដីតាដីដូននឹងបិតាមាតាខ្ញុំ ក៏ទទួលទានបៀវត្សជាខ្ញុំរាជការតៗមក ហេតុដល់ខ្លួនខ្ញុំៗឃ្លាននឹងធ្វើក្បត់ទៅចូលខាងសាសត្រូវរាជសម្បត្តិនោះ ដែលអ្នកទាំងពីរគិតដូច្នេះ ខ្ញុំក៏ត្រូវចិត្តដើម្បីនឹងកំចាត់វាចេញ តែអ្នកនឹងរិះគិតដូចម្ដេច ទើបនឹងសម្រេចតាមប្រាថ្នា, កុំយល្ងថា ខ្ញុំគិតនឹងកំចាត់ប្ដូរៈចេញជាដរាប តែនឹងរិះរកកលៗបាយយ៉ាងណាក៏នៅមិនទាន់រកប្រាជ្ញានោះឃើញ ។

គិមហាន់ថា ខ្លួនខ្ញុំជាមិត្រសំឡាញ់នឹងឥងប៊ិតក៏មែន តែនឹងទុកចិត្តវាមិនបាន ខ្ញុំគិតនឹងធ្វើកលៗបាយសម្លាប់អង់ប៉ិតចេញ ហើយដណ្ដើមយកត្រាសម្រាប់ងារនោះមកទុក មិនបានបង្គាប់បញ្ជាលើទាហានគទៅ ហើយខ្ញុំនឹងតែងជាព្រះរាជត្រាស់ព្រះបៅហៀនគេ ទៅដល់ឡាំពីឲ្យលើកទ័ពមក វាយយកស្រុកនៀមកុន យើងនឹងលើកទាហាន

ទៅធ្វើជាគល់សឹកក៏យប្រសព្វពីក្នុងវេញមក  ឃើញថាទឹងទាប់ចូឆូបាន ដោយងាយ ។

អ៊ុយឡុងឪង់កេងជីព្វផ្ទះបោះក៏មានសំណាណាស់  ទះដៃសើចហើយថា អ្នកគិតផ្ចួបផ្ចុះល្អណាស់  គិមហានថា  ខ្ញុំមានមិត្រសំឡាញ់ទៀត ២ នាក់  ឯឈ្មោះទាំង ២ នាក់នោះ  មានចិត្តឃើក្តៅក្រហាយនៅច្រើនណាស់  ព្រោះចូឆូសម្លាប់ឪពុកក់ងឹងបង់ប្អូន  យើងនឹងបបួលឈ្មោះទាំង ២ មករួមគំនិតគ្នា  កេងជីសួរថា ២ នាក់នោះឈ្មោះអ្វី  គិមហានប្រាប់ថា បង់ឈ្មោះកៀតម៉ៅ  ប្អូនឈ្មោះកៀតប៉ុក  ជាកូនកៀតប៉េងជាពេទ្យ ដែលចូឆូសម្លាប់ជាមួយនឹងតាំងស៊ុន  កៀតម៉ៅ  កៀតប៉ុករត់ចេញទៅនៅស្រុកក្រៅ  ឥឡូវចូលមកលាក់ខ្លួនពួនគ្នានៅស្រុកហ៊ូគោរក្រៅពីក្រុង  បើយើងឲ្យទៅបបួលមុខជានឹងចូលមក ធ្វើការផងមិនខាន  ព្រោះមានកិច្ចព្យាបាទចូឆូជាប់ជានិច្ច ។

អ៊ុយឡុង កេងជីយល់ឃើញតាមផង, គិមហានក៏កំណត់ថ្ងៃឲ្យអ៊ុយឡុង កេងជីមកព្រមគ្នា  ហើយឲ្យបំរើស្រុកទៅហៅខ្លួនកៀតម៉ៅ  កៀតប៉ុកឲ្យចូលមក  គិមហានក៏ប្រាប់ថា  តាមគំនិតដែលគិតនោះឲ្យស្តាប់គ្រប់ប្រការ ។  កៀតម៉ៅ កៀតប៉ុក  បានស្តាប់ ហើយក៏យំសោកាល័យ ហើយថា  ជីតាខ្ញុំស្លាប់ក៏ព្រោះចូឆូ  ព្រះចៅហៀនតេបានសេចក្តីក្តៅក្រហាយក្នុងព្រះរាជហឫទ័យណាស់ក៏ព្រោះចូឆូ  បើអ្នកគិតផ្ចួបផ្ចុះខ្ញុំសុំ

ណាស់ សូមបួរដំរិតគិតធ្វើការផង ហើយស្បថស្បានថា ខ្លួនខ្ញុំទាំងបងប្អូន នឹងសុំសម្លាប់ចួរបញ្ចោញឲ្យបាន ។

តមហាន់ថា អ្នកកុំព្រួយឡើយ ខ្ញុំនឹងជួយរិះគិតកំចាត់ចោរជាសត្រូវផែនដីឲ្យបាន ហើយឲ្យសញ្ញាថា បើដល់ខែមាឃ ១៥ កើត ជាទំនៀមអ្នកស្រុកគ្រប់ផ្ទះសំវែងអុជទៀនបូជា បណ្ដាខាម៉ឺនសព្វមុខមន្ត្រីទាំងស្រីទាំងប្រុស ក៏ស្រុះស្រួលបបួលគ្នាលេងសប្បាយដល់ពេលអធ្រាត្រសុទ្ធតែល្បែងមហោស្រព ខ្លួនយើងនឹងចូលទៅកេអង្គិបិត ហើយយើងនឹងនាំពាហានជាស្ត្រីបក្សពួកទៅពួនបង្កប់នៅក្បែរឈ្នួនកំង ត្រូវអ៊ុយឡុងនឹងគេងដីនាំបាវព្រាវដែលទំនុកទុកចិត្ត ទៅពួនបង្កប់ជាពីរកង បើឃើញពន្លឺភ្លើងដែលយើងអុជឡើងវេលាណា ឲ្យអ្នកពលគ្នាលបជុតតៗទៅ ហើយឲ្យនាំបក្សពួកកយប្រសព្វចូលមកឲ្យដល់ទីឈ្នួនអង្គិបិត អ្នកចូលតាមយើងទៅក្នុងព្រះបរមរាជវាំង យើងនឹងអញ្ជើញស្ដេចព្រះចៅហៀនគេ ឲ្យយាងឡើងទៅគង់លើកំពូលប្រាសាទទងហងឡេ យើងនឹងប្រឹក្សាខឹងមន្ត្រីទាំងពួងតាមគំនិតដែលគិតទុក ហើយឲ្យកៀតមៅកៀតចុកដែលនៅក្រៅកំផែងដុតភ្លើងឡើង ហើយនាំបក្សពួកកយប្រសព្វចូលទៅទៀវស្រុកប្រកាសដល់ពាហានទាំងពួងថា ដែលធ្វើការនេះនឹងកំចាត់សត្រូវពជសម្បត្តិបេញ នរណាសុចរិតទៀងត្រង់ នឹង ផែនដីក៏ឲ្យ

ចេញមកជួយ ហើយៈយើងនឹងក្រាបទូលព្រះចៅហៀនគេ ឲ្យមានព្រះតម្រាស់ទៅដល់សាណាប្រជានុក្រស្តតាំងពួង ឲ្យតាំងចិត្តរួមគំនិតធ្វើការជាមួយគ្នា ហើយនឹងឲ្យមានព្រះតម្រាប់ត្រាស់បង្គាប់ទៅដល់ ទៀតពីឲ្យលើកកងទ័ពមកជួយ យើងនឹងលើកទៅតាប់ប៉ូធ្លូងស្រុកសៀមកុន ៦ ការតាំងអម្បាលនេះ យើងត្រូវធ្វើជាការរហ័ស ប៉ុន្តែលះទុកឲ្យយូរមួង ឆ្នាំកឹងនាំអន្តរាយដល់ខ្លួនយើងដូចកាល តាំងពីមុនមិនខាន ។

(នៅមានត)

នរជនណា កាលគិតតែពីបានទ្រព្យសម្បត្តិ
តែងបំផ្លាញសេចក្តីសុខខ្លួនឯង នរជននោះ
ទុកដូចជាវែកភារៈដ៏ធ្ងន់ឲ្យជនដទៃ យក
ខ្លួនធ្វើជាភាជនទទួលរងទុក្ខលំបាកជំនួស
គេទទេ ។

ស្រីហិតោបទេស

# ព្រះរាជនិពន្ធរាមកេរ្តិ៍

## ភាគ ៤

លោកឌ តាម ស្រាវជ្រាវនិងរៀបរៀង

និយាយតាំងពីព្រះបាទកាលនាគរាជលើកទ័ពទៅច្បាំងនិងសហាមលីវ័ន ហើយព្រះបាទឡាស្សទៀនលើកទ័ពមកជួយ ទសកណ្ឋទូលអាសារ៉ាប់ធ្វើការថ្វាយព្រះឥស្វរ តម្រង់ភ្នំកៃលាស បានប្រទានមណ្ឌោគិរី ហើយពាលីនណ្តើមយកទៅដល់ព្រះអាចារ្យមហាឥសីមកសូមនាងមណ្ឌោគិរីឲ្យទៅភពណ៍វិញ ។

ស្រេចហើយកាលណា ព្រះបាទកាលនាគរាជក៏ជិះព្រះរាជរថ ដែលនិម្មិតបង្កើតនោះ បរចេញលើកកងទ័ពមក លុះមកដល់បុរីខេត្តព្រំព្រះនគរ ព្រះបាទសហាមលីវ័នហើយក៏ត្រាស់បង្គាប់សេនានោះឲ្យចូលវាយទំលុះទំលាយដានអសុរា គ្រានោះសេនាយោធានាគដ៏មានឫទ្ធិអានុភាពក្លៀវក្លា បានស្តាប់ព្រះឧង្ការត្រាស់ប្រើដូច្នោះហើយក៏ចូលតតាំងច្បាំងនឹងពួកសេនាអាមាត្យយក្សដែលចាំពិតក្តីរក្សាភាគបន្ទាយជាន់ក្រៅ ៗ គ្រានោះ ពួកកុម្ភណ្ឌពួកអសុរាដែលឲ្យមកចាំរក្សាទ្វារព្រះនគរកំផែងខាងក្រៅនោះ លុះបានឃើញទ័ពនាគរាជលើកចូលមកតតាំងច្បាំងដូច្នោះហើយ សេនាអាមាត្យដ៏ជាធំត្រួតត្រាទ្វារព្រៃនគរក្រៅនោះ ឃើញហើយក៏ខឹងក្រេវក្រោធពិរោធខ្លាំង ក៏ចូលច្បាំងតាំងការពារព្រះនគរវឹកវរនឹងគ្នាជាកោលាហល ខឹងតទល់នឹងពលនាគរាជពុំបាន ក៏រត់បោលខ្ចាត់ខ្ចាយទៅ

ទូលព្រះបាទសហមលីវ័ន ឲ្យទ្រង់ជ្រាប ។ កាលនោះ ព្រះបាទសហមលីវ័ន បានស្ដាប់សេនាមកក្រាបទូលថា មានពួកបច្ចាមិត្រសត្រូវ លើកទ័ពមកតតាំងច្បាំងនឹងសេនាអាត្មាចាញ់ដៃសេនានាគរាជដូច្នោះហើយ ក៏ទ្រង់ក្រេវក្រោធពិរោធខ្លាំងណាស់ ហើយស្ដេចក៏ទ្រង់រំពឹងពិចារណាក្នុងការសង្គ្រាមយុទ្ធ ថាឯសេយ្យពលនាគរាជនេះក៏សឹងខ្លាចអំណាចគ្រុឌ បើអញនឹងចេញតយុទ្ធនាការនឹងព្រះបាទកាលនាគរាជ ក៏គង់តែនឹងស្លាប់រហ័ពលសកលយោធាទាំងសងខាង បើដូច្នោះគួរអញនឹងទៅឯនគរក្រុងលង្កាទ្វីប ។ ឯព្រះបាទចមចតុក្ក្រថា សម្លាញ់អញនោះក៏ស្លាប់បាត់ទៅផង ឥឡូវនេះព្រះរាជបុត្រសោយរាជ្យស្នងឈ្មោះឡាស្យទៀន មានធ្នូសរសិល្បជ័យព្រះខ័នជាគ្រឿងប្រដាប់សម្រាប់យុទ្ធនាការ ទ្រង់ព្រះចិន្ដាគិតដូច្នោះហើយទើបបង្គាប់ប្រាប់សេនាអាមាត្យមុខមន្ត្រី ឲ្យរក្សាការបន្ទាយរាយគ្នាថាគ្រប់មុខក្រសួង ឲ្យមាំមួនហើយព្រះអង្គទ្រង់មានព្រះតម្រាស់ត្រាស់ប្រាប់ទៅ ក្រុមព្រះអាល័ក្សឲ្យសរសេរព្រះរាជសារដាក់ក្នុងបំពង់ស្រេចហើយទើបប្រើសេនាអាមាត្យឲ្យនាំរាជសារទៅឯនគរលង្កាទ្វីប ។ គ្រានោះមហាកាយយក្សសេនាបានទទួលព្រះរាជសារហើយ ក៏ក្រាស់ថ្វាយបង្គំលា ហោះជ្រែកក្រឡាមហាប្រថពីមក ។ កាលនោះ រីសេនាជាធំទាំងពីរនាក់ក៏កេណ្ឌកងយោធាឲ្យចាំរក្សាព្រះនគរ តាមឱង្ការព្រះបាទ

សហមលីវ័នស្រេចហើយ ឯព្រះបាទកាលនាគពជ លុះរាយទំលាយជាន់កំ-ផែនជាន់ក្រៅបានហើយ ក៏គៀនពលយោធាឲ្យលើកកងទ័ពចូលទៅទៀត លុះលើកទ័ពទៅបានដល់ព្រះរាជនិវេសន៍វាំង ព្រះបាទសហមលីវ័នហើយ ក៏បោះកងទ័ពបញ្ជប់រេហ៍ពលសកលយោធាតូចធំទាំងពួង ហើយទ្រង់បង្គាប់ចាត់ប្រើសេនាដ៏មានបុទ្ធិខាំងពូកែ ឲ្យចូលហោមឡោមជុំហ៊ុំព្រះនគរយក្ស គ្រានោះសេនានាគទាំង ៤ បានស្តាប់ព្រះទុង្គារ ប្រើដូច្នោះហើយក៏នាំគ្នាធ្វើតាមព្រះបង្គាប់ ព្រះទុង្គារមហាកាលនាគតាមក្រសួងមុខងាររៀងៗខ្លួនទៅហោង ។ រីឯមហាកាយសេនាព្រះបាទសហមលីវ័ន ដែលប្រើឲ្យនាំព្រះរាជសារនោះ លុះមកដល់ស្ពានក្រុងលង្កាទ្វីបហើយក៏ចូលសាលា-លុយុនហើយក៏លើកដៃគំនាប់ ដល់មហាសេនីយមន្ត្រីតូចធំ ហើយដំពបថា សម្តេចព្រះបាទសហមលីវ័ននៅនគរបាតាល ប្រើខ្ញុំជាសេនានាំព្រះរាជសារមកថ្វាយ ។ គ្រានោះ សេនាជាអធិបតីឆ្វេងស្តាំ បានដឹងសេចក្តីរាជ-ទូតប្រាប់ដូច្នោះ ហើយក៏នាំរាជទូតចូលទៅគាល់ព្រះបាទឡាស្សរៀន ជាម្ចាស់លើសិរសាហើយក្រាបបង្គំទូលថា ឥឡូវនេះព្រះបាទសហមលីវ័ន ប្រើរាជទូតនាំព្រះរាជសារមកថ្វាយទ្រង់ព្រះករុណាសូមទ្រង់ជ្រាប ក្រាបបង្គំទូលហើយក៏ទ្រង់មើលព្រះរាជសារថ្វាយ ក្នុងព្រះរាជសារថា អញជាពន្សវង្សព្រហ្ម ជាមកុដកេតន៍កំពូលពិនសោយរាជ្យនៅនគរបាតាល អញត្រូវជាសម្តេចព្រះអយ្យកាធិបតីទ្រង់ព្រះនាមឈ្មោះ ព្រះបាទសហម-

លើវែង ឲ្យពាមេផ្គលសួស្តីសិរីវឌ្ឍនាការមកដល់ទត្តា ជាហៅទៅក្រុងលង្កា ទ្វីបបាទជាជំណឹង ឥឡូវនេះមានពួកបច្ចាមិត្រនាគរាជលើកកងទ័ពមក ចោមរោមហ៊ុំព័ទ្ធព្រះនគរឲ្យតាល ហើយជីតាសោតក៏គ្មានសេនារេហ៍ពល ណាមួយ មានឫទ្ធិអានុភាពល្មមនឹងបង្ក្រាបបច្ចាមិត្រនេះក៏គ្មានសោះឡើយ ដូច្នោះសូមចៅជួយជីវិតយកចិត្តអាណិតឈឺឆ្អាល ជីតាលើកកងទ័ពជា ឆាប់ ប្រញាប់ទៅបំផ្លាញ នាគរាជពួកសត្រូវឲ្យបាក់បបខ្ទបខ្ទាចបុទ្ធិអំណាច អ្នក អាណាប្រជាជនមន្ត្រីតូចធំ នឹងបានសេចក្តីសុខក្សេមក្សាន្តបានដោយ សារអ្នកហោង ៗ គ្រានោះព្រះបាទឡាស្សទៀនធិបតី បានស្តាប់ព្រះរាជ-សារទ្រង់ជ្រាបសព្វគ្រប់ប្រការហើយ ព្រះអង្គក៏ទ្រង់ក្រេវក្រោធពិរោធ ខ្លាំងតន្ត្រំព្រះបាទ ទះដៃហើយស្រែកប្រាប់ទៅ សេនាអាមាត្យកេណ្ឌកង សេនាយោធាថា ឆាប់អញនឹងប្រញាប់លើកពលសកលកងទ័ព ទៅជួយ សម្តេចព្រះអយ្យកាក្នុងគ្រាឥឡូវនេះហោង ៗ គ្រានោះសេនាទាំង ៤ បាទ ទទួលព្រះឧង្ការហើយ ក៏តាំងកេណ្ឌកងពលអសុរក្ស សុទ្ធសឹងតែខ្លាំង ពូកែ មានឫទ្ធិធ្លាប់ធ្វើការសង្គ្រាមជយមានថ្វីដៃ គង់អាពិទ្ធ ស៊ូតស្វាញ កាប់មិនមុតដុតមិនឆេះ ចេះស្កាត់ទាំងមន្តគាថាមហាសណ្តំបំបាត់បាំង កាយ ក្លាយក្លែងខ្លួនធ្វើជាអ៊ីៗ ក៏បានដូចក្តីប្រាថ្នា ហើយហោះហើរដើរ អាកាស ក្រឡាស់មុជទឹកជ្រែកដីបាន លុះរៀបរេហ៍ពលសកលយោធា ជាស្រេចហើយរង់ចាំស្តាប់ព្រះឧង្ការមហាក្សត្រហោង ៗ រីឯព្រះបាទ

ឡាស្បៀងអសុរ លុះសេនាបានរៀបរហ័ពលសកលយោធា ស្រេច
កាលណាហើយ ព្រះអង្គក៏ទ្រង់គ្រឿងប្រដាប់សម្រាប់ព្រះអង្គស្រេច
ហើយ ក៏ស្តេចឡើងគង់លើព្រះរាជរថ ហើយក៏ត្រាស់បង្គាប់ទៅសេនា
យោធាឲ្យប្រុងប្រៀបរៀបខ្លួន លុះបានពិជ័យឫក្សពេលវេលាបានហើយ
ព្រះអង្គឲ្យលើកព្យូហ ហោះជ្រែកក្រឡាមហាប្រថពីទៅ ៗ លុះបាន
លើកកងទ័ពមកដល់ក្រុងបាតាលហើយ បានឃើញពលនាគរាជលើកមក
ពន្ធ័ទាមរោមរុំព្រះនគរដូច្នោះហើយ ក៏ទ្រង់ខ្ញាល់ណាស់ត្រាស់បង្គាប់
សេនាអាមាត្យរហ័ពលឲ្យចូលវាយពលនាគជាកោលាហល កក្រើកអស់
ពើតទាំងទឹកដី រីឯអសុរីសេហាមលីវ៉ន បានឃើញពួកកងទ័ពទៅក្រុងលង្កា
ទ្វីប លើកមកជួយដូច្នោះហើយ ក៏ទ្រង់ត្រាស់បង្គាប់ព្រះរាជបុត្រថាឲ្យ
លើកពលសេនាអាមាត្យចូលទាមច្បាំងតាំងតនឹងពលនាគរាជ ទាំងក្នុង
ក្រៅហោង ៗ

កាលនោះ មហាយមយក្សជាព្រះរាជបុត្រ បានស្តាប់ព្រះឱង្ការ ព្រះ
បិតាហើយក៏លើកទ័ពទសយោធ័ រីមហាយមយក្សឯង ក៏កាល់កងទ័ពមកពី
ក្រោយហោង វិរាហានពួកពលទាំង ២ ព្រា នគរ ក៏ចូលតតាំងច្បាំងនឹង
សេនាពលនាគ តាំងស្រែកហោជាកោលាហល កាប់ចាក់គ្នាដាវីកវីវក្នុង
នគរបាតាលហោង ៗ រីសេនានាគ លុះឃើញពលអសុរយក្សា ទាំង
ខាងក្នុងខាងក្រៅចូលទាមផ្ទុំផិតព័ទ្ធពេញពាសដ៏វាសដូច្នោះហើយ ក៏

តឿនពលនាគឲ្យចូលតតាំងច្បាំងកាប់សម្លាប់គ្នា លុះយូរបន្តិចទៅពលសេ-
នានាគក៏ចាញ់ដៃពលសេនាយក្ស ក៏ស្លាប់វិនាសដាសព្រះធរណីដោយឫទ្ធិ
តេជដៃពលយក្សហោង ។ គ្រានោះ ព្រះបាទកាលនាគរាជនោះ លុះ
បានឃើញពួកពលសេនា វរហ៍ពលសកលយោធាស្លុតស្លាប់វិនាសអស់
ផុតព្រោះហើយ ក៏ទ្រង់ក្រេវក្រោធជាខ្លាំង តាំងសម្តែងផ្លែងកាយក្លាយ
កើតជាក្បាល ៧ ដ៏មានភ្នែកនោះក្រហមប្រាលដាលប្រពាត់ដូចសែងព្រះ
អាទិត្យ ហើយក៏ស្ទុះមកដល់នៅមុខព្រះរាជរថព្រះបាទឡាស្សទៀន
រីឯព្រះបាទឡាស្សទៀនឃើញស្តេចភុជង្គនាគរាជ សំដែងឫទ្ធិអានុភាពស្ទុះ
មកដូច្នោះហើយ ទើបចាប់យកធ្នូសរពិស្សវេសដ៏មានឫទ្ធិអានុភាពបង្ក្រាប
សត្រូវគ្រប់ទិសបាន ព្រះអង្គក៏ទ្រង់ថ្លែងសរសិល្បទៅ រីឯសរនោះ
ក្លាយកើតជាក្រុងគ្រុឌាធំប៉ុនព្រះព្រហ្មដោយឫទ្ធិសក្តាអានុភាព ដេញ
ឆាបឆក់ហើយហាមាត់ចឹកខាំបំពង់ក ហើយយកជើងជាន់ចាប់រួបរឹតព្រះ
បាទកាលនាគរាជបានហើយ នាំយកមកថ្វាយព្រះបាទឡាស្សទៀនអសុក
រីឯព្រះបាទកាលនាគរាជ ដែលសិល្បសរគ្រុឌរាជចាប់ចឹកចង់រួតរឹតព្រួយ
ស្ទើរហាក់នឹងក្ស័យជីវិត ក៏មានចិត្តនោះភ័យភិតគិតខ្លួនក្រែងដួនដល់ក្ស័យ
ប្រល័យជន្ម បាត់ខ្លាសអៀនអប់អន់ទន់ទាបយសសក្តិហើយស្រែកថា
ម្ចាស់អើយសូមទានមេត្តាទុកអាយុខ្ញុំ ឲ្យបានរួចរស់ពនមានជីវិតទៅ
នៅជាខ្ញុំបំរើបាទព្រះអង្គហោង ។

កាលនោះ ព្រះបាទឡាស្សទៀនបានស្តាប់ព្រះបាទកាលនាគរាជស្រែកសូមទោសដូច្នោះ ព្រះអង្គក៏ទ្រង់មានចិត្តមេត្តាករុណាប្រោសសន្តោសទៅស្តេចនាគណាស់ ទើបត្រាស់ព្រះឱង្ការថា ម្នាលគ្រុឌអើយ ចូរអ្នកលើកលែងស្តេចកុដង្គនាគចេញ ទុកនៅមុខព្រះរាជរថអញនេះចុះ រីព្រះបាទកាលនាគរាជក៏បានរួចពីទុក្ខទោសរស់ជន្មាហើយ ក៏មានចិត្តនោះត្រេកអរសាទរក្រៃពេកក៏មានចិត្តនោះ នឹកស្រឡាញ់ព្រះបាទឡាស្សទៀនអស្សុរាក៏និមិតកាយជាមនុស្ស ហើយក៏មានដួងចិត្តនោះលះបង់ប្រទូសរ៉ាយក្រាបថ្វាយបង្គំគាល់ទូលថា ខ្ញុំទូលព្រះបង្គំជាខ្ញុំក្នុងគ្រានេះមានទោសដល់ជីវិត កុំតែព្រះអង្គទ្រង់ព្រះរាជទានមេត្តាទុកជីវិតឲ្យបានរស់ នោះព្រះអង្គក៏មានព្រះគុណនោះធ្ងន់នឹងគណនាត្រារាប់ពុំបាន ទូលព្រះបង្គំជាខ្ញុំមិនដឹងបានវត្ថុអ្វីនឹងតបស្នងសងព្រះគុណ ទ្រង់ព្រះករុណានោះ ទូលព្រះបង្គំជាខ្ញុំមានតែរាជធីតាមួយ ជាគ្រឿយដួងចិត្ត នោះខ្ញុំនឹងយកមកថ្វាយឲ្យនៅជាខ្ញុំបំរើក្រោមព្រះបាទា ។ ថាហើយព្រះបាទកាលនាគរាជក៏ក្រាបថ្វាយបង្គំលាទៅស្ថានពិមានអាត្មាវិញហោង ។

គ្រានោះ រីមហាយមយក្សាបានឃើញស្តេចកុដង្គនាគរាជចាលចាញ់បាក់បបខ្ចបខ្ចាចអំណាចបុទ្ធដូច្នោះហើយ ក៏មានចិត្តនោះត្រេកសាទរទូលថាសូមទានទ្រង់ព្រះមេត្តាអញ្ជើញ ទ្រង់ព្រះករុណាវិសេសស្តេចយាងចូលទៅក្នុងទីដំណាក់ព្រះរាជវាំងហោង ។

កាលនោះ ព្រះបាទឡាស្រទៀនបានស្តាប់ហើយព្រះអង្គក៏លើកពលសកលយោធាចូលទៅកាន់ព្រះនគរសហាមលីវ៉ៃ ។ លុះមកដល់ហើយ ព្រះអង្គក៏បញ្ឈប់កងទ័ពទៅមុខព្រះលាន ហើយព្រះអង្គក៏យាងចុះពីកដរថស្រេចស្តេចយាងចូលទៅគាល់ព្រះបាទសហាមលីវ៉ៃ ។ កាលនោះ ព្រះបាទសហាមលីវ៉ៃ ស្តេចបានឃើញព្រះរាជនត្តាមកគាល់ដូច្នោះហើយព្រះអង្គក៏ចុះពីទីព្រះទែនពេជ្រ ស្តេចយាងមកទទួលព្រះរាជនត្តាស្តេចចាប់ព្រះហស្តាដឹកដៃមកដល់ទែនទិព្វលោកាបល្ល័ង្កហើយ ស្តេចក៏ទ្រង់មេត្តាព្រះរាជនត្តា ឲ្យគង់ជាមួយនឹងគ្នាហើយទ្រង់មានមធុរសព្ទថាកុំបានតែបាឯងលើកទ័ពមកជួយតតាំង ច្បាំងឈ្នះពួកពលសេនានាគនោះ បាមានគុណនឹងជីតាណាស់កុំអីនគរក្រុងបាតាលបានទៅស្តេចនាគហោង ។ រីឯព្រះបាទឡាស្រទៀន ក៏ឱនកាយក្រាបថ្វាយបង្គំហើយទូលថាទូលបង្គំជាខ្ញុំនេះ មិនដឹងសោះថានគរបាតាលនេះមានសឹកសត្រូវធំលើកមកតតាំងច្បាំងនឹងព្រះអង្គនោះក៏ទេ លុះតែទ្រង់ព្រះករុណាវិសេសទ្រង់ប្រើរាជទូតទៅទើបបានដឹង ទូលព្រះបង្គំជាខ្ញុំក៏លើកកងសេនាយោធាមកតាមព្រះឱង្ការ ទ្រង់ព្រះករុណាជួយតតាំងច្បាំងមិនគិតកាយស្តាយជីវិតឡើយ ហេតុតែបុណ្យទ្រង់ព្រះករុណាជួយ ទ្រទ្រង់ព្រះករុណាផងទើបបានសម្រេចដូចក្តីប្រាថ្នាហោង ។ (នៅមានត)

# រឿងចៅរលាដូង

## ( រឿងព្រេងខ្មែរ )

លោក ឌ តាម ស្រាវជ្រាវនិងរៀបរៀង

មានសេចក្ដីដំណាលថា មានបុរសកំសត់ម្នាក់មានកូនស្រីម្នាក់ ។ ថ្ងៃមួយបុរសនោះ រៀបចំល្អីស្រូវសំបកឃ្លោកសំរាប់ដាក់ទឹក និងកាំបិតផ្ទុកនៅក្នុងរទេះ ជាមួយកូនស្រីដើម្បីទៅកាប់អុសក្នុងព្រៃ ។ ទៅដល់ព្រៃហើយ បុរសនោះហើយនិងកូនស្រីនាំគ្នាបរិភោគបាយស្រេច ទើបនាំគ្នារកកាប់អុស ។ នៅពេលថ្ងៃត្រង់កូនស្រីស្រេកទឹកពេក ក៏កាន់សំបកឃ្លោកទៅរកដងទឹក ។ នារីកំសត់ដើររកទឹកទៅដល់កន្លែងមួយ ស្រាប់តែឃើញទឹកចេញផ្សារនៅចំកណ្ដាលថ្មផាំមួយធំ ហូរទៅដក់នៅក្នុងក្រហែងថ្ម នោះ ។

កញ្ញាកំសត់ផឹកផងងូតផងតាមសេចក្ដីប្រាថ្នារបស់នាង ហើយទើបនាំពតិមានដែលនាងបានឃើញនោះមកប្រាប់ឪពុក ។ បុរសនោះក៏ឲ្យកូនស្រីជូនទៅកន្លែងដែលមានទឹកចេញពីថ្ម ដើម្បីនឹងរកទឹកផឹក តែពេលនោះ នាងឃើញតែក្រហែងថ្មនៅស្ងួតថែស ហើយនាងប្រាប់ទៅឪពុកថា " ពុកអម្បាញ់មិញនេះ ទឹកពេញប្រៀបចង្អូរថ្មនេះ មើលខ្លួនខ្ញុំនៅទទឹកនៅឡើយ ខ្ញុំងូត ខ្ញុំផឹកពាល់តែឆ្អែត ។ ខ្ញុំមិនដឹងជាហេតុដូចម្ដេច បានជាចង្អូរថ្មនេះស្ងួតហែងដូច្នេះ ? ។

បុរសឪពុកស្រេកទឹកស្ទើរទ្រាំមិនបាន ក៏បង្គាប់ឲ្យកូនស្រីប្រមូលអុសដាក់ទេះ ទឹមគ្របីបរត្រឡប់មកផ្ទះវិញ ។ កន្លងមកមួយសប្ដាហ៍ កូនស្រីនោះស្រាប់តែមានគភ៌ ។ មនុស្សតូចធំនៅក្នុងភូមិ ឃើញកូនស្រីបុរសនោះ ដើមគ្មានប្ដីហ្នឹង ក៏ទៅរកដីដូនជីតា ហើយពោលតិះតេះតិះដៀលថា « មើល ! ពសមមុខហើយ មានកូន ! មានទៅដើមរកមុខប្ដីមិនឃើញ » ។

ក្រុមញាតិនារីនោះក៏ឆ្លើយយ៉ាងសុភាពទៅគេវិញថា « មិនអីទេ ចាំឃើញទៅជំរាបលោកមេឃុំ ឲ្យរករឿងនេះ ។ កូនចៅខ្ញុំ តាំងពីកុមារីមកហូតដល់សព្វថ្ងៃនេះ មិនដែលមានបុរសណាមួយមកលូកលាន់ឆាយឆាយសោះ ម្ដេចក៏ទៅជាដូច្នេះកើត ខ្ញុំដូចជាមិនអស់ចិត្តសោះ ។ ប៉ុន្តែថ្ងៃមួយនោះ ពាតាមឪពុកទៅព្រៃដើម្បីរកឧស ហើយពាបានផឹកទឹកដែលចេញពីកណ្ដាលថ្មដា ហើយពាទៅនាំឪពុកពាឲ្យមកមើល តែដល់ឪពុកពាមកហើយ ទឹកនោះក៏រីងអស់ទៅវិញ ហើយក៏នាំគ្នាត្រឡប់មកផ្ទះស្រាប់តែក្រោយមកចំនួន ៧ ថ្ងៃ ពាមានផ្ទៃពោះឡើង » ។

មនុស្សម្នាក្នុងភូមិនោះ ឮក្រុមញាតិនារីនោះ សាស័ព្ទប្រាប់ហើយ ក៏លែងតិះតេះដៀលក្រុមញាតិនៃបុរសកំសត់នោះទៅ ។ កូនស្រីនោះមានគភ៌គំរប់ទសមាស ក៏សម្រាលកូនប្រុសមួយ មូលដូចរលាដូង ហើយគេសន្មត់ឲ្យឈ្មោះថា «ចៅរលាដូង» ទៅ ។ កុមារនោះកាន់តែធំឡើង

ជាលំដាប់ ដល់អាយុបាន ៧ ខែ វាចេះនិយាយស្ដីបានដូចគេឯង អាយុបាន ១ ឆ្នាំគត់ វាចេះដើរ ដល់វាអាយុបាន ៣ ឆ្នាំ វាចេះទៅឃ្វាលពពែ ។

ថ្ងៃមួយកុមារនោះត្រឡប់មកពីឃ្វាលពពែវិញ វានិយាយប្រាប់មាតាថា ឲ្យយកវាទៅនៅជាទាសនៃព្រះមហារាជ ដើម្បីឲ្យវាឃ្វាលក្របីស្ដេច ។ ម្ដាយឆ្លើយទៅវិញថា « នែកូន កូនគ្មានដៃគ្មានជើង មូលដូចរលាដូង កូនមិនចេះដើរ ចេះតែប្រមៀលខ្លួនដូចបាល់ឡុង កូនអាចឃ្វាលបានតែពពែបីទេ ម៉ែមិនហ៊ានយកកូនឲ្យទៅនៅឃ្វាលក្របីហ្លួងទេ ខ្លាចកូនធ្វើបាត់ទៅ ម៉ែមានទោស ។ កូនធ្វើម្ដេចនឹងឃ្វាលឈ្នះ បើក្របីហ្លួងច្រើនម្ល៉េះ ? ។ ម្ដាយមិនហ៊ានយកកូនទៅថ្វាយព្រះរាជាទេ» ទើបកុមារនោះថា វានឹងទៅទូលព្រះរាជាឲ្យដឹងការ ។ ឯម្ដាយក៏យ នាំកុមារនោះ ទៅថ្វាយព្រះរាជា ។

ម្ដាយទៅដល់ទ្វាររាំង ស្រាប់តែសុនខព្រុសពេញតែផ្លូវ ទើបអ្នកយាមទ្វារឆ្វេងស្ដាំស្រែកសួរទៅស្ដ្រីនោះថា " នរណាមកទីនេះ បានជាឆ្កែព្រុសដូច្នេះ ? ។ ម្ដាយចៅរលាដូងថា «ខ្ញុំមកនេះ ដើម្បីយកចៅរលាដូងមកសុំព្រះរាជានុញ្ញាតឲ្យវានៅឃ្វាលក្របីព្រះអង្គ " ។

អ្នកយាមក៏ទៅក្រាបទូលព្រះរាជាថា «សូមព្រះតេជគល់លើត្បូង ម្ដាយចៅរលាដូងថា នឹងយកចៅរលាដូងឲ្យមកនៅឃ្វាលក្របីរបស់ព្រះ

អង្គ ។ ព្រះរាជាក៏មានព្រះរាជបញ្ជាឲ្យនាំម្តាយនិងចៅលោដូងមកគាល់ ។ ព្រះរាជាក៏មានព្រះបន្ទូលទៅកាន់ម្តាយចៅលោដូងថា "ម្តេចបានជាអ្នកនាំកូនមកកន្លែងនេះ ?„ ម្តាយទូលថា "សូមព្រះតេជះគំគល់លើត្បូង កូនខ្ញុំម្ចាស់ឈ្មោះចៅលោដូងនេះ ខ្ញុំម្ចាស់នាំវាមកថ្វាយព្រះអង្គ សូមឲ្យព្រះអង្គអនុញ្ញាតឲ្យវាទៅឃ្វាលក្របីរបស់ព្រះអង្គ ។ ព្រះរាជាមានព្រះបន្ទូលថា „ អ្នកគង្វាល ៣០ នាក់ ក៏ឃ្វាលក្របីខ្ញុំមិនឈ្នះដែរ ។ ក្របីខ្ញុំដល់ទៅ ៣០ ម៉ឺនក្បាល ធ្វើម្តេចចៅលោដូងមើលឈ្នះ? ។

ព្រះរាជានាំចៅលោដូងទៅមើលក្របី ហើយមានព្រះបន្ទូលថា «ឃើញទេក្របីខ្ញុំ ៣០ ម៉ឺន អ្នកអាចឃ្វាលឈ្នះឬទេ ?» ចៅលោដូងទូលព្រះរាជាថា «ទូលព្រះបង្គំអាចឃ្វាលឈ្នះ» ។ ព្រះរាជាមានព្រះបន្ទូលទៅកាន់មាតានៃចៅលោដូងថា «បើដូច្នោះអ្នកស្រីទុកចៅលោដូងនៅទីនេះចុះ ចាំស្អែកសឹមទៅនៅឃ្វាលក្របីខ្ញុំ» ។ ម្តាយចៅលោដូងវិលត្រឡប់ទៅផ្ទះទុកកូនឲ្យនៅជាមួយព្រះរាជា ។

ព្រឹកឡើង អ្នកបំរើព្រះរាជាបើកក្រោលក្របីឲ្យចៅលោដូងយកក្របីទាំង ៣០ ម៉ឺនទៅឃ្វាល ។ អ្នកបំរើចាប់ចៅលោដូងឲ្យជិះលើខ្នងក្របី ហើយដេញក្របីឲ្យទៅរកស៊ីស្មៅនៅវាលស្រែ រួចទើបត្រឡប់មកលំនៅវិញ ។ អ្នកបំរើចេះតែនាំគ្នាឆ្ងល់ថា តើចៅលោដូងឃ្វាលក្របីដូចម្តេចកើត បើក្របីច្រើនម្ល៉េះ ។

នៅពេលថ្ងៃត្រង់ព្រះរាជបុត្រីពៅរបស់ព្រះរាជាយកបាយទៅឲ្យចៅស្រលាដូងបរិភោគ ។ ព្រះនាងឃើញក្របីស៊ីនៅជុំគ្នា ។ តែព្រះនាងមិនឃើញនៅស្រលាដូង ។ ព្រះរាជបុត្រីក៏ស្រែកហៅ « អើចៅស្រលាដូង អ្នកនៅឯណា ! ខ្ញុំរកអ្នកមិនឃើញ» ។ ចៅស្រលាដូងថា « ណេះ ! ទូលបង្គំនៅឯណេះ » ចៅស្រលាដូងក៏ប្រវៀលខ្លួនមកក្បែរព្រះរាជបុត្រី ដើម្បីយកអាហារបរិភោគ ហើយព្រះនាងក៏ត្រឡប់មកព្រះរាជដំណាក់វិញ ។

ពេលល្ងាច ចៅស្រលាដូងជិះលើខ្នងក្របី កៀងប្រមូលក្របីយកទៅក្រោលវិញ ។ អ្នកបំរើព្រះរាជាឃើញក្របីគ្រប់ចំនួន ។ ព្រះរាជាទ្រង់ព្រះចិន្តាថា « ពីមុនអ្នកគង្វាលរាប់រយនាក់ឃ្វាលក្របីនៅតែបាត់ ចុះថ្ងៃនេះ មនុស្សតែម្នាក់គ្មានដៃជើងផង ម្តេចក៏ឃ្វាលក្របីមិនឲ្យបាត់មួយៗ តើចៅនេះធ្វើដូចម្តេច បានជាវាឃ្វាលក្របីឈ្នះ» ។

ស្អែកឡើង ព្រះរាជាបង្គាប់ឲ្យចៅស្រលាដូងយកក្របីទៅឃ្វាលទៀត ហើយឲ្យកាប់វល្លិ៍យកមកដំណាក់ខ្លះផង ។ ព្រះអង្គបង្គាប់ចៅស្រលាដូងហើយ ក៏ឲ្យអ្នកបំរើបើកក្របីចេញពីក្រោល លើកចៅស្រលាដូងឲ្យជិះក្របី ហើយឲ្យកាំបិតមួយទុកគ្រាន់កាត់វល្លិ៍ ។ នៅពេលថ្ងៃត្រង់ ព្រះរាជបុត្រីយកបាយទៅឲ្យចៅស្រលាដូងបរិភោគទៀត ។ ដល់ស្តេចយាងទៅដល់កន្លែងឃ្វាលក្របី ព្រះនាងលួចមើលចៅស្រលាដូងតើកាប់វល្លិ៍ដូច

ម្តេចកើត បើគ្មានដៃជើងដូច្នេះ ។ ព្រះកជបុត្រីឃើញចៅរដូងដប់មនុស្សជាច្រើនឲ្យមកជួយ ។ នៅកន្លែងនោះ ឃើញមានប្រាសាទមួយ មានខ្ញុំកំដរ មានចៀមពពែ ជ្រូកក្អែកទាមាន់យំទ្រហឹងអឹងកង ។ មនុស្សប្រុសស្រីចាស់ក្មេង មួយពួកនាំគ្នាទៅបោចស្មៅ មួយពួកទៀតនាំគ្នាទៅចាំឃ្វាលក្របី ។ ព្រះកជបុត្រីទតឃើញហេតុនោះផ្ទាល់ព្រះនេត្រ ហើយក៏ជ្រាបថា ចៅរលាដូងជាអ្នកបះដប់មនុស្ស ព្រះនាងលាក់រឿងនេះមិនឲ្យនរណាដឹងឡើយ ។

ព្រះនាងលបមើលដូច្នោះហើយ ក៏ធ្វើជាស្រែកហៅចៅរលាដូងឲ្យមកយកបាយស៊ី ។ ឮសំឡេងនោះភ្លាម ចៅរលាដូងបង្គាប់ឲ្យមនុស្សទាំងអស់នាំគ្នាចូលទៅក្នុងដីវិញទៅ ហើយទើបកប្រែមៀលលខ្លួនទៅយកបាយមកបរិភោគ ។ ព្រះអង្គម្ចាស់ក្សត្រីយាងត្រឡប់មកតំណាក់វិញយឺតយូរជាងពេលមុន ទើបព្រះបិតាមានព្រះបន្ទូលថា «ម្តេចបានជាកូនទៅយូរម៉្លេះ» ព្រះអង្គម្ចាស់ក្សត្រីទូលថា «ព្រះនាងវង្វេងផ្លូវ» ។

ពេលល្ងាច ចៅរលាដូងកៀងក្របីមកក្រោលវិញ ។ កបានហៅមនុស្សឲ្យចេញពីក្នុងដីមកវិញ ដើម្បីឲ្យមកជួយយកល្ពុំកទឹងស្នែងក្របី ហើយឲ្យជួយដេញក្របីមកក្រោលដល់មកពាក់កណ្ដាលផ្លូវ ចៅរលាដូងបញ្ជាឲ្យមនុស្សទាំងអស់ចូលទៅក្នុងដីអស់ទៅ ។ ព្រះកជាក៏បង្គាប់

ឲ្យអ្នកបំរើជួយស្រាយវល្លិ៍ចេញពីកស្នែងក្របី គេទុកមួយកន្លែងប្រហែល ជាមួយយាយទេះទើបដឹកអស់ ។

ថ្ងៃស្អែកទៀត ចៅលោដូនយកក្របីទៅឃ្វាលដូចសព្វមួយដង ៗ ពេលថ្ងៃ ព្រះរាជបុត្រីយកបាយទៅឲ្យចៅលោដូនបរិភោគ ។ ព្រះអង្គម្ចាស់ក្សត្រីឃ្មាំមើលៈចៅលោដូនដប់ម្ដងទៀត ។ ព្រះនាងឃើញប្រុសស្រីចាស់ក្មេងក៏ពរយពាន់នាក់នៅចាំបំរើចៅលោដូន ។ សត្វចតុប្បាទ-ទ្វេបាទ ពហុបាទ បក្សាបក្សីនៅក្នុងព្រៃជាច្រើនបានមកគំនាប់គោរពចៅលោដូន មើលទៅគួរឲ្យពិចពិលរមិលមើលជាពន់ពេក ។ សំឡេងសត្វទាំងអស់នោះ ពិរោះដូចជាសំឡេងភ្លេងតូរ្យតន្ត្រី ភ្លេងពិណពាទ្យព្រះរាជទ្រព្យសម្រាប់ព្រះមហាក្សត្រ ។ (នៅមានត)

> អ្នកមានប្រាជ្ញា បើទុកជាត្រូវស្លាប់ក៏មិនប្រែ
> កែក តែមិនព្រមឲ្យធ្លាក់ខ្លួនទៅរកអ្នកក្រីក្រទេ
> ដូចជាភ្លើងសូម្បីរលត់ហើយក៏មិនព្រមត្រជាក់
>
> ស្រីហិតោបទេស

# អធិប្បាយកាសិតរបស់សាស្ត្រាចារ្យ ឈឹម-ស៊ុម

## ទឹកត្រជាក់ត្រីកុំ

### ពាក្យ ៨

ខ្ញុំសូមអធិប្បាយស្រាយកាសិត ដែលប្រាជ្ញព្រឹទ្ធប្រឌិតទុកមកជា
"ទឹកត្រជាក់ត្រីកុំ" នេះទុកជា សវនាសណ្តាប់នៃសន្តាន ។
កាសិតនេះប្រាជ្ញចេះចែកពីរបទ ជាកំណាត់កត់ទុកជាលំអាន
ទី ១ ទឹកត្រជាក់ជាប្រធាន ទី ២ មានត្រីកុំជុំជាប់ជិត ។
ពាក្យនេះឯងជាពាក្យឧបមា ចាស់ៗថាតាមប្រាជ្ញពោលប្រឌិត
ទុកប្រដៅកូនចៅជានិស្សិត ប្រើគំនិតគិតរកសេចក្តីសុខ ។
បទទី ១ ដែលថាទឹកត្រជាក់ អស់នាងអ្នកកុំយល់ថាទឹកថុក
វារីថ្លាឬល្អក់ដក់គ្រប់ស្រុក ក្នុងជង្ហុកបឹងបួរជួរទន្លេ ។
ទឹកទីនេះគឺចិត្តយើងគ្រប់គ្នា ជាចិត្តជាមេត្តាឯណោះទេ
ទន់ការណិតចិត្តល្អដល់អស់គេ គ្មានវៀចវេរធ្វើទុក្ខបុកឲ្យម្នេញ ។
ចិត្តជនណាប្រាថ្នាចង់សុខខ្លួន មិនរុកគួនឲ្យគេខ្លាយសុខចេញ
មិនជេរពោលពោលរុកមិនជ្រក់ជ្រេញ មិនម្នាម្នេញបំបាត់ជីវិតទ្រព្យ ។
ដោយយោបល់យល់ឃើញថាខ្លួនយើង ម្តេចចេះចង់រស់មិនចង់ស្លាប់
ចង់តែមានធនធានសម្បត្តិទ្រព្យ ចង់តែស្ងប់មិនចង់ក្តៅក្រហាយ ។
គេឯទៀតក៏ចង់រស់ដូចយើង ចង់តែថ្កើងមានទ្រព្យគាប់សប្បាយ
ចង់ក្សេមក្សាន្តមិនចង់ក្តៅក្រហាយ យើងទាំងឡាយទាំងគេក៏ដូចគ្នា ។

ចិត្តជននោះហៅថាចិត្តស្មោះសរ តាមព្រះធម៌ថាចិត្តមានមេត្តា
ដូចជាទឹកត្រជាក់ថែមទាំងថ្លា ពួកមច្ឆាត្រីកុំដុំជិតនៅ ។

បទទី ២ ថាត្រីកុំដុំជិត សូមពិនិត្យឲ្យមែនមិនមែនហៅ
ពួកមច្ឆានៅនាទំនាបជ្រៅ លោកសំដៅដល់ជនជាតិជិតខាង ។
គឺមនុស្សជាបងប្អូន ឬជាកូនជាចៅខ្លះសំណាង
ឬជាញាតិលោហិតនៅជិតខាង ខ្លះសំណាងមកសូមសំណាក់នៅ ។
យើងត្រូវមានមេត្តាចិត្តត្រជាក់ ឲ្យគ្នាស្នាក់ជ្រកកោនកុំឲ្យក្តៅ
ពោលវាចាកុំថាពាក្យឃោរឃៅ ដោយចិត្តក្តៅចង់គិតពង្រើចថែម ។
ត្រូវពោលតែវាចាសុភាសិត សុចរិតប្រណីតដ៏ផ្អែមល្ហែម
កាយវិការឫកពាក់ខ្វង់ខ្វែម មុខញញែមញញឹមប្រិមស្រទន់ ។
មិនតូងតាងជូងផាងអាងទាត់ធាក់ រួសរាក់ទាក់ដំណើរស្មើរទន់ភ្លន់
កុំឲ្យញាតិរវាតចិត្តអាក់អន់ អាការទន់កើតដោយចិត្តមេត្តា ។
យ៉ាងនេះទើបអ្នកផងបូលចិត្តជុំ មកកុះកុំអាស្រ័យនៅជាគ្នា
ជួយកម្លាំងផ្តល់សុខឲ្យគ្រប់គ្រា គ្រប់វេលាយើងថ្កើងដោយសារញាតិ ។
ធម្មតាមេត្តាធម៌នេះឯង អាចបង្វែនចិត្តទ្រុស្តឲ្យជ្រះឃ្លាត
ចេញពីជននៅជិតជុំជាញាតិ សូម្បីជាតិតិរច្ឆានកាចជាស្លូត ។
គឺថាជនណាមួយមានប្រាជ្ញា ភាវនាមេត្តាជាប់រហូត
ជនជិតខាងទោះកាចទៅជាស្លូត សាំងរហូតដល់ពួកម្រឹគសាហាវ ។

ដូចនិទានមានមកជាបាលី    ប្រាជ្ញពិសីបានចងជារឿងរ៉ាវ

ថាម្រឹគកាចអាចស្លុតបាត់សាហាវ    មានរឿងរ៉ាវដូចនឹងថ្លែងតទៅ ។

# រឿងជរសាណនិគ្រុធ

## បទកុជ្ជលីលា

បទទ្រង់កុជ្ជលីលា    ខ្ញុំសូមពណ៌នា    ជាថ្លែងសេចក្តី ។

តាមគម្ពីរបាលី    ប្រយោជន៍ដើម្បី    ជាឧទាហរណ៍ ។

នៃការប្រព្រឹត្តតាមធម៌    មេត្តាបវរ    ជាធម៌ប្រពៃ ។

ថាកាលមុនមានក្សត្រថ្លៃ    អង់អាចពេកក្រៃ    ព្រះនាមអសោក ។

អានុភាពគ្របពិភពលោក    ព្រះបាទអសោក    ល្បីដល់សព្វថ្ងៃ ។

កាលស្តេចកំពុងថ្កើងក្រៃ    អំណាចពេញផ្ទៃ    ជម្ពូទ្វីបា ។

ទ្រង់ទូលសួរព្រះមាតា    ថាមាននរណា    ទាយទូលបង្គំ ។

ថានឹងបានជាស្តេចធំ    អធិរាជឧត្តម    សូមម៉ែប្រាប់ផង ។

សម្តេចមាតាជាច្បង    ថាហ៎នួនល្អង    នេះឈ្មោះអ្នកទាយ ។

ទ្រង់ហុចកំណត់ទំនាយ    ដែលគេទស់ទាយ    ថ្វាយព្រះរាជបុត្រ ។

ព្រះបាទអសោកបមក្កុដ    ទ្រង់ទតសំបុត្រ    ឃើញអស់ទំនាយ ។

ត្រូវសព្វឥតល្អៀងឃ្លាតក្លាយ    ឃើញនាមអ្នកទាយ    ថាជរសាណ(១) ។

(១) ក្នុងគម្ពីរបាលីខ្លះថា ជរសាណាជីវក ។ ក្នុងគម្ពីរមហាវង្សថា ជរសាណនិគ្រុធ ។

ទ្រង់ចាត់ឲ្យស៊ើបពតិមាន　　រកជរសាណា　　ឲ្យបានដឹងឆាប់ ។
មន្ត្រីគ្រប់ខេត្តប្រញាប់　　ចាត់ការយ៉ាងឆាប់　　បានដឹងជាក់ស្តែង ។
ថាជរសាណានោះឯង　　នៅផាច់សង្វែង　　បច្ចន្តគ្រាម ។
កាន់ព្រត្ត(១)ប្រព្រឹត្តព្រាហ្មណ៍　　ខំធ្វើព្យាយាម　　តាមទ្រឹស្តីនិគ្រន្ថ ។
បាន ជាគ្រូមហន្ត　　លើសពួកនិគ្រន្ថ　　អាជីវកផង ។
ទើបទ្រង់ចាត់មន្ត្រីច្បង　　សេនាអមផង　　ត្រសង់ត្រៀបត្រា ។
ឲ្យសែងសុពណ៌សិវិកា　　គ្រែស្នែងកាញ្ចនា　　ថ្លៃថ្លាពិសី ។
ទៅនាំនិគ្រន្ថតិរ្ថិយ៍　　ជរសាណាមកខ្ញី　　ដើម្បីគោរព ។
សក្ការៈរាប់អានគ្រប់　　ហេតុព្រះបមភព　　ស្តេចទ្រង់ជ្រះថ្លា ។
ទាហានសែងព្រះសិវិកា　　ទៅតាមមាគ៌ា　　កាត់ពនាល័យ ។
ទៅដល់ទូលស្នើព្រះទ័យ　　ថាសូមអភ័យ　　ដ្បិតព្រះបមម្កុដ ។
អសោកមហារាជធ្នើមផុត　　នៅបាតលីបុត្រ(២)　　ឲ្យមកនិមន្ត ។
ជរសាណានិគ្រន្ថ　　ព្រះគ្រូមហន្ត　　និមន្តឡើងគ្រែ ។
ទាហានខ្លះសែងខ្លះហែ　　ខ្លះបក់បន្ទែ　　ខ្លះបាំងខ្លស់ក្លំ ។
ទៅតាមសម្រួលមិនខំ　　ចូលដល់ព្រៃធំ　　ទុគ៌មស្រងាត់ ។
ទទួលព្រឹក្សាច្រើនក្តាត់　　នាំគ្នាដើរកាត់　　រកបេះបុប្ផា ។
ខ្លះបេះផលគោដ្ឋព្រឹក្សា　　ខ្លះសាកសួរគ្នា　　ខ្លះពណ៌នាប្រាប់ ។

---

(១) អានថា ព្រត់ ។ បា វត្ត គឺការប្រព្រឹត្ត ។ (២) អានថា ប៉ាតៈឡីបុត ។ រាជធានីថ្មី នៃមគធរដ្ឋ ។

ព្រឹកព្រហ្មណ៍ព្រៃគាន់គាប់ ពុំកាចខឹងរាប់ ឡូសព្វគ្រប់បាន ។
(អំពែងថ្ងៃថ្ងាន់សឹងមាន បុប្ផាហោនហាន យល់ពណ៌លឿងទុំ ។
ខ្ទះថាមកពេលណាកុំ យើងបេះផ្លែស្រី ជ្រក់ត្រីអាំង ។
ខ្ទះថានៃវុយអាគាំង នេះនៃក្រអាំង យើងបេះបុកឌី ។
ខ្ទុងខ្ទះប្រមះស្រឡៀ ស្រឡៀតល្ហុង ឡើងដើមស្រឡៅ ។
ត្រឡាត់ត្រឡាចឡើងទៅ ផ្ដើផាលំនៅ ផារ្រើងទ្រលទ្រុប ។
ដើមត្រាចត្រៀលត្រាកក្រខុប ដើមត្រាំងលាស់ទ្រុប ដង្គុំខៀវខ្ចី ។
ខ្ទះថាយើងឈប់ផឹកធី ដេកសំនៅណាកុំ ក្រោមម្លប់ឈើនេះ ។
ខ្ទះថានៃវុយអាផ្ទះ លោកតានៅនេះ ឯងក្មេងក្មាងអី ។
ក្ងោកមាន់មានពាន់តាឡី ទន្ទាប់ស្មៅស្ដី ស្តុកស្តុសស្មោចស្មៃ ។
ពញាក្ងុកក្ងុងមានផ្ទៃ ក្ងោកមាន់ដុះហែ ទៅក្បែរក្ងោកនាង ។
ពពេចចង្វាដុះវាង មាត់ទឹករអាង ត្រពាំងខ្នងខ្ទួល ។
ព ពលពពាលខែស្ងួល ស្វាយស្មៃស្វាប់ស្រួល ស្ងួញស្មាញសារវា ។
ពពួលបាយតើតដៃខ្វា ពពូលថ្ពផា ពពូលទឹកទាប ។
ពព្រាពោនស្វាក្អែកព្រាប ពោនមាក់ពួចទាប ដុះរាបជាគុម្ព ។
ពាន់តាពុកធ្លាត្រសុំ ពិភេទក៏ដុរជុំ ដិតដើមស្រម៉ ។
ពង្រមាន់ពាន់តាផ្កាល្អ លឿងខ្ចីលាយស ក្រអូបឈ្ងុយឆ្ងុត ។

គគីរស្រុកើតគិត ជើងចាបផុះដិត ដើមចារផ្កាល្អ ៗ
ពពេលឥន្ទូនេលពង្រ រំដេញញេញញញ ដកពផកពាយ ៗ
កណ្ដោលកណ្ដោកផុះពាយ រពាក់រពាយ ផុះពាយជាគុម្ព ៗ
ឪឡោកមាក់ដោកឪជំ កន្ទួតប្រោងអំព្រំ កន្ទួតព្រៃព្រួស ៗ
ផ្លែជាចំណីនៃឃ្មុស មានផ្លែជន្ទុស ឃ្មុសចូលចិត្តស៊ី ៗ
កន្ទោក(១)ផុះដិតកន្ទី(២) កន្ទុយប្រើសៗស៊ី កន្ទីស្រគំ ៗ
វល្លិគុយមានផ្លែមូលធំ រសជូរអែមចំ លើអ្នកនឿយហត់ ៗ
ស្រគំផ្លែខ្ចីរសចត់ ត្រូវចំលើមាត់ អ្នកអត់ម្ហូរស្លា ៗ
ត្រៀលដោះក្របីត្រៀលស្វា ដើមស្វិតក្ដាត់ណា ឡើងដើមចម្បក់ ៗ
មើលទៅឃើញផ្លែស្រៀស្រក់ ព្នកពលសម្រក់ ទឹកមាត់បេះធី ៗ
ព្រីងបាយព្រីងដោះក្របី មានផ្លែទុំខ្ចី បេះធីផ្លែទុំ ៗ
ព្រីងចន្ទព្រីងចន្ទុះផុំ ជាជួរជង្គុំ គេពុំភោក្ដា ៗ
ត្នលភ្លៅសង្ឃ្យរសង្ហា ទន្ទាប់ទន្ទា ក្រកោះក្រឡាញ់ ៗ
ស៊ុទ្ធតែឈើផ្លែឆ្ងាញ់ ៗ ខ្វះថាអើអញ បេះផ្ញើប្រពន្ធ ៗ

---

(១) វចនានុក្រមថា៖ កន្ទោកជាឈ្មោះនៃព្រជាប់ព្រឡឹង, ប៉ុន្តែប្រជាប់ព្រឡឹងស្រុកខ្លះហៅ អន្ទោក ដូច្នេះទេ ។ កន្ទោកជាឈ្មោះនៃឈើធំប្រភេទមួយ ទាំងដើមទាំងស្លឹកស្រដៀងដើមម៉ាង គឺដើមមែកមានសាច់សរឹង សម្បកសក្រាស់ស្លឹកធំ ៗ ។ (២) កន្ទីជាឈ្មោះនៃឈើតូចមួយយ៉ាង សម្បកសស្ដើង, សាច់ដើមមែកសស្រួយ, ស្លឹកមានទងវែង បែកខ្នែងជាស្លឹកមួយម្ខាង ៗ តាមទង, ច្រើនតែប្រាំសន្លឹកមួយទង, ស្លឹករាងដូចស្រួចចុងដូចផ្ទិតចាមរ ឬដូចស្លឹកអង្គារបុស្ប ។ ទាំងមែក ទាំងស្លឹក សម្រាប់ស្ងោរផឹកបំបាត់រោគគ្រុនក្ដៅ ។

រនៀងរវៀងដោះគន់ ដើមក្លាសគគ្រន់ ក្របព្រៃដើមក្រាយ ។
ស្រឡិតឡើងមហាស្រឡាយ(១) ផ្ការីកព្រោងព្រោយ ដិតដើមស្រឡៅ ។
ក្របាសព្រៃប្របក្របៅ មានដើមបង្គៅ ដើមគ្រៀវសិ មាន ។
គូលែនមាក់ប៉ែនចែងច័ន្ទ លំពោះលំពាន់ លំពង់លូតលៃ ។
ឆ្រឹងសន្ទឹងឡើងជ្រៃ លោតដោតលាំងផៃ ព្នរជ្រៃជ្រែងជ្រៀត ។
ដើមប្រេសមានជ្រៃផុះបៀត មានវល្លិ៍មៀត ជ្រៀតឡើងដើមជ្រៃ ៗ
ដើមទេពកិរ្យ៉ាគោមួយ ផុះដិតដើមជ្រៃ និងសម្បុរល្វែង ៗ
ដើមឈើក្ដីងក្លាំងកម្រែង អញ្ចាញអញ្ចែង ទ្រមែងទ្រមូង ។
លំពែងព្រះរាមផុះប្រូង ឱបដើមគ្រញូង ស្កឹកប្រូងប្រាងជ្រំ ។
ប៉ប្រុកសម្បកធំៗ រំយោលល្បានល្បំ ទំដើមទ្រយឹង ។
ស្រកាតាសបាប់ដើមខ្លឹង បន្តោកដូចជ្រឹង ដិតដើមខ្លឹងក្ដួត ។
ឈើទាលដូងថែមកាំងក្ដំ ផ្ដៀកផ្ដឹកស្រុកំ បេងលាំងខ្លុតខ្សៀ .
ស្ទូងតែឈើធំខ្ពស់ល្ហៅ ខ្លះត្រង់ស្លងស្ងៅ ខ្លះពកខ្លះពួរ ។
ខ្លះមានរន្ធហាក់ហាសួរ ដោយក្ដីសមគួរ ចំពោះយោធា ។
ខ្លះមានស្នឹកត្រូវរាំតា ដូចបក់ហត្ថា ហៅយក្សគយគន់ ) ។

---

(១) មហាស្រឡាយ ជាឈ្មោះនៃឈើធំមួយយ៉ាង មានសម្បកដូចសម្បកធ្នូក ស្លឹកដូចស្លឹកឈាប ច្រើនតែមានដើមធំខ្ពស់ត្រសូល ព្រោះច្រើនដុះក្នុងព្រៃស្រោងស្រឹង, ខ្ទឹមក្រហមរឹងស្អិត, ក្លិនខ្ទឹមក្រអូបផ្អែម ។ ឈើនេះសម័យបុរាណគេច្នៃបិត្តឡើងជាធិទ្ធាប់ដាក់ប្រអប់មាត់ ព្រោះគេនិយមជឿថាជាធិត្តាប់ពូកែស័ក្តិសិទ្ធិ ដូចជាធិត្តាប់ដែលគេធ្វើដោយខ្លឹមចំប៉ីដែរ ។

ដរសំណាក់គ្រូ      នៅគ្រាគយគន់      ព្រឹក្សាតាំងឡាយ ។
ត្រេកអរសែនត្រេកសប្បាយ  សោមនស្សរីករាយ ដូចកើតជាតថ្មី ។
នាបាននៅវិន្ទុកោសីយ៍      ព្រោះអនុត្តរិយ៍      ត្រូវបានឡើងបុណ្យ ។
ដោយសារសេចក្ដីការុណ្យ  នៃស្ដេចមានបុណ្យ អសោកតិលក(១) ។
ដរសាណាជីវក      ព្រះគ្រូនាយក      ដែលគេហៅទៅ ។
បានដល់កណ្ដាលព្រៃជ្រៅ  នៅត្រគយគន់នៅ  ឃើញសុទ្ធព្រៃស្វាយ ។
ដែលគេដាំដុះរៀងរាយ      ជាទីសប្បាយ      នៃស្រមណ៍បណ្ឌិត ។
ដើមស្វាយរៀងរាយប្រកិត  ប្រកៀកគ្នាជិត      ជាជួរជង្គុំ ។
ដង្គោលស្រមោលម្លប់ជុំ      ជិតដូចគេហ៊ុម      ពិតានសន្ធិយា ។
ស្វាយម៉ឹងស្វាយមាសឥន្ទជា ឥន្ទជិតមានផ្កា      ស្វាយដូរនៅផ្លែ ។
ស្វាយខ្ទិះដង់ខ្ទីដុះហៃ      ស្វាយមួងកែវកែ      ស្វាយម៉ឹងស្វាយមាស ។
ស្វាយយក្សស្វាយល្ហុតពោរពាស ពន់ត្រង់ដែរដាស ស្វាយក្បាលដំរី ។
តុំសែនស្វាយកែវសំឡី      ខ្ទះផ្កាខ្ទះខ្ចី      ខ្ទះបាស់ខ្ទះទុំ ។

---

(១) អនុបា ក៏ឡូក ។ ក៏លោក បា.គ. ប្រែថា ប្រសើរ, ជាកំពូល ។ បា.ន. ប្រែថា ល្អ, ដំណុចខ្មៅដែលមានឥ មរ សកាយ (អាចម៍រុយ) ។ ត្រង់នេះជាគុណ នាម ។ បុរាណជាន់ដើម ច្រើនប្រើពាក្យនេះ ក្នុងពោរម្យងារៈនៃតិស្សរជន ដូចជាងារនៃសម្ដេចព្រះមហាសង្ឃរាជ ទៀត ជាដើមថា. សម្ដេចព្រះមហា សង្ឃរ ធរាធិបតី តាំវីសង្ឃនាយក តិលកលោក (ទំនាន់នោះ អានថា កឹឡកលោក) បរិយាព្រឹទ្ធ បរមបពិត្រ ជាអម្ចាស់លើត្បូង ។

សារិកាដង្កោលដង្គុំ   មានម្រឹគជួបជុំ   សម្រាកកាយា ។
ម្រឹគីម្រឹគាត្រៀបត្រា   សំផ្លុំគោជ្រូកខ្លា   រមាំងប្រើសក្រោយ ។
ឈ្លូសក្ដាន់ឆ្កែព្រៃទន្សាយ   មូលមិត្រសប្បាយ   លាយគ្នាញ៉ែង ។
ខ្លះដេកខ្លះឈររហង់   ខ្លះដើរតម្រង់   សំទុគ្នាទៅមក ។
រមាំងសិទ្ធឡូបចចក   ឆ្កែព្រៃដើរមក   សិទ្ធឡូបទន្សាយ ។
ជ្រូកព្រៃដេកដួចគេពយ   ខ្លាដំសប្បាយ   ដេកកើយដូចខ្នើយ ។
ភាពនេះពុំដែលមានឡើយ   គ្រានោះឯងហើយ   មានភាពដូច្នោះ ។
ហេតុតែក្នុងព្រៃស្វាយនោះ   មានមហាថេរឈ្មោះ   ព្រះអស្សគុត្ត ។
កាន់សីលសិក្ខាបរិសុទ្ធ   ព្រះទ័យមោះមុត   ក្នុងការភាវនា ។
ចំរើននូវធម៌មេត្តា   សព្វកាលវេលា   ករុណាតសព្វសត្វ ។
និគ្រន្ថឃើញហើយលាន់មាត់   ថាយីនែសត្វ   ទាំងនេះច្រើនម៉្លេះ ។
សត្វនេះមិនដែលដូច្នេះ   ទើបតែគ្រានេះ   ម្ដេចក៏យ៉ាងហ្នឹង ។
ថាហើយចុះទៅសម្លឹង   មើលគិតរំពឹង   រកហេតុពុំយល់ ។
មើលហើយៗតែតែឆ្ងល់   លុះតែបានដល់   មណ្ឌលទីកុដិ ។
លំនៅនៃព្រះអស្សគុត្ត   ក្នុងវត្តបរិសុទ្ធ   នាមនិយសេនាសន៍ ។
និគ្រន្ថលើកដៃប៉ាំងថ្ងាស   គយគន់តែពាស   ឃើញព្រះអស្សគុត្ត ។
ទោះបីខុសគ្នាបំផុត   ក៏គាត់លំអុត   លំទុនស្លូតបៅ ។
ឆាំរសារនេះពួកម្រឹគា   គេហៅឈ្មោះរក់   ថាពួកសត្វធ្មុ ។

មហាថេរពីរឆាប់ខ្ចី ជ្រាបជាតិត្រីយ៍ ធ្លាប់ស្ដាប់បរមត្ថ ។
ពីដើមគាត់កើតជាសត្វ ពស់ពេនទីស្វាត់ ស្ដាប់ព្រះវិភង្គ ។
ដែលភិក្ខុ(១)ស្វាធ្យាយខ្លាំងៗ ត្រង់អាយតនំ(២) ប្រាំមួយមាតិកា ។
ទើបលោកឆ្លើយប្រាប់មកថា នេះពួកម្រឹគា ឈ្មោះអាយតនៈ ។
និគ្រន្ថខំផ្ទៀងសោតៈ ក្នុអាយតនៈ មានឧតប្បៈឡើង ។
អៀនខ្មាសហើយលុតបត់ជើង ប្រណម្យដៃឡើង នោះព្រះថេរៈ ។
មហាថេរទាញកាសាយៈ សំពត់សមណ បរិក្ខារហុចទៅ ។
និគ្រន្ថសូមផ្លាស់បួសនៅ លែងទឹកដល់ទៅ ពួកអន្យតិរ្ថីយ៍ ។
មិនយូរប៉ុន្មានឆាប់ខ្ចី ភិក្ខុបួសថ្មី លុះអរហត្ត ។
ដោយសារបានស្ដាប់បរមត្ថ ព្រះថេរៈចាត់ ចែកចែងឲ្យស្ដាប់(៣) ។
ភិក្ខុជរសាណប្រាប់ មន្ត្រីឲ្យឆាប់ ក្រឡាប់វិនខ្ចី ។
ទៅទូលព្រះនរបតី កុំឲ្យចក្រី ទន្ទឹងឡើយណា ។

---

(១)ត្រង់នេះត្រូវអានជាភិក,កុំជាឲ្យដល់ខុ។ (២) អានជាអាយៈតៈណាំង។ (៣) ព្រះមហាថេរបានសំដែងគូរអាយតនវិភង្គទាំង ៦ មាតិកាពីរផងគឺ : ចក្ខាយតន និងរូបាយតន, សោតាយតន និងសទ្ទាយតន, ឃានាយតន និងគន្ធាយតន, ជិវ្ហាយតន និងរសាយតន, កាយាយតន និងផុស្សាយតន, មនាយតន និងធម្មាយតន ។ ព្រមទាំងពន្យល់សេចក្ដីថា: អាយតន.ទាំង ៦ ពីរផងនេះ ទាំងមនុស្សទាំងតិរច្ឆានសុទ្ធតែមានដូចគ្នា, ប៉ុន្តែមនុស្សចាត់ជាសត្វដ៏ថ្លៃថ្លាជាងតិរច្ឆាន ព្រោះមានមេត្តា, បើមនុស្សណាគិតពុំមេត្តា, នោះគួរគេហៅថា សត្វអន់ សត្វគម្រក់ជាងសត្វដែលកំពុងនៅខាងមុខកុដិនេះទៅទៀត ។

មន្ត្រីសេនីយ៍គ្រប់គ្នា   នាំអស់យោធា   រិលច្បាំងបុរី ៗ
ស្បៀងគាល់ទូលព្រះចក្រី   ដោយទូរសេចក្តី   ដូចថ្លែងមកស្រាប់ៗ
មហាក្សត្រទ្រង់ព្រះសណ្តាប់   ព្រះទ័យក្តួចដាប់   ចង់ចេញទៅជួប ៗ
ប៉ុន្តែពល់រៃកល់ខួប   ព្រះអង្គរួមរួប   រាប់គាននិគ្រន្ថ ៗ
គ្រានេះបើបោះបង់ជន   ផាពួកនិគ្រន្ថ   ចូលពុទ្ធសាសនា ៗ
ក្រែងគ្រោះកាចកើតចលា-   ចលដាន់ទន្យា   ព្រួតគ្នាមកទៀត ៗ
ព្រោះបញ្ញាមិត្រនៅធ្វៀត   ឈ្លបរកតែស្មៀត   បៀតបៀនព្រះអង្គ ៗ
លុះគ្រប់បីឆ្នាំទើបទ្រង់   ចាត់ការតម្រង់   រដ្ឋរាស្ត្ររៀបរយ ៗ
ទើបស្តេចសម្រេចញយៗ   ចាំត្រូវបន្ទយ   ពួកអាជីវក ៗ
ដែលមានទ្រឹស្តីលាមក   ថាកម្មអាក្រក់   ប្តូរល្អឥតផល ៗ
ទោះអកុសលកុសល   ឥតមានឲ្យផល   ទៅនរកសួគ៌ ៗ
ទ្រង់ចាត់បំបាត់តាមគួរ   មិនឲ្យជនជួរ   ទាំងនេះចូលជួប ៗ
បង្អាក់ពេញពេលមួយខួប   ទើបទ្រង់រួមរួប   ចូលពុទ្ធសាសនា ៗ
ដោយហេតុតែទ្រង់ជ្រះថ្លា   ចំពោះមេត្តា-   ធម៌ព្រះអស្សគុត្ត ៗ
នេះឯងហេតុដើមបំផុត   នាំព្រះបមម្កុដ   អសោកក្សត្រា ៗ
ឲ្យចូលកាន់ពុទ្ធសាសនា   ទាំងដឹកនាំមហា-   ជនចូលជាច្រើន ៗ
សាសនារីករីងចំរើន   ផ្សាយទៅបានច្រើន   ប្រទេសនានា ៗ
គេគប់គានច្រើនមហិមា   ព្រោះគេយល់ថា   សាសនាត្រជាក់ ៗ

ថែមថ្នាំបរិសុទ្ធសោភគ្គ   សមហេតុផលជាក់   ជាលទ្ធិត្រូវ ។
រឿងនេះវែងឆ្ងាយពេកកូវ   ខ្ញុំកាត់តម្រូវ   ជាឧទាហរណ៍ ។
នៃភាសិតដ៏បវរ   ដែលប្រាជ្ញផ្លូវធម៌   ប្រឌិតទុកថា ។
ទឹកត្រជាក់ហើយថ្លា   ត្រីកុំត្រៀបត្រា   មច្ឆាចូលមក ។
គឺគេតែងតែរត់រក   រុលត្បុលមកជ្រក   ក្រោមអ្នកមេត្តា ។
រឿងនេះឃ្លាតឆ្ងាយណាស់ណា   ខ្ញុំសូមពណ៌នា   នូវរឿងមួយទៀត ។
ដើម្បីអស់លោកអ្នកឆ្ងៀត   សង្កេតទៅទៀត   ដូចតទៅនេះ ។

(នៅមានតទៅទៀត)

---

រឿងផរសោណកនិគ្រន្ថ ក្នុងគម្ពីរបាលីឥតមានការកាប់ដើមឈើទេ ។ ក្មេងៗជំនាន់ថ្មី ប្រហែលមិនសូវចូលចិត្តការកាប់ដើមឈើអស់ទាំងព្រៃដូច្នេះដែរ ។ ប៉ុន្តែ ខ្ញុំយល់ថា មានប្រយោជន៍បានជាសរសេរយ៉ាងនេះ ។ (ឈឹម-ស៊ុម)

# សាវតារវត្តកោកណ្តាល

## ខេត្តក្រចេះ

លោក ឌឹក–តាម ស្រាវជ្រាវរៀបរៀង

## នាមវត្ត

វត្តកោកណ្តាល ជាវត្តដែលគេឲ្យឈ្មោះទៅតាមកិៈភាគនៃរុក្ខជាតិដែលមាន ឈ្មោះថា "ដើមកោ" ។ នៅក្នុង តាមឯកសាររបស់លោកអាចារ្យ ប្រាង-ធុត (១) វត្តកោកណ្តាលនេះថា មានដើមកោមួយដើមធំ ហើយមានដើមកោតូច ៗ ជាច្រើនដុះនៅជុំវិញដើមកោនោះ នៅខាងត្បូងវត្ត ។ ការឃើញភិនភាគដូច្នេះ អ្នកស្រុកដែលនាំគ្នាកធ្វើជាវត្តឲ្យឈ្មោះវត្តនោះថា វត្តកោកណ្តាល ។

## អ្នកផ្តើមកសាងៈ

ការកសាងវត្តនេះ មានបងប្អូនបង្កើតពីរនាក់បងឈ្មោះឧកញ៉ានរេន្ទ ប៉ុច ភរិយាឈ្មោះ ទៀង ឯប្អូនឈ្មោះ ក្រឡាពាសទៀង ភរិយាឈ្មោះណិច ជាអ្នកនាំផ្តើមឡើង ។ វត្តនេះកសាងនៅក្នុងរជ្ជព្រះបរមកោដ្ឋ (ព្រះបាទអង្គឌួង) នៅឆ្នាំចសំរិទ្ធិស័ក ព.ស. ២៣៨១ ។ ការកសាងដំបូង វត្តនេះមិនទាន់មានវិហារទេ មានតែកុដិតូច ១ ប្រក់ស្បូវ ។ ឯព្រះពុទ្ធរូបព្រះសង្ឃដំកល់ទុកនៅក្នុងកុដិ ។

---

១ – ឯកសារក្រុមទំនាមទម្លាប់ខ្មែរ ៨៥-០១៥ ។

# ព្រះសង្ឃ

ការកាប់ឆ្កាធ្វើជាវត្តបានស្រេចហើយ ឧបាសក-សិកាបាននិមន្តព្រះសង្ឃ ៤ អង្គពីវត្តក្របេះសត្វថ្ងៃ គឺលោកគ្រូសូត្រព្រះនាម ព្រំ ១ ព្រះនាម ពា ១ ព្រះនាមប៉ែន ១ ព្រះនាមសេ ១ ។ ព្រះសង្ឃទាំងនេះគង់មិនយូរប៉ុន្មាន ក៏លាចាកសិក្ខាបទទៅ ។

នៅព.ស. ២៣៩១ ឧបាសក-សិកាដើរវត្តបាននិមន្តលោកគ្រូសុខ នៅខ្សាច់កណ្ដាល ខេត្តកណ្ដាល ព្រមទាំងព្រះសង្ឃ ៤ អង្គទៀតពីវត្តក្របេះ ។ លោកគ្រូសុខ ធ្វើចៅអធិការបាន ១២ ឆ្នាំ ក៏បុគតទៅ ឯវិហារនៅពុំទាន់កើតនៅឡើយទេ ។

នៅព.ស. ២៤០៣ ឧបាសក-សិកា បាននិមន្តលោកគ្រូឡាយ នៅជ្រោយដងកើងឃុំ សាច មកធ្វើជាចៅអធិការ ។ ព្រះភិក្ខុនេះបានកសាងព្រះវិហារប្រក់ស្បូវ រួចទើបដង្ហែព្រះពុទ្ធរូបដែលដំកល់ទុកក្នុងជិ យកមកដំកល់ក្នុងព្រះវិហារ ហើយបញ្ចុះសីមាជាពេញទំបាបថ ។ លុះបញ្ចុះសីមាហើយភិក្ខុអង្គនេះ មានអាពាធ ក៏លាចាកសិក្ខាបទ ។

នៅព.ស. ២៤១៧ លោកគ្រូសោមបានឡើងធ្វើជាចៅអធិការបានពីរឆ្នាំ ។ នៅព.ស. ២៤១៩ ព្រះភិក្ខុព្រះឈ្មោះគួប និមន្តមកពីវត្តក្របេះមកគង់នៅវត្តនេះ ហើយបានពួកពុទ្ធបរិស័ទនិងចៅអធិការពេបគន



ព្រះវិហារវត្តកោកកណ្ដាល ខេត្តក្រចេះ

គេមិនឲ្យធ្វើជាមេបង្ហាយ៍ ។ ព្រះសង្ឃពីរព្រះអង្គនេះពួតដៃគ្នាកសាងវត្តអាកម រុះរើព្រះវិហារប្រក់ស្បូវចេញ ហើយធ្វើព្រះវិហារប្រក់ក្បឿងវិញ ។

បន្ទាប់ពីព្រះសង្ឃពីរព្រះអង្គនេះ នៅព.ស. ២៤៣៧ ព្រះភិក្ខុព្រះនាម កៀ បានធ្វើជាចៅអធិការ ។ លោកបានជួសជុលព្រះវិហារកុដិ សាលាខ្លះ ៗ ។ លោកធ្វើចៅអធិការបាន ១៤ ឆ្នាំ ក៏សុគតទៅ ។

នៅព.ស. ២៤៥២ លោកគ្រូកុយ បានធ្វើជាចៅអធិការ ។ លោករុះរើព្រះវិហារធ្វើសាឡើងជាថ្មីដោយឥដ្ឋនិងសីម៉ង្ត ។ លោកសុគតនៅ ព.ស. ២៤៥៨ ។

នៅព.ស. ២៤៥៩ លោកគ្រូស្រី អ៊ូ បានធ្វើជាចៅអធិការតមក ដល់សព្វថ្ងៃនេះ ។

## ផ្នែកកំណត់និងប្រវត្តិការណ៍

# អនុសំវច្ឆរមហាសន្និបាតទី ២១ នៃមន្ត្រីសង្ឃ

## មករាគ-ស- ១៩៦៥

ឆ្នាំ ១៩៦៥នេះ ជាឆ្នាំគំរប់ ២១ នៃអនុសំវច្ឆរមហាសន្និបាតនៃមន្ត្រីសង្ឃ ។ មហាសន្និបាតនេះធ្វើពីថ្ងៃទី ១៦ ដល់ថ្ងៃទី ២១ ខែមករា ឆ្នាំ ១៩៦៥ នៅវត្តឧណ្ណាលោម និងវត្តបទុមវតីរាជវរារាម ក្រោមព្រះរាជាធិបតីភាពនៃសម្ដេចព្រះសង្ឃរាជទាំងពីរគណៈ ។

### ថ្ងៃទី ១

ថ្ងៃសៅរ៍ ១៤ កើតខែបុស្ស (១៦ - ១ - ៦៥) វេលាម៉ោង ១៤,៣០ ជាពេលបើកអនុសំវច្ឆរមហាសន្និបាតទី២១ នៃមន្ត្រីសង្ឃទាំងពីរគណៈ ។

មន្ត្រីសង្ឃ ចៅអធិការគុណគ្រូនិងខេត្តក្រៅខាងគណៈធម្មយុត្តិប្រជុំនៅក្នុងព្រះវិហារវត្តបទុមវតី ចំពោះរដ្ឋមន្ត្រីក្រសួងធម្មការ ។

ចំណែកព្រះសង្ឃមេគណ, អនុគណ, ចៅអធិការគុណគ្រូ និងព្រះរាជាគណៈឋានានុក្រមខាងគណៈមហានិកាយ បានប្រជុំនៅវត្តឧណ្ណាលោម ចំពោះមុខរដ្ឋមន្ត្រីក្រសួងធម្មការ ពេលម៉ោង ១៥,០០ ។



សម្តេចព្រះសង្ឃរាជថ្នាក់ទី ១ ទ្រង់ថ្វាយព្រះពុទ្ធរូបមួយព្រះអង្គ ចំពោះសម្តេចព្រះប្រមុខរដ្ឋ ។

## ថ្ងៃទី ២

ថ្ងៃអាទិត្យ ១៤ កើត ខែបុស្ស (១៧.១ ៦៨) ពេលម៉ោង ៨ព្រឹក ព្រះសង្ឃទាំងពីរគណៈចំនួន ៤០ អង្គ ចំរើនសត្តប្បករណ៍ ឧទ្ទិសព្រះរាជកុសលថ្វាយព្រះបិតរនៅព្រះចេតិយ ក្នុងវត្តព្រះកែវមរកត ។

នៅម៉ោង ១០,៣០ព្រះសង្ឃទាំងពីរគណៈ ទទួលចង្ហាន់ថ្ងៃត្រង់ នៅវត្តឧណ្ណាលោម និងវត្តបទុមវតីចំពោះមុខរដ្ឋមន្ត្រីក្រសួងធម្មការ ។

នៅពេលម៉ោង ១៤,៣០ ព្រះសង្ឃទាំងពីរគណៈប្រជុំនៅមន្ទីរពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ។

ម៉ោង ១៤,៤០ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ, ប្រធានសភាទាំងពីរ, នាយករដ្ឋមន្ត្រី សមាជិករាជរដ្ឋាភិបាលនិងសភាទាំងពីរ និងវរជននានា ស្តេចយាងនិងអញ្ជើញដល់មន្ទីរពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ។

ម៉ោង ១៦,៣០ សម្តេចព្រះប្រមុខរដ្ឋស្តេចយាងដល់ដោយមានឧត្តមក្រុមប្រឹក្សានៃព្រះរាជបល្ល័ង្ក ព្រមទាំងព្រះរាជបរិពារផ្ទាល់ព្រះអង្គតាមហែផង ។

តាហានក្រុមរក្សាព្រះអង្គ និងក្រុមភ្លេងព្រះរាជទ្រព្យ ធ្វើគារវកិច្ចថ្វាយជាព្រះកិត្តិយស ។

លុះសម្តេចព្រះប្រមុខរដ្ឋ ទ្រង់គង់ប្រថាប់លើព្រះបុវណ្ណកោដ្ឋៈ

សម្រួលព្រះឥរិយាបថៈហើយ ព្រះសង្ឃគ្រប់អង្គស្វាធ្យាយធម៌ជយន្តោ ថ្វាយព្រះពរជ័យ ។

បន្ទាប់មក មហាជីវិន ម៉ែន-ឈុំ អនុរដ្ឋលេខាធិការក្រសួងធម្មការ ថ្លែងសុន្ទរកថា (យើងនឹងចុះទៅទំព័រក្រោយ) ហើយព្រះសង្ឃមួយព្រះអង្គជាតំណាងសង្ឃថ្លែងតបវិញ ។

តមកសម្តេចព្រះប្រមុខរដ្ឋ ទ្រង់ថ្លែងប្រាស្រ័យជាមួយព្រះសង្ឃទាំងពីរគណៈ ។ លុះចប់ព្រះសង្កថាដ៏មានខ្លឹមសារ ឥតព្រាងទុកជាមុននេះ សម្តេចព្រះប្រមុខរដ្ឋក៏ទ្រង់ក្រាបថ្វាយបង្គំលាព្រះសង្ឃ ដែលមានសម្តេចព្រះសង្ឃរាជជាប្រធាន ស្តេចនិមន្តចូលព្រះបរមរាជវាំងវិញ ។

ចាប់តាំងពីថ្ងៃទី ១៨ រហូតដល់ទី ២១ ខែមេសា ព្រះសង្ឃទាំងពីរគណៈប្រជុំនៅវត្តឧណ្ណាលោមនិងបទុមវត្តី ក្រោមព្រះរាជាធិបតីភាពនៃសម្តេចព្រះសង្ឃរាជទាំងពីរព្រះអង្គ និងតាមកម្មវិធីនៃសម្តេចព្រះសង្ឃរាជទាំងពីរព្រះអង្គ ។



សម្ដេចព្រះប្រមុខរដ្ឋ ទ្រង់ថ្លែងព្រះសង្កថាទៅចំពោះព្រះភក្ត្រព្រះសង្ឃក្នុងឱកាសអនុសំវច្ឆរមហាសន្និបាតនៃមន្ត្រីសង្ឃ

ទី ២១ នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ។

# សុន្ទរកថា

សហជីវិន ម៉ែន ឈុំ រដ្ឋលេខាធិការក្រសួងធម្មការ ថ្លែងក្នុងឱកាស

អនុសំវច្ឆរមហាសន្និបាត ទី ២១ នៃមន្ត្រីសង្ឃនៅថ្ងៃ ១៧ មករា ១៩៦៨

---

សូមព្រះតេជះគុណ ល់លើត្បូង

សូមព្រះរាជទានក្រាបបង្គំទូល សម្តេចព្រះប្រមុខរដ្ឋ

ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍

សូមទ្រង់ជ្រាប ក្រោមល្អងធូលីព្រះបាទ ។

ក្នុងនាមនៃក្រសួងធម្មការ សាសនសិក្សាធិការ និងក្នុងនាមផ្ទាល់នៃទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានព្រះបរមរាជឱកាសថ្លែងនូវព្រះមហាករុណាធិគុណដ៏ថ្លៃថ្លា ដោយគារវៈភក្តីដ៏បរិសុទ្ធចំពោះសម្តេចព្រះប្រមុខរដ្ឋ ព្រះបិតាឯករាជ្យជាតិដែលក្នុងពេលដ៏មមាញឹកនេះ ព្រះអង្គបានស្តេចយាងមកជាព្រះរាជាធិបតី ក្នុងឱកាសបើកអនុសំវច្ឆរៈមហាសន្និបាតទី ២១ នៃមន្ត្រីសង្ឃសម្រាប់ឆ្នាំកាន់ឆស័ក ។

សូមទ្រង់ព្រះមេត្តាប្រោស

លំដាប់តទៅនេះ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានព្រះបរមរាជឱកាស ដើម្បីថ្វាយ ដើម្បីប្រគេនពត៌មានចំពោះសម្តេចព្រះសង្ឃរាជ

ទាំងពីរព្រះអង្គ សម្តេចព្រះពោធិវង្ស សម្តេចព្រះវនរ័ត ព្រមទាំងព្រះថេ-រានុត្ថេរៈគ្រប់ព្រះអង្គ ដែលបានស្តេចយាង បាននិមន្តពីទីក្រុងនិងជនបទនានាក្នុងខេត្តក្រៅ ទូទៅក្នុងព្រះរាជអាណាចក្រទាំងមូល មកប្រជុំក្នុងមហាសន្និបាតនេះ ដូចតទៅ ៖

សូមព្រះតេជះតំកល់លើត្បូង

សូមព្រះរាជទានក្រាបបង្គំទូល សម្តេចព្រះសង្ឃរាជទាំងពីរព្រះអង្គ សូមថ្វាយបង្គំសម្តេចព្រះពោធិវង្ស សម្តេចព្រះវនរ័ត ព្រមទាំងព្រះថេរានុ-ត្ថេរៈជាព្រះរាជាគណៈហានានុក្រម មេគណ អនុគណ ចៅអធិការគ្រប់ព្រះអង្គ

សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ សូមទានជ្រាប ។

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា សូមថ្លែងនូវព្រះរាជអំណរនិងអំណរដ៏ក្រៃលែងចំពោះសម្តេចព្រះសង្ឃរាជទាំងពីរព្រះអង្គ និងព្រះករុណាគ្រប់ព្រះអង្គ ដែលបានស្តេចយាង បាននិមន្តមកជួបជុំនេះ ព្រោះការជួបជុំនេះ បង្កើតនូវបរិយាកាសមួយដ៏ល្អប្រពៃ ដែលអាចផ្តល់នូវសាមគ្គីធម៌នៃសេចក្តីសុខ ចំរើន រុងរឿងដល់ជាតិសាសនានិងព្រះរាជបល័ង្ក តាមគន្លងអបរិហានិយធម៌ដែលព្រះសម្ពុទ្ធបរមគ្រូទ្រង់សំដែងថា ការរួបរួមគ្នាដោយកាយសាមគ្គីជាឯកច្ឆ័ន្ទ រមែងបានសេចក្តីរុងរឿងចំរើន ឈ្នះមារសត្រូវ

គ្រប់ទិសានុទិសឥតនរណាផ្ចាញ់បានឡើយ ។

បពិត្រសម្តេចព្រះសង្ឃរាជ

- សម្តេចព្រះពោធិវង្ស

សម្តេចព្រះវនរ័ត

- ព្រះករុណាគ្រប់ព្រះអង្គ

ព្រះអង្គទ្រង់បានជ្រាប និងបានជ្រាបស្រាប់ហើយ តាំងពីពុទ្ធសតវត្សទី៣ ដែលព្រះពុទ្ធសាសនាប្រតិស្ឋាននៅក្នុងប្រទេសកម្ពុជាយើងមក ព្រះពុទ្ធសាសនាចេះតែមានជាប់ជាដរាប ហើយចេះតែចំរើនរហូតដល់សព្វថ្ងៃ ។ ខ្មែរតាំងប្រទេសសុទ្ធសឹងជាពុទ្ធសាសនិក ហើយជាពិសេស ព្រះមហាក្សត្រខ្មែរតាំងពីអតីតកាលសុទ្ធតែជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភ ។ លទ្ធផលនៃការរីកសាយទូលំទូលាយនៃព្រះពុទ្ធសាសនាក្នុងព្រះរាជអាណាចក្រកម្ពុជានេះ ក៏ដោយសារតែព្រះរាជូបត្ថម្ភដ៏មោះមុតនៃព្រះមហាក្សត្រយើងគ្រប់ព្រះអង្គ និងព្រះរាជវង្សានុវង្សព្រមទាំងពុទ្ធបរិស័ទផង ដែលស្របតាមពុទ្ធបណ្តាំថា "តថាគត ផ្ញើទុកពុទ្ធសាសនានឹងព្រះរាជា" ។

សព្វថ្ងៃនេះ ក៏ដូចជាសម័យព្រះបាទអសោកមហារាជដែរ ព្រះរាជបល្ល័ង្កនិងព្រះរាជវង្សានុវង្ស ព្រមទាំងរាជរដ្ឋាភិបាលដែលមានសម្តេចឪ

ជាព្រះអគ្គមគ្គុទ្ទេសក៍ដំបូង ទ្រង់បានយកព្រះទ័យទុកដាក់ ខ្នះខ្នែងលើកស្ទួយព្រះពុទ្ធសាសនាគ្រប់វិស័យឲ្យមានរបៀបរៀបរយ សមជាទីពឹងនៃសត្វលោកមែន ។ ទ្រង់បានធ្វើកិត្តិស័ព្ទ កិត្តិនាមនៃព្រះពុទ្ធសាសនាក្នុងប្រទេសយើងឲ្យលេចឮសុះសាយទៅក្នុងពិភពលោក ដោយព្រះអង្គទ្រង់បានព្រះរាជទានឲ្យរៀបចំមហាសន្និបាតអន្តរជាតិខាងព្រះពុទ្ធសាសនា ដូចជាបុណ្យពាក់កណ្ដាលសាសនា និងសន្និសីទព្រះពុទ្ធសាសនាសាកលលោកលើកទី ៦ ជាដើម ។ ប្រទេសនានាជាពុទ្ធសាសនិកក្ដី ពុំមែនជាពុទ្ធសាសនិកក្ដី បានសំដែងនូវសេចក្ដីកោតសរសើរ ទទួលស្គាល់ថាប្រទេសកម្ពុជាមានភ័ព្វសំណាងល្អណាស់ ព្រោះមានព្រះរាជា មានព្រះប្រមុខរដ្ឋព្រះអង្គកាន់ព្រះពុទ្ធសាសនា ឧបត្ថម្ភព្រះពុទ្ធសាសនា ធ្វើរដ្ឋឲ្យទៅជារដ្ឋអព្យាក្រឹត្យកាន់ព្រះពុទ្ធសាសនា ធ្វើព្រះពុទ្ធសាសនាក្នុងប្រទេសឲ្យរុងរឿង ។

ព្រះរាជបល្ល័ង្កបានឧបត្ថម្ភព្រះពុទ្ធសាសនាឲ្យមានពុទ្ធិកសិក្សាតាមវត្តអារាមនានាក្នុងព្រះរាជាណាចក្រតាំងពីអតីតកាលរៀងមក ដល់មកក្នុងសម័យបច្ចុប្បន្ននេះទៀត សម្ដេចព្រះមហាក្សត្រិយានី និងសម្ដេចព្រះប្រមុខរដ្ឋទ្រង់បានទំនុកបំរុងពុទ្ធិកសិក្សាឲ្យរឹតតែចំរើនខ្ពង់ខ្ពស់ឡើង ដូចទ្រង់បង្កើតឲ្យមានពុទ្ធិកមហាវិទ្យាល័យជាដើម ។ សមិទ្ធផល ១ ទៀត

ក្នុងព្រះពុទ្ធសាសនាដែលជាស្នាព្រះហស្តផ្ទាល់ព្រះអង្គ ក៏មានច្រើនជាអនេក ដូចយ៉ាងវត្តព្រះសីហនុនៅរតនគិរី និងក្រុងព្រះសីហនុជាដើម ។ ដោយហេតុសម្ដេចឪព្រះអង្គបានជួយឧបត្ថម្ភព្រះពុទ្ធសាសនា និងព្រះរាជនយោបាយកសាងជាតិ សាសនា ដូចបានរៀបរាប់មកខាងលើនេះ ពុទ្ធបរិស័ទទាំងបព្វជិតទាំងគ្រហស្ថក្នុងកម្ពុជរដ្ឋទាំងមូល មានសេចក្ដីពេញចិត្តជាអតិបរមា បានព្រមព្រៀងគ្នាជាធ្លុងមួយដើរតាមព្រះរាជនយោបាយរបស់ព្រះអង្គរហូតដល់ជីវិតបង់រៀងខ្លួន ។

មុនទីបញ្ចប់ ក្នុងនាមក្រសួងធម្មការ និងសាសនសិក្សាធិការ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានព្រះបរមរាជានុញ្ញាត ដើម្បីថ្លែងនូវព្រឹត្តការណ៍ និងសកម្មភាពខ្លះរបស់ក្រសួងធម្មការដូចតទៅនេះ ;

ក្រសួងធម្មការ បានបំរើព្រះពុទ្ធសាសនាក្រោមព្រះរាជាធិបតីភាពនៃសម្ដេចព្រះសង្ឃរាជទាំងពីរព្រះអង្គច្រើនយ៉ាងគឺ :

- ព្រះអង្គបានទ្រង់ព្រះរាជបញ្ជាឲ្យភិក្ខុសាមណេរគ្រប់វត្តបង្ហាត់បង្រៀននូវអនក្ខរជន ឲ្យចេះអានចេះសរសេរគ្រប់គ្នា ព្រមទាំងឲ្យជួយឧបត្ថម្ភសម្ភារៈខ្លះទៀតផង ។
- នៅតាមវត្តអារាម ឲ្យបង្កើតបណ្ណាល័យជាទីតំកល់ទុកនូវក្បួនច្បាប់ផ្លូវលោក ផ្លូវធម៌ សម្រាប់អប់រំពុទ្ធបរិស័ទនិងយុវជនគ្រប់វិស័យ ។
- ក្នុងវិស័យរក្សាទឹកបង្កើននូវកសិកម្ម ក្រសួងធម្មការបានពន្យល់ពុទ្ធ-

បរិស័ទព្រះសង្ឃនិងគ្រហស្ថឲ្យយល់ច្បាស់ទូវតំលៃនៃព្រៃឈើ ហើយពន្យល់ឲ្យជួយលត់ភ្លើងព្រៃ កាលណាបើមានភ្លើងកកស្ទះកន្លែងណាមួយ ។ នៅឆ្នាំ ១៩៦៣ បានចែកគ្រាប់ឈើច្រើនមុខចំនួន ២០ បារ ឆ្នាំ ១៩៦៤ គ្រាប់ម៉ៃសាក់ ចំនួន ១០ បារ ។

— ក្នុងពេលថ្មីៗ នេះ សម្តេចឪព្រះអង្គបានចាប់អារម្មណ៍ទៅលើសិល្បៈជាទំនៀមទម្លាប់ខ្មែរ មានល្បែងនិងរបាំជាដើម ក្រសួងធម្មការបានស្រាវជ្រាវប្រមូលឯកសារខាងទំនៀមទម្លាប់ខ្មែរ ហើយជាពិសេសបានបោះពុម្ពសៀវភៅរួចស្រេចហើយពីរមុខ នៅក្នុងខែធ្នូ ឆ្នាំ ១៩៦៤ នេះគឺ:

១ របាំប្រជាប្រិយខ្មែរ Danses populaires

២ ល្បែងប្រជាប្រិយខ្មែរ Jeux populaires

— ដោយបានរួបរួមជាមួយក្រសួងសុខាភិបាល ក្រសួងកសិកម្ម និងក្រសួងអប់រំជាតិ ក្រសួងធម្មការ និងពន្រឹកសកម្មភាពខាងការអប់រំសុខភាពនិងអប់រំទូទៅ តាមគន្លងព្រះពុទ្ធសាសនាឲ្យបានរីកសាយទូលំទូលាយតទៅ ។

— ហើយក្រសួងធម្មការបំរុងនឹងចាត់ការតទៅ ក្រោមព្រះអធិបតីភាពនៃសម្តេចព្រះគោដិវង្ស ជាអគ្គាធិការនៃពុទ្ធិកសិក្សា ក្នុងគម្រោងការកែទម្រង់នៃពុទ្ធិកបឋមសិក្សា ដើម្បីឲ្យរឹតតែមានវឌ្ឍនភាពទៅមុខទៀត ។

នៅទីបំផុតនេះ ទូលព្រះបង្គំជាខ្ញុំសូមប្រសិទ្ធិពរ ជូនស្ដួងចំពោះព្រះរតនត្រ័យ ទេវតាទាំងមុនលោកធាតុ មានទេវតារក្សាព្រះមហាស្វេតច្ឆត្រនៃប្រទេសកម្ពុជាជាដើម សូមជួយអភិបាលរក្សាសម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង សម្ដេចព្រះប្រមុខរដ្ឋ សូមព្រះអង្គទ្រង់គង់នៅជាព្រះបរមសុខក្នុងសិរីភពសម្បត្តិ ដើម្បីជាម្លប់នៃប្រជាពលរដ្ឋគ្រប់ប្រភេទតទៅ ។

សូមសម្ដេចព្រះសង្ឃរាជទាំងពីរព្រះអង្គ សម្ដេចព្រះពោធិវង្ស សម្ដេចព្រះវនរ័ត និងព្រះករុណាគ្រប់ព្រះអង្គ សូមទ្រង់ សូមជួបប្រទះតែនឹងសេចក្ដីសុខគ្រប់ប្រការ ដើម្បីជាស្រែបុណ្យនៃពលរដ្ឋទូទៅក្នុងប្រទេស ហើយនិងដើម្បីរក្សាព្រះពុទ្ធសាសនា ឲ្យបានរុងរឿងរហូតដល់ ៥.០០០ ព្រះវស្សាកុំបីឃ្លៀងឃ្លាតឡើយ ។

សូមអនុសំវច្ឆរមហាសន្និបាតទី ២១ នៃមន្ត្រីសង្ឃ ប្រកបដោយនូវជោគជ័យជានិរន្តរ៍តទៅ ៕

ព្រះនាមព្រះតេជះព្រះគុណដែលបានទទួលសញ្ញាបត្រ តាំងជាចៅអធិការ និងគ្រូសូត្រ ក្នុងព្រះរាជអាណាចក្រកម្ពុជា

— ព្រះតេជះព្រះគុណ គុច-សួន នាមឆាយា អភិធម្មបាលោ កើតពីឆ្នាំ ១៩២៩ ឆ្នាំ វស្សា ៧ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តឈើទាល ឃុំក្រាំងស្បូវ ស្រុកឈូក ខេត្តកំពត លេខសញ្ញាប័ត្រ ៣.៥១១ ចុះថ្ងៃទី ៤-៥-៦៣ ។

— ព្រះតេជះព្រះគុណ តឹប- អិន នាមឆាយាបានកម្មោ កើតពីឆ្នាំ ១៩៣៩ អាយុ ២៥ ឆ្នាំ វស្សា ៣ បានទទួលតែងតាំងជាគ្រូសូត្រស្តាំក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣ ៥១២ ចុះថ្ងៃទី ៤-៥-៦៣ ។

— ព្រះតេជះព្រះគុណ មោក-យូរ នាមឆាយាសុវណ្ណសរោ កើតពី គ.ស. ១៩១៧ អាយុ ៤៦ ឆ្នាំ វស្សា ២៦ បានទទួលតែងតាំងជាចៅអធិ-ការក្នុងវត្តតាកែម ឃុំកំបូល ស្រុកភ្នំពេញ ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣.៥១៣ ចុះថ្ងៃទី ៤-៥-៦៣ ។

— ព្រះតេជះព្រះគុណ គល់-ញឹម នាមឆាយាសុវណ្ណជោត កើតពី គ.ស.១៩២០ អាយុ ៤៣ ឆ្នាំ វស្សា ២៤ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ ក្នុងវត្តឃុំស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥១៤ ចុះថ្ងៃទី ៤៥៦ ។

— ព្រះតេជះព្រះគុណ អ៊ុំ សាន នាមឆាយាគន្ធសីលោ កើតពីគ.ស. ១៩៣៤ អាយុ ២៩ ឆ្នាំ វស្សា ៨ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងក្នុង

វត្ត ឃុំស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥១៥ ចុះថ្ងៃទី ៤-៥-៦៣ ។

— ព្រះតេជះព្រះគុណ ហង់ ហៀង នាមឆាយាធម្មត្ថេរ កើតពី គ.ស. ១៩១១ អាយុ ៥២ ឆ្នាំ វស្សា ៣២ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តព្នៀតសិម្ពលី ឃុំស្នោរ ស្រុកភ្នំពេញ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣-៥១៦ ចុះថ្ងៃទី ៤-៥-៦៣ ។

— ព្រះតេជះព្រះគុណ មាញ-សាំង នាមឆាយាឥន្ទបញ្ញា កើតពីគ.ស. ១៩១៧ អាយុ ៤៦ ឆ្នាំ វស្សា ២៥ បានទទួលតែងតាំងជាគ្រូសូត្រស្តាំក្នុង ឃុំស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣ ៥១៧ ចុះថ្ងៃទី ៤-៥-៦៣ ។

— ព្រះតេជះព្រះគុណ មុំ-ម៉ន នាមឆាយាសុវណ្ណត្ថេរ កើតពីគ.ស. ១៩២៣ អាយុ ៤០ ឆ្នាំ វស្សា ១៥ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងក្នុង វត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣ ៥១៨ ចុះថ្ងៃទី ៤-៥-៦៣ ។

— ព្រះតេជះព្រះគុណ មៅ-ជុំ នាមឆាយាសុណ្ណត្ថេរ កើតពី គ.ស. ១៩៣២ អាយុ ៣១ ឆ្នាំ វស្សា ៩ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងក្នុងវត្ត ឃុំស្រុកខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៣០ ចុះថ្ងៃទី ២៥-៦-៦៣ ។

— ព្រះតេជះព្រះគុណ អ៊ឹម-ឡៅ នាមឆាយាជយាភិរក្ខិតោ កើតពី គ.ស. ១៩៣៣ អាយុ ៣០ ឆ្នាំ វស្សា ៨ បានទទួលតែងតាំងជាចៅអធិ-ការក្នុងវត្តឧត្តមមានជ័យ ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣.៥៣១ ចុះថ្ងៃទី ២៥-៦-៦៣ ។

—ព្រះតេជះព្រះគុណ ឈុន-គិន នាមឆាយាអគ្គជោតោ កើតពីគ.ស. ១៩៣៦ អាយុ ២៧ ឆ្នាំ វស្សា ៧ បានទទួលតែងតាំងជាគ្រូសូត្រស្តាំក្នុងវត្ត ឃុំស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣ ៥៣២ ចុះថ្ងៃទី២៥-៦-៦៣ ។

— ព្រះតេជះព្រះគុណ ជា-អម នាមឆាយាអគ្គតេជោ កើតពី គ.ស.១៩៣៧ អាយុ ២៦ ឆ្នាំ វស្សា ៥ បានទទួលតែងតាំងជាគ្រូសូត្រ ឆ្វេងក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣ ៥៣៣ ចុះថ្ងៃទី ២៦-៦-៦៣ ។

— ព្រះតេជះព្រះគុណ អ៊ុក-ខាត់ នាមឆាយារក្ខិតធម្មោ កើតពី គ ស ១៩៣៥ អាយុ ២៨ ឆ្នាំ វស្សា ៦ បានទទួលតែងតាំងជាគ្រូសូត្រ ស្តាំក្នុងវត្តមជ្ឈិមសភាគម ឃុំគោះហ ស្រុកមុខកំពូល ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣ ៥៣១ ចុះថ្ងៃទី ២៥-៦-៦៣ ។

—ព្រះតេជះព្រះគុណ ហែម មួន នាមឆាយាសុទ្ធបញ្ញោ កើតពីគ ស. ១៩៣៨ អាយុ ២៥ ឆ្នាំ វស្សា ៥ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងវត្ត ឆ្នាំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣ ៥៣៥ ចុះថ្ងៃទី ២៥-៦-៦៣ ។

—ព្រះតេជះព្រះគុណ សួស-សំអួន នាមឆាយាចិត្តទមោ កើតឆ្នាំរោង អាយុ ៣៥ ឆ្នាំ វស្សា ១២ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តខ្នាំង ឃុំបាក់ក្ដោង ស្រុករវៀង ខេត្តកំពង់ធំ លេខសញ្ញាប័ត្រ ៣.៥៣៦ ចុះថ្ងៃទី ២៥-៦-៦៣ ។

- - - -

—ព្រះតេជះព្រះគុណ ប្រាក់ លឹម នាមឆាយាលិទ្ធថេរ កើតពី គ.ស. ១៩១១ អាយុ ៥២ ឆ្នាំ វស្សា ៣០ បានទទួលតែងតាំងជាចៅអធិ-ការក្នុងវត្តស្វាយរំពារ ឃុំស្វាយរំពារ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង លេខសញ្ញាបត្រ ៣ ៥៣៧ ចុះថ្ងៃទី ៣០-៦-៦៣ ។

—ព្រះតេជះព្រះគុណ នេត-ឯល នាមឆាយាបទុមត្ថេរ កើតពី គ.ស. ១៩១១ អាយុ ៥២ ឆ្នាំ វស្សា ៣២ បានទទួលតែងតាំងជាចៅអធិការវត្តពោធិមាស ឃុំពាមឧកញ៉ាអុង ស្រុកល្វាឯម ខេត្តកណ្ដាល លេខសញ្ញាបត្រ ៣.៥៣៧ ចុះថ្ងៃទី ៣០-៦-៦៣ ។

—ព្រះតេជះព្រះគុណ ឈឹម-ជា នាមឆាយាបញ្ញាថេរ កើតពី គ.ស. ១៩៣២ អាយុ ៣១ ឆ្នាំ វស្សា ៩ បានទទួលតែងតាំងជាគ្រូសូត្រស្ដាំក្នុងវត្តពាមតាឯក ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាបត្រ ៣.៥៣៩ ចុះថ្ងៃទី ៣០-៦-៦៣ ។

—ព្រះតេជះព្រះគុណ ញែម-ទូច នាមឆាយាកេសរិទ័យ កើតពី គ.ស. ១.៩៤០ អាយុ ២៣ ឆ្នាំ វស្សា ៣ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាបត្រ ៣.៥៤០ ចុះថ្ងៃទី ៣០-៦-៦៣ ។

—ព្រះតេជះព្រះគុណ កូ-ជឹង នាមឆាយាសន្តុស្សកោ កើតពី គ.ស. ១៩៣៦ អាយុ ២៨ ឆ្នាំ វស្សា ៣ បានទទួលតែងតាំងជាចៅអធិការក្នុង

វត្តថ្វាក ឃុំព្រែង ស្រុកបាត់ដំបង ខេត្តបាត់ដំបង លេខសញ្ញាប័ត្រ ៣.៥៤១ ចុះថ្ងៃទី ១៨-៧-៦៣ ។

– ព្រះតេជះព្រះគុណ ញឹម-ផន នាមឆាយាបទុណធម្មោ កើតពី គ.ស. ១៩៤០ អាយុ ២៤ ឆ្នាំ វស្សា ៣ បានទទួលតែងតាំងជាគ្រូសូត្រស្តាំក្នុងវត្ត ឃុំ ស្រុក ខេត្តដវែល លេខសញ្ញាប័ត្រ ៣.៥៤២ ចុះថ្ងៃទី ១៨-៧-៦៣ ។

– ព្រះតេជះព្រះគុណ យិន-បឿន នាមឆាយាបញ្ញាវេត កើតពីគ.ស. ១៩៣១ អាយុ ៣៣ ឆ្នាំវស្សា ៤ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងក្នុងវត្ត ឃុំ ស្រុក ខេត្តដវែល លេខសញ្ញាប័ត្រ ៣.៥៤៣ ចុះថ្ងៃទី ១៨-៧-៦៣ ។

– ព្រះតេជះព្រះគុណ ស្រី-សឿន នាមឆាយាវិនយបញ្ញោ កើតឆ្នាំ ថោះ អាយុ ៤៨ ឆ្នាំ វស្សា ២៦ បានទទួលតែងតាំងជាចៅអធិការក្នុងវត្ត ត្បូងក្រពើ ឃុំត្បូងក្រពើ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ លេខសញ្ញាប័ត្រ ៣.៥៤៤ ចុះថ្ងៃទី ១៨-៧-៦៣ ។

– ព្រះតេជះព្រះគុណ គាំ-គឹម នាមឆាយាសុមង្គលត្ថេរ កើតឆ្នាំ ម្សាញ់ អាយុ ៣៤ ឆ្នាំ វស្សា ១៤ បានទទួលតែងតាំងជាចៅអធិការក្នុងវត្ត អង្គព្រាច ឃុំត្បែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣.៥៤៥ ចុះថ្ងៃទី ១៨-៧-៦៣ ។

– ព្រះតេជះព្រះគុណ អ៊ូ-រស់ នាមឆាយាធម្មត្ថេរ កើតពី គ.ស.

១.៩៣៥ អាយុ ២៩ ឆ្នាំ វស្សា ១០ បានទទួលតែងតាំងជាចៅអធិការ ក្នុងវត្តអម្ពវ័ន្ត ឃុំសៀមរាប ស្រុកខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៤៦ ចុះថ្ងៃទី ១៨-៧-៦៣ ។

- ព្រះតេជះព្រះគុណ ហ៊ុម-ហៀន នាមឆាយាឥន្ទជោតោ កើតឆ្នាំឆ្លូវ អាយុ ២៧ ឆ្នាំ វស្សា ៥ បានទទួលតែងតាំងជាគ្រូសូត្រស្តាំក្នុងវត្ត ឃុំស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៤៧ ចុះថ្ងៃទី ១៨-៧-៦៣ ។

- ព្រះតេជះព្រះគុណ សេ-លាប់ នាមឆាយាយសបាលោ កើតឆ្នាំខាលអាយុ ២៦ ឆ្នាំ វស្សា ២ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៤៨ ចុះថ្ងៃទី ១៨-៨-៦៣ ។

- ព្រះតេជះព្រះគុណ លេញ-អ៊ុម នាមឆាយាលទ្ធគ្គោ កើតពីគ.ស. ១.៩០៦ អាយុ ៥៧ ឆ្នាំ វស្សា ៦ បានទទួលតែងតាំងជាគ្រូសូត្រស្តាំក្នុងវត្តថ្មី ឃុំពង្រ ស្រុកកំពេញ ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣.៥៤៩ ចុះថ្ងៃទី ១៨-៧-៦៣ ។

- ព្រះតេជះព្រះគុណ យិន-យឹម នាមឆាយាតិស្សត្ថេរ កើតពីគ.ស. ១.៩០២ អាយុ ៦១ ឆ្នាំ វស្សា ៣ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៥០ ចុះថ្ងៃទី ១៨-៨-៦៣ ។

—ព្រះតេជះព្រះគុណ ហែម-ដួន នាមឆាយាព្រហ្មត្ថេរ កើតឆ្នាំថោះ អាយុ ៧២ ឆ្នាំ វស្សា ៥១ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តបទុម-រតនៈដីដុះ ឃុំកំពង់ចាម ស្រុកកំពង់សៀម ខេត្តកំពង់ចាម លេខសញ្ញាប័ត្រ ៣.៥៥១ ចុះថ្ងៃទី ១៨-៧-៦៣ ។

—ព្រះតេជះព្រះគុណ ទិត-ប៉ក់ នាមឆាសុធម្មត្ថេរ កើតឆ្នាំមមី អាយុ ៧ ឆ្នាំ វស្សា ៤៨ បានទទួលតែងតាំងជាគ្រូសូត្រស្តាំក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៥២ ចុះថ្ងៃទី ១៨-៧-៦៣ ។

—ព្រះតេជះព្រះគុណ កែវ-ចេង នាមឆាយាឥន្ទសរ កើតឆ្នាំថោះ អាយុ ៦១ ឆ្នាំ វស្សា ៣៨ បានទទួលតែងតាំងជាគ្រូសូត្រក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៥៣ ចុះថ្ងៃទី ១៨-៧-៦៣ ។

—ព្រះតេជះព្រះគុណ ឃួន-សៅ នាមឆាយាវិសាលបញ្ញា កើតឆ្នាំរោង អាយុ ៧៣ ឆ្នាំ វស្សា ៤៦ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តជ័យនាទី ឃុំចុងកោះសំរោង ស្រុកខេត្តដដែល លេខសញ្ញាប័ត្រ ចុះថ្ងៃទី ១៨-៧-៦៣ ។

—ព្រះតេជះព្រះគុណ រស់-ហ៊ុយ នាមឆាយាវជិរប្បញ្ញោ កើតពី គ.ស. ១៩០៥ អាយុ ៥៩ ឆ្នាំ វស្សា ៣៥ បានទទួលតែងតាំងជាគ្រូសូត្រស្តាំក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៥៤ ចុះថ្ងៃទី ១៨-៧-៦៣ ។

– ព្រះតេជះព្រះគុណ គង់-ជ័រ នាមឆាយាញាណសារោ កើតពី គ.ស.១៩៣៨ អាយុ ២៥ ឆ្នាំ វស្សា ៥ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៥៦ ចុះថ្ងៃទី ១៨-៧-៦៣ ។

– ព្រះតេជះព្រះគុណ នុម-គុន នាមឆាយាចន្ទុត្តោ កើតពីព.ស. ២៤៦៥ អាយុ ៤១ ឆ្នាំ វស្សា ២២ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តព្រៃធំ ឃុំស្រងែ ស្រុក ខេត្តសៀមរាប លេខសញ្ញាប័ត្រ ៣.៥៥៧ ចុះថ្ងៃទី ៣១-៧-៦៣ ។

– ព្រះតេជះព្រះគុណ នង-ប៉ែន នាមឆាយានន្ទុត្តោ កើតពីគ.ស. ១៩១៤ អាយុ ៤៩ ឆ្នាំ វស្សា ២៩ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តវន្ទធម្ម ឃុំក្លើងឆេះរទេះ ស្រុកកំពេញ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣.៥៥៨ ចុះថ្ងៃទី ៣១-៧-៦៣ ។

– ព្រះតេជះព្រះគុណ ប៉ិន-សាម នាមឆាយាសហទុត្តោ កើតពី គ.ស ១៩២២ អាយុ ៤១ ឆ្នាំ វស្សា ២២ បានទទួលតែងតាំងជាគ្រូសូត្រស្តាំក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៥៩ ចុះថ្ងៃទី ៣១-៧-៦៣ ។

– ព្រះតេជះព្រះគុណ មាស-ស៊ុម នាមឆាយាឥន្ទជោត កើតពីគ ស. ១៩១៧ អាយុ ៤៦ ឆ្នាំ វស្សា ១៦ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង

កុដិវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៦០ ចុះថ្ងៃទី ៣១.៧-៦៣ ។

— ព្រះតេជះព្រះគុណ សោម-អ៊ុន នាមឆាយាធម្មត្ថេរ កើតពី គ.ស. ១៨៨៥ អាយុ ៧៨ ឆ្នាំ វស្សា ២២ ឆ្នាំ បានទទួលតែងតាំងជាចៅអធិការកុដិវត្តធម្មត្រៃ ឃុំព្រៃសរ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៦១ ចុះថ្ងៃទី ៣១-៧-៦៣ ។

— ព្រះតេជះព្រះគុណ ណែម-ពៅ នាមឆាយាសុវណ្ណត្ថេរ កើតពី គ.ស. ១៩៣៤ អាយុ ២៩ ឆ្នាំ វស្សា ៩ បានទទួលតែងតាំងជាគ្រូសូត្រស្តាំកុដិវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៦២ ចុះថ្ងៃទី ៣១-៧-៦៣ ។

— ព្រះតេជះព្រះគុណ ខួន ណន នាមឆាយាឥន្ទត្ថេរ កើតពី គ.ស. ១៩៣៨ អាយុ ២៥ ឆ្នាំ វស្សា ២ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងកុដិវត្តធម្មត្រៃ ឃុំព្រៃសរ ស្រុកក្នំពេញ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣.៥៦៣ ចុះថ្ងៃទី ៣១-៧-៦៣ ។

— ព្រះតេជះព្រះគុណ ប៉ុច ឆាយ នាមឆាយាចន្ទត្ថេរ កើតពី ព.ស. ២៤៧៩ អាយុ ២០ ឆ្នាំ វស្សា ៧ បានទទួលតែងតាំងជាចៅអធិការកុដិវត្តតាំងក្រសាំងខាងត្បូង ឃុំកាកាប ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៦៤ ចុះថ្ងៃទី ៣១-៧-៦៣ ។

– ព្រះតេជះព្រះគុណ សាន់ អ៊ុន នាមឆាយាធម្មត្ថេរ កើតពី ព.ស. ២៤៤៥ អាយុ ៥៣ ឆ្នាំ វស្សា ៤ បានទទួលតែងតាំងជាគ្រូសូត្រស្តាំក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៦៥ ចុះថ្ងៃទី ៣១-៧-៦៣ ។

– ព្រះតេជះព្រះគុណ ឈុន ឈុំ នាមឆាយាមុនីបញ្ញា កើតពី គ.ស. ១៩៣៨ អាយុ ២៥ ឆ្នាំ វស្សា ២ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៦៦ ចុះថ្ងៃទី ៣១-៧-៦៣ ។

– ព្រះតេជះព្រះគុណ ជួប គុណ នាមឆាយាព្រហ្មត្ថេរ កើតពី គ.ស. ១៩១៦ អាយុ ៤៧ ឆ្នាំ វស្សា ២៦ បានទទួលតែងតាំងជាគ្រូសូត្រស្តាំក្នុងវត្តឈូកភរ ឃុំគោករកោរ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៦៧ ចុះថ្ងៃទី ៣ -៧-៦៣ ។

– ព្រះតេជះព្រះគុណ អ៊ុង-ឯក នាមឆាយាព្រហ្មសរោ កើតពី គ.ស. ១៩២៦ អាយុ ៣៧ ឆ្នាំ វស្សា ១៥ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងក្នុងវត្ត ឃុំ ស្រុក ខេត្តដដៃ លេខសញ្ញាប័ត្រ ៣.៥៦៨ ចុះថ្ងៃទី ៣១-៧-៦៣ ។

– ព្រះតេជះព្រះគុណ យង់ សួង នាមឆាយាព្រហ្មបញ្ញា កើតពី គ.ស. ១៩២២ អាយុ ៤១ ឆ្នាំ វស្សា ២១ បានទទួលតែងតាំងជាគ្រូសូត្រស្តាំក្នុងវត្តអង្គពពាយ ឃុំក្រាំងម្កាក់ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៦៩ ចុះថ្ងៃទី ៣១-៧-៦៣ ។

– ព្រះតេជះព្រះគុណ ជា គៀម នាមឆាយាធម្មជោតិ កើតពី

គ.ស. ១៩២១ អាយុ ៤២ ឆ្នាំ វស្សា ១៩ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងកុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៧០ ចុះថ្ងៃទី ៣១-៧-៦៣ ។

— ព្រះតេជះព្រះគុណ ដៀប-ម៉ុច នាមឆាយាឥន្ទកេសរសុវណ្ណ កើតពី គ.ស. ១៩២០ អាយុ ៤៣ ឆ្នាំ វស្សា ២៣ បានទទួលតែងតាំងជាចៅអធិការកុងវត្តចែងម៉ែង ឃុំលំហាច ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៧១ ចុះថ្ងៃទី ៣១-៧-៦៣ ។

— ព្រះតេជះព្រះគុណ ជឹប-សម នាមឆាយាធម្មសរ កើតពី គ.ស. ១៩១០ អាយុ ៦៣ ឆ្នាំ វស្សា ១២ បានទទួលតែងតាំងជាគ្រូសូត្រស្តាំកុងវត្តកំបូល ឃុំកំបូល ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៧២ ចុះថ្ងៃទី ៣១-៧-៦៣ ។

— ព្រះតេជះព្រះគុណ កែវ-ជា នាមឆាយាសង្ឃសរ កើតពី គ.ស. ១៩០៣ អាយុ ៦០ ឆ្នាំ វស្សា ២៨ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងកុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៧៣ ចុះថ្ងៃទី ៣១-៧-៦៣ ។

— ព្រះតេជះព្រះគុណ ដេត សៀក នាមឆាយាសុវណ្ណជោតិ កើតឆ្នាំរោងអាយុ ៣៧ ឆ្នាំ វស្សា ១៦ បានទទួលតែងតាំងជាចៅអធិការកុងវត្តកែវឧត្តម ឃុំលាជ ស្រុកកំក្រពាញ ខេត្តពោធិសាត់ លេខសញ្ញាប័ត្រ

៣.៩៧៤ ចុះថ្ងៃទី ៣១-៧-៦៣ ។

— ព្រះតេជះព្រះគុណ ហ៊ុន ម៉ូ នាមងាយាសុវណ្ណត្ថេរ កើតឆ្នាំមមី អាយុ ៣៩ ឆ្នាំ វស្សា ១៤ បានទទួលតែងតាំងជាគ្រូសូត្រស្តាំកុដិវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៩៧៥ ចុះថ្ងៃទី ៣១.៧.៦៣ ។

— ព្រះតេជះព្រះគុណ យង់ កឹម នាមងាយាយសត្ថេរ កើតឆ្នាំឆ្លូវ អាយុ ៦៥ ឆ្នាំ វស្សា ៦ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងកុដិវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៩៧៦ ចុះថ្ងៃទី ៣ ១៧ ៦៣ ។

— ព្រះតេជះព្រះគុណ មុំ គង់ នាមងាយានន្ទត្ថេរ កើតពី គ.ស. ១៩០២ អាយុ ៦១ ឆ្នាំ វស្សា ៣៨ បានទទួលតែងតាំងជាគ្រូសូត្រស្តាំកុដិវត្តព្រៃវែង ឃុំព្រៃវែង ស្រុកភ្នំពេញ ខេត្តកណ្តាល លេខសញ្ញាប័ត្រ ៣.៩៧៧ ចុះថ្ងៃទី ៣ ១៧ ៦៣ ។

— ព្រះតេជះព្រះគុណ ហង់ ព្រហ្ម នាមងាយាព្រហ្មត្ថេរ កើតពី គ.ស. ១៩០៤ អាយុ ៥៩ ឆ្នាំ វស្សា២៨ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងកុដិវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៩៧៨ ចុះថ្ងៃទី ៣១-៧.៦៣ ។

— ព្រះតេជះព្រះគុណ យឹម អាន នាមងាយាបញ្ញាជោតត្ថេរ កើតពី គ.ស.១៨៩១ អាយុ ៧២ ឆ្នាំវស្សា ៥២ បានទទួលតែងតាំងជាចៅអធិការកុដិវត្តប្រែគល់ ឃុំព្រែកពោធិ៍សួស្តី ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម

លេខសញ្ញាប័ត្រ ៣.៥៧៩ ចុះថ្ងៃទី ៣១-៧-៦៣ ។

– ព្រះតេជះព្រះគុណ ហង់ ក៉ត នាមឆាយាចន្ទជោត កើតឆ្នាំខាល អាយុ ៧៣ ឆ្នាំ វស្សា ៥៣ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តសំពៅធំ ឃុំសំពៅធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣.៥៨០ ចុះថ្ងៃទី ១៧-៩-៦៣ ។

– ព្រះតេជះព្រះគុណ ទិត យូន នាមឆាយាមង្គលត្ថេរ កើតពី គ.ស. ១៩៣៨ អាយុ ៤៦ឆ្នាំ វស្សា ២៤ បានទទួលតែងតាំងជាចៅអធិ-ការក្នុងវត្តព្រែកប្រា ឃុំច្បារអំពៅ ស្រុកកៀនស្វាយ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣.៥៨១ ចុះថ្ងៃទី ១៧-៩-៦៣ ។

– ព្រះតេជះព្រះគុណផូរ សុផល នាមឆាយាកោវិទប្បញ្ញោ កើតពីគ.ស. ១៩៣៣ អាយុ ៣០ ឆ្នាំវស្សា ៩ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តទួលសាលា ឃុំ ព្រែពួច ស្រុកក្ដំពេញ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣.៥៨២ ចុះថ្ងៃទី ១៧-៩-៦៣ ។

– ព្រះតេជះព្រះគុណ មុំ សេង នាមឆាយាមុនីសារោ កើតពី គ.ស.១៩៣៤ អាយុ ២៩ ឆ្នាំ វស្សា ៨ បានទទួលតែងតាំងជាគ្រូសូត្រ ធ្វើងក្នុងវត្ត ឃុំស្រុកខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៨៣ ចុះថ្ងៃទី១៧-៩-៦៣ ។

– ព្រះតេជះព្រះគុណ ជួន ឆិល នាមឆាយាចក្កុសរោ កើតពី

គ.ស. ១៩៣៧ អាយុ ២៦ ឆ្នាំ វស្សា ៥ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៨៤ ចុះថ្ងៃទី ១៧-៩-៦៣ ។

— ព្រះតេជះព្រះគុណ ខៀវ ម៉ុច នាមងាយាសុទ្ធិតស្សគ្គោ កើតពី ព.ស. ២៤៥៣ អាយុ ៥៣ ឆ្នាំ វស្សា ៣១ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តគោកខ្សាច់ ឃុំក្តីងផេះទេះ ស្រុកក្តុំពេញ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣.៥៨៥ ចុះថ្ងៃទី ១៧-៩-៦៣ ។

ព្រះតេជះព្រះគុណ ឃួន ចាន់ នាមងាយាវិរិយបណ្ឌិតោ កើតពី គ.ស. ១៩៣៩ អាយុ ២៤ ឆ្នាំ វស្សា ៤ បានទទួលតែងតាំងជាគ្រូសូត្រស្តាំក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣ ៥៨៦ ចុះថ្ងៃទី ១៧-៩-៦៣ ។

— ព្រះតេជះព្រះគុណ ទូច សំអាន នាមងាយាបគុណធម្មោ កើតពី ព.ស.២៤៨២ អាយុ ២៤ ឆ្នាំវស្សា ៤ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៨៧ ចុះថ្ងៃទី ១៧-៩-៦៣ ។

— ព្រះតេជះព្រះគុណ ពេជ មាស នាមងាយាជោតគ្គោ កើតពី ព.ស. ២៤៤៣ អាយុ ៦៣ ឆ្នាំវស្សា ៣១ បានទទួលតែងតាំងជាចៅអធិ-

ការក្នុងវត្តពោធិបាន ឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣.៥៨៨ ចុះថ្ងៃទី ១៧-៩-៦៣ ។

— ព្រះតេជះព្រះគុណ ជី សឹម នាមឆាយាបញ្ញាសារោ កើតពី ព.ស. ២៤៦៥ អាយុ ៤១ ឆ្នាំ វស្សា ២១ បានទទួលតែងតាំងជាគ្រូសូត្រស្ដាំក្នុងវត្ត ឃុំស្រុកខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៩៩ ចុះថ្ងៃទី ១៧-៩-៦៣ ។

— ព្រះតេជះព្រះគុណ ទិត គួន នាមឆាយាអត្ថទីបោ កើតឆ្នាំជូតអាយុ ៣៨ ឆ្នាំ វស្សា ៤ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៥៩០ ចុះថ្ងៃទី ១៩-៩-៦៣ ។

— ព្រះតេជះព្រះគុណ ពេជ សាត នាមឆាយាជោតត្ថេរ កើតពី គ.ស. ១៩៣២ អាយុ ៣១ ឆ្នាំ វស្សា ១០ បានទទួលតែងតាំងជាគ្រូសូត្រស្ដាំ ក្នុងវត្តឧង្ការ ឃុំទួលព្រេច ស្រុកក្ដាំពេញ ខេត្តកណ្ដាល លេខសញ្ញាប័ត្រ ៣ ៥៩១ ចុះថ្ងៃទី ១៧-៩-៦៣ ។

— ព្រះតេជះព្រះគុណ ម៉ែន សម នាមឆាយាធម្មត្ថេរ កើតពី គ.ស. ១៩៣៧ អាយុ ២៦ ឆ្នាំ វស្សា ៥ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣ ៥៩២ ចុះថ្ងៃទី ១៧-៩-៦៣ ។

— ព្រះតេជះព្រះគុណ ផង់ ចន នាមឆាយាឧបសន្តោ កើតពី

គ.ស.១៩៣៥ អាយុ ២៨ ឆ្នាំ វស្សា ៨ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ ក្នុងវត្តព្រៃព្នៅ ឃុំព្រៃព្នៅ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៩៩៣ ចុះថ្ងៃទី ១៧-៩-៦៣ ។

— ព្រះតេជះព្រះគុណ ស្រី សាក នាមឆាយាឯសកោ កើតពី គ.ស. ១៩៣៦ អាយុ ២៧ ឆ្នាំ វស្សា ៧ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៩៩៤ ចុះថ្ងៃទី ១៧-៩-៦៣ ។

— ព្រះតេជះព្រះគុណ តា ណែម នាមឆាយានន្ទតេរ កើតពី គ.ស. ១៩៣០ អាយុ ៣៣ ឆ្នាំ វស្សា ១០ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តពោធិវ័ន ឃុំស្មោ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៩៩៥ ចុះថ្ងៃទី ១៧-៩-៦៣ ។

— ព្រះតេជះព្រះគុណ មាច ថៃ នាមឆាយាធម្មជោតិ កើតពី គ.ស. ១៩៣១ អាយុ ៣២ ឆ្នាំ វស្សា ១១ បានទទួលតែងតាំងជា ចៅអធិការក្នុងវត្តកោះ ឃុំក្រាំងម្កាក់ ស្រុកក្តុំពេញ ខេត្តកណ្តាល លេខសញ្ញាប័ត្រ ១៩៣១ ចុះថ្ងៃទី ១៧-៩-៦៣ ។

— ព្រះតេជះព្រះគុណ ចាប ចក់ នាមឆាយាមង្គលបញ្ញា កើតពី គ.ស. ១៩៣០ អាយុ ៣៣ ឆ្នាំ វស្សា ១៣ បានទទួលតែងតាំងជាឧបជ្ឈាយ៍ក្នុងវត្ត សុរិយាពោធិមាស ឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល

លេខសញ្ញាប័ត្រ ៣៥៩៧ ចុះថ្ងៃ ១៨-៩-៦៣ ។

- ព្រះតេជះព្រះគុណ ស ជុន នាមធាយាចន្ទបញ្ញា កើតពី គ.ស. ១៩៣៧ អាយុ ២៦ឆ្នាំ វស្សា ៦ បានទទួលតែងតាំងជាចៅអធិការកុដិវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣ ៥៩៨ ចុះថ្ងៃ ១៨-៩-៦៣ ។

- ព្រះតេជះព្រះគុណ យឹម ឌុល នាមធាយាខន្ធសារោ អាយុ ៥៧ ឆ្នាំ វស្សា ២៣ បានទទួលតែងតាំងជាចៅអធិការកុដិវត្តដំរីស ឃុំស្វាយ-ទៀ ស្រុកសង្កែ ខេត្តបាត់ដំបង លេខសញ្ញាប័ត្រ ៣.៥៩៩ ចុះថ្ងៃ ១៨-៩-៦៣ ។

- ព្រះតេជះព្រះគុណ គួច ង៉ែក នាមធាយាវិនយបញ្ញោ អាយុ ៥២ ឆ្នាំ វស្សា ៣១ បានទទួលតែងតាំងជាគ្រូសូត្រស្តាំកុដិវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣៦០០ ចុះថ្ងៃ ១៨-៩-៦៣ ។

- ព្រះតេជះព្រះគុណ កែវ យ៉ុន នាមធាយាអគ្គិទន្តោ អាយុ ៣០ ឆ្នាំ វស្សា ៩ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងកុដិវត្ត ឃុំ ស្រុក ខេត្ត ដដែល លេខសញ្ញាប័ត្រ ៣ ៦០១ ចុះថ្ងៃ ១៨-៩-៦៣ ។

- ព្រះតេជះព្រះគុណ នួន យ៉ឹង នាមធាយាចន្ទទេវោ អាយុ ៣១ ឆ្នាំ វស្សា ១០ បានទទួលតែងតាំងជាចៅអធិការកុដិវត្ត សំពៅង៉កុង ឃុំសំពៅង៉កុង ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣ ៤០៦ ចុះថ្ងៃ ១៨-៩-៦៣ ។

— ព្រះតេជះព្រះគុណ ទេស ថាំង នាមធាយាឥទ្ធសុវណ្ណ គ.ស. អាយុ ៤៦ឆ្នាំ វស្សា ២៣ បានទទួលតែងតាំងជាគ្រូសូត្រស្តាំក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៦០៣ ចុះថ្ងៃទី ១៨-៩-៦៣ ។

— ព្រះតេជះព្រះគុណ ផាត ជទ នាមធាយាតិស្សសំវេ អាយុ ៣២ ឆ្នាំ វស្សា ១១ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងក្នុងវត្ត ឃុំស្រុកខេត្តដដែល លេខសញ្ញាប័ត្រ ៣.៦១៤ ចុះថ្ងៃទី ១៨-៩-៦៣ ។

— ព្រះតេជះព្រះគុណ មិត ធីរ នាមធាយាធម្មសារោ អាយុ ២៤ ឆ្នាំ វស្សា ៤ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តម្កដបុរី ឃុំចម្ងក្លួយ ស្រុកបាត់ដំបង ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៦០៥ ចុះថ្ងៃទី ១៨-៩-៦៣ ។

— ព្រះតេជះព្រះគុណ សាច់ ឯម នាមធាយាធម្មសារោ អាយុ ៦១ ឆ្នាំ វស្សា ៦ បានទទួលតែងតាំងជាគ្រូសូត្រស្តាំក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៦០៦ ចុះថ្ងៃទី ១៨-៩-៦៣ ។

(នៅមានត)

# លទ្ធផលនៃការប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ

## នៅឆមាសទី ២ ឆ្នាំ ១៩៦៤

នៅឆមាសទី ២ គឺពីខែកក្កដា ដល់ខែធ្នូ ឆ្នាំ ១៩៦៤ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ បានបើកសម័យប្រឡងប្រជែងខាងទំនៀមទម្លាប់ខ្មែរ ២ មុខគឺ ៖

## ១– សិប្បិយការជារបររបស់ខ្មែរ

## ២ – ទំនុកច្រៀងបុរាណរបស់ខ្មែរ

ដើម្បីប្រមូលឯកសារផ្នែកនេះយកមករក្សាទុកជាគោលចារិកនៃប្រពៃណីរបស់ប្រទេសជាតិតទៅអនាគត ។

ក្នុងរយៈកាល ៦ ខែ ក្រោយដែលបានប្រកាសផ្សាយរួចហើយ ក្រុមជំនុំទំនៀមទម្លាប់ បានទទួលអត្ថបទខាងពីរមុខនេះជាបន្តបន្ទាប់គ្នា ចំនួន ៤៨ រឿងអំពីសមាជិកឆ្លើយឆ្លងរបស់ក្រុមជំនុំខ្លះ និងអំពីបេក្ខជនក្រៅអំពីសមាជិកខ្លះចំនួន ៣៥ រូបជាបព្វជិតខ្លះ ជាគ្រហស្ថខ្លះ ។

ក្រុមជំនុំបានប្រជុំគ្នាពិនិត្យវិញ្ញាសាទាំងនេះយ៉ាងហ្មត់ចត់ ប៉ុន្តែដោយគ្មានវិញ្ញាសាណាមានខ្លឹមសារល្មមឡើងតម្លៃជារង្វាន់លេខ ១ និងលេខ ២ បាន ក្រុមជំនុំក៏កំណត់ត្រឹមរង្វាន់លេខ ៣ ខាងពីរផ្នែកដូចមានលទ្ធផលតទៅនេះ ៖

## ក - អំពីសិប្បការជារបររបស់ខ្មែរ

១- លោក ផាស ឡាំ នៅឃុំលាច ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ បានជាប់លេខ ៣ ត្រូវបានរង្វាន់ ៦០០រ០០ ។

២- លោក នុត ប៊ុនធឿន នៅឃុំឆាយ ស្រុកបាភ្នំ ខេត្តព្រៃវែង បានជាប់លេខ ៤ ត្រូវបានរង្វាន់ ៤០០រ០០ ។

## ខ - អំពីទំនុកច្រៀងបុរាណខ្មែរ

១- លោក ឌួង អ៊ុច អតីតមេឃុំ ឃុំអង្កាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ បានជាប់លេខ ៣ ត្រូវបានរង្វាន់ ៦០០រ០០

២- លោក កែវ កុល នៅឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ បានជាប់លេខ ៤ ត្រូវបានរង្វាន់ ៤០០រ០០ ។

ក្នុងឱកាសជាមួយគ្នានេះ ក្រៅអំពីការប្រឡង ក្រុមជំនុំបានទទួលឯកសារស្តីអំពីទំនៀមផ្សេង ៗ ចំនួន ១២ រឿងទៀត អំពីសមាជិកឆ្លើយឆ្លងខ្លះ ពុំមែនសមាជិកខ្លះចំនួន ១០ រូប ដែលមានឧត្តមគតិល្អយល់ច្បាស់នូវប្រយោជន៍ជាតិពិតប្រាកដ មានចិត្តសប្បុរសសរសេរឲ្យការណ៍ទៅក្រុមជំនុំ ។

ឯចំណែករង្វាន់ដែលត្រូវបានដល់បេក្ខជនប្រឡងជាប់ ដល់សមាជិកនិងក្រៅសមាជិក ដែលបានផ្ញើអត្ថបទទៅដល់ក្រុមជំនុំតាមកាលកំណត់ទាំងនោះ ក្រុមជំនុំបានចាត់ការប្រគេន-ជូនរួចអស់ហើយ ។

សូមបញ្ជាក់ថា នៅក្រោយពេលដែលក្រុមជំនុំពិនិត្យឲ្យពិន្ទុសម្រេចរួចហើយ មានវិញ្ញាសាផ្ញើមកដល់ជាច្រើនទៀត ប៉ុន្តែដោយអធ្យាស្រ័យចង់សន្សំឯកសារទុកឲ្យបានច្រើននោះ ក្រុមជំនុំបានសម្រេចថា នឹងពិនិត្យជូនក្រៅការប្រឡងប្រជែង បើឃើញថាមានសារៈ គួរយកជាការបាន នឹងជូនរង្វាន់ទៅក្នុងឆមាសទី ១ ឆ្នាំ ១៩៦៨ នេះទៀត ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣៧ លេខ ២ ខែ កុម្ភៈ

ព. ស. ២៥០៧ គ. ស. ១៩៦៥

– ភ្នំពេញ –

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ
បេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង


*ផ្នែកសាសនា* ទំព័រ

១– អំពីទេវតា (វិចារណកថា) លោក ផេង - ជ្រីវ រៀបរៀង . . . . . ១០៩
២– ភិក្ខុអបរិហានិយធម៌ សម្តេចព្រះពោធិវង្ស រៀបរៀង (ត–ចប់) . . . . ១១៧
៣– ការត្រាស់ដឹងនៃព្រះសម្ពុទ្ធ ព្រះមហា ប៉ាង–ខាត់ រៀបរៀង (ត) . . . ១៣១
៤– វិធុរជាតក (ត–ចប់) . . . . . . . . . ១៤២
៥– សុខមូលកធម៌ ភិក្ខុ ឧបសេនោ ញ៉ែម - នី រៀបរៀង . . . . . ១៥៤

*ផ្នែកអក្សរសាស្ត្រ*

៦– វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង–ខាត់ រៀបរៀង (ត) . . . ១៦៦
៧– សង្គហធម៌ ៤ ប្រការ លោក ឈឹម ស៊ុម រៀបរៀង . . . . . ១៦៨
៨– ចលនាអក្សរខ្មែរ លោក ឧ. តាម រៀបរៀង . . . . . . ១៧៦
៩– រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ–កន ប្រែរៀបរៀង(ត) . . . ១៨៤
១០– រឿងចោរហ្លួង លោក ឧ. តាម ស្រាវជ្រាវនិងរៀបរៀង (ត) . . . ១៩១
១១– ព្រះរាជនិពន្ធភមកេរ្តិ៍ លោក ឧ. តាម ស្រាវជ្រាវ(១) . . . . . ១៩៩

*ផ្នែកកំណត់ទិនប្រវត្តិការណ៍*

១២– ការតាំងចៅអធិការ និង គ្រូសូត្រ (ត) . . . . . . . ២០៧
១៣– ទំព័រកំសាន្ត : ចម្លើយចំណោទមហោស . . . . . . ២១៧

# ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការលាមក, ឲ្យធ្វើល្អទៅ.
ឲ្យផុសខាត់ចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។
ប.ព.

## អំពីទេវតា

(វិចារណកថា)

លោក ដេង - ញ៉ឹម រៀបរៀង

ទេវតាគឺជាអ្វី ?

តាមច្បាប់ព្រះពុទ្ធសាសនា ទេវតាជាសត្វមានកាយទិព្វមួយក្រុម ៗ សត្វក្រុមនេះមានបីផ្នែក ១ – ថ្នាក់នៃទេវតាដែលអាស្រ័យនៅក្នុងឋានកណ្តាល; ២ – ថ្នាក់នៃទេវតាដែលអាស្រ័យនៅក្នុងឋានសួគ៌ ៦ ជាន់ មានឋានចាតុមហារាជិកាជាដើម; ៣ – ថ្នាក់នៃទេវតាដែលអាស្រ័យនៅក្នុងឋានព្រហ្ម ១៦ ជាន់ មានព្រហ្មបារិសជ្ជាជាដើម ។

បណ្តាទេវតាទាំងបីពួកនេះ ក្នុងពួកទី ១ ទេវតាថ្នាក់នេះមានផលបុណ្យនិងអានុភាពខ្សត់ខ្សោយជាងគេបង្អស់ ជួនកាលខ្សោយជាងមនុស្ស ឬសត្វដទៃទៀតផង ។

សួរថា: ទេវតាទាំងបីពួក កាលពីជាតិមុន គឺជាអ្វី ?

ឆ្លើយថា: តាមលទ្ធិព្រះពុទ្ធសាសនា ហើយជាការណ៍ពិតប្រាកដមែន

ផង ពួកទេវតាពីជាតិមុន គឺជាមនុស្សដែលបានកសាងអំពើកុសលផ្សេងៗ តាមសទ្ធាធ្ងន់ស្រាល តាមធនធានច្រើនតិច តាមទឹកចិត្តយល់ច្បាស់ឬព្រាល ៗ តាមវិចារញ្ញាណជ្រៅរាក់ ៗ ឯផលបុណ្យ អានុភាពនិងថ្នាក់ខ្ពស់ទាប សម្រេចទៅតាមស្ថានការណ៍ខាងលើនេះ ។

សួរថា: បណ្តាមនុស្សទាំងឡាយ ពិសេសគឺជនជាតិខ្មែរ តើមានឈ្មោះណា ទោះជាមានបណ្តាសក្តិខ្ពង់ខ្ពស់ក្តី ទោះជាអ្នកថយថោកក្តី ទោះជាអ្នកសុចរិតក្តី ទោះជាអ្នកទុច្ចរិតក្តី ដែលបានជួប ឬដែលបានឃើញទេវតាម្តងឬទេ ? (កុំយកក្នុងរឿង ឬក្នុងគម្ពីរមកនិយាយ) ។

ឆ្លើយថា: ក្នុងឋានៈខ្ញុំដែលមានវ័យប៉ុណ្ណឹងហើយ ខ្ញុំដូចជាមិនដែលបានឮថាមានឈ្មោះណា បានជួប ឬបានយល់ទេវតាម្តងសោះ ។

សួរថា: បើដូច្នេះ ដែលពោលថាមានទេវតានោះ ជាការណ៍ប្រាកដឬយ៉ាងណា ?

ឆ្លើយថា: តាមយោបល់ខ្ញុំ ទេវតាពិតជាមានយ៉ាងជាក់ច្បាស់ តែមិនដឹងជាដោយហេតុអ្វីបានជាទេវតាអស់នោះ មិនព្រមបញ្ចេញអាត្មាឲ្យមនុស្សបានឃើញនឹងភ្នែកម្តង ?

តាមក្នុងគម្ពីរពុទ្ធសាសនាថា ឋានកណ្តាលនេះ (ឋានមនុស្ស) មានសភាពខ្ពើមឆ្អាប ធុំក្លិនមិនសូវស្រួល បានជាទេវតាមិនព្រមចុះមក ធៀបឧបមាដូចយើងចូលក្នុងបង្គន់ដូច្នោះ ។ ការពោលយ៉ាងនេះទុកជាជាគ្រាន់ចុះ

តែឯចំណែកទេវតា ដែលអាស្រ័យនៅក្បែរមនុស្សសព្វថ្ងៃ ដែលប្រមុះខ្លួនភាសាដូចប្រមុះមនុស្សដែរទៅហើយ ដូចម្តេចក៏មិនដែលឃើញបង្ហាញអាត្មាឲ្យគេយល់ដល់ម្តងផង ?

តាមយោបល់របស់ខ្ញុំ ទេវតា គឺពិតជាសត្វមួយក្រុមដែលគ្មានគិតអ្វីទាល់តែសោះក្រៅពីខ្លួនឯង ៗ ដូច្នេះបានជា ទោះបីមនុស្សសុចរិត ត្រូវគេរំលោភឈ្លានពាន ក៏ទេវតាមិនរវល់អើពើ ចាំទេវតានៅឯសួគ៌នាយចុះ គឺនៅឆ្ងាយផង ហើយរវល់តែសប្បាយរីករាយ ទីឯកញ្ញាទេពអប្សរ ទីឯកំឡោះទេពបុត្រសម្ផស្សទិព្វ រវល់តែសប្បាយនឹងប្រាសាទពេជ្រ ប្រាសាទមាស ប្រាសាទប្រាក់ រវល់តែសប្បាយនឹងការកំសាន្តក្នុងសួនទិព្វប្រកបដោយបុប្ផាមានក្លិនពិដោរឈ្ងុយឈ្ងប់ រវល់តែសប្បាយឆ្ងាញ់នឹងអាហារទិព្វដែលមានឱជារសហើយឈ្ងុយផង បានជាភ្លេចមិនបានចុះមកជួយមនុស្សម្តងម្កាល ចុះទេវតាឯកណ្តាលដែលអាស្រ័យនៅនឹងខ្លោងទ្វារផ្ទះមនុស្ស អាស្រ័យនៅលើកំពូលព្រះចេតិយ អាស្រ័យនៅតែដោយវត្តអារាម ៗលៗ តើឯបទីឯអ្វីដែរ ក៏មិនជួយ មិនប្រាប់ហេតុការណ៍ឲ្យមនុស្សបានដឹងមុន ឬក៏ជួយប្រាប់មធ្យោបាយ ដើម្បីការពារឲ្យរួចពីក្តីអន្តរាយផង ៗ

ដូច្នេះ ឃើញថាអានុភាពជួយសង្គ្រោះរបស់ទេវតា មិនមានទាល់តែសោះ ហើយហេតុនេះគួរតែឲ្យមនុស្សយកជាទីពឹងបានទេឬ? សូមអ្នក

ប្រកបដោយសុភនិច្ឆ័យ ជួយពិចារណាមើល?

តួយ៉ាងដូចព្រះឥន្ទ្រដែលមាននាមថា "ទេវានមិន្ទោ" ប្រែថាជាស្តេចនៃទេវតាទាំងឡាយ ហើយមាននាមច្រើនដទៃទៀត មានជាអាទិ៍ គឺ "សហស្សន័យន៍" ដែលប្រែតាមសព្ទត្រង់ថា "មានព្រះនេត្រមួយពាន់" បើប្រែយកន័យដ៏ទូលាយថា "អាចដឹងហេតុសព្វគ្រប់ ទោះនៅជិតក្តី នៅឆ្ងាយក្តី មើលឃើញក្តី កំបាំងក្តី ដូចជាមនុស្សមានភ្នែកមួយពាន់" ។ តាមគម្ពីរព្រះពុទ្ធសាសនា ព្រះឥន្ទ្រនេះជាពុទ្ធមាមកជនមួយរូបដ៏មុតមាំណាស់ ។

សួរថា: បើយ៉ាងដូច្នេះ ហេតុដូចម្តេចក៏ព្រះឥន្ទ្រមិនដែលឃើញហោះចុះមកបង្ហាញកាយ ឬបញ្ចេញព្រះវាចាប្រាប់ហេតុការក្រក់ល្អ ដែលបំរុងនឹងកើតមានដល់សប្បុរសពុទ្ធសាសនិកជនណាសោះ ព្រោះលោកជាអ្នកមានឫទ្ធិ មានអំណាចខ្លាំងពូកែគ្រប់សព្វ ឬមួយព្រះឥន្ទ្រខ្លាចគ្រាប់បែកបរមាណូ ដូចនាងទេពធីតា ជាអតីតព្រះមាតានៃព្រះបាទធនញ្ជ័យកោរព្យកុលខ្លាចបុណ្ណកយក្ស (រឿងវិធុរបណ្ឌិត)?

ឆ្លើយថា: ចំពោះសំនួរនេះ ឃើញថាមិនងាយនឹងដោះស្រាយឲ្យបានត្រឹមត្រូវឡើយ ។ តែបើតាមការជញ្ជឹងគិតរិះ ឃើញថាព្រះឥន្ទ្រក៏មិនខុសគ្នាពីទេវតាស្រុកមញ្ញទេ ហើយនាមគរគោករបស់ព្រះឥន្ទ្រ មានសហស្សន័យន៍ជាដើម គឺជាការលើកតម្កើងយ៉ាងធំ ព្រោះព្រះឥន្ទ្រមិន

បានគោរពសោះ គួរគប្បីតែឈប់យកនាមទាំងនេះមកនិយាយតទៅទៀត ដើម្បីកុំឲ្យរាប់ទើសទែង ។

ចំណែកសម្ដេចសហជីវិនវិញ គឺមានសភាពផ្ទុយពីព្រះឥន្ទ្រស្រឡះ ៗ ព្រះអង្គទ្រង់បានទទួលព្រះបរមនាមយ៉ាងច្រើនដូចព្រះឥន្ទ្រដែរ ពីសំណាក់ប្រជាពលរដ្ឋជាកូនចៅនៃព្រះអង្គ តែព្រះអង្គទ្រង់គោរពតែស្ងៀម ៗ ឯព្រះបរមនាមថ្មីទាំងនោះគឺ ១- ព្រះបិតាឯករាជ្យជាតិ ២- ព្រះបិតាសាមគ្គីជាតិ ៣- ព្រះបិតាសិក្សាធិការជាតិ ៤- ព្រះបិតាសុខាភិបាល ៥- ព្រះបិតាការហត្ថកម្ម ៦- ព្រះបិតាកីឡាជាតិ ៧- ព្រះបិតាសេដ្ឋកិច្ចជាតិ ៨- ព្រះបិតានស្សាហកម្ម ៩- ព្រះបិតាសិល្បជាតិ ១០- សម្ដេចឪ ។ ចំពោះព្រះបរមនាមទាំងនេះ មិនមានព្រះបរមនាមណាមួយ ដែលសម្ដេចជាម្ចាស់ទ្រង់មិនគោរពនោះឡើយ ; ដែលប្រជាពលរដ្ឋថ្វាយព្រះបរមនាមថា «ព្រះបិតាឯករាជ្យជាតិ» ព្រោះព្រះអង្គទ្រង់តស៊ូដោយឥតគិតដល់ព្រះជន្មក្ស័យ នូវឯករាជ្យដ៏ពិតប្រាកដ មកប្រទានដល់កូនចៅនិងមាតុភូមិរបស់ព្រះអង្គ ; ដែលគេថ្វាយព្រះបរមនាមថា «ព្រះបិតាសាមគ្គីជាតិ» ព្រោះសម្ដេចទ្រង់បានបង្កើតអង្គការ «សង្គមរាស្ត្រនិយម» ដើម្បីបង្រួបបង្រួមជាតិ ដែលមានការបែកបាក់គ្នា កាលពីក្នុងសម័យគណបក្ស ; ដែលគេថ្វាយព្រះបរមនាមថា «ព្រះបិតាសិក្សាធិការជាតិ» ព្រោះមុនពេលសង្គមរាស្ត្រនិយម កិច្ចសិក្សានៃប្រជារាស្ត្រមានសភាពស្ទួចស្ទើង ហើយសម្ដេចទ្រង់ធ្វើឲ្យកិច្ច

សិក្សានេះមានវឌ្ឍនភាពជាអតិបរមា; ដែលគេថ្វាយព្រះបរមនាមថា «ព្រះបិតាសុខាភិបាល» ព្រោះព្រះអង្គទ្រង់ធ្វើឲ្យមានមន្ទីរពេទ្យពាសពេញប្រទេស សម្រាប់ឲ្យប្រជារាស្ត្រមានមធ្យោបាយគ្រប់គ្រាន់ ដើម្បីថែរក្សារោគផ្សេងៗ; ដែលគេថ្វាយព្រះបរមនាមថា «ព្រះបិតាការហត្ថកម្ម» ព្រោះសម្តេចជាព្រះមហាក្សត្រខ្មែរតែមួយព្រះអង្គ ដែលទ្រង់ជាហត្ថករគំរូនៃកូនចៅព្រះអង្គក្នុងការបំពេញហត្ថកម្មផ្សេងៗ ក្នុងប្រទេស មានការកាប់គាស់ដីដើម្បីស្ថាបនាវិស័យនានា មានថ្នល់រថភ្លើង និងទំនប់ទឹកជាដើម; ដែលគេថ្វាយព្រះបរមនាមថា «ព្រះបិតាកីឡាជាតិ» ព្រោះសម្តេចទ្រង់ជាកីឡាករមួយព្រះអង្គយ៉ាងឆើត គឺព្រះអង្គសម្តេចនេះហើយដែលទ្រង់ជាមេដឹកនាំប្រជារាស្ត្រជាកូនចៅព្រះអង្គឲ្យយល់នូវតម្លៃកីឡា និងឲ្យពេញចិត្តក្នុងការលេងកីឡាផង; ដែលគេថ្វាយព្រះបរមនាមថា «ព្រះបិតាសេដ្ឋកិច្ច» ព្រោះព្រះអង្គទ្រង់ធ្វើឲ្យសេដ្ឋកិច្ចជាតិមានឯករាជ្យនិងរីកចំរើន ដោយកាត់ជំនួយមានចំណងនៃសហរដ្ឋអាមេរិកចោល ជាអំពើតែមួយក្នុងលោកដែលគ្មានរដ្ឋបុរសណាហ៊ានធ្វើ; ដែលគេថ្វាយព្រះបរមនាមថា «ព្រះបិតាឧស្សាហកម្ម» ព្រោះសម្តេចទ្រង់ដឹកនាំ និងពន្យល់ណែនាំផ្លូវដល់កូនចៅឲ្យយល់នូវតម្លៃនៃឧស្សាហកម្ម និងឲ្យបង្កើតនូវឧស្សាហកម្មយ៉ាងច្រើនក្នុងព្រះរាជាណាចក្រ; ដែលគេថ្វាយព្រះបរមនាមថា «ព្រះបិតាសិល្បជាតិ» ព្រោះសម្តេចជាសិល្បករមួយព្រះអង្គយ៉ាងឆើតជំនាញអស្ចារ្យ ទ្រង់និពន្ធ

បទភ្លេង ទំនុកចម្រៀងយ៉ាងពិរោះ ៗ ក្រៃលែង មិនតែប៉ុណ្ណោះទ្រង់ប៉ិនប្រសប់យ៉ាងចំឡែកក្នុងចម្រៀង និងក្នុងការសដែងតួនៃរឿងល្ខោនថែមទៀតផង; ដែលគេថ្វាយព្រះបរមនាមថា «សម្ដេចឪ» ព្រោះសម្ដេចទ្រង់ប្រកបដោយព្រហ្មវិហារធម៌ យ៉ាងមុតមាំជាងឪធម្មតា គឺថាទ្រង់មិនដែលបណ្ដែតបណ្ដោយឲ្យប្រជាពលរដ្ឋជាកូនចៅ ស្ថិតនៅក្រោមអនាថា គ្មានទីពឹងចំពោះអំពើអយុត្តិធម៌ ឬចំពោះសេចក្ដីទុក្ខវេទនាផ្សេង ៗ ដោយទ្រង់ព្រះបញ្ញាឲ្យបង្កើតប្រជាសានាការ និងបង្កើតក្រុមសង្គហជាតិ ៗ

ដូច្នេះ ឃើញថា សម្ដេចព្រះនរោត្តមសីហនុ ឧបយុវរាជ ព្រះប្រមុខរដ្ឋប្រទេសកម្ពុជា ព្រះអង្គទ្រង់ប្រសើរលើសព្រះឥន្ទ្រឆ្ងាយណាស់ ៗ បានជាហ៊ានពោលយ៉ាងនេះ ព្រោះព្រះឥន្ទ្រមិនបានគោរពនាមដ៏ជាក់ច្បាស់ដូចព្រះអង្គឡើយ ៗ នាមខ្លះរបស់ព្រះឥន្ទ្រជានាមបោកបញ្ឆោត ជានាមឥតប្រយោជន៍ នាំឲ្យគេហៅ គេទន្ទេញទៀយតែមាត់ តែគ្មានលទ្ធផលអ្វី ៗ

មានបញ្ហាមួយចោទប្រឆាំងឡើងថា ព្រះឥន្ទ្រមានដែលមកបង្គាប់យើងឲ្យយកនាមលោកមកទន្ទេញ មកសូត្រឯណា ? នេះហាក់តែយើងគិតភ័យស្រាក់នោះមិនដល់ ស្រាក់នេះមិនដល់ ក៏នាំគ្នាអំពាវនាវទៅទេតើ !

ការចោទប្រឆាំងមកនេះ ហាក់ដូចជាសមពិតប្រាកដមែន ព្រោះនៅខាងលើ យើងបានពោលថាមិនដែលឃើញ[illegible]ណា សូម្បីព្រះឥន្ទ្រក៏ដោយមកបង្ហាញកាយដល់មនុស្សម្ដងសោះ ក៏ប៉ុន្តែចំពោះរឿងព្រះឥន្ទ្រ

ដែលថាមាននាមមួយហៅ «សហស្សន័យន៍» បើពិចារណាត្រិះរិះទៅឃើញថា ពិតមែនតែព្រះឥន្ទ្រមិនចុះមកបង្គាប់ តែនាមនេះមានក្នុងគម្ពីរនៃពុទ្ធសាសនាដ៏ពិតប្រាកដ ដែលជាហេតុនាំឲ្យខ្មែរពុទ្ធសាសនិកត្រូវតែបួងសួងអំពាវនាវរកក្នុងពេលមានអាសន្ន ៗ ដូចសព្វថ្ងៃនេះ ពួកបរទេសទុរយសមានអាមេរិកាំងនិងយួនខាងត្បូងជាដើម កំពុងប្រព្រឹត្តរំលោភឈ្លានពានគម្រាមកំហែង និងវាយប្រហារមកលើកម្ពុជាស្លូតត្រង់ ហេតុម្ដេចក៏ព្រះឥន្ទ្រមិនចុះមកមើលការខុសត្រូវផង? ពាក្យបុរាណពោលថា : «តែមានផ្សែង តែងមានភ្លើង» ៗ នាមព្រះឥន្ទ្រថា: «សហស្សន័យន៍» ពិតជាមានមែន តែមិនដឹងជាអ្នកណាឲ្យដោយក្តីប្រឡំ ឬឲ្យដោយអគតិ ពុំនោះសោតឲ្យលេងក៏មិនដឹង ៗ

ដូច្នេះ គួរឲ្យមនុស្សមានសេចក្ដីសង្ស័យទៅលើទេវតាតទៅទៀត ឬយ៉ាងណា? អម្បាលទេវតា ដែលគេចាត់ទុកថាជាសត្វមួយក្រុមមានបុណ្យនិងមានឫទ្ធានុភាពក្រៃលែង ហើយមិនអាចមកជួយសង្គ្រោះមនុស្សបាន តើគួរយើងសង្ស័យចំពោះការពឹងផ្អែកទៅលើគ្រូដទៃក្នុងលោក មានអារក្ស អ្នកតា យាយទេពជាដើម បានឬទេ? តើតួទាំងនេះអាចផ្ដល់ប្រសិទ្ធិភាព តាមសំណូមពរ តាមការបន់ស្រន់នៃយើងបានឬទេ ?

(នៅមានតទៅទៀត)

# ភិក្ខុអបរិហានិយធម្មសូត្រ

(តមក)

សម្ដេចព្រះពោធិវង្ស រៀបរៀង

## ការប្រជុំសេចក្ដីចំរើនក្នុងធម៌ទី ១

១– អ្នកដែលពុំទាន់បានចេះដឹង នឹងបានទៅជាអ្នកចេះដឹង:

២– អ្នកចេះដឹងតិច នឹងបានទៅជាអ្នកចេះដឹងច្រើន,

៣– អ្នកដែលចេះដឹងច្រើន ក៏រឹតតែចំរើនខាងការចេះដឹងទៀត,

៤– នឹងមានសាមគ្គីកើតឡើងរវាងអ្នកប្រជុំគ្នានោះ.

៥– ប្រទេសជាតិ, សាសនា និងព្រះមហាក្សត្រ របស់អ្នកដែលប្រជុំគ្នារឿយ ៗ នោះ នឹងបានសេចក្ដីចំរើនឡើងជាបំផុត ។

**ត្រង់ធម៌ទី ២**– ក្នុងវគ្គកថា មានសេចក្ដីពន្យល់ជា ២ ផ្នែក គឺ ផ្នែកខាងផ្លូវលោក និងផ្លូវព្រះពុទ្ធសាសនា ។

## អំពីការព្រមព្រៀងគ្នាប្រជុំ

**ខាងផ្លូវលោក**– កាលបើគេវាយស្គរឲ្យសញ្ញា(១) ប្រាប់ពេលថា ត្រូវប្រជុំហើយ, ប្រសិនបើអ្នកដែលត្រូវមកប្រជុំ ទម្រន់ជំអក់ដោយការថា ខ្លួនមានកិច្ចរវល់ ថាខ្លួនមានការមង្គល ហើយមិនមកកាន់ទីប្រជុំ

---

១ សម័យយើងសព្វថ្ងៃ ប្រើម៉ោងជាសញ្ញាណាត់ពេលប្រជុំ ។

ឬក៏មកដែរ ប៉ុន្តែមកមិនទាន់វេលា, យ៉ាងនេះឈ្មោះថា មិនមានការព្រមព្រៀងគ្នាចូលកាន់ទីប្រជុំ ។ ពួកអ្នកដែលត្រូវមក កាលបើឮស្គរហើយ នោះបើកំពុងបរិភោគអាហារក្តី កំពុងតាក់តែងខ្លួនក្តី កំពុងស្លៀកពាក់ក្តី ក៏មិនហ៊ានបណ្តែតបណ្តោយ គឺបរិភោគអាហារបានប៉ុន្មានក៏ឈប់ប៉ុណ្ណោះ តាក់តែងខ្លួនបានប៉ុន្មានក៏យកប៉ុណ្ណោះ ស្លៀកពាក់បានយ៉ាងណាក៏យកយ៉ាងនោះ ហើយស្ទុះទៅកាន់ទីប្រជុំឲ្យទាន់ពេលវេលា; យ៉ាងនេះហៅថា **មានការព្រមព្រៀងគ្នាចូលកាន់ទីប្រជុំ ។**

**បំណែកខាងផ្លូវព្រះពុទ្ធសាសនា** ក្នុងពេលដែលសង្ឃត្រូវប្រជុំម្តងៗ កាលបើគេវាយគងឲ្យសញ្ញាថាសង្ឃត្រូវប្រជុំ ដើម្បីធ្វើកិច្ចការរបស់សង្ឃ មានការសំអាតទីព្រះចេតិយជាដើម, ប្រសិនបើពួកភិក្ខុដែលត្រូវមកប្រជុំ បានឮស្គរគងហើយទម្រន់ដំអក់ដោយអាងថា កំពុងជុតបាត្រ កំពុងមានកិច្ចរវល់ ហើយមិនមកកាន់ទីប្រជុំ ឬក៏មកដែរ ប៉ុន្តែមកមិនទាន់ពេល, យ៉ាងនេះហៅថា **មិនមានការព្រមព្រៀងគ្នាប្រជុំ ។** ពួកភិក្ខុដែលត្រូវមកប្រជុំនោះ កាលបើឮស្គរគងហើយ, បើទុកជាមានកិច្ចរវល់យ៉ាងណាក៏ត្រូវតែបញ្ឈប់ការរវល់នោះសិន ត្រូវស្រូតមកកាន់ទីប្រជុំដោយគាំងចិត្តថា «អញមុនគេ អញមុនគេ» ហើយបានប្រជុំដោយឯកច្ឆហារ, យ៉ាងនេះទើបឈ្មោះថា **មានការព្រមព្រៀងគ្នាប្រជុំ ។**

## អំពីការព្រមព្រៀងគ្នាក្រោកចាកទីប្រជុំ

ខាងផ្លូវលោក - *ពួកអ្នកដែលប្រជុំ កាលបើគិតរួចហើយ ប្រឹក្សាគ្នាហើយ ធ្វើកិច្ចដែលត្រូវធ្វើរួចហើយ មិនក្រោកចេញឲ្យព្រមព្រៀងគ្នា ខ្លះក្រោកទៅមុន ខ្លះក្រោកទៅក្រោយ, យ៉ាងនេះឈ្មោះថា* មិនព្រមព្រៀងគ្នាក្រោកចាកទីប្រជុំ ។ *មែនពិត, បណ្ដាពួកអ្នកដែលក្រោកចេញយ៉ាងនេះ, អ្នកណាក្រោកទៅមុនគេ អ្នកនោះតែងមានគំនិតយ៉ាងនេះថា (ពាក្យដែលយើងបានស្ដាប់សុទ្ធតែជាពាក្យវាងក្រៅទេ ពាក្យដែលសម្រេចកិច្ចការប្រហែលជានឹងមានឥឡូវនេះ គឺក្នុងពេលវាងក្រោយបន្ទាប់អំពីពេលដែលខ្លួនចេញទៅ) ។ (ការក្រោកចេញមុនគេ មិននៅចាំឲ្យព្រមគ្នា ជាហេតុនាំឲ្យមានរង្កៀសខ្លះយ៉ាងនេះពុំទាន) ។ កាលបើក្រោកចេញដោយព្រមគ្នា ទើបឈ្មោះថា* ព្រមព្រៀងគ្នាក្រោកចាកទីប្រជុំ ។

*ចំណែកខាងផ្លូវព្រះពុទ្ធសាសនា ក្នុងអដ្ឋកថា មានសេចក្ដីពន្យល់មិនប្លែកគ្នាឡើយ ។*

## អំពីការព្រមព្រៀងគ្នាធ្វើកិច្ចដែលសង្ឃត្រូវធ្វើ

ខាងផ្លូវលោក- *បើការងាររបស់ជនម្នាក់ត្រូវលិចលង់ គឺត្រូវវិនាសអន្តរាយ, ជនឯទៀតត្រូវបញ្ជូនកូនចៅបងប្អូនឲ្យទៅជួយឧបត្ថម្ភ*

ការងាររបស់ជននោះ កុំឲ្យវិនាសអន្តរាយបាន ។ បើជនម្នាក់ៗមានមង្គលក្តី មានភេទក្តី មានទុក្ខសុខសមគួរដល់មង្គលនិងភេទនោះកើតឡើងក្តី ជនទាំងអស់ត្រូវរួបរួមជាមួយគ្នា ទៅជួយកិច្ចការទាំងនោះ ឬជួយរួមទុក្ខសុខជាមួយគ្នា, យ៉ាងនេះឈ្មោះថា **ព្រមព្រៀងគ្នាធ្វើកិច្ចការដែលត្រូវធ្វើ ។**

**ខាងផ្លូវព្រះពុទ្ធសាសនា**- សង្ឃត្រូវព្រមព្រៀងគ្នាជួយធ្វើការសង្ឃដោយមិនប្រវាំគ្នា មិនមើលបំណាំគ្នាឡើយ, កាលបើភិក្ខុ ១ រូប ៗ មានកិច្ចការដែលសង្ឃត្រូវធ្វើ, សង្ឃត្រូវតែជួយធ្វើកិច្ចការទាំងនោះដោយរួបរួមគ្នា យ៉ាងនេះឈ្មោះថា**ព្រមព្រៀងគ្នាធ្វើកិច្ចការដែលសង្ឃត្រូវធ្វើ។**

ការព្រមព្រៀងគ្នាទាំង ៣ ស្ថានខាងលើនេះ នាំឲ្យនៅសេចក្តីចំរើននិងសេចក្តីសុខស្រួល មិនមែនជាផ្លូវនាំឲ្យវិនាសខូចខាតឡើយ ព្រោះការព្រមព្រៀងគ្នាជាកម្លាំងដ៏ក្លាខ្លាំងបំផុត អាចញ៉ាំងកិច្ចការដែលមនុស្សម្នាក់ ៗ ធ្វើឲ្យសម្រេចមិនបាននោះ ឲ្យសម្រេចបានដោយងាយទៅវិញ ។ សាមគ្គី គឺសេចក្តីព្រមព្រៀងគ្នានេះ សូម្បីមានក្នុងពួកក្រុមសត្វល្អិតតូចៗ. ក៏គង់មានកម្លាំងមានបុរិក្ខារច្រើនស្ទើរណាស់ ដូចសត្វកណ្តៀរជាសត្វតូចល្អិត ប៉ុន្តែពួកសត្វនេះ មានសាមគ្គី អាចរួបរួមគ្នាធ្វើលំនៅរបស់ខ្លួនវាយ៉ាងធំមាំមួនបាន, ហើញថាលំនៅរបស់សត្វកណ្តៀរធំមាំមួនហួសមាន

ហួសកម្លាំង កើតឡើងបានដោយអាស្រ័យការព្រមព្រៀងគ្នាជាកម្លាំង ។ ម្យ៉ាងទៀត, ដូចពួកស្រមោចកើតជាសត្វតូចល្អិតៗ នៅក្នុងរន្ធនីមួយ ៗ ពុំសូវមានមនុស្សណា អាចហ៊ានចូលទៅជាន់បំផ្លាញបានឡើយ ព្រោះស្រមោចនោះរស់ស្រុះគ្នាណាស់ ។ កាលបើមានមនុស្សណាមួយចូលទៅឈរក្បែររន្ធវា ឬ ជាន់សង្កត់ពីលើ វាចេញពីរន្ធដោយស្រុះគ្នាយ៉ាងរហ័ស អាច ហ៊ានខាំមនុស្សឲ្យស្ទុះប្រឡោតចេញពីទីនោះបាន, សាមគ្គីរបស់ស្រមោច វាចបញ្ចេញឥទ្ធិពលធ្វើឲ្យសត្វ ឬ មនុស្សញញើតវាបាន ។

សាមគ្គីរបស់មនុស្សនិងសត្វ ទោះបីជាមនុស្សប្រភេទណាក្តី ជាសត្វតូចតាចដូចម្តេចក្តី គង់មានកម្លាំងមានឥទ្ធិពល នាំឲ្យសម្រេចប្រយោជន៍បានតាមបំណង ប៉ុន្តែមនុស្សនិងសត្វកុំយកមកថ្លឹងដុះ ព្រោះសត្វតែមានចិត្តមានវិញ្ញាណ គ្មានសតិបញ្ញាចាំមិនជាអស្ចារ្យប៉ុន្មាន, ដូច្នេះយើងត្រូវគិតពីវត្ថុឥតវិញ្ញាណវិញ បើវត្ថុណាមួយប្រកបដោយសាមគ្គី តើវត្ថុនោះនឹងនៅដូចដែល ឬក៏ក្លាយទៅជាវត្ថុមានឫទ្ធិគួរឲ្យស្ញើចដែរ មិនមែននៅដូចដែលទេ; ដូចអម្បោះនៅ ១ សរសៃ ជាអម្បោះផុយក្រៃពេក គេទាញតែបន្តិច ក៏ដាច់ដោយងាយ, អម្បោះនោះ កាលបើគេប្រមូលគ្នារាប់ពាន់ម៉ឺនសែនសរសៃ ហើយគេវេញត្របាញចូលគ្នា អម្បោះនោះប្រែទៅជាមានឫទ្ធិអាចចងដំរី ១ ឲ្យរើខ្លួនមិនរួច; នេះជាឧទាហរណ៍, សម្រាប់ពិចារណាឲ្យឃើញថា សាមគ្គី គឺសេចក្តីព្រមព្រៀងគ្នា គួរ

មនុស្សក្នុងលោកដែលត្រូវការរកសេចក្ដីសុខចំរើន គប្បីចង់បានណាស់ គប្បីខំប្រឹងបណ្ដុះបណ្ដាលឲ្យមានឡើង; ពុំគួរបើមនុស្សក្នុងលោកទាំងបញ្ញិតទាំងគ្រហស្ថ ក្មេងខ្លួនបើកឱកាសឲ្យពួកអកុសលធម៌ ចូលមកគ្របសង្កត់ក្នុងសន្ដានចិត្ត បិទបាំងកំនិតគិតមិនយល់ទាល់តែរកផ្លូវឲ្យសាមគ្គីកើតឡើងមិនបាននោះឡើយ ។ ឯអកុសលធម៌ទាំងនោះ មានច្រើនបែបច្រើនយ៉ាងណាស់ ប៉ុន្តែក្នុងទីនេះ សូមចង្អុលឈ្មោះចំពោះតែអកុសលធម៌ធំ ៗ មានដើមគឺ :

១– លោភោ លោភ

២– ទោសោ កំហឹង

៣ មោហោ ល្ងង់

៤– មានោ មានះរឹងត្អឹង

៥– អភិជ្ឈា ចង់បានហួស

៦– ឥស្សាចារោ គុំគួន

៧– កោធោ ក្រេវក្រោធ

៨– ឧបនាហោ ចងកំហឹង ឬ ចងពៀរ ។

បាបធម៌ប៉ុណ្ណោះជាដើម សម្រាប់បំបែកមនុស្សក្នុងលោកឲ្យកើតវិវាទទាស់ទែងគ្នា ឲ្យរួបរួមគ្នាមិនជិត គិតតែពីដណ្ដើមប្រណាំងប្រជែងយកឈ្នះ ។ អ្នកដែលមានបំណងចង់ឲ្យមានសាមគ្គី គឺការរួបរួមចងបាច់គ្នា

ដើម្បីនឹងបណ្តុះកម្លាំងឲ្យបានក្លាខ្លាំងឡើង ដើម្បីនឹងបានបំពេញកិច្ចការទាំងឡាយ ដែលមានប្រយោជន៍ដល់ប្រទេស, ដល់ព្រះពុទ្ធសាសនា, ដល់ព្រះមហាក្សត្រ គប្បីកំចាត់អកុសលធម៌ទាំងលើនេះចេញ ទើបសាមគ្គីធម៌នឹងកើតមានឡើង, បើមានសាមគ្គីហើយ សេចក្តីសុខចំរើននឹងកើតឡើងសមតាមបំណងបាន, ដូចព្រះពុទ្ធភាសិតថា :

សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ

"ការព្រមព្រៀងគ្នានៃសង្ឃ គឺពួកក្រុមនីមួយ ៗ នាំឲ្យមានសេចក្តីសុខ តបធម៌ គឺសេចក្តីព្យាយាមរបស់ពួកជនដែលព្រមព្រៀងគ្នា តែងនាំសុខមកឲ្យ" ។

## ប្រយោជន៍សេចក្តីចំរើនក្នុងធម៌ទី ២

១– នាំឲ្យបានសេចក្តីសុខស្រួល;

២– នាំឲ្យមានមេត្រីភាព រវាងពួកជនដែលព្រមព្រៀងគ្នា;

៣– នាំឲ្យមានពលានុភាព អាចសម្រេចកិច្ចការទាំងឡាយដែលមនុស្សម្នាក់ ៗ ធ្វើមិនសម្រេច;

៤– នាំឲ្យមានឥទ្ធិពល ឥតមានបច្ចាមិត្រណាមួយចូលមកប្រមាថពាធាបាន;

៥– នាំឲ្យប្រទេសជាតិ, សាសនានិងព្រះមហាក្សត្រ របស់ពួកជនដែលព្រមព្រៀងគ្នា មានសេចក្តីចំរើនរុងរឿង, មានតម្លៃថ្លៃថ្នូរ;

៦-- នាំឲ្យមនុជនយកតម្រាប់តាម ពេញចិត្តប្រព្រឹត្តកាន់តាមលំ-អានដំប្រពៃនោះ ។

ត្រង់ធម៌ទី ៣– គន្ធអដ្ឋកថា មានសេចក្ដីពន្យល់ថា ពួកភិក្ខុដែលកាន់តាមគតិការវត្ត ឬ សិក្ខាបទថ្មីៗ ដែលមិនប្រកបដោយធម៌ ហៅថា បញ្ញត្តនូវសិក្ខាបទដែលព្រះសម្មាសម្ពុទ្ធមិនបានបញ្ញត្ត ។ ពួកភិក្ខុដែលសំដែងផ្សាយសាសនា ខុសចាកធម៌ ខុសចាកវិន័យ ហៅថា ដកហោលនូវសិក្ខាបទដែលព្រះបរមសាស្ដាបានបញ្ញត្តហើយ ។ ពួកភិក្ខុដែលខ្លួនឲ្យត្រូវអាបត្តិ ទោះជាអាបត្តិតូចតាចក៏ដោយ ហៅថា មិនប្រព្រឹត្តកាន់តាមសិក្ខាបទ ដែលព្រះបរមគ្រូបានបញ្ញត្តហើយ ។ ភិក្ខុដែលមិនប្រព្រឹត្តធ្វើដូចពោលលើនេះ ទើបហៅថា មិនបញ្ញត្តនូវសិក្ខាបទដែលព្រះអង្គមិនបានបញ្ញត្ត, មិនដកនូវសិក្ខាបទដែលព្រះអង្គបញ្ញត្តហើយ, ប្រព្រឹត្តកាន់តាមសិក្ខាបទដែលព្រះអង្គទ្រង់បញ្ញត្តហើយ ។

ត្រង់ស្ថាននេះ ចំណែកខាងគ្រហស្ថដែលកាន់ព្រះពុទ្ធសាសនា ក៏ត្រូវប្រព្រឹត្តកាន់សិក្ខាបទ តាមឋានរបស់ខ្លួនដែរ ទើបបានឈ្មោះថា បានប្រតិបត្តិតាមអបរិហានិយធម៌ទីបីនេះ ។

ម្យ៉ាងទៀត. តាមធម្មតាបវេណីក្នុងលោក បុគ្គលដែលកើតមកត្រូវអាស្រ័យមាតាបិតាចិញ្ចឹមបីបាច់ថែរក្សា ប្រៀនប្រដៅរំលឹកដាស់តឿនជាដរាប ទើបមានសេចក្ដីចំរើនទិងការចេះដឹងឡើងជាលំដាប់ ។ មនុស្សក្នុងលោក ដែលចិញ្ចឹមបានល្អ ឬ ទីងមានសេចក្ដីចំរើនឡើង ក៏ព្រោះអាស្រ័យការស្ដាប់ពាក្យប្រៀនប្រដៅ ព្រមទាំងប្រតិបត្តិតាមឱវាទរបស់មាតាបិតា មិនប្រព្រឹត្តក្រៅគន្លងឱវាទ ព្រោះមាតាបិតាតែងដាស់តឿនប្រៀនប្រដៅឲ្យប្រតិបត្តិតែចំណែកល្អដែលប្រកបដោយប្រយោជន៍ មិនឲ្យប្រព្រឹត្តបំពាបំពានក្នុងផ្លូវខុសផ្លូវអាក្រក់ ។ ត្រកូលនីមួយៗ ដែលមិនវិនាសហិនហោចចុះទៅបាន ក៏អាស្រ័យអនុជនប្រតិបត្តិត្រឹមត្រូវ ដែលបុព្វជនបានធ្វើបានទុកតម្រាប់តមក មិនបញ្ញត្តរបៀបថ្មីដែលខុស ឬអាក្រក់ ឬក៏ ដែលមិនមានផលប្រយោជន៍ ដោយខ្លួនឯងឡើយ ។ មួយទៀតទំនៀមទម្លាប់ ឬសណ្ដាប់ធ្នាប់ណាដែលត្រឹមត្រូវល្អស្រេចស្រាប់មកហើយ នាំគ្នារក្សាទុកមិនឲ្យបាត់, ណាដែលផ្ដាំផ្គង នាំគ្នារំលៀកយកចេញតាមកាលសម័យ ។

ត្រង់ធម៌ទី២ ក្នុងអដ្ឋកថា មានសេចក្ដីពន្យល់ថា ពួកភិក្ខុណាមិនធ្វើសក្ការ គោរពកប់អានភិក្ខុជាថេរៈ ជាសង្ឃបិតា ជានាយកលើសង្ឃមិនទៅបំរើដើម្បីទទួលឱវាទលោកទេ ព្រោះថេរៈទាំងនោះទីងមិនបានឲ្យ

ឱវាទ មិនបានសំដែងនូវបវេណិកថា មិនបានបង្ហាត់បង្រៀននូវធម្មបរិយាយ ដែលមានខ្លឹមសារដល់ពួកភិក្ខុទាំងនោះឡើយ ។ ដូច្នេះ ពួកភិក្ខុទាំងនោះ ឈ្មោះថាត្រូវព្រះថេរៈទាំងឡាយលះបង់ចោលហើយ នឹងត្រូវសាបសូន្យ វិនាស ចាកគុណទាំងឡាយមានសីលគុណជាដើមផង ចាកអរិយទ្រព្យ ទាំង ៧ ផង ។ បើភិក្ខុណាធ្វើសក្ការៈគោរពរាប់អាន ព្រមទាំងបាន ទៅបំរើព្រះថេរៈទាំងនោះៗ នឹងបានឲ្យឱវាទ ដំបូន្មាន សំដែងនូវបវេ-ណិកថា បង្ហាត់បង្រៀននូវធម្មបរិយាយដែលមានខ្លឹមសារជាដើម, ពួកភិក្ខុទាំងនោះ កាលបើបានឋិតនៅក្នុងឱវាទល្អនៃព្រះថេរៈទាំងនោះហើយ ក៏នឹងបានចំរើនដោយគុណទាំងឡាយមានសីលគុណជាដើម ដរាបដល់ បានសម្រេចនូវសាមញ្ញគុណ ។

**ប៉ែកខាងគ្រហស្ថ** គួរឲ្យគោរពរាប់អានអ្នកធំដែលជាប្រធាន ក្នុងពួកក្នុងគណៈ ព្រមទាំងជឿស្តាប់ពាក្យ ត្រឹមត្រូវរបស់លោកទាំងនោះៗ ការគោរពអ្នកធំព្រមទាំងការជឿស្តាប់ពាក្យទាំងនោះ ជាផ្លូវដែលគ្រហស្ថ គួរប្រតិបត្តិឲ្យម៉ឺងម៉ាត់ ព្រោះសង្គមនីមួយៗ ដែលអាចញ៉ាំងសាមគ្គីឲ្យ ឋិតនៅបាន ដោយអាស្រ័យមានអ្នកដែលជាអធិបតីជាប្រមុខ ប្រៀបដូច ជាកិច្ចការរបស់ប្រទេស ដែលនឹងមានដំណើរទៅកាន់វឌ្ឍនភាពបានក៏-ដោយអាស្រ័យព្រះមហាក្សត្រជាទីគោល, កាលបើព្រះអង្គទ្រង់ព្រះតំរិះ ឃើញថាគួរនឹងចាត់ការបញ្ញត្តិយ៉ាងណា ដើម្បីឲ្យកើតមានសេចក្តីចំរើន

ក្នុងព្រះពជាណាចក្រ ព្រះអង្គក៏បានបញ្ញត្តឡើង, ប្រជារាស្ត្រជាពលរដ្ឋដែលបានទទួលនូវសេចក្ដីសុខសាន្តនិងសេចក្ដីចំរើន គួរតែតាំងចិត្តគោរពចំពោះព្រះមហាក្សត្រ ព្រមទាំងទទួលស្ដាប់សេចក្ដីបញ្ញត្តិរបស់ព្រះអង្គ ។ ឯក្នុងវិសុទ្ធិបាត ពួកអ្នកប្រជុំក៏គួរគោរពរាប់អានលោកដែលជាប្រធាន ព្រមទាំងជឿស្ដាប់ពាក្យលោក, យ៉ាងនេះទើបនាំឲ្យកើតសេចក្ដីចំរើនតាមលំដាប់កាល ។

ត្រង់ធម៌ទី ៥– ក្នុងអដ្ឋកថា ពន្យល់ថា ភិក្ខុណាចេះតែដើរតាមស្នាម ជើងនៃពួកឧបដ្ឋាក គឺចេញពីស្រុកទៅកាន់ស្រុកព្រោះហេតុនៃចតុប្បច្ច័យ, ភិក្ខុនោះឈ្មោះថា លុះក្នុងអំណាចនៃតណ្ហា ។ ឯភិក្ខុក្រៅពីនោះ គឺភិក្ខុដែលមិនប្រព្រឹត្តដូចខាងលើនេះ ទើបឈ្មោះថា មិនលុះក្នុងអំណាចនៃតណ្ហា ។

ការមិនលុះក្នុងអំណាចនៃតណ្ហានោះ ពួកគ្រហស្ថក៏អាចប្រតិបត្តិបានឥតមានរើសអាក់អ៊ូទេ ព្រោះតណ្ហានេះជាហេតុឲ្យកើតអកុសលដែលជាមូលនៃសេចក្ដីទុក្ខ, បានសេចក្ដីថា កាលបើបុគ្គលប្រកបដោយតណ្ហាមានសេចក្ដីប្រាថ្នាដុតឲ្យក្ដៅអន្ទះអន្ទែងហើយ បណ្ដោយចិត្តឲ្យលង់ទៅតាមតណ្ហានេះ, ដល់ទីបំផុត នាំឲ្យហ៊ានប្រព្រឹត្តធ្វើវេរាទាំង ៥ ឥតញញើត ។ ម្យ៉ាងទៀត កាលបើបណ្ដោយឲ្យលុះលង់ទៅតាមតណ្ហា លុះមិនបានសមតាមប្រាថ្នាហើយ ក៏ត្រូវបានទុក្ខព្រួយផ្សេងៗ ទឹងប្រកប

ការងារណាមួយ ក៏មិនបានសេចក្ដីសុខ ព្រោះសេចក្ដីទុក្ខដែលកើតអំពីតណ្ហានោះចូលមកគ្របសង្កត់ ។

ព្រោះហេតុនោះ ពួកគ្រហស្ថគួរតែលះតណ្ហានេះឲ្យស្រាលខ្លះតាមទំនងដែលអាចធ្វើបាន ។

ត្រង់ធម៌ទី ៦–ក្នុងអដ្ឋកថា ពន្យល់ថា ភិក្ខុដែលអាស្រ័យនៅក្នុងសេនាសនៈក្នុងស្រុក ទុកជាបានឈានហើយក៏ដោយ វេលាចេញអំពីឈាននោះភ្លាម ក៏ឮសម្លេងស្ត្រីនិងបុរសជាដើម ជាហេតុនាំឲ្យគុណវិសេសដែលភិក្ខុនោះបានហើយ ប្រែជាសាបសូន្យបាត់ទៅវិញ ។ ឯភិក្ខុដែលនៅក្នុងសេនាសនៈក្នុងព្រៃ ទុកជាសិងលក់ហើយក៏ដោយ គ្រាន់តែភ្ញាក់ឡើងភ្លាមក៏ឮសម្លេងសត្វសីហៈ, សត្វខ្លានិងក្ងោកជាដើម បាននូវបីតិក្នុងព្រៃដោយអារម្មណ៍ណា, កាលពិចារណានូវអារម្មណ៍នោះទៅក៏អាចតាំងនៅក្នុងមគ្គផលបាន ។ អាស្រ័យហេតុយ៉ាងនេះ បានជាព្រះមានព្រះភាគទ្រង់សរសើរភិក្ខុដែលសិងលក់ក្នុងព្រៃ ថាគ្រាន់បើជាងភិក្ខុដែលបានឈានក្នុងសេនាសនៈក្នុងស្រុក ។ ព្រះសព្វញ្ញុពុទ្ធទ្រង់គាប់សេចក្ដីត្រង់នេះ ព្រះអង្គត្រាស់ថា ភិក្ខុចូលចិត្តអាស្រ័យនៅក្នុងសេនាសនៈក្នុងព្រៃ (ចាត់ជាអបរិហានិយធម៌ទី ៦ ) ។

សេចក្ដីប្រតិបត្តិត្រង់ស្ថាននេះ ជាកិច្ចលំបាកដល់ពួកគ្រហស្ថដែលនឹងប្រតិបត្តិបាន ព្រោះគ្រហស្ថនៅមានជាប់ជំពាក់ដោយកង្វល់ផ្សេង ៗ

ប៉ុន្តែប្រសិនបើអាចប្រតិបត្តិបាន ក៏ជាកិច្ចប្រសើរបំផុត, បើមិនអាចចូលទៅនៅក្នុងព្រៃទេ គ្រាន់តែស្វែងរកទីស្ងាត់ កាត់អាល័យឲ្យដាច់ពីពួកពីគណៈ ចូលវត្តអារាមសមាទានសីលស្ដាប់ធម៌ទេសនា ប៉ុណ្ណោះក៏ចាត់ថាជាផ្លូវប្រតិបត្តិដ៏ប្រសើររបស់គ្រហស្ថបានដែរ ។ បើមិនអាចធ្វើជាធុតង្គៈធ្វើក្នុងវេលាមានឱកាស សូម្បី ១ ថ្ងៃ ឬ ១ ពេលក៏បាន ព្រោះជាកិច្ចធ្វើចិត្តឲ្យស្ងប់រម្ងាប់បាតកង្វល់បានខ្លះដែរ ដើម្បីញុំាងចិត្តឲ្យធ្លាប់ ។

ត្រង់ធម៌ទី ៣– ក្នុងអដ្ឋកថា ពន្យល់ថា នេវាសិកភិក្ខុ គឺភិក្ខុដែលនៅជានិច្ចក្នុងអាវាស កាលបើមិនចង់ឲ្យសព្រហ្មចារីភិក្ខុមកកាន់អាវាសរបស់ខ្លួនទេ ត្រូវចាត់ថាជាអ្នកឥតមានសទ្ធា ឥតមានសេចក្ដីជ្រះថ្លា ។ នេវាសិកភិក្ខុនោះ ឈ្មោះថាកាត់ឃាត់ដំណើរ មិនឲ្យសព្រហ្មចារីភិក្ខុបានចូលមកកាន់ទីអាវាស ។ អាវាសយ៉ាងនេះ ជាអាវាសមិនមែនជាទីនៅអាស្រ័យរបស់ភិក្ខុទាំងឡាយដទៃ ។ ដូច្នេះ នេវាសិកភិក្ខុនោះនឹងត្រូវបានតែសេចក្ដីវិនាសមិនមានសេចក្ដីចំរើនឡើយ ព្រោះលែងបានឃើញពួកភិក្ខុដែលមានសីល លែងបានជួបនឹងលោកអ្នកចេះដឹង ដែលអាចកំចាត់បង់នូវសេចក្ដីសង្ស័យ ព្រមទាំងលែងបានស្ដាប់នូវធម៌ពីរោះផងទៀត ។ បើនេវាសិកភិក្ខុទាំងឡាយ មានបំណងចង់ឲ្យសព្រហ្មចារីទាំងឡាយ ដែលមិនទាន់មកឲ្យបានមកកាន់អាវាសរបស់ខ្លួន ដែលបានមកដល់ហើយឲ្យបាននៅជាសុខសួស្ដី គឺយកចិត្តទុកដាក់ចំពោះសព្រហ្ម-

ចារីភិក្ខុទាំងនោះឥតធ្វេសប្រហែស គាំងចិត្តគោរពចំពោះលោកជាថេរៈ គាំងចិត្តរាប់អានចំពោះលោកដែលមានវស្សាស្មើគ្នា ឬដែលក្មេងជាង ៗ

ភិក្ខុដែលអាស្រ័យនៅក្នុងវត្តនីមួយ ១ បើមានអធ្យាស្រ័យជាសប្បុរសប្រព្រឹត្តប្រតិបត្តិមិនឲ្យខាសនូវអបរិហានិយធម៌ ៧ នេះ ក៏នឹងកើតមានសេចក្តីចំរើនច្រើនយ៉ាងគឺ

១-- នាំឲ្យមានកេរ្តិ៍ឈ្មោះល្អខ្ចរខ្ចាយផ្សាយទៅគ្រប់ទិស;

២– នាំឲ្យមានមេត្រីភាពចំរើនឡើងរវាងភិក្ខុផងគ្នា;

៣– នាំឲ្យមានសាមគ្គីល្អគួរលាស់ចំរើនឡើងក្នុងពួកសង្ឃ;

៤– នាំឲ្យមានវត្តអារាមនីមួយ ១ បានជាទីនៅអាស្រ័យនៃភិក្ខុអ្នកមានសីល;

៥– នាំឲ្យព្រះពុទ្ធសាសនាមានដំណើរល្អទៅកាន់សេចក្តីចំរើន ៗ

ផ្លូវប្រតិបត្តិក្នុងស្ថាននេះ បើចំណែកខាងគ្រហស្ថវិញ គឺគាំងចិត្តឲ្យពួកជនជាសប្បុរសមកកាន់ទីលំនៅរបស់ខ្លួន ដើម្បីនឹងបានសន្ទនាជាមួយ ដើម្បីនឹងបានរួបរួមជាមួយ ៗ ឯការរួបរួមជាមួយនឹងពួកសប្បុរសនោះ ជាហេតុនាំឲ្យបានសម្រេចផល គឺសេចក្តីសុខនិងសេចក្តីចំរើនដោយពិត ៗ

## បប់ដោយសង្ខេប

# ការត្រាស់ដឹងនៃព្រះសម្ពុទ្ធ

ព្រះមហា ប៉ាង.ខាត់ រៀបរៀង

(តមក)

យើងបានឃើញថា ក្នុងយប់ដែលទ្រង់ត្រាស់ដឹង មានព្រឹត្តិការណ៍ធំ ៗ មួយខណ្ឌ ៗ ជាលំដាប់ ហើយមួយខណ្ឌ ៗ មានសេចក្ដីសំខាន់ ៗ ដ៏ក្រៃលែង មានសម្បូណ៌ភាពក្នុងខ្លួនឯង ធ្វើឲ្យយើងដឹងច្បាស់ថា ការត្រាស់ដឹងនោះជាកិច្ចការដ៏ធំក្រៃលែងបំផុត ៗ ការដែលព្រះសម្ពុទ្ធបានបំពេញប្តូមួយផលដែលកើតឡើង តាមលំដាប់នៃរាត្រីកាលដែលទ្រង់ត្រាស់ដឹងនោះ មានព្រឹត្តិការណ៍ធំក្រៃលែង តាំងតែពីបឋមយាមនៃរាត្រីជាដើមទៅ គឺទ្រង់បានចូលឈានជាន់ ៗ តាមលំដាប់ ហើយទ្រង់បានបញ្ញាខ្ពស់បំផុតហៅថា « ញាណ » ក្នុងបឋមយាមទ្រង់បានញាណមួយឈ្មោះ «បុព្វេនិវាសានុស្សតិញ្ញាណ ក្នុងមជ្ឈិមយាម ទ្រង់បានញាណទីពីរឈ្មោះ « ចុតូបបាតញ្ញាណ », ក្នុងបច្ឆិមយាម ទ្រង់បានញាណទីបីឈ្មោះ "អាសវក្ខយញ្ញាណ" ញាណទាំងបីនេះមានការសំខាន់ក្រៃលែង ព្រោះជាដើមហេតុ ដែលជាដំណើរទៅដល់ផលទីបំផុតគឺ អរិយសច្ច បានសេចក្ដីថា ការចេះដឹងអរិយសច្ចនេះ គឺជាផលនៃដើមលំពួរទេ បើយើងប្រៀបធៀបទៅផ្លែស្វាយដូចដែលយើងបានប្រៀបធៀបទុកមកហើយ ក៏អាចនឹងពោលបានថា បុព្វេនិវាសានុស្សតិញ្ញាណ "ជាតួដើមស្វាយ" ចុតូបបាតញ្ញាណ "ជាឫសគល់ដើមស្វាយ" អាសវក្ខយញ្ញាណ "ជាសាខា.

ដើមស្វាយ,, អរិយសច្ចជា "ផ្លែស្វាយ" ។

សេចក្តីដូចបានពោលមកនេះ ទើបយើងគួរនឹងសិក្សាការត្រាស់ដឹងរបស់ព្រះសម្ពុទ្ធឲ្យបានទូលាយបន្តិច ដោយយកញាណទាំងបីប្រការនេះមកជាវត្ថុធាតុសម្រាប់ពិចារណា ល្មមឲ្យយើងចូលចិត្តស្តាប់សេចក្តីបានព្រមទាំងមើលឲ្យឃើញ សេចក្តីសំខាន់ដ៏ក្រៃលែងក្នុងការត្រាស់ដឹងនោះថា "ការត្រាស់ដឹងនោះវិសេសដូចម្តេច" តទៅ យើងល្បងពិចារណាញាណទាំងបីប្រការដោយសង្ខេប :

**ក) បុព្វេនិវាសានុស្សតិញាណ** – នេះជាវិជ្ជាទីមួយដែលព្រះសម្ពុទ្ធទ្រង់បានរកឃើញក្នុងបឋមយាមនៃរាត្រីកាល គឺទ្រង់បានរកឃើញថា សារពើអ្វី ៗ តែងតែកើតចេញមកពីចំណែកប្រកប ៥ ប្រការដែលហៅថា "ខន្ធ" ។

ព្រះសម្ពុទ្ធទ្រង់ញែកធាតុខន្ធ ( Eléments ) ទុកមកជាមាន ៥ ប្រការ គឺ: ១ – រូបក្ខន្ធ ឬ រូបូបាទានក្ខន្ធ, ២ – វេទនាខន្ធ ឬ វេទនូបាទានក្ខន្ធ, ៣ – សញ្ញាខន្ធ ឬ សញ្ញូបាទានក្ខន្ធ; ៤ – សំខារក្ខន្ធ ឬ សំខារូបាទានក្ខន្ធ; ៥ – វិញ្ញាណក្ខន្ធ ឬ វិញ្ញាណូបាទានក្ខន្ធ ។

**១_ រូបខន្ធ** បានដល់កងរូប ដែលមានគ្រឿងប្រកប ២៨ យ៉ាង គឺ ធាតុ ( Substances ) ៤ យ៉ាង; អាយតនៈ ( sens ១០ យ៉ាង; ឥន្ទ្រិយ (Organes) ៥ យ៉ាង; លក្ខណាការ ៨ យ៉ាង, អាហារ ១ ។

ធាតុ ៤ បានដល់ បឋវីធាតុ ធាតុដី, អាបោធាតុ ធាតុទឹក, វាយោ-ធាតុ ធាតុខ្យល់, តេជោធាតុ ធាតុភ្លើង, អាកាសធាតុ ធាតុអាកាស សំដៅយកត្រឹមតែចន្លោះទទេនៅក្នុងកាយដូចប្រហោងមាត់ រន្ធច្រមុះ រន្ធត្រចៀក ជាដើម ។

អាយតនៈ ១០ បានដល់កាយតនៈខាងក្នុង ៦ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ហទយវត្ថុ, កាយតនៈខាងក្រៅ ៤ គឺ រូប សំឡេង ក្លិន រស ។

ឥន្ទ្រិយ ៣ បានដល់ ជីវិតិន្ទ្រិយ គឺកម្លាំងដែលធ្វើឲ្យជីវិតរស់នៅ (Energie) បុរិសិន្ទ្រិយ គ្រឿងសំគាល់ភាវៈជាប្រុស (Virilité) ឥត្ថិន្ទ្រិយ គ្រឿងសំគាល់ភាវៈជាស្រី (Féminité) ។

លក្ខណាការ ៩ បានដល់កាយវិញ្ញត្តិ ការចលនានៃកាយ; វចីវិញ្ញត្តិ ការនិយាយ; លហុតា ភាពស្រាល (Légèreté); មុទុតា ភាពទន់ភ្លន់ (Elasticité); កម្មញ្ញតា ភាពគួរពត់បាន (Souplesse); ឧបចយៈ ការចំរើនធំឡើង (Développement), សន្តតិ ការជាប់គ្នា (Durée); ជរតា ភាពទ្រុឌទ្រោម (Déclin); អនិច្ចតា ភាពមិនទៀង (Impermanence) ។

អាហារ ១ បានដល់ កវលិង្ការាហារ គឺអាហារដែលបរិភោគចូលទៅ (ក្នុងពុទ្ធសាសនាមាន ៤ ប្រការ គឺកវលិង្ការាហារ ដូចបាយ,..ផស្សៈ ការប៉ះពាល់ដោយកាយ; មនោសញ្ចេតនា ចិត្តនឹកប៉ង, វិញ្ញាណការដឹង ។:

២– វេទនាខន្ធ (Sensation) បានដល់ការដឹង តាមលក្ខណៈ ៣ ប្រការគឺ សុខវេទនា; ទុក្ខវេទនា; អសុខមទុក្ខវេទនា ។ បើចែកតាមកំណើតមាន ៦ យ៉ាងគឺ :

១ – ចក្ខុសម្ផស្សជាវេទនា ការដឹងដែលកើតមកពីការបានឃើញដោយភ្នែក;

២ – សោតសម្ផស្សជាវេទនា ការដឹងដែលកើតមកពីការបានឮដោយត្រចៀក;

៣ – ឃានសម្ផស្សជាវេទនា ការដឹងដែលកើតមកពីការដឹងក្លិនដោយច្រមុះ;

៤ – ជិវ្ហាសម្ផស្សជាវេទនា ការដឹងដែលកើតមកពីការភ្លក់រសដោយអណ្ដាត;

៥ – កាយសម្ផស្សជាវេទនា ការដឹងដែលកើតមកពីការប៉ះពាល់ដោយកាយ,

៦ – មនោសម្ផស្សជាវេទនា ការដឹងដែលកើតមកពីការដឹងដោយចិត្ត ។

៣– សញ្ញាខន្ធ (Perception) សញ្ញាសេចក្ដីសំគាល់ជាការដឹងដូចវេទនាដែរតែខ្ពស់ជាងវេទនា ឧទាហរណ៍ : កាលណាមានសំឡេងស្គរ

មកប៉ះត្រចៀក វេទនាមានអំណាចឲ្យដឹងត្រឹមតែថាមានសំឡេងមកប៉ះត្រចៀក តែទឹងដឹងថា សំឡេងនោះជាសំឡេងអ្វី មិនបានទេ ការសំគាល់ដឹងថា សំឡេងស្គរជាទីរបស់សញ្ញា ។ សញ្ញានេះចែកទៅជា ៦ ប្រការ តាមកំណើតដូចជាវេទនាដែរ ហៅថា ចក្ខុសម្ផស្សជាសញ្ញា សោតសម្ផស្សជាសញ្ញា ឃានសម្ផស្សជាសញ្ញា ជិវ្ហាសម្ផស្សជាសញ្ញា កាយ-សម្ផស្សជាសញ្ញា មនោសម្ផស្សជាសញ្ញា ។

៤_ សំខារខន្ធ (Propriété mentale) សង្ខារនេះ (បាលីលោកប្រើពហុវចនៈ) បានដល់គ្រឿងផ្សំតាក់តែង ដែលជាមូលហេតុធ្វើឲ្យកើតជីវិត ឯល្អ ឬអាក្រក់ ជានាទីរបស់កម្ម ចែកជា ៥២ ប្រការ រួមយកវេទនានឹងសញ្ញាចូលមកក្នុងសង្ខារនេះដែរ បើដកយកវេទនានឹងសញ្ញានេះចេញនៅសល់តែ ៥ គត់ :-

១៤ ប្រការជាធម៌គូនឹងគ្នាគឺ ហិរិ ខ្មាសបាប អហិរិកៈ មិនខ្មាសបាប; ឱត្តប្បៈ ខ្លាចបាប អនោត្តប្បៈ មិនខ្លាចបាប; អលោភៈ មិនលោភ លោភៈ លោភ; អទោសៈ មិនក្រោធ ទោសៈ ក្រោធ; វិរិយៈ ព្យាយាម ឧទ្ធច្ចៈ រវើរវាយ; ឯកគ្គតា ភាពមានចិត្តមាំ កុក្កុច្ចៈ ចិត្តអណ្តែតអណ្តូង; សទ្ធា ជំនឿ វិចិកិច្ឆា សេចក្តីសង្ស័យ;

២ ប្រការជាពួកកម្លាំង ហៅថា ឥន្ទ្រិយ គឺ ជីវិតិន្ទ្រិយ យកទាំងកម្លាំងកាយនឹងកម្លាំងចិត្ត ព្រមទាំងបញ្ញិន្ទ្រិយ, កម្លាំងបញ្ញាផង ។

១៦ ប្រការជាធម៌កណ្ដាលៗ គឺ ផស្ស: ការប៉ះពាល់, ចេតនា បំណង មនសិការ: ការធ្វើទុកក្នុងចិត្ត, វិតក្ក: ការត្រិះរិះ, វិចារ: ការពិចារ, បីតិ សេចក្ដីឆ្អែតចិត្ត, ឆន្ទ: សេចក្ដីពេញចិត្ត, តត្រមជ្ឈតា ដំណើរជាកណ្ដាល, កាយលហុតា ភាពស្រាលនៃកាយ, ចិត្តលហុតា ភាពស្រាលនៃចិត្ត, កាយមុទុតា ភាពទន់ភ្លន់នៃកាយ, ចិត្តមុទុតា ភាពទន់ភ្លន់នៃចិត្ត, កាយ-កម្មញ្ញតា ភាពគួរដល់ការពត់កាយ, ចិត្តកម្មញ្ញតា ភាពគួរដល់ការពត់ចិត្ត; កាយបាគុញ្ញតា ភាពជំនាញនៃកាយ, ចិត្តបាគុញ្ញតា ភាពជំនាញនៃចិត្ត ។

៧ ប្រការប្រព្រឹត្តទៅក្នុងការអាក្រក់ គឺ មោហ: សេចក្ដីវង្វេង; មាន: ការប្រកាន់ខ្លួន; ឥស្សា សេចក្ដីប្រណែន; ទិដ្ឋិ ការប្រកាន់មាំតាមគំនិតយល់ឃើញរបស់ខ្លួន; មច្ឆរិយ: សេចក្ដីកំណាញ់; ថីន: ភាពនៃចិត្តងងុយ; មិទ្ធ: ភាពនៃចិត្តងោក ។

១១ ប្រការប្រព្រឹត្តទៅក្នុងការល្អ គឺ អធិមោក្ខ: ការកាត់ចិត្ត (Fermeté); សតិ ការតាំងចិត្ត (Attention). កាយបស្សទ្ធិ ការស្ងប់កាយ; ចិត្តបស្សទ្ធិ ការស្ងប់ចិត្ត; សម្មាវាចា វាចាប្រពៃ; សម្មាកម្មន្ត: ការងារប្រពៃ; សម្មាអាជីវ: ការប្រកបអាជីពប្រពៃ, ករុណា សេចក្ដីអាណិត; មុទុតា ចិត្តទោទន់ កាយុជុកតា ភាពទៀងត្រង់នៃកាយ ចិត្តុជុកតា ភាពទៀងត្រង់នៃចិត្ត ។

៥_ វិញ្ញាណខន្ធ (Conscience) វិញ្ញាណក្នុងទីនេះសំដៅយកចិត្ត

ចែកទៅជាច្រើនប្រការ ក្នុងទីនេះ ចែកត្រឹមតែ ៨៩ ហើយលើកយកមកតែគោល ៗ ដើមដំបូង យើងចែកចិត្តជា ៣ ពួកគឺ

ពួកទីមួយ កុសលវិញ្ញាណ ចិត្តជាកុសល (Pensée méritoire)

ពួកទីពីរ អកុសលវិញ្ញាណ ចិត្តជាអកុសល (Pensée déméritoire)

ពួកទីបី អព្យាកតវិញ្ញាណ ចិត្តជាអព្យាក្រិត្យ (Pensée indifférente)

ពួកទីមួយបានដល់កុសលវិញ្ញាណ ចែកជាកាមាវចរកុសលចិត្ត ៨ ប្រការ, ជារូបាវចរកុសលចិត្ត ៥ ប្រការ; ជាអរូបាវចរកុសលចិត្ត ៤ ប្រការ, ជាលោកុត្តរកុសលចិត្ត ៤ ប្រការ, រួមត្រូវជា ២១ ប្រការ ។

ពួកទីពីរ បានដល់ អកុសលវិញ្ញាណ ចែកជា លោភសហគតចិត្ត ៨ ប្រការ; ជាបដិឃសម្បយុត្តចិត្ត ២ ប្រការ, ជាមោមូហចិត្ត ២ ប្រការ រួមជា ១២ ប្រការ ។

ពួកទីបី បានដល់អព្យាកតវិញ្ញាណ ចែកជាចំណែកធំ ពីរចំណែកទៅទៀត គឺជាវិបាក មួយចំណែក ជាកិរិយា មួយចំណែក ។ វិបាកចែកជា អកុសលវិបាកចិត្ត ៧ ប្រការ, ជាកុសលវិបាកចិត្ត ៨ ប្រការ; ជាសហេតុកកាមាវចរវិបាកចិត្ត ៨ ប្រការ, ជាអរូបាវចរវិបាកចិត្ត ៤ ប្រការ ជាលោកុត្តរវិបាកចិត្ត ៤ ប្រការ រួមត្រូវជា ៣៦ ប្រការ ។ ឯកិរិយា ចែកទៅជា អហេតុកកិរិយាចិត្ត ៣ ប្រការ, ជាសហេតុកកាមាវចរកិរិយាចិត្ត ៨

ប្រការ, ជា រូបាវចរកិរិយាចិត្ត ៥ ប្រការ, ជា អរូបាវចរកិរិយាចិត្ត ៤ ប្រការ រួមទៅត្រូវជា ២០ ប្រការ ។

ការសិក្សាយើងក្នុងទីនេះ មិនមែនសិក្សាធម៌ដោយល្អិតទេ ដែលលើកយកមកពោលនេះ គ្រាន់តែឲ្យឃើញថា បើយើងបានពិចារណា «ញាណទាំង ៣ ប្រការ» នោះ មួយម្ដងៗជាលំដាប់ទៅយើងនឹងឃើញច្បាស់ថា "ការត្រាស់ដឹង" នោះមានសេចក្ដីសំខាន់ក្រៃលែងឥតប្រៀបបាន ព្រោះខន្ធ ៥ ប្រការនេះជាវិជ្ជាគម្ពីរភាព ហៅថា បរមត្ថវិជ្ជា (Méta-physique) ព្រះសម្ពុទ្ធទ្រង់បានគន់គិតរកឃើញបរមត្ថវិជ្ជានេះពិតប្រាកដ ហើយចែករំលែកបញ្ញត្តដោយព្រះអង្គឯង ទាល់តែទ្រង់ឃើញច្បាស់ក្នុងព្រះទ័យថា នេះណា "ទ្រឹស្ដីដែលប្រើបាន" ទើបទ្រង់ចូលទៅកាន់ញាណទីពីរតទៅទៀត ។

**២) ចុតូបបាតញាណ** — ពាក្យនេះ ប្រែតាមសព្ទថាប្រាជ្ញាដែលតាមដឹងការចុតិនិងបដិសន្ធិនៃសត្វទាំងឡាយ បើនឹងហៅមួយទៀតថា «ទិព្វចក្ខុញាណ» ក៏បាន តែមិនមែនសំដៅសេចក្ដីថា «ភ្នែកទិព្វ» តាមទៅមើលឃើញដួងវិញ្ញាណហៀរហោះទៅកើតឯនេះឯនោះ ឬកើតជាយ៉ាងនេះយ៉ាងនោះទេ ។ ញាណទីពីរនេះ សំដៅសេចក្ដីថា ទ្រង់ឃើញកម្ម ទ្រង់ឃើញច្បាស់ថា «ការដែលមនុស្សឬសត្វអន្ទោលស្លាប់កើតមានសភាពផ្សេងៗគ្នា ល្អខ្លះ អាក្រក់ខ្លះ ទុក្ខខ្លះ សុខខ្លះ ទាំងអស់នេះសុទ្ធតែ

កើតមកដោយអំណាចកម្ម ដែលខ្លួនមនុស្សសត្វនោះៗ បានធ្វើទុកមកពីកាលមុន កម្មដែលសត្វបានធ្វើទុកពីភពមុន តែងឲ្យផលក្នុងភពនេះ កាលបើកម្មនេះមិនទាន់អស់ទៅដរាបណា សត្វតែងតែមានការកើតតទៅដរាបនោះ សេចក្តីទុក្ខលំបាកក៏តែងតែកើតមានឡើងជាធម្មតា បើមិនឲ្យមានទុក្ខលំបាក ក៏ត្រូវតែធ្វើកុំឲ្យកើតទៀត តែការដែលធ្វើមិនឲ្យកើតទៀតនោះត្រូវតែឲ្យកម្មនោះអស់ទៅ ការដែលធ្វើឲ្យកម្មអស់ទៅ ក៏ត្រូវបំពេញគុណគឺសេចក្តីល្អឲ្យច្រើនក្រៃលែងដែលនឹងអាចច្រើនបានហើយ លាងសំអាតកម្មដែលលាមកអាក្រក់ទាំងអស់របស់ចិត្តឲ្យអស់ទៅ ឲ្យនៅសល់តែក៏ដែលល្អបរិសុទ្ធប្រសើរ ធ្វើដូច្នេះ កម្មនោះនឹងអស់ទៅ មិននាំឲ្យទៅកើតទៀតទេ នេះហៅថា «និព្វាន» ។ ការគិតបែបនេះ កើតមានមកយូរហើយក្នុងលទ្ធិព្រាហ្មណ៍ ក្នុងកាលដែលព្រាហ្មណ៍បានកសាងព្រះព្រហ្មឲ្យកើតហើយបញ្ញត្តលទ្ធិ «អាត្មន» នេះឡើង គឺមនុស្សបែរគំនិតទៅគិតថា «កម្មនាំឲ្យមនុស្សនិងសត្វវិលវល់កើតស្លាប់» ត្រូវបំពេញតបៈត្រូវបំពេញយោគៈ ឲ្យទាល់តែបានផលសម្រេចគឺឲ្យត្ត «អាត្មន ឬ អត្តា» វិលត្រឡប់ចូលទៅរកព្រហ្ម ចូលទៅនៅក្នុងព្រហ្មដែលហៅថា «ព្រហ្មន» វិញទើបលែងកើតតទៅទៀត ។ ឯព្រះសម្ពុទ្ធ ទ្រង់មានសេចក្តីយល់ឃើញថា «អាត្មន ឬ អត្តា» នេះមិនមានទេ ការកុំឲ្យវិលវល់ស្លាប់កើតទៅទៀត ត្រូវធ្វើចិត្តឲ្យបរិសុទ្ធកុំឲ្យមានមន្ទិលសៅហ្មង ហើយកម្មអាក្រក់

កម្មល្អក៏អស់ទៅលែងបង្វិលមនុស្សសត្វឲ្យវិលវល់ស្លាប់កើតតទៀតហើយ នេះហៅថា « និព្វាន » មិនហៅថា « ព្រហ្មន៍ » ដូចលទ្ធិព្រាហ្មណ៍ទេ ។

និព្វានប្រែថា «រលត់» ព្រះសម្ពុទ្ធទ្រង់ប្រើជាន័យពីរយ៉ាង ន័យទីមួយថា ការរលត់កិលេសសេចក្ដីសៅហ្មងរបស់ចិត្តអស់ទៅ ហើយបានសម្រេចភាពជាព្រះអរហន្តហៅថា សឧបាទិសេសនិព្វាន គឺរលត់គ្រប់យ៉ាងនៅសល់តែកាយនិងជីវិត បានសេចក្ដីថា នៅមានជីវិតរស់នៅ អស់ទៅតែកិលេសសេចក្ដីសៅហ្មង និងហៅថា «កិលេសនិព្វាន» ក៏បាន, ន័យទីពីរថា ការរលត់ជីវិត គឺការរស់នៅនៃមនុស្ស បានសេចក្ដីថា ការស្លាប់អ្នករលត់កិលេសសេចក្ដីសៅហ្មងនោះ ឯង ឬ ការស្លាប់នៃព្រះអរហន្ត ស្លាប់បែបមិនកើតតទៅទៀត ហៅថា «អនុបាទិសេសនិព្វាន» គឺការរលត់អស់ទាំងអស់ រលត់ទាំងជីវិតវិញ្ញាណ រលត់ទាំងកិលេស ការរលត់អស់ទាំងអស់ ឬអនុបាទិសេសនិព្វាន នេះហៅមួយទៀតថា «ខន្ធនិព្វាន» បានសេចក្ដីថា «ការរលត់ខន្ធទាំង ៥» ឬនឹងហៅថា ខន្ធបរិនិព្វាន» ក៏បានដែរ ។ តទៅ ទ្រង់ចូលទៅដល់ញាណទីបីទៀត ។

**គ) អាសវក្ខយញាណ** – ញាណទីបីនេះ ទ្រង់ពិចារណាបដិច្ចសមុប្បាទ គឺហេតុនិងផលដែលទាក់ទងគ្នាដូចជាច្រវាក់ ព្រះសម្ពុទ្ធទ្រង់គន់គិតក្នុងញាណទីបីនេះថា «អ្វីជាហេតុរបស់អ្វី អ្វីជាផលតមកពីអ្វី» ទីបំផុតទ្រង់រកឃើញថា

អវិជ្ជា ជាហេតុឲ្យកើត សំខារ Agréyat ,

សំខារ ជាហេតុឲ្យកើត វិញ្ញាណ (Conscience )

វិញ្ញាណ ជាហេតុឲ្យកើត នាមរូប (Nom et forme )

នាមរូប ជាហេតុឲ្យកើត អាយតនៈ (Sens)

អាយតនៈ ជាហេតុឲ្យកើត ផស្ស (Contact)

ផស្សៈ ជាហេតុឲ្យកើត វេទនា (Sensation)

វេទនា ជាហេតុឲ្យកើត តណ្ហា (Désire)

តណ្ហា ជាហេតុឲ្យកើត ឧបាទាន (Attachement )

ឧបាទាន ជាហេតុឲ្យកើត ភព (Existence)

ភព ជាហេតុឲ្យកើត ជាតិ (Naissance )

ជាតិ ជាហេតុឲ្យកើត ជរា; មរណៈ, សោកៈ

(Chagrins) បរិទេវៈ ( Lamentation)

ទុក្ខ (Douleur) ទោមនស្ស (Mauvaise disposition de l'esprit ou isprit pervers),

ឧបាយាស (Désespoir) ។

(នៅមានត)

# វិធុរជាតក

(តមកចប់)

ពោធិសត្វស្ដាប់ហើយ ឆ្លើយថា បពិត្រមហារាជអើយ នាកាលចៅបុណ្ណកយក្ស គាត់ទៅលេងស្កានឹងមហាក្សត្រាធិរាជ ហើយគាត់ឈ្នះមហាក្សត្រានោះ គាត់នាំខ្ញុំមកជាតំណាងស្កា គាត់បានដោយនូវធម៌ មិនបានដោយនូវសហិចសហារឡើយ ។ ព្រះបាទពិរុណនាគរាជស្ដាប់ហើយ មានព្រះហឫទ័យនោះត្រេកអរក្រៃពេក ហើយដឹកដៃពោធិសត្វចូលទៅកាន់ឋាននាងវិមលាទេវី ហើយមានព្រះបន្ទូលប្រាប់ទៅនាងវិមលាទេវីថា ហៃនាងវិមលានាងអើយ នាងប្រាថ្នាចង់ស៊ីថ្លើមចៅវិធុរអ្នកប្រាជ្ញនោះ ឥឡូវនេះ ចៅមាណពនោះគាត់ទៅនាំមកដល់ពិភពយើងហើយ នាងអើយ ចូរនាងសូមសាច់នឹងថ្លើម នៃចៅវិធុរ អ្នកប្រាជ្ញនោះស៊ី តាមដោយនូវចំណង់នាងហោង នាងអើយ នាងៗនឹងបានយល់ចៅវិធុរអ្នកប្រាជ្ញនោះកម្រក្រៃក្រៃណាស់ ។ នាងវិមលាទេវី នាងទតយល់ពោធិសត្វហើយ នាងលើកអម្រាមដៃទាំង ១០ គ្រប់នូវក្រចកង៍ មានហឫទ័យប្រពៃត្រេកអរស្មោះសារក្រៃពេក ហើយមានព្រះសវនីយ៍ ទៅនឹងពោធិសត្វថា ហៃចៅវិធុរអ្នកប្រាជ្ញហើយ នាចៅមិនដែលបានដល់ពិភពនាគនេះ កាលបើចៅបានយល់ឥឡូវនេះហើយ ក៏ចៅគិតភ័យខ្លាចស្លាប់ឬអ្វី ទើបចៅមិនសំពះយើង ។ ពោធិសត្វស្ដាប់ហើយឆ្លើយថា ហៃសម្ដេចវិមលាទេវីអើយ

នាងខ្ញុំនឹងគិតភ័យខ្លាចស្លាប់ ក៏ខ្ញុំមិនសំពះនោះតែអង្គមានឡើយ ហើយខ្ញុំនេះសោតទេ ឧបមាដូចអ្នកទោសពេជ្ឈឃាដក៏បណ្តើរគាក្រោស អ្នកទោសនាំទៅសម្លាប់ហើយ ទើបហូតដាវគំរាមប្រើឲ្យសំពះ ទោះបើអ្នកនោះនឹងសំពះ ពេជ្ឈឃាតនោះនឹងលែងសម្លាប់អ្នកទោសនោះអង្កាលឡើយ សឹងតែសម្លាប់តាមដូចដែលហោង រីខ្លួនខ្ញុំនេះឧបមាដូច្នោះហោង ៗ ហៃសាធុសប្បុរសផងទាំងឡាយអើយ នាព្រះនាងវិមលាទើបទូលសួរទូលទៅពិធូរអ្នកប្រាជ្ញនោះដូច្នេះហោង ៗ អណ្តាប់នោះនាងវិមលាទើបយកទឹកគាងអប់ត្រឡប់ទូវគន្ធពិដោរឲ្យពោធិសត្វស្រង់ព្រះអង្គ ស្រង់ស្រេចហើយឲ្យព្រះពស្ត្រទិព្វព្រះអង្គស្លៀកស្រេច ឲ្យយកក្រវែះប្អូនចន្ទន៍ គ្រឿងគន្ធ-ពិដោរ ឲ្យព្រះអង្គលាបស្រេចហើយ ឲ្យព្រះអង្គគង់លើកំរាលទៀមចំព្រែព្រាំបទ្ទំប្រសើរហើយ យកបំណាំគោជនាគាហារ ទើបឲ្យព្រះអង្គសោយស្រេចហើយ ឲ្យប្រដាប់ទូវឆម្មាស្នាក្រោលទូវកំរាលទៀមចំព្រែព្រាំ សឹងដ៏ទិព្វទន់ល្មនប្រសើរហើយ ទើបគាពជនាអញ្ជើញពោធិសត្វឲ្យព្រះអង្គគង់លើគ្រែឆម្មាស្នា ហើយព្រះអង្គសម្តែងថ្វេងធម៌វិសេសទេសនាដាសណ្តាប់នៃព្រះបាទនាគរាជ និងនាងវិមលាទេវីនោះ មិនយល់ជាវៅពិធូរអ្នកប្រាជ្ញទេឡើយ យល់ហាក់ដូចកាលដំណើរព្រះពុទ្ធប្រសើរសំដែងថ្វេងធម៌វិសេសទេសនាដាសណ្តាប់ប្រាប់អ្នកផងទាំងឡាយនោះហោង ៗ កាលបើពោធិសត្វសំដែងថ្វេងធម៌ទេសនាស្រេចហើយ ឯព្រះបាទពិរុណនាគ-

ការនិងនាងវិមលាទេវី ផ្កាចសាចមាសប្រាក់កែវ សត្តបុត្តវត្ថុ បូជាធម៌ទេសនាពោធិសត្វនោះច្រើនក្រៃពេក ទើបព្រះបាទវរុណនាគរាជ និងនាងវិមលាទេវី មានព្រះបន្ទូលថា ហៃពៅវិធូរអ្នកប្រាជ្ញអើយ នាងប្រាថ្នាហៅសំដែងថ្លែងធម៌ទេសនានោះពីរោះឲ្យអញក្អប់ ហើយហៅ នាងធម៌ទេសនាហៅនេះឯងហើយ ជាថ្លើមនិងសាច់ហៅ យើងសុំហោង រីយើងបានសុំថ្លើមនិងសាច់ហៅនោះ ដ្បិតតែគុណហៅអន្ទួន(១)នាំហៅមកឲ្យយើង ក៏យើងនឹងឲ្យនាងឥរន្ទតីកូនក្រមុំយើងទៅជាប្រពន្ធហៅអន្ទួននោះ នាថ្ងៃនេះឯង ព្រះបាទវរុណនាគរាជមានព្រះបន្ទូលកំបាលនេះហើយ ទើបឲ្យនាងឥរន្ទតីទៅជាប្រពន្ធបុណ្ណកយក្ស កាលនោះឯងហោង ។ រីឯបុណ្ណកយក្សសោត មានចិត្តនោះត្រេកអរសាទរក្រៃពេក ស្រដីទៅនឹងពោធិសត្វថា ហៃពៅវិធូរអ្នកប្រាជ្ញអើយ នាអញបាននាងឥរន្ទតីជាប្រពន្ធអញនេះ ដ្បិតតែគុណហៅឯង ក៏អញនឹងឲ្យកែវមណីរត្ននេះទៅហៅ អញនឹងនាំហៅទៅកាន់ឥន្ទបត្តបុរីស្រីមហានគរនាថ្ងៃនេះឯងហោង ។ បុណ្ណកយក្សស្រដីម្ល៉ោះហើយ ហុចកែវមណីរត្នឲ្យទៅពោធិសត្វហើយ បុណ្ណកយក្សនិងនាងឥរន្ទតី ក្រាបលាព្រះបាទវរុណនាគរាជ និងនាងវិមលាទេវីស្រេចហើយ នាំពោធិសត្វទៅឡើងជិះលើមនោម័យ រីបុណ្ណកយក្សឯងជិះកណ្ដាល ឲ្យពោធិសត្វជិះមុខ ឲ្យនាងឥរន្ទតីជិះខាងក្រោយ បុណ្ណកយក្សបរសេះមនោម័យ ស្ទុះហោះទៅកាន់ឥន្ទបត្តបុរីស្រីមហានគរនោះឯង

១– "អន្ទួន" គឺជាឈ្មោះបុណ្ណកយក្ស ។

ហោង ៗ នាចិត្តមនុស្សផងសព្វថ្ងៃនេះ ចាប់ពីគិតនឹងទៅឯណាៗហើយ គឺវិញ្ញាណចិត្តនោះទៅត្រង់នោះ មួយរំពេចនោះឯង រីឯកម្លាំងមនោម័យរត់ស្រូតឆាប់ក្រៃលើសលែង ទើបចិត្តមនុស្សផងទាំងឡាយនោះហោង ៗ គាថានោះបុណ្ណកយក្ខ រមិលទៅយល់កំពែងប្រាការខ្លោងទ្វារគោបន្ទាយឥន្ទបត្តបុរីស្រីមហានគរនោះហើយ ស្រដីទៅនឹងពោធិសត្វថា ហៃចៅពិធុរអ្នកប្រាជ្ញអើយ ចូរហោរមិលមើលទៅឥន្ទបត្តបុរីស្រីមហានគរយល់ជាក់ច្បាស់ប្រាកដហើយចៅអើយ ទៅមើលមួយឧទ្ទនៃទេវឡាន ព្រៃស្វាយនោះយល់ទុំទងគុម្ពល្វៀយុលមកជាក់ប្រាកដ ហៃចៅពិធុរអ្នកប្រាជ្ញអើយ អញបានប្រពន្ធថ្ងៃនេះឯងប្រសើរក្រៃពេក ឯចៅនឹងបានទៅដល់យល់ ប្រពន្ធកូន ចៅ ផ្ទះសម្បែងលំនៅឋានវៅនោះឯងហោង ៗ ឧម្ភសុរ ឧ-តារណ្ហំ ធិដ្ឋិតំ ៗ នេះទើងស្រដីកណ្ដាកាលព្រះបាទពារុណនាគរាជ និងនាងវិមលាទៅស្ដាប់ធម៌ទេសនាពោធិសត្វមិញចប់នូវប្រការអំបាលនោះហោង ៗ

តស្មិំ ខណេ និរោស បច្ចូសកាលេ រជា សុបិនំ អទ្ទស ៗ

ឮដល់កាលថ្ងៃនោះឯង ព្រះសុរិយារះឡើង ឯព្រឹកព្រហាមព្រះបាទធនញ្ជយ-កោរព្យរាជ ព្រះអង្គជួយយល់សប្ដិហាក់ដូចមានឈើធំនោះ គឺប្រាជ្ញាទៅពិធុរអ្នកប្រាជ្ញមានមែកនោះ ៤ គឺសីល ៥ មានផ្លែនោះប្រកបនឹងទៅនូវរសប្រាំប្រការ រីដើមឈើនោះសោតជាមួយត្រូឈើនឹងត្រៃឈើ ដ៏មានជំរំគោក្របីផងពឹងរាក់សំណាក់អាស្រ័យក្រោមដើមឈើនោះពុំឆ្ងាយនឹងព្រះរាជវាំងឡើយ

ម្នោះហើយ ហាក់ដូចមហាក្សត្រាធិរាជ នូវអស់មហាជនផងទាំងឡាយ
តែងគោរពប្រណិប័តន៍ បូជាសក្ការផងដ៏ច្រើន ហើយយល់ហាក់ដូច
មានបុរស ១ ខ្មៅ ស្រមកស្លៀកសំពត់ក្រហមហើយសៀតផ្កានៅត្រចៀក
ទាំងសងខាង ដ៏មានដៃកាន់និទៅនូវគ្រឿងអាវុធ មុតថ្លាសស្រស្បាង កាត់
ទន្ទាំលលាំចូលមក អស់មហាជនផង សឹងដ៏ស្រែកយំ ហើយបុរសនោះ
កាត់ដើមឈើនោះនាំយកចេញទៅ ហើយនាំមកតម្កល់ទុកដូចដែលវិញ
ហើយបុរសនោះ ក្រឡាប់វិលទៅវិញហោង ៗ កជា តំ សុបិនំ
បរិក្កហិត្វា ៗ មហាក្សត្រាធិរាជព្រះអង្គតើនឡើងហើយ ទ្រង់
ព្រះចិន្តាពិចារណាថា នាដើមឈើធំនោះ មិនគឺអ្វីឡើយ គឺទេវពិជូរអ្នក
ប្រាជ្ញ វិមែកទាំង ៥ នោះ គឺ សីលទាំង ៥ ដ៏មានផ្លែផ្កានោះ គឺព្រះធម៌
ទេសនា មូបសាខានោះ គឺប្រាជ្ញា អស់ដីរ គោ ក្របី តែងនឹងចូល
ពឹងពាក់ សំណាក់នៅនោះ គឺមហាក្សត្រ ១ រយ និងមួយ នូវអស់មុខ
មន្ត្រី សេនាបតីមហាជនផងទាំងឡាយ តែងនឹងចូលមកស្ដាប់ព្រះធម៌
វិសេសទេសនាតែសព្វថ្ងៃហោង ៗ មហាក្សត្រទ្រង់ព្រះចិន្តាស្រេច
ហើយ មានព្រះរាជហឫទ័យ ត្រេកអរក្រៃពេក ម្នោះហើយស្ដេចឲ្យបុក
ចាំងប្រាប់រាជទូវនាមុខព្រះលាន ហើយប្រជាប់នូវកំពលចៀមចំ ព្រៃព្រំ
ស្រេចហើយ ស្ដេចលីលាទៅកាន់ធម្មសភាសាលា មានស្ដេចមួយរយ
និងមួយនូវអស់ពពួកអាមាត្យផង ច្រើនហាមរោមដាបរិវារ ហើយស្ដេច

មានព្រះបន្ទូលលោមអស់មហាជនផងទាំងឡាយថា ម្នាលអស់អ្នកទាំង-ឡាយអើយ អ្នកទាំងឡាយ កុំគិតថប់បារម្ភយំសោកទៅពិធូរអ្នកប្រាជ្ញឡើយ អ្នកទាំងឡាយ នឹងបានយល់ទៅពិធូរអ្នកប្រាជ្ញ ក្នុងថ្ងៃនេះឯងហោង ៗ មហាក្សត្រ មានព្រះបន្ទូលម៉្លោះហើយ ព្រះអង្គគង់ទន្ទឹងមើលផ្លូវពោធិសត្វទីងលីលាមកនោះហោង ៗ បុណ្ណកោបិ បណ្ឌិតំ ឱតារេត្វា ធម្មសភាយ ទ្វារេ បរិសមជ្ឈេ ឋបេត្វា ៗ ក្នុងកាលនោះបុណ្ណកយក្សនាំពោធិសត្វទៅដាក់ នាកណ្តាលជំនុំបរិស័ទផងទៀបទ្វារធម្មសភាសាលានោះហើយ បុណ្ណកយក្សនាំនាងឥរន្ទតី ទៅនគរអាត្មាវិញហោង ៗ រាជាបិ តំ ទិស្វា បរមប្បតីតោ ឧដ្ឋាយ ពាហាហិ បលិស្សជិត្វា ៗ បណ្តាប់នោះ ព្រះបាទធនញ្ជ័យកោរព្យរាជ យល់ពោធិសត្វមកដល់ដូច្នោះហើយ ស្តេចមានព្រះហឫទ័យនោះត្រេកអរសោទរត្រេកពេក ហើយងោះឡើងលែងអាស្នាទៅបះបោសអង្អែលពោធិសត្វ នាកណ្តាលជំនុំអស់ស្តេចមួយរយឯងមួយ ទូវអស់ពពួកមុខមន្ត្រីសេនាបតីផង ហើយនាំពោធិសត្វនោះមកអង្គុយនាកំពលអាស្នាចំពោះព្រះភក្ត្រមហាក្សត្រនោះហើយ មានព្រះបន្ទូលទៅកាន់ពោធិសត្វថា ហៃពៅពិធូរអ្នកប្រាជ្ញអើយ រីខ្លួនពៅនេះ ចបមាប់ដូចខេះ គេយកទៅពោលបាត់បង់លង់ ទើបគេនាំមកទុកវិញដូចដែល រីពៅមកនេះ កើតមានអំណរ អស់អ្នកនគរផង សឹងត្រេកអរសោទរ ដ្បិតតែបានយល់មុខ

ទៅ។ ហៃទៅពិធូរអ្នកប្រាជ្ញអើយ ទៅធ្វើទូវអំពើដូចម្ដេច ក៏ចៅបានរួច អំពីកណ្ដាប់ដៃនៃចៅមាណពនោះ ហ៎ៈ ចូរទៅសំដែងថ្លែងប្រាប់អញ ហោង ៗ អជ ធំ មហាសេត្តា ៗ ពោធិសត្វ ស្ដាប់ហើយ ថ្វាយបង្គំប្រណម្យទូលថា បពិត្រព្រះនរបតីស្រីសម្មតិទេព មហារាជ-ក្សត្រថ្លៃប្រសើរអើយ នាចៅមាណពនោះ មិនអ្វីជាមនុស្សវិស័យ ឡើយ ព្រះអង្គបានឮបានដឹងឬទេ រីយក្ខនោះឈ្មោះបុណ្ណកយក្ខ គាត់ ជាក្មួយ ព្រះបាទវេស្សវណកុវេរមហារាជ ហើយមានស្ដេចនាគ ១ ឈ្មោះ ព្រះបាទពិរុណនាគរាជ មានអានុភាពនោះច្រើន មានព្រះរាជទេពីមួយ ឈ្មោះ នាងវិមលាទេវី មានកូនក្រមុំ ១ ឈ្មោះ នាងឥរន្ទតី រីព្រះបាទ ពិរុណនាគរាជនោះ ដែលមកចាំសីលនៅមនុស្សលោកនេះមួយអន្លើ នឹង ព្រះអង្គឯង កាលនោះមានចិត្តត្រេកអរសាទរ នឹងធម៌ទេសនាខ្ញុំ យក កែវមណីគេន្ទ បូជាខ្ញុំហើយ ទៅកាន់ពិភពនាគនាយវិញហោង ទើបនាង វិមលាទេវី នាងដណ្ដឹងថា បពិត្រមហារាជអើយ នាកែវមណីគេន្ទនោះ តើបាត់ទៅឯណា ក៏មិនឃើញ ៗ ឯព្រះបាទពិរុណនាគរាជ សរសើរប្រាប់ អំពីធម៌ទេសនាខ្ញុំហើយ ក៏យកកែវមណីគេន្ទនោះបូជាខ្ញុំហោង រីនាងវិមលា ទេវីនោះ នាងចង់ស្ដាប់ធម៌ទេសនាខ្ញុំហើយ នាងបង្កើតចំណង់ចង់ស្ដាប់ ធម៌ រីឯព្រះបាទពិរុណនាគរាជ ហេតុតែកំណាន់កាន់ខុសមានបន្ទូលទៅនឹង នាងឥរន្ទតី ថាហៃនាងឥរន្ទតីអើយ រីម្ដាយនាងនោះមានចំណង់ចង់ស៊ី

ថ្លើម ទៅពិធូរអ្នកប្រាជ្ញ ចុះនាងទៅស្វែងរកប្ដីឲ្យគេទៅស្វែងរកថ្លើមទៅ ពិធូរអ្នកប្រាជ្ញនោះនាំមកហោង ។ រីនាងឥរន្ទតី នាងស្វែងរកប្ដីនោះ ទៅយល់យក្សមួយ ជាក្មួយវេស្សវណ្ណកុវេរមហារាជ នាងដឹងថាយក្សនោះ ស្រឡាញ់នាងហើយ នាងនាំយក្សនោះទៅកាន់ព្រះបិតានាង ។ រីព្រះបាទ វរុណនាគរាជនោះ មានព្រះបន្ទូលទៅនឹងបុណ្ណកយក្សថា ហៃវរមាណព អើយ ថាបើទៅអាចទៅយកថ្លើមទៅពិធូរអ្នកប្រាជ្ញនោះមកឲ្យយើងហើយ យើងនឹងឲ្យនាងឥរន្ទតី កូនក្រមុំយើងជាប្រពន្ធទៅហោង ។ រីឯបុណ្ណកយក្ស នោះសោត ទៅយកកែវមណីរតន៍ ជាគ្រឿងប្រដាប់នៃមហាចក្រពត្តិ-រាជទុកនៅក្នុងវេបុល្លបព៌ត យកមកលេងស្កា នឹងមហារាជនោះឯង លុះបុណ្ណកយក្ស ឈ្នះមហារាជហើយ ក៏នាំខ្ញុំទៅ ឲ្យខ្ញុំមកកាន់កន្ទុយសេះ ហើយបរទៅក្នុងព្រៃភ្នំ នឹងឲ្យខ្ញុំរណ្ដំនឹងថ្មឲ្យខ្ញុំស្លាប់ ដ្បិតនឹងចង់សម្លាប់ខ្ញុំ យល់មិនស្លាប់ឡើយ បរសេះទៅកាន់ខ្យល់ខ្ទាត ដ៏មានកំពស់នោះ ៧ ជាន់ ហើយយកដាក់ខ្ញុំលើភ្នំកាឡាគិរី ដ៏មានកំពស់ ៦១ យោជន៍ហើយ និម្មិតកាយាជារាជសីហ៍ ដំរីស្រែកសន្ធាប់ ហើយដំណែងជានាគជាយក្ស បោះបោលខ្ញុំនឹងឲ្យខ្ញុំស្លាប់ ទើបខ្ញុំដណ្ដឹងទៅបុណ្ណកយក្ស ៗ នោះ ប្រាប់ខ្ញុំ អស់សេចក្ដីហើយ ខ្ញុំសម្ដែងថ្វែងសាធុនធម៌ ជាសណ្ដាប់នៃបុណ្ណកយក្ស នោះ លុះបានស្ដាប់ធម៌ខ្ញុំហើយ មានចិត្តនោះត្រេកអរសាទរនឹងខ្ញុំហើយ នឹងនាំខ្ញុំមកកាន់ឥន្ទបត្តបុរី ស្រេចហាននគរវិញហោង ។ អណ្ដាប់នោះ

ខ្ញុំឲ្យបុណ្ណកយក្ខ នាំខ្ញុំទៅកាន់ពិភពនាគនាយ លុះខ្ញុំបានសម្ដែង ថ្វាយធម៌ទេសនាជាសណ្ដាប់នៃ ព្រះបាទពិរុណនាគរាជ និងនាងវិមលាទេវី សឹងដ៏មានចិត្តនោះត្រេកអរសោទរ និងចង់ស្ដាប់ធម៌ទេសនាខ្ញុំហើយ ព្រះបាទពិរុណនាគរាជ ឲ្យនាងឥរន្ទតីជាប្រពន្ធបុណ្ណកយក្ខហោង ៗ រីឯបុណ្ណកយក្ខ កាលណាបើបាននាងឥរន្ទតីហើយ ក៏មានចិត្តនោះត្រេកអរសោទរក្រៃពេក យកកែវមណីត្របូជាខ្ញុំ ហើយនាំខ្ញុំមក បុណ្ណកយក្ខ ជិះកណ្ដាលឲ្យខ្ញុំជិះឯមុខ នាងឥរន្ទតី ជិះឯក្រោយ ហើយនាំខ្ញុំមកដាក់នាកណ្ដាលជំនុំ ហើយបុណ្ណកយក្ខ នាំនាងឥរន្ទតី ទៅកាន់នគរអាត្មាឯងហោង ៗ បពិត្រមហារាជអើយ នាបុណ្ណកយក្ខនោះសង្ហាតទុហាតទឹងសម្លាប់ខ្ញុំនេះ ដ្បិតតែចង់បាននាងឥរន្ទតី នោះឯងហោង នាខ្ញុំបានកែវមណីរតន៍នោះអំពីបុណ្ណក-យក្ខនោះប្រសើរក្រៃពេក សូមទានមហារាជទទួលយកកែវនេះហោង ៗ ពោធិសត្វ ថ្វាយកែវមណីរតន៍នោះទៅព្រះបាទធនញ្ជយកោរព្យរាជ ។ មានព្រះបន្ទូលប្រាប់អស់មហាជនពស្ត្រផងទាំងឡាយថា នាកាលហៀបទៀបទឹងបែក បច្ចូសរះឡើងនោះ អញយល់សប្តិហាក់ដូចមានដើមឈើធំមានមែកនោះ ៤ កើតមាននាងក្រៅទៀបទ្វាររាំងអញ ដើមឈើនោះសោតប្រកបនូវផ្លែផ្កាជាផលប្រយោជន៍ ហើយមានដំរីសេះនូវត្បូងត្រីផង សំពប់ដើមឈើនោះ ហើយយល់ដូចបុរសខ្មៅម្នាក់ស្លៀកសំពត់ក្រហមសៀតផ្កា នៅត្រចៀក ហើយមកកាត់យកដើមឈើនោះ យកទៅបន្តិចហើយនាំ

មកវិញ នាដើមឈើនោះ គឺតួចៅពិធូរអ្នកប្រាជ្ញនេះឯង អ្នកឯណាមួយ
បើមានចិត្តនោះ គោរពអំពុងត្រេកអរទើងចៅពិធូរអ្នកប្រាជ្ញនេះហើយ ឲ្យ
ទ្រព្យរបស់ទទៃ ៗ តាមតែសទ្ធា មកបូជាដើមឈើនេះឯង គឺតួចៅពិធូរ
អ្នកប្រាជ្ញហើយ សត្វឯណាមានទោសក្នុងព្រះនគរនេះ ទោះនៅក្នុងទ្រុង
ច្រួលច្រវាក់ អន្ទាក់ដែលខ្នោះឃ្នាងតាន់ក៏នផងទាំងឡាយឲ្យដោះស្រាយ
អំពីទុក្ខភ័យពីថ្ងៃនេះឯងកុំឲ្យសំណល់ដល់តិចឡើយ ហើយអស់អ្នកនគរ
ផង ឲ្យលះបង់នូវខគ្គលនោសំបុរានទៃមួយ ហើយឲ្យនាំនូវចំណីអាហារ
បាយទឹកផងឲ្យព្រាហ្មណាចារ្យផងទាំងឡាយ បរិភោគឲ្យឆ្អែតស្កប់ស្កល់
ហើយឲ្យស្រាបាយអស់ពលផងទាំងឡាយ រាំផឹករាំស៊ីឲ្យឆ្អែត ហើយ
ឲ្យលេងនូវល្បែងមហោស្រព កុំបីឲ្យបៀតបៀនគ្នាទៅវិញទៅមកឡើយ
កាលនោះអស់អ្នកនគរផងទាំងឡាយ កាលបើបានឮព្រះបន្ទូល មហា-
ក្សត្រនោះហើយ សឹងតែប្រដាប់ប្រដាចំណីភោជនាហារស្រាបាយ មក
ផឹកស៊ីហើយ ប្រមូលគ្នាលេងនូវល្បែងមហោស្រព ជាគំរប់ខែមួយហើយ
ជាសូរេចហោង៍ រីពោធិសត្វ ធ្វើបុណ្យឲ្យទានចាំសីល ចំរើនមេត្តាភាវនា
សំដែងថ្ងៃធម៌ទេសនាជាសណ្ដាប់ មហាក្សត្រាធិរាជនូវអស់មហាជនផង
ទាំងឡាយ ដរាបលុះអស់ព្រះជន្ម ព្រះអង្គបានទៅកើតនៅសួគ៌ាទិព្វលោក
នាយហោង៍ ៗ រីមហាក្សត្រាធិរាជ នូវអស់មហាជនផងទាំងឡាយ សឹង
លុះដោយនូវដំបូន្មានពោធិសត្វហើយ សឹងសន្សំតទុបាតធ្វើបុណ្យ ឲ្យ

ទានបាំសីល ព្យាយាមចំរើនមេត្តាភាវនា ដរាបអស់អាយុទៅ ។ សឹងបាន
ទៅកើត នៅនាសួគ៌ទេពលោកនាយនោះ ប្រាកដហោង ។ រីព្រះជិនជា
គ្រូព្រះអង្គនាំធម៌ទេសនានោះ មកសំម្ដែងថ្លែងប្រាប់អស់ភិក្ខុផងទាំងឡាយ
ថាម្នាលភិក្ខុផងទាំងឡាយអើយ នាអញតថាគត ប្រកបខ្លួនប្រាជ្ញា មិន
ប៉ុន្តែឥឡូវនេះទេឡើយ កាលជាពោធិសត្វនៅឡើយ សឹងមានប្រាជ្ញាឆ្លាស
ខ្លួនអធិប្បាយផងទាំងនេះឯង ព្រះអង្គបន្ទូលម៉្លោះហើយ ព្រះអង្គឧប
ក្រសោប អស់សន្តានធម៌ផងទាំងពួង មកផ្ដុំព្រះជាតក ហើយព្រះអង្គ
បន្ទូលថាហៃភិក្ខុផងទាំងឡាយអើយ នាព្រះមាតាបិតាពោធិសត្វនោះ គឺ
ចេរវិលវិលមក បានជាត្រកូលស្ដេចធំនេះឯងហោង រីប្រពន្ធពោធិសត្វជា
ច្បង អស់ភរិយាផងទាំងឡាយនោះ គឺព្រះមាតានៃរៅរាហុលកុមារនោះ
ហោង រីរៅធម្មបាលរាជបុត្រច្បងពោធិសត្វនោះ គឺចេរវិលវិលមកជារៅ
រាហុលនោះឯង រីនាងវិមលាទេវី គឺចេរវិលវិលមកជានាងឧប្បលពណ៌វិញ
រីព្រះបាទពិរុណនាគរាជ គឺចេរវិលវិលមកបានជាព្រះមហាសារីបុត្តត្ថេរ
រីព្រះបាទសុបណ្ណគ្រុឌរាជ គឺចេរវិលវិលមកបានជាព្រះមហាមោគ្គល្លានត្ថេរ
រីសម្ដេចសក្រទេវរាជ គឺចេរវិលវិលមក បានជាអនុរុទ្ធត្ថេរ រីព្រះបាទ
ធនញ្ជយកោរព្យរាជ គឺចេរវិលវិលមកបានជាព្រះមហាអានន្ទត្ថេរ រីអស់
បរិស័ទផងទាំងឡាយ សំណល់សែននោះ គឺចេរវិលវិលមកបានជាបរិស័ទ
ព្រះពុទ្ធកាលឥឡូវនេះឯងហោង រីទៅពិធូរអ្នកប្រាជ្ញនោះសោតគឺអង្គអញ

តថាគតនេះឯង មកត្រាស់ប្រាជ្ញាសារៈពេជ្ញតាញាណ ដាក់ប្រាកដនូវធម៌ទាំង ៨ ម៉ឺន ៤ ពាន់ខន្ធនូវព្រះគម្ពីរជាពំនាក់ ព្រះត្រៃបិដកទាំង ៣ នោះហោង ៗ ភោ សាធវោ ហៃសាធុសប្បុរសជនទាំងឡាយអើយ នូវសប្បុរសបុគ្គលឯណាមួយ ប្រាថ្នាសម្បត្តិសួគ៌ សម្បត្តិនិព្វាន ដ៏ជាស្ថានបរមសុខប្រសើរ ឲ្យអ្នកនោះសង្វាតឧស្សាហ៍រៀនសូត្រស្ដាប់ត្រាប់ត្រងរង សោតាប់ធម៌ប្រសើរ គឺនិយាយនិទាន ព្រះពុទ្ធជាតកនេះហើយ អ្នកនោះនឹងបានសម្រេចបរិបូណ៌ដូចសេចក្ដីប្រាថ្នាអ្នកនោះទៀងប្រាកដហោង ៗ វិធុរជាតកំ និដ្ឋិតំ ៗ រីឯពណ៌នាសរសើរនិយាយនិទាន ព្រះពុទ្ធជាតកជាគំរប់ ៦ ជាតិនេះមិញ គឺតិបការជាស្រេចនូវប្រការអម្បាលនេះហោង ៗ

វិធុរបណ្ឌិតជាតកចប់ ៗ

មានប្រយោជន៍អ្វី ចំពោះកូនដែលកើត
ហើយល្ងង់ផង មិនប្រកបដោយធម៌ផង
ដូចក្អែកឈើមានប្រយោជន៍អ្វី បានគ្រាន់
តែឈើ ចាក់ដោតនាំឲ្យវិនាសប៉ុណ្ណោះ ៗ

ស្រីហិតោបទេស

# សុខមូលកធម៌

ភិក្ខុឧបសោភោ ញ៉ែម-នី កុដិលេខ ២៦ វត្តសាភារ័ង

រៀបរៀង

ធម៌ជាហេតុនាំឲ្យកើតសេចក្ដីសុខនេះ ព្រះសម្ពុទ្ធទ្រង់បានសំដែងទុកជាច្រើនបែប ៖

កន្លែងខ្លះ បានសំដែងថា „សុខោ បុញ្ញស្ស ឧច្ចយោ ការសន្សំនូវបុណ្យ ជាហេតុនាំមកនូវសេចក្ដីសុខ" ។

កន្លែងខ្លះ បានសំដែងថា „សុខោ ពុទ្ធានមុប្បាទោ កិរិយាកើតឡើងនៃអ្នកប្រាជ្ញទាំងឡាយ ជាហេតុនាំឲ្យកើតសេចក្ដីសុខ" ។

កន្លែងខ្លះ បានសំដែងថា „សុខា សទ្ធម្មទេសនា ការសំដែងនូវព្រះសទ្ធម្ម ជាហេតុនាំឲ្យកើតសេចក្ដីសុខ" ។

កន្លែងមួយទៀតបានសំដែងថា „សុខា សង្ឃស្ស សាមគ្គី ការព្រមព្រៀងគ្នានៃពួកក្រុម ជាហេតុនាំមកនូវសេចក្ដីសុខ" ។

តែ, ដើម្បីតម្រូវតាមសេចក្ដីត្រូវការនៃប្រទេសកម្ពុជា នាបច្ចុប្បន្នសម័យ ជាចាំបាច់ ហើយជាបន្ទាន់ផងនោះ ព្រះពុទ្ធដីកាបីវគ្គខាងដើមមិនបានអធិប្បាយក្នុងឱកាសនេះទេ សូមលើកយកតែមួយវគ្គខាងចុងមកធ្វើអត្ថាធិប្បាយ គឺត្រង់វគ្គថា "សុខា សង្ឃស្ស សាមគ្គី" ។

ពាក្យថា "សុខ" ប្រែថា "ធម្មជាតិងាយអត់ទ្រាំ" បើប្រែយកសេចក្ដីថា "ងាយទាំងសព្វ" គឺងាយប្រកបការងារកម្ម; ងាយធ្វើគមនាគមន៍ទាក់ទងគ្នាទៅវិញទៅមក; ងាយក្នុងការបំពេញករណីយកិច្ច; ងាយក្នុងការគ្រប់គ្រងពួកក្រុម; ងាយក្នុងការលក់ចេញទិញចូល ។ល។ បានសេចក្ដីថា ងាយសព្វបែបសព្វយ៉ាង គ្មានពិបាកក្នុងរឿងអ្វីមួយឡើយ ដូច្នេះហៅថា "សុខ" ។ តែសុខក្នុងអត្ថបទនេះត្រូវប្រែថា នាំមកនូវសេចក្ដីស្រួលងាយ; ជាហេតុឲ្យកើតសេចក្ដីសុខ; ជាដើមចមនៃសេចក្ដីសុខ ជាមូលដ្ឋាននៃសេចក្ដីសុខ; ជាមេកសាងនូវសេចក្ដីសុខស្រួលងាយដល់ក្រុម សង្គមគ្រួសារ ។

សេចក្ដីសុខនេះចែកជាប្រភេទដោយសង្ខេបមាន ៣ យ៉ាងគឺ

១- កាយិកសុខ សុខប្រព្រឹត្តទៅក្នុងកាយ ។

២- វាចសិកសុខ សុខប្រព្រឹត្តទៅក្នុងវាចា ។

៣- ចេតសិកសុខ សុខប្រព្រឹត្តទៅក្នុងចិត្ត ។

ការងាយស្រួលក្នុងការដើរ ឈរ អង្គុយ ដេក ងាយក្នុងការបរិភោគប៉ុណ្ណោះជាដើមហៅថា "កាយិកសុខ" សុខប្រព្រឹត្តទៅក្នុងកាយ ។

ងាយពោល ងាយនិយាយ; ងាយប្រកាសឃោសនាឲ្យដំណឹងដល់ពួកក្រុម; ងាយដោយការធ្វើក្បួនច្បាប់, ងាយក្នុងការសរសេរ

របនាអត្ថប៉ុណ្ណោះជាដើមហៅថា "វិបសិកសុខ" សុខប្រព្រឹត្តទៅក្នុងកាយ ។

ការស្រួលចិត្ត មានចិត្តរីករាយសប្បាយ មានចិត្តត្រជាក់ត្រជុំ មិនមានទោមនស្សទាស់អធ្យាស្រ័យអាក់អន់ស្រពន់ចិត្ត មិនមានការក្រហល់ក្រហាយពេលពលអន្ទះសាក្នុងចិត្ត ព្រោះមិនមានឧបសគ្គខាងក្រៅមកធ្វើឲ្យកករល្អក់ ជាចិត្តស្រស់បំព្រងទៅដោយការម្មណ៍ដែលគួរប្រាថ្នា ដូច្នេះជាដើមហៅថា "ចេតសិកសុខ" សុខប្រព្រឹត្តទៅក្នុងចិត្ត ។

សេចក្តីសុខទាំង ៣ ប្រការនេះ ដែលនឹងកើតឡើងបាន លុះតែមាន "សង្ឃស្ស សាមគ្គី" សេចក្តីព្រមព្រៀងមូលមិត្រប្រមូលគ្នានៃពួកក្រុម ទើបកើតឡើងបាន ។

ពាក្យថា "សង្ឃស្ស" មកពីពាក្យ "សង្ឃៈ" ប្រែថា ពួកបក្សក្រុម សង្គម គ្រួសារ ៗ បានសេចក្តីថា គ្នាច្រើន រួបរួមគ្នាជាបែបតែមួយ ៗ ឯបក្សពួកសង្គមគ្រួសារនីមួយ ៗ បើចង់បានសុខស្រួល ត្រូវតែនាំគ្នាបណ្តុះបណ្តាលនូវសាមគ្គីធម៌ឲ្យមានប្រចាំក្នុងសន្តានចិត្តជានិច្ច ទើបបានសុខចំរើនសមតាមប្រាថ្នា ។

ពាក្យថា "សាមគ្គី" ប្រែថា សេចក្តីមូលមិត្រ, សេចក្តីរាប់អានស្និទ្ធស្នាល, ដំណើរមិនកន្ទែកបែកចេញពីគ្នា, ដំណើរមិនប្រឆាំងគ្នា ។

បានសេចក្ដីថា ការដែលស្របគ្នា ការដែលមិនទទឹងទាស់ ឬការជួយចិត្ត ដល់គ្នានិងគ្នា, ស្មើគំនិត ស្មើអធ្យាស្រ័យគ្នា ។

សាមគ្គីនេះបើចែកជាប្រភេទ មាន ៣ គឺ

១– កាយសាមគ្គី ព្រមព្រៀងដោយកាយ ។

២– វចីសាមគ្គី ព្រមព្រៀងដោយសំដី ។

៣– មនសាមគ្គី ព្រមព្រៀងដោយចិត្ត ។

ការព្រមព្រៀងរួបរួមគ្នាធ្វើកិច្ចដោយកាយ បើធ្វើអ្វីៗ ធ្វើទាំងអស់គ្នា មិនប្រចាំមួយៗ ឬមិនមើលបំណាំគ្នា, គួយ៉ាងដូចជាព្រះសង្ឃក្នុងមណ្ឌល ព្រះពុទ្ធសាសនា បើមានកិច្ចការណាមួយដែលត្រូវខ្វល់ខ្វាយដោយកាយ ដូចជាជួសជុលកុដិសាលាព្រះវិហារ ទីវត្តអារាមជាដើម មិនត្រូវមើលបំ-ណាំគ្នា ។ ល ។

បើខាងគ្រហស្ថ ដូចជានៅក្នុងសង្គមភូមិមួយៗ បើមានអន្តរាយ ណាមួយកើតឡើងមានចោរប្លន់ជាដើម ត្រូវព្រួតដៃចុះទៅប្រយុទ្ធទាំង អស់គ្នា មិនបណ្ដោតបណ្ដោយឲ្យម្នាក់ៗ ហើយនាំគ្នាដោះដៃគេចចេញ ឡើង ។ ការរួបរួមព្រមគ្នាធ្វើដូច្នេះជាដើមហៅថា " កាយសាមគ្គី " ព្រមព្រៀងគ្នាដោយកាយ ។

សំដីដែលស្របគ្នា សំដីដែលចុះសម្រុងគ្នា មិនប្រឆាំង ប្រកែក

ប្រណាំងគ្នា គឺយ៉ាងដូចជាបែកខាងព្រះសង្ឃក្នុងព្រះពុទ្ធសាសនា បានដល់ការសិក្សាស្វាធ្យាយ ធម៌វិន័យត្រូវបែបគ្នា, ក្នុងការអានបាលីភាសាក៏ត្រូវគ្នា, ការឲ្យឱវាទត្រូវទំនងគ្នា, ព្រមព្រៀងប្រតិបត្តិតាមឱវាទដែលត្រឹមត្រូវតាមពុទ្ធដីកា ទាំងអស់គ្នា, មានវាទៈប្រកបដោយធម៌ត្រូវគ្នា ។

បើបែកខាងគ្រហស្ថ ដែលនៅក្នុងស្រុកភូមិនីមួយៗ បានដល់ការដែលនិយាយអំពីប្រយោជន៍ដែលស្របគ្នា; គោលលទ្ធិត្រូវគ្នា, សំដីដែលប្រកបដោយហេតុផលស្តាប់បានត្រូវគ្នា ។ ល ។ បើអ្នកនិយាយនោះនិយាយទៅសមរម្យតាមហេតុ ក៏ព្រមជឿស្តាប់ទាំងអស់គ្នាជាដើមហៅថា "វចីសាមគ្គី" ព្រមព្រៀងគ្នាដោយសំដី ។

ការស្រុះស្រួលដោយចិត្ត គឺមានអធ្យាស្រ័យត្រូវគ្នា ។ បើផ្នែកខាងបព្វជិត នោះបើបព្វជិតរូបណាមួយមានយសស័ក្តិតូចតាច ឬមានវ័យក្មេងក្តី តែមានយោបល់ល្អ ចេះស្វែងរកប្រយោជន៍ដល់សាសនា ចេះយល់ឃើញហេតុការណ៍ល្អ ត្រូវតែមូលមតិគ្នាយកយោបល់នោះ មកតាំងជាមូលដ្ឋានសម្រាប់ស្រាវជ្រាវការរកវឌ្ឍនភាពតទៅ ។

ចំណែកខាងឃរាវាសវិញក៏ដូច្នេះដែរ បើអ្នកណាមួយក្នុងក្រុមរបស់ខ្លួន នាំបំពេញប្រយោជន៍អ្វីមួយ ទោះជាប្រយោជន៍ជាតិក្តី ប្រយោជន៍សាសនាក្តី ប្រយោជន៍ពួកប័ក្ខខ្លួនក្តី ក៏ចេះតែព្រមតាមទាំងអស់គ្នា

មិនមានបញ្ញាមតិ ណាផ្សេងពីប្រយោជន៍ឡើយ ដូច្នេះហៅថា "ចិត្តសាមគ្គី" ព្រមព្រៀងដោយចិត្ត ។

បើរួមបទទាំងបីមកគឺ "សុខ ១ សន្តិសុខ ១ សាមគ្គី ១" បានសេចក្តីថា ការព្រមព្រៀងរួបរួមរួបចិត្តមូលគំនិត មូលគោលជ្រោស្រ័យនៃពួកក្រុម ជាហេតុឲ្យរាយទាំងសុខ, ត្រង់ការរាយហ្នឹងហើយជាគុណអង្គនៃសេចក្តីសុខ ។

មិនត្រឹមតែប៉ុណ្ណោះទេ សាមគ្គីនេះមានប្រភានុភាពណាស់ សូម្បីខ្លួនតូចតាច ក៏ប៉ិចកប៉ិល្អិតល្អោចក៏ដោយចុះ ឲ្យតែមានការព្រមព្រៀងសស្រោកសស្រាំជាឯកភាព ប្តូជាធ្លុងមួយហើយមុខជាអាចផ្តាញ់ផ្តាល់អ្នកធំស្តុកស្តម្ភណាដែលហ៊ានប្រមាថមើលងាយបានហ៊ែងស្រួលទៀតផង ។

ដូចមានអតីតនិទានយ៉ាងសង្ខេប ដែលព្រះសម្ពុទ្ធទ្រង់បានសំដែងថា "សូម្បីតែសត្វចាបចៀបកប្បាស ដែលជាសត្វតូចល្អិត ក៏អាចបំផ្លាញជីវិតសត្វដំរីជាមហាសត្រូវ ឲ្យវិនាសបានដោយសារមធ្យោបាយសាមគ្គីរបស់ខ្លួនដែរ" ។

ម្យ៉ាងទៀតឧទាហរណ៍បច្ចុប្បន្ន បានដល់រដ្ឋខ្មែរទាំងព្រះសង្ឃទាំងគ្រហស្ថ ដែលកំពុងតែមានសាមគ្គីភាពយ៉ាងរស់រវើក រឹងប៉ឹងដង្ហែតាមក្រោយព្រះកិច្ចដឹកនាំនៃសម្តេចព្រះអគ្គប្រមុខរដ្ឋ មិនគ្រាន់តែធ្វើឲ្យប្រទេសជាតិបានចំរើនផុះផាលគ្រប់វិស័យប៉ុណ្ណោះទេ សាមគ្គីនេះថែម

តាំងអាចធាក់ច្រានរំលាយចោល នូវការប៉ុនប៉ងបំផ្លិចបំផ្លាញយ៉ាងសាហាវព្រៃផ្សៃរបស់បរទេស ដែលបរិបូណ៌ដោយអាវុធនិងមធ្យោបាយ ឲ្យរទទួលនូវបរាជ័យយ៉ាងអាមាស់មុខគ្រប់កាលៈទេសៈទៀតផង ។ នេះបញ្ជាក់ឲ្យឃើញថា ជីវិតនិងសេចក្ដីសុខសាន្តនៃអ្នកតូចតាច ប្រាកដជាស្ថិតថេរបរកាលជាអង្វែងទៅបាន ដោយសារសាមគ្គីធម៌នេះឯង ។

ប៉ុន្តែទោះបីដូច្នេះក៏ដោយ ការព្រួយបារម្ភប្រាកដជានៅមានទៀត, ព្រោះបើគេមិនខំថែរក្សាថ្នាក់ថ្នមចងក្រៀកទុកឲ្យមាំមួនទេ ថ្ងៃណាមួយសាមគ្គីនេះ មុខជានឹងរលាយសាបសូន្យបាត់បង់ទៅវិញជាមិនខាន ។

អាស្រ័យហេតុនេះ ទើបព្រះពុទ្ធជាបរមគ្រូនៃយើងទ្រង់បានសំដែងទៀត នូវធម៌ជាចំណងចងក្រៀក ឬធម៌ជាឃ្នាបគាបពួកក្រុម ឲ្យមានសាមគ្គីជាប់លាប់ជាស្ថាពរយូរអង្វែងតទៅ កុំឲ្យសាបរលាបបាន ។

ឯធម៌ជាឃ្នាបឬជាចំណងសាមគ្គីនោះមាន ៦ យ៉ាងគឺ :

១ – វីរិយ សេចក្ដីព្យាយាម

២ – ខន្តិ សេចក្ដីអត់ធន់

៣ – សច្ចៈ សេចក្ដីពិតត្រង់

៤ – អធិដ្ឋាន: ការតាំងទុកក្នុងចិត្តដោយបញ្ញា

៥ – មេត្តា ការរាប់អាន

៦ – បរិច្ចាគៈ ការចែកលាភគ្នា

អធិប្បាយថា

១– វីរិយៈ ប្រែថាព្យាយាម ប្រឹងប្រែងស្រវាស្រទេញ បើហៅ
ថា ឧដ្ឋានៈ ប្បធានៈ កំប្លាន ៗ  វីរិយៈ នេះបើចែកទៅទៀតមាន ៤
យ៉ាងគឺ :

ក – បហានប្បធានៈ: ព្យាយាមលះទោសដែលកើត
ឡើងដល់ពួកក្រុមខ្លួន ។

ខ – សំវរប្បធានៈ: ព្យាយាមហាមឃាត់ទោស មិនឲ្យ
កើតឡើងដល់ពួកក្រុមខ្លួន ។

គ – ភាវនាប្បធានៈ: ព្យាយាមចំរើនសេចក្តីល្អឲ្យកើតឡើង
ដល់ពួកក្រុមខ្លួន ។

ឃ – អនុរក្ខនាប្បធានៈ: ព្យាយាមរក្សាសេចក្តីល្អដែល
កើតឡើងហើយ មិនឲ្យបាត់ទៅវិញ ។

២– ខន្តិ ប្រែថាការអត់ធន់មិនប្រកាន់ទោស មិនប្រទូស្តតប
ចំពោះពួកក្រុម ។ បើអ្នកណាម្នាក់ក្នុងក្រុមមានការឆ្គាំឆ្គងមិនសមរម្យ ក៏
មិនមានប្រកាន់កំណាន់ចិត្តទុកឡើយ ។ ខន្តិនេះមិនត្រឹមតែប៉ុណ្ណោះទេ ត្រូវ
មានចិត្តតស៊ូទ្រាំអត់ធន់ចំពោះប្រយោជន៍ដល់ពួកក្រុមទៀត គឺថាធ្វើការ
ដើម្បីពួកក្រុមខ្លួនមិនខ្លាចក្តៅត្រជាក់ ដោយសំអាងលើហេតុ ៦ យ៉ាង
នោះឡើយ ។

ហេតុ ៦ យ៉ាងនោះគឺអាងថា ត្រជាក់ពេក, ក្តៅពេក, ព្រឹកពេក, ល្ងាចពេក, ឃ្លានពេក ស្រេកពេក ហើយឈប់មិនធ្វើការ ។

ការអត់ទ្រាំនឹងក្តៅ-ត្រជាក់-នឿយព្រួយ ដើម្បីបំពេញប្រយោជន៍បក្ស គណៈក្រុមដូច្នេះហៅថា « ខន្តី » ។

៣ – សច្ចៈ ការពិតទៀងត្រង់ ការស្មោះត្រង់ការឥតលាក់លាក់ ការមិនកុហកឆបោក ការមិនវៀចវេរ ហៅថា សច្ចៈ ។ សច្ចៈចែកទៅទៀតមានបីគឺ:

ក – កាយសច្ចៈ : ពិតត្រង់ដោយកាយ

ខ - វចីសច្ចៈ: ពិតត្រង់ដោយសំដី

គ -- មនោសច្ចៈ: ពិតត្រង់ដោយចិត្ត ។

ការទៀង ការពិតមានកំរិត ការប្រាកដប្រជាដោយអំពើដែលត្រូវប្រកបដោយកាយ ដូចជាទៀងក្នុងការបរិភោគ, ក្នុងការដេក ក្នុងការធ្វើការងារ ទៀងក្នុងការប្រជុំ ប្រាកដក្នុងរបរប្រកបអាជីវកម្មជាដើម ហៅថា «កាយសច្ចៈ» ពិតត្រង់ដោយកាយ ។

ការពិតត្រង់មិនវៀចវេរ មិនភូតភរកុហកដោយពាក្យសំដី ឬថាមិនលាក់ទុកនូវហេតុដែលគួរប្រាប់ប្រេងដល់ពួកក្រុម ឬក៏ការមិននិយាយបំផ្លើសឲ្យលើសហួសអំពីហេតុដែលខ្លួនដឹង ដឹងដូចម្តេចនិយាយដូច្នោះ ។ យ៉ាងនេះជាដើមហៅថា «វចីសច្ចៈ» ។

ការពិតប្រាកដនឹងខ្លួន ការស្មោះត្រង់ដោយចិត្ត មិនមានចិត្តក្រឡិចក្រឡុច មិនមានចិត្តវៀចវេរ ឬថាមានចិត្តមិនភ្ញាក់ផ្អើលសាវាទៅតាមការឃោសនានៃលទ្ធិដទៃ ឬសាសនាដទៃ, ការដែលមានចិត្តនឹងធឹងមាំមួនយ៉ាងនេះ ហៅថា «មនោសច្ចៈ» ។

៤ – អធិដ្ឋាន : ការដែលមានបញ្ញាប្រចាំនៅក្នុងសន្តានចិត្តជានិច្ច សំរាប់លៃលកពិចារណាល្អិតពិសោធមើលការងារសព្វជំពូកក្នុងពួកក្រុម មិនបណ្តែតបណ្តោយ លះបង់ចោលឡើយ ។ ដូច្នេះហៅថា «អធិដ្ឋាន» ។

៥ មេត្តា ប្រែថា ការរាប់អាន, ចែកទៅជា ៣ យ៉ាងគឺ

ក – មេត្តាកាយកម្ម មានមេត្រីភាពដោយកាយ ។

ខ – មេត្តាវចីកម្ម មានមេត្រីភាពដោយសំដី ។

គ – មេត្តាមនោកម្ម មានមេត្រីភាពដោយចិត្ត ។

ការប្រកបអំពើល្អ ៗ ដោយកាយដល់ពួកក្រុម សុទ្ធតែមានចិត្តស្មោះស្មើ មានចិត្តរាប់អានដោយត្រង់ មិនធ្វើដើម្បីតាមតារយកតែប្រយោជន៍ផ្ទាល់ខ្លួន ៗ ដូចយ៉ាងជាពួកបព្វជិតក្នុងព្រះពុទ្ធសាសនា ឃើញបព្វជិតដទៃគ្នាមានធុរៈ ដូចជាមានរោគាព្យាធិបៀតបៀនជាដើម ក៏ជំនួយបំរើដោយខ្មីឃ្មាត មានជូនរកថ្នាំសង្គ្រោះជាដើម ត្រូវជួយមើលថែទាំការខុស

ត្រូវឲ្យដោយត្រង់សុចរិត និងការរាប់អានដូច្នេះឯង ហៅថា «មេត្តាកាយកម្ម» ។

ការនិយាយពាក្យទន់ភ្លន់ផ្អែមល្ហែមពីរោះពិសា ប្រកបដោយមេត្រីភាព ជាសំដីជាទីស្រឡាញ់ពេញចិត្តគាប់អធ្យាស្រ័យនៃជនទូទៅ ឬក៏ជាពាក្យប្រៀនប្រដៅដោយចិត្តចង់ឲ្យបានល្អ សំដីប្រកបដោយប្រយោជន៍ មិនបន្ទោសដេរស្តី ដោយចិត្តចង់ឲ្យតែវិនាសនោះឡើយ ឬក៏និយាយពាក្យសប្បុរសទៅកាន់គ្នា ដោយមេត្រីចិត្ត មិនមែនឃើញគ្នាតូច ហើយហៅគ្នាអាមីងតាមទំនើងចិត្តនោះឡើយ ។ ទោះបើមានការខុសមួយដងមួយកាល ក៏នៅតែមានចិត្តរាប់អានស្តីប្រដៅឲ្យបានល្អឡើងវិញ គឺមិនប្រើសំដីប្រទូស្តទាល់តែវិនាសខូចខាតបាត់ប្រយោជន៍នោះឡើយ ។ ដូច្នេះហៅថា «មេត្តាវចីកម្ម» ។

ការផ្សាយមេត្រីចិត្តដល់ពួកក្រុម មានចិត្តត្រង់រាប់អានចង់ឲ្យគេបានសុខ ចំរើនបានប្រយោជន៍ មិនច្រណែនឈ្នានីសនឹងគេឡើយ ។ បើឃើញពួកក្រុមណា ឬក្រុមខ្លួនបានលូតលាស់ ហើយក៏ជួញចិត្តត្រេកអរសាទរជាមួយគ្នា ។ ដូច្នេះហៅថា «មេត្តាមនោកម្ម» ។

៦_ **បរិច្ចាគៈ** ការលះ ការឲ្យ ការចែករំលែកដល់គ្នីគ្នា ។ បរិច្ចាគៈ នេះចែកទៅជាពីរយ៉ាងទៀតគឺ

៣– អាមិសបរិច្ចាគៈ ការឲ្យនូវគ្រឿងអាមិសមានម្ហូបអាហារសំលៀកបំពាក់ ប្រដាប់ប្រើប្រាស់ជាដើម ។

១– ធម្មបរិច្ចាគៈ ការលះឲ្យនូវធម៌ មានសំដែងធម្មទេសនានិងចែកចាយនូវក្បួនច្បាប់ធម៌ជាដើម ។

ធម៌ទាំង ៦ យ៉ាងគឺ វីរិយៈ សេចក្ដីព្យាយាម; ខន្តិ សេចក្ដីអត់ធន់; សច្ចៈ សេចក្ដីពិតត្រង់; អធិដ្ឋាន ការតាំងទុកក្នុងចិត្តដោយបញ្ញា, មេត្តា ការរាប់អានគ្នា, បរិច្ចាគៈ ការចែកលាភគ្នានេះហើយ ជាចំណងយ៉ាងស្វិតស្វាញបំផុត សំរាប់ចងក្រៀកពួកក្រុមឲ្យមានសាមគ្គីជាប់លាប់ដោយល្អ ។

ជាការពិតប្រាកដណាស់ បើបក្សពួកសមាគមក្រុមហ៊ុនណាមួយបានបណ្ដុះបណ្ដាលធម៌ទាំង ៦ ប្រការនេះឲ្យតាំងនៅក្នុងសន្ដានចិត្តជានិច្ចហើយ បក្សពួកចលនាសមាគមក្រុមហ៊ុននោះ ឈ្មោះថាបានរក្សាការពារទុកនូវសាមគ្គីភាពយ៉ាងប្រពៃពន់ពេក មិនមានថ្ងៃណាមួយអាចនឹងសាបសូន្យ ប្រេះឆាពុករលួយរលាយបង់ទៅបានឡើយ ។

កាលបើពួកក្រុម បុគ្គលការអ្វីមួយ មានការព្រមព្រៀងរួបរួមគ្នាជាស្ពានដូច្នេះហើយ សេចក្ដីសុខពោលគឺសេចក្ដីស្រួលងាយសព្វយ៉ាងតែងហូរបូលមកគគោចដូចទឹកហូរធ្លាក់ពីលើកំពូលភ្នំ ពុំងាយបើកឱកាសបន្តិចបន្តួចឲ្យកាលៈទេសៈលំបាកណាមួយបូលលាយឡើងបានឡើយ ។

ការអធិប្បាយអំពី សុខមូលកធម៌ អស់សេចក្ដីតែប៉ុណ្ណេះ ។

# ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគត់មត់
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ

ប ព.

## វចនានុក្រមសំស្ក្រឹត-ខ្មែរ

(ត)

*ព្រះមហា ម៉ាង ទាត់ រៀបរៀង*

អនាក្តាក្ស គុ (អន៑+អាក្ត+អក្ស ដែលមានភ្នែកមិនស្អិតស្អាងហើយ ។

អនាក្រាន្ត គុ (អន៑+អក្រាន្ត) ដែលមិនដើរតម្រង់ទៅ ។

អនាក្រាន្ទ គុ. ដែលមិនមានជនគួរហៅ (មកជួយ), ដែលមិនសោយសោក ។

អនាក្រម្យ គុ. ដែលមិនគប្បីចូលចុះ ។

អនាក្សារិត គុ. ដែលមិនតេះដៀល ។

អនាគត គុ. ដែលមិនទាន់មក, ដែលមិនមក, ដែលរកមិនឃើញ ។ អនាគត, ដែលមិនដល់, ដែលមិនរៀន, ដែលមិនបេះ ។ នពុំ អនាគត ។ អនាគតំ ក្រិ គិតទៅអនាគត, អនាគតវន្ត៑ គុ. ដែលមានអនាគត ។ – វិជាគ្ញ បុំ. "អ្នកប្រាជ្ញអនាគត" អ្នកគិតទៅមុខ, ព្រះអាទិទេព, ឈ្មោះត្រីមួយ ។ - វិជាន នបុំ.

ការបាត់វិនាសការណ៍ទៅអនាគត ។ **អនាគតាពាធ** បុំ (អនាគត + អាពាធ) អនាគតាពាធ, ការមានគ្រោះទៅអនាគត · **អនាគតាត៌ភ** ស្ត្រី. (អនាគត + អត៌ភ) ស្ត្រីដែលមានផ្ទៃពោះមិនទាន់ដល់ហើយ, ស្រីមិនទាន់មានផ្ទៃ ។ **អនាគតាវេក្ខណា** នបុំ កិរិយាមើលទៅកាលដែលមិនទាន់មកដល់ ។

**អនាគតិ** ស្ត្រី អនាគតិ, ការមិនទាន់មកដល់, ដំណើរមិនទាន់មកដល់, ការមិនទាន់ដល់ ។

**អនាគម** បុំ. អនាគម, ការមិនទាន់មកដល់, ការមិនមកដល់, គុ ដែលមិនតាំងនៅតាមប្រពៃណី ។ **អនាគមន** នបុំ. កិរិយាមិនមកដល់

**អនាគមិន៑** គុ. ដែលមិនមកទៀត, ដែលមិនមកកាន់លោកនេះទៀត, បុំ. នាមព្រះអរិយបុគ្គលជាន់អនាគាមិ ។

**អនាគស៑** គុ. ដែលមិនមានទោស ។ **អនាគោហត្យា** ស្ត្រី. ឃាតកម្មនូវមនុស្សមិនមានទោស ។ **អនាគា** ស្ត្រី ឈ្មោះស្ទឹង ។

**អនាគ្រយណ** គុ ដែលមិនមានអាគ្រយណៈ ។

**អនាឃ្រាត** គុ. ដែលមិនបានហិត ឬ ភ្លក់ ។

**អនាចរណ** នបុំ. ការមិនប្រព្រឹត្តតាមប្រពៃណី, ការប្រព្រឹត្តខុស ។

**អនាចរិត** គុ. ដែលមិនប្រព្រឹត្តតាម ។

**អនាចារ** បុំ. អនាចារ, ការមិនប្រព្រឹត្តតាមច្បាប់ ឬ ប្រពៃណី ។

(នៅមានត)

អធិប្បាយភាសិត

# ទឹកត្រជាក់ត្រឹកុំ

របស់សាស្ត្រាចារ្យ ឈឹម - ស៊ុម (តពីលេខ ១ មក)

## សង្គហធម៌ ៤ ប្រការ

### បទព្រហ្មគីត

លោកអ្នកទាំងឡាយអើយ      យើងឃើញហើយដោយនេត្រា
នូវព្រះម្ចាស់សិរសា      ជាបិតាសន្តិភាព(១)      ៗ
ទ្រង់មានព្រះមេត្តា      ករុណាជាដរាប
ព្រះទ័យទន់សុភាព      រាបសាសព្វកាយវាចា      ៗ
សង្គហធម៌ទាំងបួន      គ្រប់ចំនួនមាតិកា
ទ្រង់កាន់ជាចរិយា      គ្រប់វេលាជានិរន្តរ៍      ៗ
ទី ១ គឺទានៈ      ព្រះអង្គៈដ៏សោភ័ណ
បរិច្ចាគទ្រព្យរយពាន់      ជូនក្រែលគ្រាន់ដល់ម៉ឺនសែន      ៗ
សង្គ្រោះអ្នកមានភ័យ      ដោយព្រះទ័យមេត្តាមែន
ដល់ជនអ្នកខេត្រដែន      ដែលរងគ្រោះដោយភ្លើងឆេះ      ៗ
រងគ្រោះដោយទឹកលិច      ដោយទង្គិចឡានបុកបេះ
ដោយចោរប្លន់សម្លុះ      សម្លាប់ប្ដីប្រពន្ធ      ៗ

(១) សម្ដេចព្រះនរោត្តម - សីហនុ ។

ទ្រង់លះព្រះរាជទ្រព្យ　យ៉ាងគួរគាប់ដ៏មហន្ត
កសាងទីជប់ទ　សម្រាប់ជនជាតិទុគ៌ត ។
កើតមកអនាថា　ខ្វះកំព្រាខ្វះក្រខ្សត់
ទ្រង់សាងទីទុគ៌ត　បានអ្នកខ្សត់ច្រើនកន្លែង ។
ជួនកាលទ្រង់លើកគ្នា　សង់គ្រឹះហាផ្ទះសំបែង
យ៉ាងល្អ ៗ ចំឡែង　ប្រទានផ្ដាច់ដល់មេម៉ាយ ។
បរិច្ចាគព្រះរាជទ្រព្យ　សាងសង់សព្វគ្រឹះទាំងឡាយ
សម្រាប់ការស្វាធ្យាយន៍　គឺសាលារៀនគ្រប់ខេត្ត ។
សាងមន្ទីរសម្ភព　សាងសព្វគ្រប់ទាំងផ្ទះពេទ្យ
សាងថ្នល់ស្ពានគ្រប់ខេត្ត　សាងទំនប់អណ្ដូងទឹក ។
ទ្រង់លះព្រះរាជទ្រព្យ　ប្រសើរគាប់ច្រើនសន្ធឹក
ឧបត្ថម្ភរាល់យប់ព្រឹក　ចំពោះព្រះពុទ្ធសាស្នា ។
ទោះបីអ្នកឯទៀត　គេចាំញៀតដោយជ្រះថ្លា
កសាងដូចពណ៌នា　ខាងដើមនេះដោយខ្លួនគេ ។
ក៏ទ្រង់តែងតែជួយ　ជាជំនួយមិនខានទេ
ទាល់តែទៅជាមេ　នៃកុសលផងទាំងឡាយ ។
សូម្បីអ្នកកើតក្ដី　ទាំងប្រុសស្រីក្ដៅក្រហាយ
ព្រោះចាញ់ក្ដីអន្តរាយ　ហើយមកថ្វាយបង្គំគាល់ ។

ថ្វៃនទុក្ខទូលព្រះអង្គ ក៏ស្តេចទ្រង់ទទួលស្គាល់
ប្រទានប្រាក់ឲ្យដល់ អ្នកចាញ់ក្តីតាំងរយពាន់ ។

៤- បិយវាចា ព្រះក្សត្រាមហាសេកកណ
មានបន្ទូលសេពន៍ ពក់ទាក់គេជនពលគ្នា ។
មិនត្រឹមតែមន្ត្រី គហបតីដ៏ថ្វៃថា
សូម្បីពស្ត្រីប្រជា អនាថាទោកក្រខ្សត់ ។
ពាក្យត្រទ្រង់ពក់ទាក់ ហៅនាងអ្នកតាមដោយបទ
ពុំមីនយាយតាគាត់ ឯកឧត្តមលោកព្រះអង្គ ។
ឥតគ្គងដោយវាចា ព្រះក្សត្រាទ្រង់ស្មោះត្រង់
វាចាគួរគិសវង់ ស្តាប់ហើយចង់តែស្តាប់ទៀត ។
ទ្រង់ពុំដែលបញ្ចេញ សព្វគួរម្ចេញគួរចង្អៀត
គឺពាក្យពោលជ្រៀតបៀត ដល់ជនណាម្នាក់សោះឡើយ ។
ទ្រង់ពោលតែពាក្យសត្វ ច្បាប់បរមត្ថដែលជាក្រើយ
ជាគ្រាណាបានលំហើយ លំហែចិត្តបាត់ក្តីទុក្ខ ។
ទ្រង់ពោលតែពាក្យថ្នម ទន់ទាំងព្រមឥតគ្រលុក
គ្រលាសឬបុករុក ឲ្យកើតទុក្ខដល់អ្នកណា ។
ព្រះសូរសៀងព្រះអង្គ គួរគិសវង់គួរជ្រះថ្លា
ពុះហើយជាបចិន្តា ជាវាចាគួរស្រឡាញ់ ។

៣ - សមានត្តតា  កាយវាចា យ៉ាងអស់អញ

បុកពាក្យស្រឡាញ់  ព្រោះចម្រាញ់អស់ឈ្លើសឈ្លួង ៗ

ឥតប្រជែងប្រឆាំង  ឥតក្អេងក្អាងខុសគន្លង

ឥតវាគការម្យ៉ាងផង  តាមគន្លងស្មើប្រក្រតី ៗ

កិរិយាស្មើដរាប  បុកសុភាពគួរប៉ើតី

ទន់ភ្លន់ជាប្រក្រតី  មិនវ៉ៃបុកខ្ពស់ ៗ ទាប ៗ

គេញ្ញាប់ចំណាំបាន  ជាក់ត្រេកក្រៃបុកសុភាព

ពីកុមារដរាប  ចេះបន្ទាបបន្ទន់អង្គ ៗ

រហូតដល់សោយរាជ្យ  ពេញអំណាចគួរក្រេវក្រទ

ដំកើងបុកក្រទន់  ប៉ុន្តែទ្រង់មិនដូច្នោះ ៗ

៤ - អត្ថចរិយា  មហាក្សត្រប្រព្រឹត្តស្មោះ

ចង់ឲ្យតែមានឈ្មោះ  មានប្រយោជន៍ទាំងអស់គ្នា ៗ

ខ្លួនទៅតាំងប្រទេស  ថ្កើងវិសេសក្រៃមហិមា

មិនដែលមានផ្តន្ទា  ជាអ្នកនេះជួយអ្នកនោះ ៗ

ការប្រព្រឹត្តប្រឹងប្រែង  ការខ្វះខ្វែងឥតមានសោះ

ថ្ងៃខែណាមួយសោះ  ព្រោះទ្រង់ចង់បានប្រយោជន៍ ៗ

ចែកជូនជនក្នុងទៅ  រាស្ត្រខ្លួនទៅកុំឲ្យបោច

ព្រោះទ្រង់តែងផ្ចាខ្វាច  អាណិតជាតិស្មើជីវិត ៗ

យើងអាចយល់បានថា បើក្សត្រាព្រះអង្គគិត
តែត្រង់ជួនជីវិត ព្រះអង្គមួយមិនបាច់ប្រើង ។
ព្រោះព្រះអង្គត្រកាល ជាមហាសាលស្តុកស្តម្ភមាំង
គង់តែរស់យ៉ាងថ្កើងថ្កាន ។
ប៉ុន្តែមហាក្សត្រា មានមេត្តាជាប្រធាន
កាសូរព្រហ្មត្រែប្រាណ បានជាទំនត់តឈបណរ ។
សព្វពោះប្អូនមាតា នេះក្សត្រាដ៏បវរ
ទ្រង់តែងតែត្រេកអរ កាន់កាប់ជាប់ជាធម្មតា ។
រីធម៌ប្អូននេះឯង ពិតជាខ្នែងនៃមេត្តា
ជាដើមជាសាខា នៃមេត្តាធម៌ជាគល់ ។
មេត្តាជាតួចិត្ត សុខុមល្អិតកង់មណ្ឌល
បេះដូងជាបុសគល់ បញ្ចេញផលមកជាតាន ។
ជាបិយវាចា ជាបុកតារស្មើស្មោះស្មាន
ជាការប្រព្រឹត្តប្រាណ ប្រើងរកប្រយោជន៍ចែកគ្នា ។
រីឯសម្តេចឪ ប្រព្រឹត្តត្រូវធម៌នេះណា
ប្រៀបដូចជាគង្គា ត្រជាក់ថ្លាទើបត្រឹកុំ ។
សូមលោកអ្នកពិនិត្យ គង់ឃើញពិតដូចជាខ្ញុំ
ដែលឃើញថាមនុស្សផ្តុំ នៅកុះកុំក្នុងស្រុកយើង ។

ឆ្នាំមុននេះឯណា កស្ត្រប្រជាតិចតួចស្តើង
គឺមនុស្សប្រទេសយើង មានតែប្រាំលាននាក់គត់ ។
ឆ្នាំនេះចំរើនពាស់ (១) ច្រើនក្រៃក្រាស់ដល់កំណត់
ឡើងពីប្រាំលានគត់ ដល់កំណត់ប្រាំមួយលាន ។
ព្រោះជនជាតិជិតខាង ខ្វះសំណាងហើយចង់បាន
សេចក្តីសុខក្រេមក្រុទ្ធ បានរត់មកជ្រកអាស្រ័យ ។
មួយទៀតពីមុននេះ ខ្មែរយើងចេះតែក្រណក្រយ
ច្រើនជាងកើតសព្វថ្ងៃ ឥឡូវក្រោយបែរជាតិច ។
ដោយសារតែក្រោ ទ្រង់មេត្តាគ្រប់កលកិច្ច
បានជាខ្មែរស្ទាប់តិច រស់ចំរើនច្រើនក្តាត់ណា ។
នេះជាអានិសង្ស នៃការទ្រង់ធម៌មេត្តា
នៃព្រះជាបិតា ជាប្រមុខកម្ពុជរដ្ឋ ។
ហេតុនេះយើងពល់គ្នា គួរមេត្តាដល់សព្វសត្វ
ដែលកើតមកច្រើនក្តាត់ ទោះទាំងមនុស្សទាំងតិរច្ឆាន ។
កុំធ្វើទុក្ខបុកម្នេញ កុំបញ្ចេញការបំពាន
បំពាហួសប្រមាណ គួរប្រមើលមើលប្រមុខ ។
នៃរដ្ឋយើងនេះឯង ទើបហៅស្ងួនរកក្តីសុខ
បំបាត់សេចក្តីទុក្ខ ដោយមេត្តាថាដោយបទ ។

(១) ឆ្នាំ ១៩៦៣ ។

រឿងនេះជារឿងវែង ខ្ញុំថាថែងតាមប្រាកដ
និយមដោយសង្ខេត ទុកជាចប់ដោយសង្ខេប ។

# និម្ប្រធានពិលមហាជន

## បដក្កាកកត

ហៃអស់មហាជន គួរកុំទម្រន់ គួរតាមសម្តេច សំដៅតាមផ្លូវ ដែលខ្ញុំយើងត្រេច ឈានទៅដូចម្តេច យើងឈានដូច្នោះ ។ មិនតែ-ប៉ុណ្ណោះ សម្តេចខ្ញុំនេះ ចាត់ការត់តង្ខោះ ផែនការប្រាំផ្នាំ ត្រូវតែតបន្ទោះ ត្រូវតែតមានខ្ទោះ ចាតពុទ្ធសាសនា ។ ដែលព្រះបរម សម្ពុទ្ធជាធំ ទ្រង់សំដែងថា អារាមរោបៈ វនរោបា នរជនណា ចង់សុខសម្រាន្ត ។ បានដាំសួនផ្កា ស្លឹកផ្កាស់ពណ៌គ្នា បានដាំទឡាន ដើមឈើធំៗ ផ្កាល្បិផ្លែល្បាន ជាទីសម្រាន្ត សម្រើបគំនិត ។ ហេចជនា សេតុការកា ជនណាមានចិត្ត សទ្ធាសប្បុរស នាំអស់ពួកមិត្រ មូលមកជុំជិត ធ្វើផ្លូវធ្វើស្ពាន ។ ហេចបបំ ទទបានំ ជនទាំងណាមាន ចិត្តកាត់តម្វា សទ្ធាជាយាន បានសាងទីបាន តម្កល់ទឹកទុក ។ គឺធ្វើត្រពាំង ទំនប់ទប់ពាំង ជីកស្រះជិតស្រុក ឬជីកអណ្តូង ប្រឡាយត្រលុក តម្កល់ទឹកទុក ប្រើប្រាស់គ្រប់គ្នា ។ ហេចទទំ ឧបស្សយំ អស់ទាំង-ជនណា បានសាងទីស្នាក់ គឺកុដិសាលា គ្រឹស្ថានសិក្សា គ្រឹហា-ព្យាបាល ។ ដែនទាំងនោះ បានបុណ្យឥតលោះ ចំរើនសព្វកាល

ថ្ងៃក៏សុខសព្វ យប់ក៏ត្រេកអាល ត្រេកអរសព្វកាល រហូតឋានសួគ៌ ។ កាសិតព្រះពុទ្ធ ប្រពៃបំផុត យើងគេងឥតគួរ កាន់កាប់កុំភ្លេច សម្រេចឋានសួគ៌ មិនមានទោមួរ តាំងពីឥឡូវ ។ ហេតុនេះបានជា សម្ដេចបិតា ដែលយើងហៅឪ បានចាត់ផែនការ ប្រាំឆ្នាំតម្រូវ តម្រង់ឡើងត្រូវ តាមកាសិតនេះ ។ យើងទាំងអស់គ្នា ត្រូវតែខ្មីខ្មា ធ្វើតាមដូច្នេះ ទើបបានក្ដីសុខ តាំងពីជាតិនេះ ហើយឈ្មោះថាចេះ ជ្រោងជាតិសាសនា ។ តម្កើងមហាក្សត្រ ដែលជាបរមត្ថ កំពូលរដ្ឋា តាមសម្ដេចឪ ត្រូវបាវចនា ទាំងបីថ្ងៃថា ដូចថ្ងៃមកនេះ ។ កាសិតជាត្រយ ខ្ញុំបានលើកស្ទួយ ស្ទង់តាមការចេះ សង្ខេបសេចក្ដី ខ្ញុំត្រឹមប៉ុណ្ណោះ ប៉ុណ្ណឹងហើយស្មេះ ប៉ុណ្ណោះឯងហោង ។៚

ចប់

ទឹកត្រជាក់ត្រីកុំ

កែប៉ុណ្ណោះ

ព.ស. ២៥០៦

គ.ស. ១៩៦

រក្សាសិទ្ធិ
(អនុញ្ញាតឲ្យដកស្រង់ ប៉ុន្តែត្រូវដាក់ឈ្មោះដើម)

# ចលនាអក្សរខ្មែរ

លោក ឌ. តាម រៀបរៀង

## ជំពូកមួយ

ខ្ញុំបាទសរសេរភាសាសាស្ត្រនិងអក្សរសាស្ត្រខ្មែរ ចុះក្នុងទស្សនាវដ្ដីកម្ពុជសុរិយាឆ្នាំ ១៩៦២ ចាប់ពីលេខ ៥ ម្ដងរួចទៅហើយ ។ ពេលនោះ ខ្ញុំសរសេរក្នុងការពិសោធន៍ ពេលនេះខ្ញុំសរសេរម្ដងទៀត តែខ្ញុំសរសេរតែចលនានៃអក្សរខ្មែរ ។ មុននឹងខ្ញុំសរសេរដល់ចលនានៃអក្សរខ្មែរ ខ្ញុំសូមបរិយាយយ៉ាងសង្ខេបនូវអក្សរបុរាណខ្លះ ដែលប្រើនៅក្នុងពិភពលោក ។

## សក្ដិលេខ

ដើមឡើយ មនុស្សយើងនៅក្នុងយុគសិលា (Age paléolithique) មិនទាន់មានបែបអក្សរកត់ត្រាចំណាំអ្វីទេ តែជំនាន់ក្រោយមក គឺសម័យយុគនវសិលា (Age néolithique) រវាង ៣.០០០ ឆ្នាំ មុនគ្រិស្តសករាជ ទើបមនុស្សយើងចេះបង្កើតសញ្ញាសំរាប់កត់ត្រាចំណាំរឿងរ៉ាវ តែសញ្ញាទាំងនោះ មិនមែនជាអក្សរដូចសម័យសព្វថ្ងៃនេះទេ ។ ដល់មនុស្សយើងចេះបង្កើតសញ្ញាសំរាប់សំគាល់នូវពាក្យ ឬប្រវត្តិសាស្ត្រហើយ សញ្ញាជាគ្រឿងសំគាល់ពាក្យ ឬប្រវត្តិសាស្ត្រនោះ សុទ្ធជារូបសត្វ ឬរូបអ្វីដទៃទៀតគឺ :

# ១ - សក្តិលេខរបស់ជនជាតិអេហ្ស៊ីប

(Hierographie égyptienne)

ជនជាតិអេហ្ស៊ីប បានបង្កើតសក្តិលេខសំរាប់កត់ត្រាពាក្យពេចន៍ ច្រើនពីប្រមាណជាង ៣.០០០ ឆ្នាំ មុនគ្រិស្តសករាជ ។ សក្តិលេខជនជាតិអេហ្ស៊ីបនេះ គេច្រើនតែឃើញធ្វើជាសញ្ញារូបសត្វ រូបមនុស្ស រុក្ខជាតិ ឬផ្កាឈូកជាដើម ។

សក្តិលេខរបស់ជាតិអេហ្ស៊ីប ដែលលោកសម៉ុលស្រី Champollion បានបង្ហាញគឺមានសញ្ញាសូរវិទ្យា និងអក្សរសញ្ញាវាទគំនិត ។

ក - សញ្ញាសូរវិទ្យា (Signes phonéthiques) ជួនកាលគេយករូបសញ្ញាធ្វើជាអក្សរមួយតួ ៗ ឬពាក្យមួយម៉ាត់ ហើយគេយករូបនោះមកដាក់ទន្ទឹមគ្នា ដូចជាឃើញរៀបពាក្យពេចន៍ដូច្នេះ ។

១.  រូបនេះជាពាក្យមួយថា «ដេហ្ស៊ីបា (dyeba) បានន័យថា «ម្រាមដៃ» ឬ «លេខ ១០.០០០» ។

 នេះជារូបផ្កាឈូកថា «Kha — ខា ឬ «ចំនួន ១.០០០» ។

ឯរូប  នេះ មានន័យថា «គោ» ។ តែដល់គេយករូបទាំងនេះមកដំរៀបឲ្យជាប់គ្នាទៅជា:



បើយើងសង្កេតមើលរូបនេះ ហើយអានទៅតាមរូបសព្ទថា «គោ ១ ក្រោមដៃ ៣ ផ្កាឈូក ២» តែអានតាមសញ្ញាសព្ទវិញថា «គោ ៣២.០០០ ក្បាល» ។

ខ – អក្សរសញ្ញាខាងគំនិត (Signes idéographiques)

ជួនកាលគេយករូបសញ្ញាមួយ ៗ ឲ្យឈ្មោះរបស់មួយតែម្ដង ៗ

ក.  រូបនេះបានន័យថា «ភ្នំ» ជួនកាលគេធ្វើរូបសញ្ញាហើយ គេអាចឲ្យន័យផ្សេង ៗ ពីគ្នា តាមតែយោបល់យល់ឃើញ

ខ.  រូបនេះមានន័យថា «ចាស់»,
មនុស្សចាស់, ឬមនុស្សកាន់ឈើច្រត់ ៗ

ឧទាហរណ៍នៅមួយទៀតដែលយើងអាចយកជូនបាន ដើម្បីឲ្យជាក់ច្បាស់ ដូចជា  រូបនេះ ៗ បើយើងសង្កេតទៅ រូបនេះអាចថា «កង់បួនជ្រុងទ្រវែង» តែគេបានសន្និដ្ឋានថា «អាងទឹក» ។ បើយើងពិនិត្យមើលរូប  នេះ មុខជាយើងពន្យល់ន័យថា «អាងទឹកដើរ» តែមិនដូច្នោះទេ រូបនេះគេសន្មត់ជាកិរិយាសព្ទមួយថា «ដើរ» ទៅវិញ ៗ

# ព្យញ្ជនៈ និងស្រៈនៃអក្សរ

របស់ជនជាតិអេហ្ស៊ីប



## ២ – សក្តិលេខរបស់ជនជាតិហ្វេនិស្យាង

(Hierographie phénicienne)

ភាសារបស់ជនជាតិហ្វេនិស្យាន ជាភាសាមួយនៅក្នុងអម្បូររបស់ភាសានៃជនជាតិហ្យូវីហ្វ (Juif) និងហេប្រ៊ូខាងជើង (Hebrew du nord) តែភាសារបស់ជាតិនេះ ស្រដៀងទៅនឹងភាសាជនជាតិហេប្រ៊ូជាង ។ ភាសានៃជនជាតិហ្វេនិស្យានប្លែកពីភាសាហេប្រ៊ូតែបន្តិចបន្តួចគឺ សណ្ឋានវិទ្យា (morphologie) និងពាក្យសព្ទ (Vocabulaire) ។

សក្តិលេខរបស់ជនជាតិហ្វេនិស្យាន ដែលអ្នកប្រាជ្ញបានរកឃើញមុនគេ នៅលើម៉ុងតម្កល់ព្រះសពនៃព្រះរាជាមួយព្រះអង្គ ទ្រង់ព្រះនាមជា ស៊ីដុន (Sidon) នៅឆ្នាំ ១៨៥៥ ។ អ្នកប្រាជ្ញបានពិនិត្យទៅដោយគ្មានសង្ស័យថាសក្តិលេខនេះ គេប្រើមុនគ្រិស្តសករាជ ៦០០ ឆ្នាំ ។

## អក្សររបស់ជនជាតិហ្វេនិស្យាង



## ៣ - សក្តិលេខនៅឥណ្ឌូចិន

(Hierographie indochinoise)

នៅឥណ្ឌូចិនយើង ក៏មានកុលសម្ពន្ធខ្លះប្រើសក្តិលេខ នៅពេលដែលជននោះមិនទាន់ទទួលអារ្យធម៌ខាងអក្សរសាស្ត្រមកប្រើប្រាស់ ។ ដើម្បីនឹងសរសេរប្រយោគឬពាក្យ គេគូររូបរបស់នោះ ៗ ធ្វើជាសញ្ញា ហើយគេឲ្យន័យទៅតាមគោលបំណងរបស់គេ ។

ឧទាហរណ៍ :




បើសង្កេតទៅតាមនេះ យើងអាចយល់បានថា ជនខ្មែរលើប្រហែលជាមានសញ្ញាគូមួយសំរាប់ប្រើជំនួសពាក្យមិនបាន ។ ខ្ញុំស្តាយណាស់ ដោយខ្ញុំស្រាវជ្រាវរកមើលឯកសារមិនទាន់ឃើញ ។

## ជំពូកទីពីរ

# កំណើតអក្សរខ្មែរ

អក្សរខ្មែរយើងពីបុរាណកាល តាំងពីសម័យនគរភ្នំ (Founan) មានសណ្ឋានទ្រង់ទ្រាយដូចអក្សរឥណ្ឌាប៉ែកខាងទក្ខិណបថ គឺអក្សរសម័យបល្លវៈ និង ចាលុក្យៈ ។ ហេតុដែលខ្មែរយើងមានអក្សរដូចអក្សរឥណ្ឌា ទំនងជាខ្មែរយើងសម័យនោះមិនទាន់បង្កើតសញ្ញាអ្វីជាអក្សរប្រើទេដឹង បានជាយើងខ្ចីយកអក្សរឥណ្ឌាសម័យបល្លវៈ និង ចាលុក្យៈ នៅដើមសតវត្សនៃគ្រិស្តសករាជ ។ អក្សរខ្មែរសម័យនោះ នៅលើផ្ទាំងសិលា មានសណ្ឋានដូចអក្សរឥណ្ឌាណាស់ សូមអានសិលាចារឹកឥណ្ឌាខាងក្រោយ ។

អ្នកប្រាជ្ញបារាំងជាច្រើនមានលោកបារថជាដើម បានសរសេរប្រៀបធៀបអក្សរខ្មែរដូច្នោះគឺ :

- អក្សរចារឹកនៃព្រះបាទស្រីមារៈ នៅវ៉ូកាញ់ ដូចអក្សរសិលាចារឹកនៃព្រះបាទរុទ្រទាមនិ នៅគិរនារ (Girnar) ឬដូចសិលាចារឹកសាតកណ៌វាសិដ្ឋីបុត្រ នៅកាន់ហេរី (Kan heri) ។

- អក្សរចារឹកហាន់ជ័យ ខេត្តកំពង់ចាម ដូចអក្សរចារឹកបាបបាថ នៅបត្តកល ។

-អក្សរចារឹកបាយ៉ាំងខេត្តតាកែវ ដូចអក្សរសិលាចារឹកមង្គលីឝ នៅបាតាម៉ ។

តាមសេចក្ដីពន្យល់របស់ភិក្ខុវិរិយបណ្ឌិតោ ប៉ាង-ខាត់ ថា «ឯកសារខ្លះក្នុងប្រទេសកម្ពុជាថា អក្សរខ្មែរយើងបែបអក្សរគ្រិន្ទ: តែតាមឯកសារបរទេសដែលខ្ញុំយកជាគោលក្នុងការស្រាវជ្រាវ មិនប្រទះឃើញដូច្នេះទេ ឃើញតែថា អក្សរដែលជនជាតិមនខ្មែរចាម ប្រើពីសម័យបុរាណ ហើយយាក្រោយៗ គ្នាមក បានជាយើងក្នុងបច្ចុប្បន្នកាលនេះ ជាអក្សរឥណ្ឌាទក្ខិណាបថ សម័យបល្លវៈ និង ចាលុក្យ: ដែលជាអក្សរបែបព្រាហ្មី មានទ្រង់ទ្រាយផ្សេងគ្នាពីអក្សរគ្រិន្ទ: ។ តាមការពិនិត្យមើលឃើញថា រូបអក្សរគ្រិន្ទ:ផ្សេងគ្នាពីសម័យបល្លវៈ និង ចាលុក្យ: ដែលជាអក្សរបែបអក្សរខ្មែរយើងពីបុរាណនោះឆ្ងាយណាស់ ។ ពាក្យថាគ្រិន្ទ នេះ ប្រែថា «គម្ពីរ» ទំនងជាអក្សរសំរាប់ចារលើស្លឹករឹតជាគម្ពីរ ក៏ជាអក្សរឥណ្ឌាខាងទក្ខិណាបថមួយដែរ តែមានដើមកំណើតផ្សេងពីអក្សរទាំងពួង ហើយប្រហែលជាកើតមានឡើងក្នុងជំនាន់ក្រោយផង ។

ដូច្នេះខ្ញុំយល់ឃើញថា អក្សរខ្មែរយើងមិនមែនជាបែបអក្សរគ្រិន្ទ:ទេ ជាអក្សរបែបសម័យបល្លវៈ និង ចាលុក្យ: ដែលជាអក្សរបែបព្រាហ្មី» ។

អក្សរខ្មែរយើង ជាអក្សរបែបសម័យបល្លវៈ និង ចាលុក្យ: ដែលជាបែបអក្សរព្រាហ្មី ដូច្នេះ ខ្ញុំសូមជូនបែបអក្សរព្រាហ្មី ជូនជាការពិនិត្យ:

(នៅមានត)

# រឿងសាមពុក

ឧកញ៉ាវិបុលរាជសេនា ង៉ូ កាន ប្រែរៀបរៀង

(តពក)

> រឿងសាមពុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាស់បើបានអាន
> នឹងចេះខំបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ
>
> យូរ អ៊ុន

លុះប្រឹក្សាយល់ឃើញព្រមគ្នាទាំង ៤ នាក់ហើយ ក៏ចាក់ឲ្យហូរលោហិតចេញលាយនឹងស្រាតាំងសច្ចាស្បថគ្នា រួចផឹកទាំងអស់គ្នាក្នុងខណៈនោះ, រួចអ៊ុយឡុង កេងជី កៀតមៅ កៀតបុក ក៏លាគិមហាន់ត្រឡប់ទៅកាន់ទីលំនៅរៀងខ្លួន, ឯអ៊ុយឡុង កេងជី ចាត់ចែងបាវព្រាវបានក្នុងម្នាក់ៗ ចំនួន ៣០០ ជាយ និងគ្រឿងសាស្ត្រាវុធត្រៀមទុក, ឯកៀតមៅ កៀតបុកនោះ បបួលបានពួកកៀនជាង ៣០០ នាក់កាន់អាវុធគ្រប់ដៃ លើកគ្នាទៅពួនបង្កប់នៅក្នុងព្រៃក្បែរទីក្រុង ធ្វើបែបជាលើកគ្នាដេញសត្វ ដើម្បីមិនឲ្យគេមន្ទិលសង្ស័យ ។

ឯគិមហាន់នោះ លុះដល់ថ្ងៃ ១៤ កើតក៏ចូលទៅរកអង់ប៊ិតគំនាប់គ្នា ហើយក៏និយាយនឹងអង់ប៊ិតថា សព្វថ្ងៃនេះ ស្រុកក៏សុខសាន្តសប្បាយ ដោយសារបុណ្យព្រះចៅវុយអង ទ្រង់បានប្រាប់ប្រាមសត្រូវពបចាបអស់ ហើយ ព្រឹកស្អែកជាថ្ងៃចូលឆ្នាំថ្មី ទម្លាប់អ្នកស្រុកប្រុសស្រី ត្រូវអុជគោម

នឹងទៀនធូបបូជា បណ្តានាម៉ឺនសព្វមុខមន្ត្រីនិងអាណាប្រជារាស្ត្រផ្ទាប់លេងមហោស្រពល្បែងតាមទំនៀមបុរាណ សូមឲ្យអ្នកជួយប៉ាវគងឲ្យអស់បណ្តារាស្ត្រលេងតាមទំលាប់សព្វទីលំនៅទៅចុះ នឹងបានជាទីរុងរឿងថ្កើងព្រះចេស្តា អង់បិតគិយល់ឃើញត្រូវ ទើបចាត់ប្រើទាហានឲ្យចេញទៅប៉ាវគងប្រាប់គ្រប់សព្វទិសនៅបណ្តារាស្ត្រឲ្យធ្វើតាមទម្លាប់ចូលឆ្នាំ ។

លុះដល់ថ្ងៃ១៥កើត ពេលយប់កណ្តាលអធ្រាត្រ អស់អ្នកស្រុកក៏អុជគោមតាមលំដាប់ផ្ទះសម្បែងស្វាងរុងរឿងទូទាំងទីក្រុង អស់បណ្តានាហ៊ឺនមុខមន្ត្រីធំតូច និងចាស់ប្រុសស្រីក៏ដើរលេងឈូតឆរជាទីត្រេកអរសប្បាយ ខ្លះលេងភ្លេងតូរ្យតន្ត្រីតាប៉ុប្រ តាមមហោស្រពល្បែងទាំងឡាយ លាន់ឮខ្ទរខ្ទាយពេញទីក្រុង អង់បិតឃើញដូច្នោះ ក៏សោមនស្សត្រេកអរណាស់ ឲ្យតែងតុលៀងអាហារនៅទីឈ្ពននោះ ។

គណៈនោះតិមហាទ ក៏នាំបក្សពួកទៅពួនបង្កប់នៅប្របទ្វារព្រះបរមរាជវាំងទិសខាងកើត អ៊ុយឡុង គេងជ័ និងគៀតម៉ៅ គៀតបុក ក៏នាំបក្សពួកទៅពួនបង្កប់នៅតាមកន្ទែងដែលមត់សញ្ញា ។ លុះដល់ពេលយាម ២ វេលាណា តិមហាទ ក៏តាំងដុតភ្លើងជាប្រេនដំបទ អ៊ុយឡុងឃើញដូច្នោះក៏តាំងតែដុតតទៅ ហើយដេញកាប់សម្លាប់មនុស្សម្នា ជាច្រួលច្របល់ គៀតម៉ៅ គៀតបុក ដែលនៅក្រៅក៏ផេងឃើញដូច្នោះ ក៏ដុតភ្លើងរាយតង

ឈ្មោះបង្រ្គះចូលមកជាពីរផ្លូវ ហើយស្រែកប្រកាសប្រាប់ដល់បណ្ដាអ្នកស្រុកទាំងពួងថា យើងនឹងបាត់សត្រូវផែនដីនេះណានឹងចូលខាងយើង ត្រូវស្រូតរូតមកជួយធ្វើការចុះ អស់នាម៉ឺនដែលមានចិត្តគិតគំគួនបួងបួងទាំងប៉ុន្មាន ក៏នាំចូលមកជាច្រើន ៗ

ឯអង្គបិតឃើញពន្លឺភ្លើងឆេះឡើងជាច្រើនដំបន់ ហើយកលដាលមកដល់ជិតទីឈ្មួនដូច្នោះក៏ភ័យណាស់ ស្ទុះឡើងសេះបរចេញទៅពីទីនោះ ប្រទះនឹងគេងដី ក៏ចូលប្រយុទ្ធគ្នាជាចលាចលអង្គបិតនោះត្រូវព្រួញអាវុធមុតជាប់អស់ទាំងខ្លួន ធ្លាក់ពីលើសេះហើយក៏លោតឡើងទៅវិញ ថែមត្រូវព្រួញទឹងអាវុធទៀត ក៏ធ្លាក់ពីលើសេះ ៤ ៥ ដង អង្គបិតឃើញលើសកម្លាំងនឹងទ្រាំតស៊ូពុំបាន ក៏បំផាយសេះរត់ទៅដល់មុខផ្ទះគិមហាន់ ហើយស្រែកហៅគិនហាន់ ៗ

ឯភរិយារបស់គិមហាន់បានឮដូច្នោះ ក៏សំគាល់ថាគិមហាន់ជាប្ដីទើបរត់ចេញទៅបើកទ្វារហើយសួរថា បានក្បាលអង្គបិតមកហើយឬអ្វី?ៗ អង្គបិតឮដូច្នោះក៏ភ័យស្លុតស្មារតីគិតថា កើតហេតុទាំងនេះព្រោះគិមហាន់ឯនបណ្ដាលឡើង ទឹងធ្វើយើងឲ្យវិនាសអន្តរាយ ហើយក៏បរសេះបង្ហួសទៅ ប្រទះនឹងវោហ៊ាវលើកទាហានមកប្រហែល ១.០០១ នាក់, អង្គបិតក៏ប្រាប់ពត៌មានឲ្យដឹង, វោហ៊ាវឮហើយក៏នាំទាហាន ស្រូតរូតប្រញាប់ទៅឃើញភ្លើងឆេះពលជាប់ទៅដល់ទ្វារព្រះរាជវាំងជាច្រើនអន្ទើ ហើយ

ឆេះរាលចូលទៅដល់ទ្វារក្បែរហាងឡៅ ក៏ឲ្យទាហានចូលទៅជួយលត់ភ្លើងនោះជាប្រួលប្របល់ ។

ឯព្រះចៅហៀនតេក៏ក្រោកគេចរំដោះពីភ្លើងវិលចូលព្រះរាជវាំង សព្វសំឡេងមនុស្ស ក៏ស្រែកឡាន់រំពងទាំងក្រុងថាយើងទឹងក៏បាត់ពួកសត្រូវពេជសម្បត្តិចេញ ដើម្បីទឹងវ៉ាងុកបំរុងព្រះចៅហៀនតេ ឲ្យបានគង់នៅជាសុខតទៅ ខណៈនោះ បណ្ដាបងប្អូនទឹងបក្សពួកចុងថូ ក៏ប្រជុំគ្នាជាពួក ៗ មកប្រចាំការរក្សាតាមព្រះរាជវាំងគ្រប់ទ្វារ ។

ឯហៃហ៊្វុន ដែលចុងថូប្រើឲ្យមកចាំមើលហេតុការខាងក្រៅស្រុកនោះ លុះឃើញពន្លឺភ្លើងឆេះឡើងក្នុងក្រុងសន្ធឹកសន្ធាប់ណាស់ ក៏ឲ្យទាហាន ១ កងទៅជួយការពារលត់ភ្លើងនោះ ឲ្យទាហាន ១ កងទៀតនៅការពារពីក្រៅ ចៅហ៊ុយឃើញទាហានហៃហ៊្វុនលើកចូលទៅក៏ត្រេកអរណាស់ បណ្ដោយទាហានរបស់ខ្លួនឲ្យចូលទៅជួយលត់ភ្លើង ឯពួកចុងថូដែលលបលួចដុតភ្លើងឲ្យឆេះផ្ទះសំបែងនោះ ក៏កាប់សម្លាប់គ្នាស្លាប់ជាច្រើនណាស់ ទាល់តែភ្លឺស្រាង ។

ឯអ៊ុយឡុងទឹងកេងជីនោះពួកម៉ាតក៏កាន់តែរលោះអស់ទៅ ទឹងកេអ្នកឯណាបញ្ចូលជាពួកបំពេញឡើងគ្មាន មានបាវម្នាក់រត់មកប្រាប់ថា ពួកចុងថូត្រូតគ្នាសម្លាប់គិមហាន់ កៀតម៉ៅទឹងកៀតបុកស្លាប់អស់ទៅហើយ អ៊ុយឡុងទឹងកេងជី ក៏ភ័យស្លុតស្មារតី នាំបាវព្រាវដែលសល់តាំងប៉ុន្មាន បំពារ

បំពានចំណាយភ្លើងតែទៅមាត់ទ្វារក្រុង បទះនឹងហៃហ៊្វីទុន លើកទាហានមកព័ទ្ធកំផែងខាងនៅពីមុខណែនណាស់ ហៃហ៊្វីទុនឃើញប្ចុក, ក៏ឲ្យទាហានដេញកាប់សម្លាប់បាវព្រាវអ៊ុយឡុងនឹងកេងជីស្លាប់អស់ នៅតែអ៊ុយឡុងនិងកេងជី ២ នាក់ ហៃហ៊្វីទុនឲ្យចាប់បានយកទៅឃុំទុកគុកយ៉ាងខ្ជាប់ខ្ជួន ហើយនាំទាហានទៅជួយលត់ភ្លើងដែលឆេះនោះរលត់អស់ទៅ ទើបឲ្យនាំយកខ្លួនអ៊ុយឡុង កេងជីមកពិចារណាសួរ បានសេចក្ដីហើយ ក៏ឲ្យទាហានទៅចាប់គ្រប់គ្រួនិងបងប្អូនញាតិសន្ដានអ៊ុយឡុង កេងជី កៀតមៅ កៀតបុក តិមហាន់មកដាក់គុកទាំងអស់ ទើបហៃហ៊្វីទុនវាត់បំរើសេះឲ្យកាន់សំបុត្រទៅទូលព្រះចៅវុយអងតាមហេតុនេះគ្រប់ប្រការ ។

ចូឆ្ងដឹងការតាមសំបុត្រហើយ ក៏ឲ្យធ្វើបុតហ្វាយតបទៅវិញសេចក្ដីថាឲ្យហៃហ៊្វីទុនសម្លាប់អ៊ុយឡុងនិងកេងជីហើយ និងស្ម័គ្របក្សពួកគ្រួសារញាតិកា អាកំណាចទាំងអម្បាលនោះឲ្យអស់កុំឲ្យសល់ ហើយឲ្យហៃហ៊្វីទុនយកខ្លួនបណ្ដានាម៉ឺនធំ តូចទាំងប៉ុន្មានដែលមានក្នុងក្រុងហ៊្វីគោបញ្ជូនទៅឯចូឆ្ងនៅស្រុកសៀបកុន ដើម្បីនឹងពិចារណាឯង ។

ហៃហ៊្វីទុនទទួលបង្គាប់តាមបុតហ្វាយ ក៏ឲ្យយកអាកំណាចដូចមានឈ្មោះទាំង ៩ នាក់, និងស្ម័គ្របក្សពួកគ្រប់គ្រួញាតិសន្ដានទៅប្រហារជីវិតទាំងអស់ ឯអ៊ុយឡុងនឹងកេងជីក៏មិនបានកោតញញើតនឹងសេចក្ដីស្លាប់សោះ ចេះតែទ្រគោះដេរចូឆ្ងមិនឈប់មាត់ ទាល់តែទាហានចុះដាវប្រហារ

ជីវិតតែម្តង ហើយហៃហ្លួងក៏ឲ្យចាប់អស់នាម៉ឺនមុខមន្ត្រីទាំងធំ តូច បណ្តាដែលមានក្នុងក្រុងហ្វ៊ុតោនោះ បញ្ជូនទៅឲ្យចូវឆូឯស្រុកងៀបកុន ។

ចូវឆូក៏ឲ្យយកខ្លួននាម៉ឺនមុខមន្ត្រីទាំងអស់នោះទៅប្រជុំនៅមុខព្រះលាន ហើយឲ្យយកទង់ពណ៌ក្រហមដោតម្ខាង យកទង់សដោតម្ខាង ចម្ងាយពីគ្នាប្រហែល ១០ ស៊ិន ហើយចូវឆូនិយាយថា កាលកោះតោះកំណាចទាំង ៥ នាក់ គប់គិតគ្នាដុតផ្ទះសំបែង អ្នកស្រុកក្នុងក្រុងហ្វ៊ុតោឆេះឡើងនោះ អស់អ្នកឯងពីកល់គ្នា តើអ្នកឯណាបានទៅជួយលត់ភ្លើងខ្លះ បើនណាជួយលត់ត្រូវទៅអង្គុយខាងទង់ក្រហម នរណាដែលមិនបានទៅជួយលត់ទេ ឲ្យទៅអង្គុយខាងទង់ស ។

នាម៉ឺនមុខមន្ត្រីទាំងអស់នោះ លុះបានឮចូវឆូថាដូច្នោះ ក៏នាំគ្នាគិតថា ចូវឆូឲ្យធ្វើដូច្នេះ ប្រាថ្នានឹងយកទោសអ្នកដែលមិនបានទៅជួយលត់ភ្លើង ទើបនាំគ្នាទៅខាងទង់ក្រហមដល់ ៤,៥ ភាគ ឯនាម៉ឺនដែលមានចិត្តទៀងត្រង់មិនបានទៅជួយលត់ភ្លើងនោះ ក៏នាំគ្នាទៅខាងទង់សប្រ-ហែល ១ ភាគ ។

ចូវឆូឃើញដូច្នោះក៏ថា បណ្តាអ្នកដែលទៅជួយលត់ភ្លើងនោះ គឺមិនមែនទៅដោយសុចរិតទេ ទៅព្រោះចូលគំនិតគ្នានឹងអាក្បត់ ប្រាថ្នានឹងរួមបញ្ចូលគ្នាមកប្រទុស្តរ៉ាយយើងប្រាកដ ថាហើយក៏ឲ្យចាប់ខ្លួននាម៉ឺនដែលទៅនៅខាងទង់ក្រហមប្រហែល ៣០០ បាយនាក់ទៅប្រហារជីវិត

នៅក្បែរមាត់ទន្លេសៀងហោ ឯនាម៉ឺនដែលទៅនៅវាំងទង់សនោះ ចូច្ចូ ថាអ្នកទាំងអស់នេះ សុទ្ធតែមានចិត្តសុចរិតត្រង់នឹងយើងក៏បំណាច់រង្វាន់ តាមសមគួរ ហើយឲ្យគង់ស័ក្តិយសនៅដូចដែល ឲ្យវិលត្រឡប់ទៅនៅ ធ្វើការរាជការឯក្រុងហ៊ូគោវិញ ។

ខណៈនោះ មានសំបុត្រចោហ៊ុំប្ដឹងមកចូច្ចូសេចក្ដីថា អង់ប៊ិតនោះ ត្រូវអាវុធមានរបួសជាច្រើនអន្លើ របួសទីងព្រួញកំរើបខ្លាំង ក៏ទទួល អនិច្ចកម្មទៅហើយ ចូច្ចូដឹងដូច្នោះក៏មានចិត្តអាណិតណាស់ ទើបបើក មាសប្រាក់ឲ្យទៅតែងការសពអង់ប៊ិតបញ្ចុះទុកក្នុងស្រុកហ៊ូគោ ហើយឲ្យ តែងសំបុត្រទៅតាំងចោហ៊ុំឲ្យបង្គាប់បញ្ជាទាហាន ទាំងពួងក្នុងក្រុងហ៊ូគោ ឲ្យចុងអ៊ីផាមហាចបរាជហ៊ូហ៊ុមផាហ្វាល័ដ្ឋចបរាជ ឯវីនាម៉ឺនដែលគ្មានខ្លួន នោះ ក៏វាត់ទាហានធំ តូច តាំងឡើងតាមថ្នាក់ នឹងគុណបំណាច់តាម ដំណែង ។

ចូច្ចូគិតថា ក្លួនឡៀបំណានក្នុងក្បួននាំនាយពិតប្រាកដណាស់ ក៏វាត់ មាសប្រាក់ នឹងរបស់ទ្រព្យមានដំឡៃ ឲ្យជាបំណាច់រង្វាន់ក្លួនឡៀ ។ គំនាប់ទទួលហើយថា ខ្លួនខ្ញុំបាទនេះមានចិត្តស្ម័គ្រស្រឡាញ់តែស្នេងទៅ នៅក្នុងវង្សភក្រ័ថ្ន និងទទួលយកមាសប្រាក់នៅអស់របស់ទ្រព្យទៅនោះ មិនជាប្រយោជន៍អ្វីទេ សូមជូនលោកទុកចែកពលទាហានតាមត្រូវការចុះៗ

(នៅមានត)

# រឿងបៅរលាដូង

( រឿងព្រេងខ្មែរ )

(ក)

លោក ខ. តាម ស្រាវជ្រាវនិងរៀបរៀង

ព្រះអង្គម្ចាស់ក្សត្រីឡើងដើមឈើ ដើម្បីនឹងលបមើលឲ្យឃើញច្បាស់ថា តើបៅរលាដូងធ្វើដូចម្ដេចខ្លះ ៗ ព្រះនាងទតរកមើលបៅរលាដូងក្រែងនៅឃ្វាលក្របី តែព្រះនាងរកមើលទៅហ្វូងក្របី មិនឃើញបៅរលាដូងសោះ ៗ ព្រះនាងទតដូងវិញ ស្រាប់តែឃើញបៅរលាដូងកំពុងតែចេញពីក្រោម មានសម្បុរល្អរកគូប្រៀបពុំបាន នៅម្រាមដៃមានពាក់ចិញ្ចៀនព្រះទម្រង់មួយវង់ រស្មីដូចជាព្រះចន្ទពេញបូណ៌មី ហើយមានមនុស្សពោនក្មេងដូនជាកិត្តិយសផង ៗ បៅរលាដូងអង្គុយនៅចំកណ្ដាល ៗ ព្រះនាងទតឃើញហើយ ក៏មានចិត្តលួចស្នេហាក្រៃចខ្លួនៈតែរបូតព្រះហស្ត ធ្លាក់មកដី ៗ ព្រះនាងលាក់រឿងនេះទុកមិនឲ្យនរណាដឹងឡើយ ៗ

បៅរលាដូងនឹកថាថ្ងៃនេះ ម្ដេចបានជាព្រះអង្គម្ចាស់ក្សត្រីយកបាយមកឲ្យស៊ីយូរម្ល៉េះ ហើយក៏បញ្ជាឲ្យមនុស្សចូលទៅក្នុងដូងវិញ ឯខ្លួនឯងក៏ត្រឡប់ចូលទៅក្នុងក្រោមវិញ ៗ ចំណែកព្រះអង្គម្ចាស់ក្សត្រី ឃើញរូបសម្បត្តិរបស់បៅរលាដូងហើយ ក៏មានសេចក្ដីស្នេហាដ៏ពោរពេញទន់ដៃ ជើង តែព្រះនាងមិនដឹងជាគិតធ្វើដូចម្ដេចឲ្យសេចក្ដីស្នេហានេះបានសំរេច ៗ ព្រះអង្គម្ចាស់ក្សត្រីលបមើលដូច្នោះហើយ ក៏ចុះយកបាយទៅ

ឲ្យចៅរលោផុង តែព្រះនាងធ្វើអាការដូចជាមិនដឹងការណ៍អ្វីសោះ ទើបព្រះនាងក៏ហៅថា „អើបងចៅរលោផុង! សូមអញ្ជើញមកយកបាយទៅពិសា" ។ ចៅរលោផុងឮហើយក៏ប្រមៀលខ្លួនទៅយកបាយបរិភោគ ហើយនិយាយទៅព្រះអគ្គម្ចាស់ក្សត្រីថា „ព្រះអគ្គម្ចាស់ក្សត្រី សូមទ្រង់កុំហៅទូលព្រះបង្គំថា បង សូមហៅទូលព្រះបង្គំដូចជាក្មេងធម្មតាទៅចុះ" ។ ព្រះអគ្គម្ចាស់ក្សត្រីថា ពេលមុន ខ្ញុំមិនទាន់ស្និទ្ធស្នាលនឹងបង ដូច្នេះហើយបានជាជួនកាលខ្ញុំហៅបងដូចជាក្មេងធម្មតា ជួនកាលខ្ញុំហៅថាលោក! ឥឡូវខ្ញុំយល់ថាបងនៅជាមួយខ្ញុំ ទំជួយឃ្វាលក្របីខ្ញុំតែម្នាក់ឯងមិនដែលឲ្យបាត់ក្របីមួយសោះ ហើយម្យ៉ាងទៀតបងបានជួយកាប់ល្មើខ្ញុំបានច្រើនប្រហែលមនុស្សរាប់ម៉ឺននាក់ ។ ខ្ញុំមានសេចក្តីករុណាចំពោះបងណាស់ព្រោះបងនៅឃ្វាលក្របីម្នាក់ឯងនៅក្នុងព្រៃ ហើយបងបានជួបប្រទះនឹងសេចក្តីលំបាកមួយរយចំពូក ។ ខ្ញុំស្តាយណាស់ធ្វើម្តេចឲ្យបងបានកើតជាបងរបស់ខ្ញុំបង្កើត ។

ចៅរលោផុងតបថា „ទូលបង្គំមិនដឹងជាគិតដូចម្តេចទេ ស្រេចតែព្រះនាងសព្វព្រះទ័យចុះ ចង់ហៅខ្ញុំថាក្មេងក៏បាន ថាលោកក៏បាន ថាបងក៏បាន ទូលព្រះបង្គំមិនយាក់ឡើយ ។

ព្រះអគ្គម្ចាស់ក្សត្រីត្រឡប់មកព្រះរាជដំណាក់វិញនៅពេលថ្ងៃសៀល ទើបព្រះរាជាសង្ស័យហើយទ្រង់មានព្រះឱង្ការថា „នែកូន! កូនយកបាយ

ទៅឲ្យចៅលាផូនទៅឯព្រៃម្ដេចក៏គួរនៅជាមួយពាក់យូរម្ល៉េះ ? ព្រះរាជធីតាកុហកព្រះបិតាម្ដងទៀតថា វង្វេងផ្លូវ ។

ព្រះរាជាហៅព្រះរាជបុត្រីទាំងអស់មកជុំ ហើយថា ស្អែកនេះឲ្យកូនទាំងអស់ជូននាងពៅយកបាយទៅឲ្យចៅលាផូន ឯព្រះរាជបុត្រីច្បងខ្សឹបប្រាប់ព្រះរាជបុត្រីឯទៀត ៗ ថា យើងកុំទៅទុកឲ្យតែនាងពៅគេទៅតែម្នាក់ឯងចុះ ព្រោះគេមិនសូវខ្ពើមមនុស្សខុសខ្នាត គ្មានជើងគ្មានដៃ ប្រមៀលខ្លួនមើលតែជុំ ៗ ចុះបើយើងយកបាយទៅ ស្រាប់តែវាប្រមៀលខ្លួនមក យើងមិនភ្ញាក់លោះព្រលឹងអស់ហើយ យើងកុំយកទៅ បើនាងពៅមិនយកទៅទេ ទុកឲ្យអាលាផូនអត់បាយស្លាប់ទៅចុះ ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ព្រះរាជបុត្រីច្បងហើយក៏មានព្រះបន្ទូលថា បើដូច្នោះទុកឲ្យនាងពៅគេទៅចុះ ។ គ្រាន់តែឮពាក្យនេះភ្លាម នាងពៅហាក់ដូចជាបានទៅកើតលើស្ថានសួគ៌មុនទៅហើយ ហើយក៏យកបាយទៅឲ្យចៅលាផូន ។

ចៅលាផូនយកក្របីទៅឃ្វាល ហើយជប់មនុស្សឲ្យមកជួយឃ្វាលទៀត ។ នៅល្ងាចថ្ងៃនោះ ខ្យល់ព្យុះសង្ឃរាលិតព្រៃកមើលអ្វីមិនឃើញសោះ ចំណែកចៅលាផូន ក៏បង្គាប់ឲ្យមនុស្សទាំងនោះឲ្យយកវល្លិ៍មកពាក់តោញក្របីហើយកៀងមកផ្ទះ ។ ដល់បកជិតដល់ផ្ទះ ចៅលាផូនបង្គាប់ឲ្យមនុស្សចូលទៅក្នុងដី ឯខ្លួនឯងកៀងក្របីទៅពេញទីធ្លាដើម្បីឲ្យ

គេយកវល្លិ៍ចេញពីក្របី ហើយប្រមៀលខ្លួនទៅកំដៅខ្លួននៅក្នុងបង្ក្រាន ។

នៅពេលនោះ ព្រះរាជបុត្រីច្បងនិងព្រះរាជបុត្រីបន្ទាប់កំពុងតែទៅចំអិនព្រះក្រយាទៅក្នុងផ្ទះបាយ ឃើញចៅស្រលាដូងអង្គុយអាំងភ្លើង ក៏ជេរប្រទេចថា «នែអាកំរក់! នៅអាំងភ្លើងដល់ណាទៀត ម្តេចមិនទៅឃ្វាលក្របីទៅ ចេញពីនេះ រមៀលចេញពីកន្លែងនេះ អាកន្ទ្វេងអញឆ្អែតចិត្ត ណាយ ។

ចៅស្រលាដូង ធ្វើពុតជាត្បិតប៉ះព្រះបាទព្រះអង្គម្ចាស់ក្សត្រីច្បង ។ ព្រះរាជធីតាច្បងជេរប្រទេចថា «នែ! អាកំរក់ម៉េចបានជាឲ្យប៉ះជើងអញ! ប្រឡាក់អស់ជើង! ទៅ! ប្រមៀលចេញពីកន្លែងនេះទៅ! ប្អូនពៅឮបងស្តីជេរឲ្យចៅស្រលាដូងដូច្នោះ ព្រះនាងមានសេចក្តីឈឺចាប់ជាពន់ពេកចំពោះបងស្រីទាំងពីរព្រះអង្គ ។ ព្រឹកឡើងទៀតចៅស្រលាដូងទៅឃ្វាលក្របីដូចធម្មតា ។ ឯព្រះរាជាក៏បង្គាប់ថា «ថ្ងៃនេះចៅមិនបាច់ហោចវល្លិ៍ទៀតទេ ព្រោះយើងមានវល្លិ៍ច្រើនហើយ ចូរចៅកាប់ឆ្លោលចងជាបាច់ហើយ សឹមខ្ញុំឲ្យមនុស្សទៅដឹកយក» តែក្នុងព្រះទ័យរបស់ព្រះរាជានឹកថា ចៅស្រលាដូងពិតជាមនុស្សមានមន្តសិល្ប៍អ្វីមិនខាន ។

ថ្ងៃឡើងព្រះអង្គម្ចាស់ក្សត្រីពៅយកបាយទៅឲ្យចៅស្រលាដូងទៀត ដោយមានទាំងកន្ទ្រេងវេចស្ងោម្ជូរផង ។ ព្រះនាងទៅដល់ព្រៃដែលចៅស្រលាដូងទៅឃ្វាលក្របីនោះ ព្រះអង្គឮសូរមាត់មនុស្សពេញតែព្រៃកាប់

ឈើធ្វើជាថ្ពោល សើចសប្បាយដូចជាទៅក្នុងពិធីបុណ្យអ្វីមួយ តែដល់ព្រះនាងយាងទៅដល់កន្លែងសំឡេងនោះភ្លាម ស្រាប់តែសំឡេងនោះបាត់ស្ងាត់ឈឹងឃើញតែស្នាមកាប់ឈើ ហើយទឹងចៅរលាដូងអង្គុយឃ្លាល ក្រាបក្រង់សម្ងាត់ឯង ។

ព្រះអង្គម្ចាស់ពៅក៏ឲ្យបាយហើយនឹងកន្សែងស្លាម្ររទៅចៅរលាដូង ។ ចៅរលាដូងស្រាយកន្សែងឡើងឃើញស្លាម្ររៀបចំយ៉ាងប្រណីត ហើយទើបសួរទៅព្រះនាងថា «ព្រះនាង! នរណាបៀកស្លាម្ររនេះ? ព្រះនាងពៅមានបន្ទូលថា «ខ្ញុំ! ខ្ញុំបៀកស្លាម្ររនេះដោយដៃខ្លួនខ្ញុំ ហើយខ្ញុំសូមផ្តាំថា ដល់បងរកប្រពន្ធ ត្រូវរកនារីណាដែលចេះបៀកស្លាម្ររដូចខ្ញុំអ៊ីចឹង ប៉ុន្តែកុំទៅនិយាយប្រាប់គេថា ខ្ញុំបៀកស្លាមកជូនបងណា» ។ ចៅរលាដូងតបទៅព្រះនាងពៅវិញថា «ទូលបង្គំដឹងគុណព្រះនាងមិនភ្លេចទេ ចំពោះបណ្តាំនេះ» ។ ព្រះនាងក៏សួរទៅចៅរលាដូងថា «បងកាប់ថ្ពោលនេះពីកាលណាមកបានជាច្រើនម្ល៉េះ? ចៅរលាដូងតបថា «ទូលបង្គំកាប់តាំងពីព្រឹកម្ល៉េះ» ។ «បើដូច្នោះ សូមបងកាប់ថ្ពោលមួយឲ្យខ្ញុំមើលមើល៍ បងកាប់ដូចម្តេច?» ចៅរលាដូងឆ្លើយតបថា ទូលបង្គំហាត់ណាស់កាប់មិនបានជាដាច់ខាត» ។ ព្រះនាងពៅក៏ទ្រង់ព្រះសិតាការ ហើយក៏យាងត្រឡប់ទៅដំណាក់វិញ ។

ចៅហេដូងហៅមនុស្សពីក្នុងផងឲ្យមកកាប់ឈើថ្ពោលទៀតរហូតទាល់

ល្ងាចបានថ្នោលចំនួនមួយរយនេះ ។ ពេលល្ងាចចៅលាដូងគៀងក្របីទៅក្រោលវិញហើយទៅទូលព្រះរាជាថា «បពិត្រព្រះអង្គ ទូលព្រះបង្គំកាប់ថ្នោលបានហើយ សូមព្រះអង្គឲ្យគេទៅយករទេះទៅដឹកចុះ» ។ ស្អែកឡើងព្រះរាជាឲ្យអាមាត្យយករទេះពីរទៅដឹកថ្នោល ។ អាមាត្យទៅឃើញថ្នោលគរដូចភ្នំ ក៏យកតែពីររទេះហើយមកទូលព្រះរាជាថា «សូមទូលព្រះអង្គ ចៅលាដូងកាប់ថ្នោលគរដូចភ្នំ ប្រហែលមួយរយរទេះទើបដឹកហើយ» ។ ព្រះរាជាក៏បង្គាប់ឲ្យគេឈ្នួលរទេះអ្នកស្រុកទៅដឹកថ្នោលឲ្យអស់ពីព្រៃ ។

កិត្តិស័ព្ទចៅលាដូងល្បីសុសសាយពេញតែប្រទេស នៅកន្លែងណាក៏ឮគេនិយាយថា ចៅលាដូងគ្មានដៃ គ្មានជើងហេតុដូចម្ដេចបានជាកាប់ថ្នោល ហ្មោចល្ងៃ ឃ្វាលក្របី ដែលមនុស្សរាប់រយនាក់ទើបធ្វើកើត នេះពិតជាចៅលាដូងមានបេះមន្តគាថាវិជ្ជាអ្វីមិនខាន ។ មនុស្សម្នាដើរទៅក្បែរព្រះលានស្ដេច តែងកើតសេចក្ដីស្ញប់ស្ញែងចំពោះកំលាំងរបស់ចៅលាដូងហ្មោចល្ងៃ កាប់ថ្នោលមកគរពេញតែវាំងហ្លួង ។

ចៅលាដូងនៅឃ្វាលក្របីព្រះរាជាចំនួនមួយអន្លើមាស ទើបទៅលេងផ្ទះម្ដង ហើយវាប្រាប់ម្ដាយវាថាឲ្យទៅដណ្ដឹងកូនស្រីពៅឲ្យវា តែម្ដាយមិនហ៊ានចូលទៅស្ដីដណ្ដឹងកូនស្ដេចឲ្យចៅលាដូងឡើយ ហើយម្ដាយតបទៅកូនថា «កូនឯងគ្មានដៃ គ្មានជើង ចំណែករូបរាងទៀត

សែនអាក្រក់ ហើយមកឲ្យម៉ែទៅដណ្ដឹងព្រះនាងទៅ ម៉ែមិនហ៊ានទៅទេ» ។ ចៅស្រលាដូងមិនស្ដាប់ម្ដាយឡើយ ចេះតែទទូចបង្ខំម្ដាយឲ្យទៅស្ដីដណ្ដឹងនាងទៅ ។ ហេតុដល់ម្ដាយប្រថុយទៅស្ដីដណ្ដឹងកូនស្ដេចឲ្យចៅស្រលាដូងដោយសេចក្ដីករុណាកូន ។

ម្ដាយចៅស្រលាដូងទៅដល់ទ្វារវាំង ស្រាប់តែផ្លែត្របែក ហើយអ្នកយាមក៏ស្រែកសួរមកគាត់ថា «យាយណាមករកអ្វីក្នុងវាំងនេះ បានជាផ្លែត្របែកម្ល៉េះ?» ។ ម្ដាយចៅស្រលាដូងឆ្លើយតបទៅថា «ខ្ញុំ! មកមានការជាមួយព្រះរាជា» អ្នកយាមស្រែកសួរថា «មានការអ្វីប្រាប់មកមើល» ។ ម្ដាយចៅស្រលាដូងឆ្លើយថា «កូនខ្ញុំចៅស្រលាដូងចង់បាននាងទៅព្រះរាជធីតាធ្វើជាភរិយា ខ្ញុំពុំមិនហ៊ានទេ តែដោយសារពឹងបង្ខិតពេក ទើបខ្ញុំដាច់ចិត្តប្រថុយមកដណ្ដឹងព្រះរាជបុត្រីទៅតាមសេចក្ដីអង្វរ» ។

កាលមាត្យទៅក្រាបទូលព្រះរាជាហើយ ព្រះអង្គក៏អនុញ្ញាតឲ្យម្ដាយចៅស្រលាដូងចូលទៅគាល់ ។ គាត់សារភាពថ្វាយព្រះរាជាដូចបានពណ៌នាឲ្យអាមាត្យស្ដាប់ ព្រះអង្គក៏មានព្រះបន្ទូលវិញថា «ខ្ញុំស្រឡាញ់ណាស់ចៅស្រលាដូង កូនខ្ញុំ ៧ នាក់ មិនដឹងជាមួយណាគេស្រឡាញ់ចៅស្រលាដូង ចាំខ្ញុំហៅបុត្រីខ្ញុំទាំង៧មកសួរសិន» ។ ព្រះអង្គហៅព្រះរាជបុត្រីទាំង៧ ព្រះអង្គហើយមានព្រះបន្ទូលថា «ម៉ាលកូន! នាងណាសុខចិត្តស្រឡាញ់ចៅស្រលាដូង? បើនាងណាម្នាក់ស្រឡាញ់ពិតនឹងរៀបចំការពារហ៍ហមដល់ឲ្យ?»

ព្រះរាជបុត្រីច្បងនឹងបន្ទាប់ តបទៅព្រះរាជាថា «បិតា! ទូលបង្គំមិនស្រឡាញ់ទេ យកប្ដីមកធ្វើអ្វីដុនយ៉ាងនេះនោះ គ្មានដៃ គ្មានជើងចង់ធ្វើប្ដីគេធ្វើម្ដេចកើត ។ ឲ្យខ្ញុំរៀបការជាមួយមនុស្សគំរក់ដូច្នេះ កូនមិនព្រមរៀបការទេ» ។ ព្រះរាជាក៏សួរទៅនាងពៅថា «មើលកូនពៅ! កូនស្រឡាញ់ចៅរលាដូងឬទេ? នាងពៅទូលតបថា បិតា! កូនគ្មានជំទាស់ព្រះបិតាទេ តាមតែព្រះបិតាឲ្យកូនទៅរៀបការជាមួយនរណា ក៏កូនពុំប្រកែកដែរ ឥឡូវបើបិតាសួរកូនថាស្រឡាញ់ ចៅរលាដូងដែរនោះ កូនមិនយល់ទាស់ទេ កូនអាចបំពេញព្រះទ័យព្រះបិតាបាន» ។

ព្រះរាជាក៏មានបន្ទូលទៅកាន់មាតាចៅរលាដូងថា «ឥឡូវកូនពៅខ្ញុំសុខចិត្តរៀបការជាមួយចៅរលាដូងហើយ ។ ចាំថ្ងៃណាមួយបានពេលល្អ យើងនឹងរៀបការកូនយើង ។ ឥឡូវលោកយាយអញ្ជើញទៅផ្ទះវិញ ហើយជំរាបបងប្អូនញាតិសន្ដានចុះ ថាខ្ញុំសុខចិត្តឲ្យកូនស្រីពៅធ្វើជាប្រពន្ធចៅរលាដូងហើយ» ។

ម្ដាយចៅរលាដូងត្រឡប់ទៅផ្ទះវិញ ឯព្រះរាជាក៏ផ្ញើព្រះរាជសារទៅគ្រប់កន្លែងថា «ស្ដេចនឹងរៀបអាពាហ៍ពិពាហមង្គលការកូនពៅនៅថ្ងៃពុធ សូមអញ្ជើញលោកអ្នកមកពិសាភោជនាហារតាមគាប់ចិត្ត» ។ ព្រះរាជាបង្គាប់ឲ្យអាមាត្យប្រុងប្រៀបរៀបចំម្ហូបអាហារ មានសាច់សត្វស្រុក ព្រៃគ្រប់បែប ហើយមានស្រាគ្រប់ពីយកមកជប់លៀងការកូនស្រីពៅជាមួយចៅរលាដូង។

(នៅមានត)

# ព្រះរាជនិពន្ធរាមកេរ្តិ៍

## ភាគ ៤

### (ក)

លោក ឌ. ពាម ស្រាវជ្រាវ និង រៀបរៀង

ឯព្រះបាទសហមលីវ័ន បានស្ដាប់ព្រះរាជបន្ទូលដូច្នោះហើយ ក៏មានព្រះទ័យនោះត្រេកអរ សាទរ សោមនស្សក្រៃពេក ហើយព្រះអង្គទ្រង់ព្រះរាជទាន ព្រះទំរង់សង្វារមកុដកែវមណី បណ្ដាពួកពលសេនាមាត្យយោធាទាំងពួង ក៏ទ្រង់ព្រះរាជទានតាមការតែគ្រប់ ៗ គ្នាហោង ។

គ្រានោះ ឯព្រះបាទឡាស្សរៀន ក៏ក្រាបបង្គំទូលយកសង្វារមកុដកែវមណីហើយ ទ្រង់មានព្រះចិន្ដានោះត្រេកអរណាស់ ស្រេចហើយក៏ក្រាបថ្វាយបង្គំលា លើកកងសេនាយោធាវិលទៅកាពចុរីវិញហោង ។

កាលនោះ ឯព្រះបាទកាលនាគរាជ លុះត្រឡប់វិលមកស្ថានពិមានគាត់កាលណាហើយ ក៏ចូលទៅដល់ខែនទីក្រឡាបន្ទំស្រេច ក៏ព្រួយព្រះទ័យណាស់ ទើបត្រាស់ព្រះឧង្ការទៅនឹងព្រះអគ្គមហេសី ថាប្អូនអើយបងលើកកងទ័ពទៅច្បាំងដណ្ដើមយកនគរគេនោះ ឥឡូវនេះបងក៏ចាញ់គេដៃព្រះបាទឡាស្សរៀន គេចាប់ខ្លួនបងបាន ហើយគេក៏លែងបង ទុកជីវិតឲ្យបងបានរួចរស់វិលត្រឡប់មកនគរវិញ បានឃើញមុខប្រពន្ធកូន កុំអីបងក៏ខានឃើញមុខទាំងហោង ។ ឥឡូវនេះគេមានគុណនឹងបងណាស់ បងគិតទៅមិនដឹងជាមានទីងបានរបស់អ្វីទឹងតបស្នងសងគុណគេ បងតើងទៅ

ឃើញតែព្រះរាជធីតាយើងៗ នឹងយកទៅថ្វាយគេហោង ៗ ការនេះណ្ហើយ ចុះបងសូមអង្វរចិត្តឲ្យអាណិតបងកុំតូចចិត្តទោមនស្សឡើយ ៗ កាលនោះ នាងប្រញាទេវីអគ្គមហេសី លុះបានស្តាប់សម្តេចព្រះស្វាមីហើយ ក៏ឆ្លើយទូលតបព្រះស្វាមីថា ព្រះអង្គកុំព្រួយព្រះទ័យឡើយ សូមព្រះអង្គទ្រង់កំសាន្តព្រះទ័យកុំទ្រង់ព្រះកន្សែងសោកា ខ្ញុំម្ចាស់ក៏យល់ព្រមតាមសព្វព្រះ-រាជហឫទ័យ ឯព្រះបាទឡាស្រទៀននេះ គេក៏មានពូជពង្សវង្សត្រកូលអំបូរនឹងព្រហ្មលោក មិនមែនជាចោកអាប់អន់ទន់ទាបប៉យនោះក៏ទេ សូមស្តេចព្រះស្វាមីថ្វាយចុះហោង នឹងបានជាទីពឹងពាក់តទៅ ៗ កាលព្រះ-បាទកាលនាគរាជបានស្តាប់ព្រះរាជមហេសី ទូលមិនទទឹងរឹងទាស់ដូច្នោះហើយ ក៏ទ្រង់មានព្រះទ័យនោះត្រេកអរសោមនស្ស ហើយទ្រង់ត្រាស់ហៅទៅព្រះរាជធីតាឲ្យមកអង្គុយជិតខាងព្រះអង្គ ហើយថាឥឡូវនេះ កូនឯងអាពុកនឹងយកនាងទៅថ្វាយព្រះបាទឡាស្រទៀនអសុពជាចមលង្កាទ្វីប ចូរកូនចាំពាក្យដំបូន្មានបណ្តាំអាពុកប្រដៅកុំភ្លេច ចូរយកចិត្តនោះឧស្សាហ៍គោរពប្រណិប័តន៍កុំខ្ជិលច្រអូស ហើយប្រច័ណ្ឌឆ្នាព្យាបាទនោះឡើយ ចូរកូនស្ងួននាងឲ្យមានចិត្តជិតយកព្រះស្វាមីជាទីពឹងជីវិតតទៅ ត្រាស់ហើយក៏ស្តេចប្រាប់ទៅព្រះរាជធីតាថា កូនចូរនាងងូតទឹកតែងអង្គទ្រង់គ្រឿងអលង្ការដ៏ពិចិត្ររចនា បិតានឹងនាំទៅថ្វាយព្រះបាទឡាស្រទៀនក្នុងគ្រានេះហោង ៗ

រីព្រះរាជធីតាក៏រៀបអាត្មាស្រេចកាលណាហើយ ព្រះបិតាក៏នាំព្រះរាជធីតាឡើងគង់លើព្រះរាជរថ ក៏បើកបរចេញត្រេចយាត្រា នាំពួកពលសេនាអាមាត្យមុខមន្ត្រីហែហមជាបរិវារៈទៅពីនគរហ្នឹងកាលហោង ។

លុះស្តេចបានមកដល់ក្រុងលង្កាទ្វីបកាលណាហើយ ក៏បញ្ឈប់ពួកពលសេនានៅខាងក្រៅស្រេច ស្តេចក៏នាំព្រះរាជធីតាយាត្រាឡើងចូលគាល់ព្រះបាទឡាស្សទៀន អស់ក្រាបបង្គំទូលថា ទូលព្រះបង្គំជាខ្ញុំសូមថ្វាយព្រះរាជធីតា ទ្រង់ព្រះករុណាតាមតែទ្រង់ព្រះមេត្តាប្រោសហោង ។ កាលនោះ ព្រះបាទឡាស្សទៀនទ្រង់ទស្សនាការទតទៅ ឃើញរូបឆោមលោមពណ៌ព្រះរាជធីតា ព្រះបាទកាលនាគរាជនោះល្អល្អះត្រចះត្រចង់ទ្រង់ព្រាយល្អងល្អងម៉ត់ហ្មង់មានលក្ខណាដូចទេពកញ្ញា នៅស្ថានសួគ៌ទេវលោកនាយ ហើយស្តេចពិនិត្យគិតទៅសមជាអគ្គមហេសី ទសកត្រ្គអស់កូនអញហោង ទ្រង់ព្រះចិន្តាដូច្នោះហើយ ក៏មានព្រះឧង្ការត្រាស់ថា ម្នាលព្រះបាទកាលនាគរាជ ដែលអ្នកថ្វាយព្រះរាជបុត្រីយើង យើងមានសេចក្តីត្រេកអរសោទរសោមនស្សនឹងអ្នកណាស់ ឥឡូវនេះយើងនឹងឲ្យរាជ-ធីតាអ្នកទៅទសកត្រ្គ ព្រះរាជបុត្រាយើងធ្វើជាព្រះអគ្គមហេសី នឹងបានគ្រប់គ្រងរាជបុរីតពូជពង្សវង្សត្រកូលយក្ស ជាឡាក់ខនគរលង្កាតរៀងទៅហោង ។

រីព្រះបាទកាលនាគរាជបានស្ដាប់ព្រះឱង្ការត្រាស់ថាដូច្នោះហើយ ក៏ទូនអង្គលើកគំបង់អញ្ជលីវន្ទិទូលតបទៅថា ការនេះតាមតែទ្រង់ព្រះមេត្តាស្រេចនៅលើទ្រង់ព្រះករុណាជាអម្ចាស់ចាត់ចែងហោង ។ ស្ដេចភុជង្គ-នាគរាជទូលស្រេចហើយ ក៏ក្រាបថ្វាយបង្គំលាវិលត្រឡប់លើកពលយោធាទៅនគរក្រុងបាតាលវិញហោង ។

កាលនោះ ព្រះបាទឡាស្សទៀននោះ ព្រះអង្គសោយរាជសម្បត្តិជាប់តជាយូរអង្វែងមក ព្រះអង្គទ្រង់ក៏ទ្រង់ជរាចាស់គ្រាំគ្រាហើយស្ដេចទ្រង់ប្រឈួនជាទម្ងន់ធ្ងន់ ហើយព្រះអង្គទ្រង់គិតរំពឹងពិចារណាទៅដឹងថារាត្តានេះនឹងក្ស័យប្រល័យជន្មា ទើបស្ដេចឲ្យអភិសេកវសក្ត្រព្រះរាជបុត្រា ឡើងសោយរាជសម្បត្តិហើយ ក៏តាំងនាងកាត់ខាគជាភរិយអគ្គម-ហេសីធំលើសស្នំក្រមការទាំង ៥៤.០០០ហោង ។ រីឯបុស្សការតេមណីនោះ ក៏ទ្រង់ព្រះរាជទានឲ្យទៅគូរប៉ាន់ ឲ្យទៅសោយរាជ្យឯនគរកាលចក្រភាពរាជបុរីនៅកណ្ដាលព្រៃហេមពាន្ត រីឯពពណាសួរអស្សុពឲ្យទៅគ្រងនគរក្រុងចក្រវាឡជាខែត្រខណ្ឌ រីឯជាតានោះឲ្យទៅគ្រងនគរក្រុងវត្ស្យកណ្ឌបុរី រីឯមាក៉ីទឲ្យទៅនៅគ្រងនគរក្រុងសោឡ្សបុរី រីឯទូតខរនោះឲ្យទៅនៅគ្រងនគរក្រុងជនបទបុរី រីឯអង្គគ្រីសៀននោះឲ្យទៅនៅគ្រប់គ្រងសោយរាជ្យឯក្រុងនគរមច្ឆពរ៍ រីឯនាងសាមណាក្នារជាពៅបង្អស់នោះដូំឲ្យទៅជាប្រពន្ធដំភ្ជាយក្ស រីឯកុម្ភការណ៍និងពិភេក្យានោះ ស្ដេចឲ្យ

នៅក្រុងលង្កាទ្វីបជាមួយនឹងទសកណ្ឋរាជ តែក្នុងកាលនោះឲ្យរះធ្វើជាមហាឧបរាជ ព្រះបាទឡាស្រទៀនស្តេចតាំងរៀបចាត់ចែងព្រះរាជបុត្រាបុត្រី ឲ្យទៅគ្រងបុរីតាមអណ្តាប់អណ្តាយគ្រប់ព្រះអង្គហើយ ឯព្រះអង្គទ្រង់សោយរាជសម្បត្តិផាត់ស្ថានបានយូរមក ៦០.០០០ ឆ្នាំ ស្តេចមិនមានរោគា ទោសា មោហា ព្យាបាទឡើយ ព្រះអង្គក៏ស្តេចសោយព្រះពិលាល័យក្ស័យព្រះជន្មាទៅហោង ។

កាលនោះ ព្រះបាទទសកណ្ឋអសុរ លុះបានរាជសម្បត្តិគ្រប់គ្រងក្រុងគរលង្កាទ្វីបស្រេចកាលណាហើយ ព្រះអង្គក៏មានបុណ្ណ្យអានុភាពល្បីឮខ្ចរខ្ចាយសាយសព្វគ្រប់នគរ សឹងមានអំណាចក្លាចបារមីដល់ទៅស្ថានទេវលោកទាយ ពពួកទេវតាខ្លះ អសុរឲ្យទៅហៅមកគាល់បំរើប្រើប្រាស់តាមចិត្តបានហោង ។ រីឯទសកណ្ឋអសុរនោះ មានមិត្តសំឡាញ់នោះ ៧ នាក់ សុទ្ធតែទ្រង់មានបុណ្ណ្យអានុភាពខ្លាំងពូកែតែគ្រប់ ៗ អង្គ ។ ឈ្មោះព្រះបាទអដ្ឋកណ្ណមារ ១ ឈ្មោះព្រះបាទភ័យបិត្រសូរអសុរ ១ ឈ្មោះព្រះបាទសត្តាសូរ ១ ឈ្មោះព្រះបាទមូលកលាំយក្ស ១ ឈ្មោះព្រះបាទចក្រ-ពត្តិ ១ ឈ្មោះព្រះបាទសត្តល័ង ១ ឈ្មោះព្រះបាទមហាមល ១ សុទ្ធតែគ្រប់គ្រងជំរើកជាស្ថានមានឫទ្ធិជាអនេក ឯកអគ្គ័ស្ស ជាបជាសុខស្ថាពរហោង ។ ឈប់ស្ទុះ ។

នេះនឹងនិយាយដែលពីព្រះបាទវិរុឡ្ហក នៅឯនគរក្រោមដីជាចន្លោះភ្នំត្រី

ក្នុងបពិតនគរនោះសន្មតនាមឈ្មោះត្រីកូដបាតាលបពិត មានប្រាសាទកុដ
រតិកកំពែងកេងទងនោះជាសុខក្សេមក្សាន្ត ប្រសើរល្អរុងរឿងថ្កើងដូចស្ថាន
ត្រៃត្រឹង្សទេវលោក រីឯព្រះបាទវិរុលហកនោះតែងតែឡើងទៅគាល់ហៅ
សម្ដេចព្រះឥសូរនោះមួយឆ្នាំ ទៅ ៧ ដងចាំពល់រៀងឆ្នាំទៀងជាប្រក្រតី
លុះដល់កំណត់អសុរីយក្ស ត្រូវឡើងទៅគាល់ហៅព្រះបាទចមកតពជាមកុដ
លោកា អសុរាក៏ទ្រង់តែងគ្រឿងរុងរឿងថ្ងៃថ្លាស្រេចរួចកាលណាហើយ
អសុរាវិរុលហក ក៏សម្ដែងឫទ្ធិចាប់យកនាគពងមកធ្វើជាសង្វារពាក់មួយ
គូ ៗ រីឯក្បាលនាគពងនោះ ប្រែមុខប្រឈមចូលគ្នា ហើយចាប់យក
នាគពងមកទៀត ធ្វើជាចិញ្ចៀនពាក់នៅម្រាមដៃតាំងដប់គ្រប់ហើយ ក៏
ហោះផ្លែកក្រទ្យាមហាប្រថពី ដោយឫទ្ធិអានុភាពមក លុះមកដល់ស្ថាន
គិរីកៃលាសហើយ ក៏លូនវារចូលទៅគាល់សម្ដេចព្រះឥសូរ នៅទីដែល
តែងគាល់ តែក្នុងសម័យថ្ងៃមួយ ពេលវេលានោះព្រះឥសូរលោកកំពុង
តែនៅផ្ទុំលក់នៅឡើយ មិនទាន់ភ្ញាក់ព្រះអង្គ ឯកាលព្រះបាទវិរុលហកវារ
លូនទុនក្រាបទៅមិនដែលហ៊ានងើបមើលព្រះភក្ត្រាព្រះឥសូរនោះឡើយ ៗ

ក្នុងគ្រានោះ មានសារក្អ ១ នៅចុងកំពូលភ្នំស្ថានកៃលាស ជា
យូរអង្វែងហើយ ជួនមួយថ្ងៃនោះសារក្អក្រឡេកឃើញ អសុរាវិរុលហក
នោះ វារលូនតាំងពីដណ្ដើរ ឡើងទៅគាល់ព្រះឥសូរ ដូច្នោះហើយ
សារក្អនោះ ក៏ស្រែកយំថាក្រត ៗ គុកកែ ៗ ហើយ វាក្រឡេកមើលមកមុខ

ព្រះបាទវិរុឡ្ហក អសុរាគ្រវីក្បាលញាក់មុខ ធ្វើអកឡុកឡើយឲ្យអសុរា រីឯព្រះបាទវិរុឡ្ហកតែក្រាបពាំល្បួនទៅកាលណាហើយ ពាំក៏ស្រែកទៀត ក្រត ៗ តុកកែ ៗ ឡុកឡើយឲ្យថែមមកទៀតហោង ។

កាលនោះ ព្រះបាទវិរុឡ្ហកយក្សក៏នឹកថា ស្អានតែសម្តេចព្រះ-ឥស្សរលោកបើកទ្វារ ចេញមកឲ្យគាល់ហើយ ទើបបានតែឮសំឡេងសារិកាស្រែកក្រត ៗ តុកកែ ៗ កាលណាហើយ ក៏ក្រាបភ្លាមមួយរំពេចទៅ ៗ លុះយូរបន្តិចទៅ ក៏មិនឮសំឡេងសូរសន្ធឹក ព្រះបាទព្រះឥស្សរយាងមកទេ ព្រះអង្គនឹកចូលក្នុងព្រះទ័យណាស់ ថានរណាអេះមកធ្វើបញ្ឆោតអញ ក៏នឹកខ្ញាញ់ក្នុងព្រះទ័យណាស់ ទើបងើបមើលឡើង មិនឃើញព្រះឥស្សរលោកា ស្រាប់តែឃើញសារិកាតុកកែពាំឡុកចំអកឲ្យ មាត់ឆាយមិនគោរពក្រែងឡើយ អសុរាក៏ក្រេវក្រោធពេកខ្លាំងណាស់ ក៏ចាប់យកសង្ហារនាគមួយគូ ដែលពាក់នឹងខ្លួននោះ ក៏គ្រវែងចោលទៅដោយឫទ្ធីកំលាំងអសុរា ក៏ត្រូវសារិកាតុកកែនោះ ស្លាប់ខ្ទេចខ្ទីល្អិតជាធូលីអស់ ហើយត្រូវភ្នំកំពូលស្ពានកៃលាសក្រុតផ្ដៀងទ្រេតទៅហោង អសុរាក៏នឹកភ័យខ្លាចព្រះឥស្សរលោកាហើយ អសុរាក៏ហោះជ្រែកក្រឡាមហាប្រថពី មកឯនគរបាតាលវិញហោង ។

កាលនោះ ព្រះចមមកុដបំផុតលោកា ផ្ទំលក់លើខែនទិព្វសោយរន្ទា ព្រះអង្គក៏ភ្ញាក់តើនឡើងមួយរំពេចកាលណាហើយ ក៏បានឮសំឡេង

លាន់ឮគគ្រឹកគគ្រេងជាកោលាហល ស្តេចក៏ចុះចាកពីគ្រែទេនទិព្វក្រឡា ព្រះបន្ទំចេញមក ដល់នៅមុខព្រះមន្ទីរស្ថានបានទ្រង់ទស្សនាទតទៅឃើញ ភ្នំគីរីកៃលាសនោះ ក៏ទ្រេតទ្រេតផ្អៀងទៅខាងទិសឦសាន ព្រះអង្គក៏ទ្រង់ទតសន្និះធ្លុលក្នុងព្រះវិញ្ញាណ ហេតុដូច្នេះ ម្តេចក៏បានជាដូច្នេះព្រះអង្គទ្រង់ត្រិះរិះពិនិត្យពិចារណា មើលដោយទិព្វចក្ខុ ទៅក៏ឃើញដឹងដោយព្រះប្រាជ្ញាញាណហើយព្រះអង្គក៏ទ្រង់មានមានព្រះឧង្ការថា ឱអសុរវិរុល-ហយក្បាក់បោលសារក្ញុកកៃនឹងសង្ហារនាគដោយឫទ្ធិ ត្រូវគីរីកៃលាសទ្រេតទ្រោមផ្អៀងទៅ ហើយព្រះអង្គទ្រង់មានព្រះឧង្ការថា អ្នកណាមានឫទ្ធិអានុភាពដំរង់ស្ពានកៃលាសនេះបានត្រង់ អញនឹងឲ្យរង្វាន់អ្នកនោះហោង ។

កាលនោះ វីត្លកទេវលោក គ្រប់ស្ថាន ដែលបានទៅគាល់ ប្រជុំព្រមនៅក្នុងទីនោះ លុះបានឮព្រះឧង្ការត្រាស់ថាដូច្នោះ ក៏ក្រាបថ្វាយបង្គំទូលទៅព្រះឥស្សរស្សរាធិបតីវិញ ក៏ទូលថា ព្រះបដ្ឋជាខ្ញុំក្រោមល្អងធូលីព្រះបាទទាំងអស់គ្នានេះ នឹងសូមយកអាសាធ្វើការថ្វាយតាមបន្ទាល់ ទូលហើយក៏បង្គួលគ្នាថ្វាយបង្គំលាចេញមក ហើយក៏តាំងសំដែងឫទ្ធិគេចះតែដោយរៀងខ្លួនស្រេចហើយ ក៏នាំគ្នាចូលទៅលើកភ្នំកៃលាស ទេវលោកខ្លះក៏រុញពីក្រោយដោយរឹកវិរហោរ៉ក្រេវ ៗ ករក្រើកកំពើកតាំងប្រថពី លុះទាល់តែអស់ឫទ្ធិកំលាំងទាំងអស់គ្នា ក៏សូម្បីឡែកក្រើកល្បើកក្រើតចេញ

(នៅមានតទៅទៀត)

## ផ្នែកកាំណាត់និងប្រវត្តិការណ៍

# ព្រះនាមព្រះតេជៈព្រះគុណដែលបានទទួលសញ្ញាប័ត្រ ចាត់តាំងជាចៅអធិការ និង គ្រូសូត្រក្នុងព្រះរាជអាណាចក្រកម្ពុជា

-ព្រះតេជព្រះគុណ ខុប-អឹម នាមឆាយាកណ្ហវណ្ណោ អាយុ ២៣ ឆ្នាំ វស្សា ២ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង ក្នុងវត្តមង្គលបុរី ឃុំចម្លងគួយ ស្រុកបាត់ដំបង ខេត្តបាត់ដំបង លេខសញ្ញាប័ត្រ ៣.៦០៧ ចុះថ្ងៃទី ១៨-៩-៦៣ ។

-ព្រះតេជះព្រះគុណ មាស ហោ នាមឆាយាអគ្គពហុស្សុតោ កើតឆ្នាំថោះ អាយុ ២៥ ឆ្នាំ វស្សា ៣ បានទទួលតែងតាំងជាចៅអធិការ ក្នុងវត្តទឹកហូត ឃុំទឹកហូត ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង លេខសញ្ញាប័ត្រ ៣.៦០៨ ចុះថ្ងៃទី ១៨-៩-៦៣ ។

-ព្រះតេជះព្រះគុណ ចាប ពិន នាមឆាយាអគ្គសេដ្ឋោ កើតឆ្នាំម្សាញ់ អាយុ ២៣ ឆ្នាំ វស្សា ២ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ ក្នុងវត្ត ឃុំ ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៦០៩ ចុះថ្ងៃទី ១៨-៩-៦៣ ។

-ព្រះតេជះព្រះគុណ សុខ ទង់ នាមឆាយាបុរិន្ទត្ថេរ កើតឆ្នាំច អាយុ ៦៥ ឆ្នាំវស្សា ៤៤ បានទទួលតែងតាំងជាចៅអធិការ ក្នុងវត្តបន្ទាយត្រាវ ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ លេខសញ្ញាប័ត្រ ៣.៦១០ ចុះថ្ងៃទី ១៨-៩-៦៣ ។

–ព្រះតេជះព្រះគុណ ដៃ ប្រាក់ នាមងាយាធម្មជោតោ កើតឆ្នាំមមែ អាយុ ៥៧ ឆ្នាំ វស្សា ១១ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៦១១ ចុះថ្ងៃទី ១៨-៩-៦៣ ។

–ព្រះតេជះព្រះគុណ ជេត ប៉ាង នាមងាយាឋិតធម្មោ កើតឆ្នាំឆ្លូវ អាយុ ៥១ ឆ្នាំ វស្សា ១ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង ក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣ ៦១២ ចុះថ្ងៃទី ១៨-៩-៦៣ ។

–ព្រះតេជះព្រះគុណ ភ៊ិន យុន នាមងាយាតន្ទុត្ថេរ កើតពីគ.ស. ១៩៣១ អាយុ ៣២ ឆ្នាំ វស្សា ១២ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តសិរីវង្ស ឃុំប៉ាង្គង់ ស្រុករំដួល ខេត្តស្វាយរៀង លេខសញ្ញាប័ត្រ ៣.៦១៣ ចុះថ្ងៃទី ១៨-៩-៦៣ ។

–ព្រះតេជះព្រះគុណ ប៉ាល ក៉ស នាមងាយាធម្មកេសរ កើតពី គ.ស. ១៩៤២ អាយុ ២១ ឆ្នាំ វស្សា ១ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តទួលសាលា ឃុំជ្រុងតាពេល ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៦១៤ ចុះថ្ងៃទី ១៨-៩-៦៣ ។

–ព្រះតេជះព្រះគុណ សោម យឹម នាមងាយាធម្មសត្ថា កើតឆ្នាំម្សាញ់ អាយុ ៥៩ ឆ្នាំ វស្សា ៣៦ បានទទួលតែងតាំងជាចៅអធិការ ក្នុងវត្តទួលអណ្តែត ឃុំទឹកក្រហម ស្រុកដាំខ្សាន ខេត្តកំពង់ធំ លេខសញ្ញាប័ត្រ ៣.៦១៥ ចុះថ្ងៃទី ១៨-៩-៦៣ ។

–ព្រះតេជះព្រះគុណ សៅ-កង នាមឆាយាឥន្ទត្ថេរ កើតពី គ.ស. ១៨៩០ អាយុ ៧៣ ឆ្នាំ វស្សា ៥១ បានទទួលតែងតាំងជាចៅអធិការ ក្នុងវត្តបំការ ឃុំកាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ លេខសញ្ញា-ប័ត្រ ៣.៦១៦ ចុះថ្ងៃទី ១៨-៩ ៦៣ ។

–ព្រះតេជះព្រះគុណ ខៀវ ប៉ៃ នាមឆាយាសុវណ្ណជោតិ កើតពី គ.ស. ១៩១៩ អាយុ ៤៤ ឆ្នាំ ២៤ វស្សា បានទទួលតែងតាំងជាគ្រូសូត្រស្តាំក្នុងវត្ត ឃុំ ស្រុក ខេត្ត ដដែល លេខសញ្ញាប័ត្រ ៣.៦១៧ ចុះថ្ងៃទី ១៨-៩-៦៣ ។

–ព្រះតេជះព្រះគុណ ម៉ន ញ៉េន នាមឆាយាព្រហ្មត្ថេរ កើតពីគ.ស. ១៩៤០ អាយុ ២៣ ឆ្នាំ វស្សា ៣ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង ក្នុងវត្តបំការ ឃុំកាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ លេខសញ្ញាប័ត្រ ៣.៦១៨ ចុះថ្ងៃទី ១៨-៩-៦៣ ។

–ព្រះតេជះព្រះគុណ តាំង គន នាមឆាយាឥន្ទត្ថេរ កើតពីគ.ស. ១៩២២ អាយុ ៤១ ឆ្នាំ វស្សា ២០ បានទទួលតែងតាំងជាចៅអធិការ ក្នុងវត្តអាងលើ ឃុំអាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម លេខសញ្ញា-ប័ត្រ ៣.៦១៩ ចុះថ្ងៃទី ១៨-៩-៦៣ ។

–ព្រះតេជះព្រះគុណ សារ សន នាមឆាយាជោតត្ថេរ កើតពី គ.ស. ១៩៣៥ អាយុ ២៨ ឆ្នាំ វស្សា ៧ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ

ក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៦២០ ចុះថ្ងៃទី ១៨-៩-៦៣ ។

-ព្រះតេជះព្រះគុណ គង់ ស៊ឹម នាមឆាយាមន្តត្ថេរ កើតពីគ.ស ១៩៣៨ អាយុ ២៥ ឆ្នាំ វស្សា ៤ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង ក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៦២១ ចុះថ្ងៃទី ១៨-៩-៦៣ ។

-ព្រះតេជះព្រះគុណ ពត ឈាន នាមឆាយាសំរក្ខិត កើតឆ្នាំរោង អាយុ ៣៦ ឆ្នាំ វស្សា ១៥ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តពោធិ៍-មាស ឃុំភូមិថ្មី ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង លេខសញ្ញាប័ត្រ ៣.៦២២ ចុះថ្ងៃទី ៤-១០ ៦៣ ។

-ព្រះតេជះព្រះគុណ យិន អ៊ុំ នាមឆាយាសុទ្ធសារ កើតពីគ ស.១៩០៧ អាយុ ៥៦ ឆ្នាំ វស្សា ៣៦ បានទទួលតែងតាំងជាចៅអធិការក្នុងវត្តស្តៅ ឃុំស្តៅ ស្រុកកងមាស ខេត្តកំពង់ចាម លេខសញ្ញាប័ត្រ ៣.៦២៣ ចុះថ្ងៃទី ១៤-១០-៦៣ ។

-ព្រះតេជះព្រះគុណ ទុំ ចិន នាមឆាយាមុនីបញ្ញាថេរ កើតពីគ.ស. ១៩០៨ អាយុ ៥៥ ឆ្នាំ វស្សា ៣៥ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ ក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៦២៤ ចុះថ្ងៃទី ១៤-១០-៦៣ ។

–ព្រះតេជះព្រះគុណ សៅ នុក នាមឆាយាឥន្ទបញ្ញោថេរ កើតពី គ.ស. ១៩៤២ អាយុ ២១ ឆ្នាំ វស្សា ២ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងកុដិវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៦២៥ ចុះថ្ងៃទី ១៤-១០-៦៣ ។

–ព្រះតេជះព្រះគុណ កង ផេង នាមឆាយាមទូថេរ កើតពីគ.ស. ១៩២៣ អាយុ ៤០ ឆ្នាំ វស្សា ១៧ បានទទួលតែងតាំងជាចៅអធិការកុដិវត្តគោក្រោម ឃុំគោក ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៦២៦ ចុះថ្ងៃទី ១៤-១០-៦៣ ។

–ព្រះតេជះព្រះគុណ មាស យ៉ង់ នាមឆាយាមង្គលកេសរ កើតពី គ.ស ១៩៣៣ អាយុ ៣៣ ឆ្នាំ វស្សា ១៣ បានទទួលតែងតាំងជាគ្រូសូត្រស្ដាំ កុដិវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៦២៧ ចុះថ្ងៃទី ១៤-១០-៦៣ ។

-ព្រះតេជះព្រះគុណ ឡេា ជួប នាមឆាយាមង្គលថេរ កើតពីគ.ស. ១៩ ៣ អាយុ ៣០ ឆ្នាំ វស្សា ១០ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងកុដិវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣.៦២៨ ចុះថ្ងៃទី ១២-១០-៦៣ ។

–ព្រះតេជះព្រះគុណ គង់ ជូរ នាមឆាយា ព្រហ្មជោតត្ថេរ កើតពី គ.ស. ១៩០៥ អាយុ ៥៩ ឆ្នាំ វស្សា ៣៦ បានទទួលតែងតាំងជា គ្រូ

ស្ងួតក្តាំ កុដិវត្តប្រកល់ ឃុំព្រែកពោធិស្ងួត ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម លេខសញ្ញាបត្រ ៣ ៦២៩ ចុះថ្ងៃទី ១២-១០-៦៣ ។

–ព្រះតេជះព្រះគុណ ជិន ចេង នាមឆាយាសុវណ្ណបញ្ញោ កើតពី គ.ស. ១៩០៨ អាយុ ៥៥ ឆ្នាំ វស្សា ៣៥ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាបត្រ ៣៦៣០ ចុះថ្ងៃទី ១២-១០-៦៣ ។

–ព្រះតេជះព្រះគុណ កាយ បន នាមឆាយាធម្មជោតិ កើតពីគ.ស. ១៩១១ អាយុ ៥២វស្សា ៣២ បានទទួលតែងតាំងជាចៅអធិការ កុដិវត្តព្រៃឃ្មៀង ឃុំបុស្សស្រាញ់ ស្រុក ខេត្តដដែល លេខសញ្ញាបត្រ ៣៦៣១ ចុះថ្ងៃទី ២៩-១០-៦៣ ។

–ព្រះតេជះព្រះគុណ ណាន់ គង់ នាមហៅមតុទ្ទមគ្គលតេរ កើតពី គ.ស. ១៩០១ អាយុ ៦២ ឆ្នាំ វស្សា ២០ បានទទួលតែងតាំងជាចៅអធិការ កុដិវត្តបាសិទ្ធិលើ ឃុំម្កាក់ ស្រុកកំពេញ ខេត្តកណ្តាល លេខសញ្ញាបត្រ ៣៦៣២ ចុះថ្ងៃទី ៤-១១-៦៣ ។

–ព្រះតេជះព្រះគុណ ពិយ អេង នាមឆាយាព្រហ្មត្ថេរ កើតពីគ.ស. ១៩៣០ អាយុ ៣២ ឆ្នាំ វស្សា ១២ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ កុដិវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាបត្រ ៣៦៣៣ ចុះថ្ងៃទី ៤-១១-៦៣ ។

ព្រះតេជះព្រះគុណ ប៉ុល កង នាមឆាយាសស្សនាគត្តោ កើតពី គ.ស. ១៩០០ អាយុ ៦៣ ឆ្នាំ វស្សា ៦ បានទទួលតែងតាំងជាគ្រូសូត្រ សូត្រឆ្វេង ក្នុងវត្ត ឃុំ ស្រុក ខេត្តដៃល លេខសញ្ញាប័ត្រ ៣.៦៣៤ ចុះថ្ងៃទី ៤-១១-៦៣ ។

ព្រះតេជះព្រះគុណ អ៊ិច អ៊ឹម នាមឆាយាចន្ទសារោ កើតពីគ.ស. ១. ៦២ អាយុ ៣៩ ឆ្នាំ វស្សា ១៨ បានទទួលតែងតាំងជាចៅអធិការ ក្នុងវត្តឈូកណ្ដាំ ឃុំទួលព្រេច ស្រុក ខេត្តដៃល លេខសញ្ញាប័ត្រ ៣ ៦៣៥ ចុះថ្ងៃទី ៤-១១-៦៣ ។

· ព្រះតេជះព្រះគុណ ដែក ឌុយ នាមឆាយាឥន្ទបេរ កើតពីគ.ស. ១ ៨៩២ អាយុ ៧១ ឆ្នាំ វស្សា ១១ បានទទួលតែងតាំងជាចៅអធិការ ក្នុងវត្តអង្គក្រពើ ឃុំគោករកា ស្រុក ខេត្តដៃល លេខសញ្ញាប័ត្រ ៣.៦៣៦ ចុះថ្ងៃទី ៤-១១-៦៣ ។

–ព្រះតេជះព្រះគុណ សាន់ សុត នាមឆាយាពុទ្ធថេរ កើតពី ព.ស. ២៤៦៣ អាយុ ៤៣ ឆ្នាំ វស្សា ១៤ បានទទួលតែងតាំងជាចៅអធិការ ក្នុងវត្តអង្គមុនី ឃុំតាខ្ពង់ ស្រុក ខេត្តដៃល លេខសញ្ញាប័ត្រ ៣ ៦៣៧ ចុះថ្ងៃទី ៤-១១-៦៣ ។

–ព្រះតេជះព្រះគុណ ហៀន ចាន់ នាមឆាយាកេសរោ កើតឆ្នាំមមែ អាយុ ៣៣ ឆ្នាំ វស្សា ១៣ បានទទួលតែងតាំងជាចៅអធិការ ក្នុងវត្តព្រៃខ្ពង

ឃុំលាជ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ លេខសញ្ញាប័ត្រ ៣ ៦៣៨ ចុះថ្ងៃទី ៨-១១-៦៣ ។

-ព្រះតេជះព្រះគុណ តាត ឆាន់ នាមឆាយាចន្ទធិត្តោ កើតពីគ.ស. ១៩៣៤ អាយុ ២៩ ឆ្នាំ វស្សា ១០ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ ក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣ ៦៣៩ ចុះថ្ងៃទី ៨-១១-៦៣ ។

-ព្រះតេជះព្រះគុណ សួស ជុំ នាមឆាយាអគ្គចិត្តោ កើតឆ្នាំកុរ អាយុ ២៩ ឆ្នាំ វស្សា ១០ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង ក្នុងវត្តព្រៃខ្ពង់ ឃុំលាជ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ លេខសញ្ញាប័ត្រ ៣ ៦៤០ ចុះថ្ងៃទី ៨-១១-៦៣ ។

-ព្រះតេជះព្រះគុណ យឹម ប៉ក់ នាមឆាយាឥន្ទត្ថេរ កើតឆ្នាំជូត អាយុ ៣៩ ឆ្នាំ វស្សា ១៧ បានទទួលតែងតាំងជាចៅអធិការ ក្នុងវត្តទ្រព្យគរ ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ លេខសញ្ញាប័ត្រ ៣.៦៤១ ចុះថ្ងៃទី ៨-១១-៦៣ ។

-ព្រះតេជះព្រះគុណ ឯក ពយ នាមឆាយាព្រហ្មថេរ កើតពី គ.ស. ១៩១៩ អាយុ ៤៤ ឆ្នាំ វស្សា ២៤ បានទទួលតែងតាំងជាចៅអធិការ ក្នុងវត្តព្រលឹង ឃុំត្រាចទង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ លេខសញ្ញាប័ត្រ ៣.៦៤២ ចុះថ្ងៃទី ៨-១១-៦៣ ។

-- ព្រះតេជះព្រះគុណ ស៊ុំ សម្បូរ នាមឆាយាព្រហ្មត្ថេរ កើតឆ្នាំកុរ អាយុ ៤១ ឆ្នាំ វស្សា ២១ បានទទួលតែងតាំងជាចៅអធិការ ក្នុងវត្ត ចមបុណ៌គិរី ឃុំក្រគោះ ស្រុកសន្ទុក ខេត្តកំពង់ធំ លេខសញ្ញាប័ត្រ ៣ ៦៤៣ ចុះថ្ងៃទី ៩-១២-៦៣ ។

–ព្រះតេជះព្រះគុណ តាន់ យី នាមឆាយាសុវណ្ណបញ្ញា កើតពី គ.ស ១៩៣៣ អាយុ ៣០ ឆ្នាំ វស្សា ៩ បានទទួលតែងតាំងជាចៅ អធិការ ក្នុងវត្តកំពង់ចម្លង ឃុំផាត់សណ្តាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ លេខសញ្ញាប័ត្រ ៣ ៦៤៤ ចុះថ្ងៃទី ៩-១២-៦៣ ។

–ព្រះតេជះព្រះគុណ គឹម មាស នាមឆាយាព្រហ្មសុវណ្ណ កើតឆ្នាំមមី អាយុ ៥៨ ឆ្នាំ វស្សា ៣៩ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង ក្នុងវត្ត នគរខាងត្បូង ឃុំនគរធំ ស្រុក ខេត្តសៀមរាប លេខសញ្ញាប័ត្រ ៣ ៦៤៥ ចុះថ្ងៃទី ១៩ ២-៦៣ ។

–ព្រះតេជះព្រះគុណ សង់ គិត នាមឆាយាព្រហ្មសរ កើតពីគ.ស. ១.៩០២ អាយុ ៦១ ឆ្នាំ វស្សា ១៤ បានទទួលតែងតាំងជាចៅអធិការ ក្នុង វត្តសុខារាម ឃុំត្រាចទង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ លេខសញ្ញាប័ត្រ ៣.៦៤៦ ចុះថ្ងៃទី ៩-១ -៦៣ ។

–ព្រះតេជះព្រះគុណ មាស ឌូ នាមយាពុទ្ធសាកេ កើតឆ្នាំខាល អាយុ ២៦ ឆ្នាំ វស្សា៥ បានទទួលតែងតាំងជាគ្រូសូត្រស្តាំ ក្នុងវត្តពោធិមាស

ឃុំគូមិថ្មី ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង លេខសញ្ញាប័ត្រ ៣.៦៤៧ ចុះថ្ងៃទី៩ ១២-៦៣ ។

-ព្រះតេជះព្រះគុណ ទក ហូរ នាមនាយកធម្មវិន័យ កើតពីឆ្នាំថោះ អាយុ ២៥ ឆ្នាំ វស្សា ៥ បានទទួលតែងតាំងជាគ្រូសូត្រឆ្វេង ក្នុងវត្ត ឃុំ ស្រុក ខេត្តដដែល លេខសញ្ញាប័ត្រ ៣ ៦៤៨ ចុះថ្ងៃទី៩-១០-៦៣ ។

កូនមានគុណគាប់តែម្នាក់ជាកូនប្រសើរ
កូនល្ងង់រាប់រយមិនប្រសើរទេ ដូចព្រះបន្ទ
តែមួយដួង អាចកំចាត់ងងឹតអន្ធការបាន
កងតារាទាំងឡាយ កំចាត់បង់ងងឹតមិន
បានឡើយ ។

ស្រីហិតោបទេស

**ទំព័រកំសាន្ត**

# ចម្លើយចំណោទមហោស

(ចំណោទក្នុងទស្សនាវដ្ដីកម្ពុជសុរិយាលេខ ១២ ឆ្នាំ ១៩៦៤)

យើងមានសេចក្ដីត្រេកអរជាទីបំផុត ដោយបានទទួលចម្លើយពីអ្នកអានទស្សនាវដ្ដីកម្ពុជសុរិយា ដែលបានផ្ញើចម្លើយមកការិយាល័យយើង ៗ យើងសូមសរសើរនូវប្រាជ្ញាដ៏ពន់ពេករបស់អស់លោកអ្នក ដែលឆ្លើយចំណោទមហោសរបស់យើង ៗ

ចម្លើយត្រូវនោះគឺ : **កាកបាទ ឬ ជើងក្អែក និង គោមូត្រ**

នាមរបស់អស់លោកអ្នក ដែលឆ្លើយចំណោទមហោសត្រូវ ដូចមានរាយនាមខាងក្រោមនេះ :

១– លោក ម៉ាញ-ធន អធិការដ្ឋាន បឋមសិក្សាកំពង់ចាម

២– លោក ពេជ-ប៊ុនធួន ជាតិមន្ទីរប្ដូរប្រាក់ ភ្នំពេញ

៣– លោក អ៊ុង-ឈឺន វិទ្យាល័យ កំពង់ធំ

៤– លោក ជឹម-ជុំ ប្រៃសណីយ៍ និង ទូរគមនាគមន៍ បាត់ដំបង

៥– លោក ធុង-សារឿន ក្រឡាបញ្ជីសាលាដំបូង កំពង់ចាម

## ចំណោទមហោស

ទង់ព្រះពុទ្ធសាសនា ដែលយើងប្រើប្រាស់ក្នុង

ពិធីបុណ្យ មាន ៦ ពណ៌ គឺ :

១ – ពណ៌ទាំង ៦ នោះគឺអ្វីខ្លះ ?

២ – ពណ៌ទាំងនោះ ជាតំណាងអ្វី ?

៣ – ពុទ្ធិកសមាគមពិភពលោក បានអនុមតិឲ្យ

ប្រើជាដំបូងនៅឆ្នាំណា ?

៤ – នៅប្រទេសណា ?